# លក្ខណៈវិនិច្ឆ័យព្រះវិន័យ





ចងក្រងដោយ
ភិក្ខុ សតិវិមុត្តោ **គុយ និមល**

# លក្ខណៈវិនិច្ឆ័យព្រះវិន័យ



# ឧស្សាហ៍ការះកថា

ការវិនិច្ឆ័យព្រះវិន័យគ្រប់កន្លែងក្នុងវិន័យបិដក ត្រូវតែផ្ទៀងផ្ទាត់ជាមួយអដ្ឋកថាជាចាំបាច់ ក្នុងការពន្យល់សេចក់បន្ថែមទៀត ទៅលើព្រះពុទ្ធដីកាដ៏មានជម្រៅ ព្រោះព្រះអង្គទ្រង់សម្តែងយកសេចក្តីជាធំ មិនយកព្យញ្ជនៈជាធំទេ ដូច្នេះអត្ថន័យសេចក្តីក្នុងព្រះបាលី ព្រះអរហន្តទាំងឡាយមានព្រះឧបាលីជាដើម យល់ពុទ្ធបំណង សម្តែងពង្រីកបទនោះៗឱ្យមានសេចក្តីរាក់ងាយយល់ ដល់សិក្ខាកាមកុលបុត្រទាំងឡាយ អ្នកប្រាថ្នាការសិក្សាក្នុងព្រះសាសនានេះ ។

ក្នុងសៀវភៅនេះ ពន្យល់ពីលក្ខណៈវិនិច្ឆ័យសិក្ខាបទទូទៅក្នុងព្រះវិន័យ ខ្ញុំព្រះករុណាស្រង់ចាកគម្ពីរព្រះត្រ័យបិដកខ្លះ មាតិកដ្ឋកថាខ្លះ និងសមន្តប្បា-សាទិកាខ្លះ ឱ្យជាគោលក្នុងការចងក្រងសៀវភៅនេះឡើង នឹងឯកសារផ្សេងៗមួយចំនួនទៀត ដើម្បីឱ្យមានន័យទូលាយក្នុងការវិនិច្ឆ័យ ។ តែទោះជាយ៉ាងណាកង្វះខាតអាចមានដោយការភ្លាំងភ្លាត ឬចេះមិនដល់ ដូច្នេះសូមអ្នកសិក្សាទាំងឡាយ ដែលឈ្លាសក្នុងព្រះវិន័យ ជួយកែតម្រូវដោយកុសលចេតនាផងចុះ។

គោលបំណងនៃការចងក្រងសៀវភៅនេះឡើង ដើម្បីជាជំនួយខ្លះ ៗ ដល់អ្នកដែលសិក្សាព្រះវិន័យដំបូង ។ សង្ឃឹមថាសៀវភៅនេះ នឹងបានជាប្រទីបក្នុងការវិនិច្ឆ័យព្រះវិន័យមួយចំណែកតូច ដល់អ្នកសិក្សាទាំងឡាយ ។ ដោយការខំប្រឹងប្រែងព្យាយាមចងក្រងសៀវភៅនេះឡើង សូមបានជាគ្រឿងសក្ការៈបូជាថ្វាយចំពោះព្រះរតនៈត្រ័យ ។ កាលអន្ទោលទៅក្នុងសង្សារ សូមជួបតែសប្បុរស បានទាន់ព្រះអរិយៈមេត្រីមានព្រះភាគ បួសជាឯហិភិក្ខុឧបសម្បទា មានបញ្ញាក្រាស ជំនាញក្នុងការប្រកាសសមែងនូវអរិយសច ដែលព្រះមាន-

ព្រះភាគប្រកាសសម្ដែងហើយ ។ ជាទីអវសាន សូមឱ្យកុលបុត្រទាំងឡាយតាំងនៅក្នុងលជ្ជីធម សិក្សាបដិបត្តិ ផ្សព្វផ្សាយ បើកបង្ហាញ នូវព្រះវិន័យ ដើម្បីការតាំងនៅមាំនៃព្រះពុទ្ធសាសនា ។

## ព្រះមហាកស្សបត្ថេរគាថា

**វិនយោ សាសនស្ស មូលំ**

ព្រះវិន័យជាឫសគល់នៃព្រះពុទ្ធសាសនា ។

**វិនយោ នាម ពុទ្ធសាសនស្ស អាយុ**

ព្រះវិន័យឈ្មោះថា ជាអាយុរបស់ព្រះពុទ្ធសាសនា ។

**វិនយេ ឋិតេ សាសនំ ឋិតំ**

កាលបើព្រះវិន័យតាំងនៅដរាបណា ព្រះពុទ្ធសាសនាឈ្មោះថាតាំងនៅដរាបនោះ ។

**វត្តសុវណ្ណបទុម ១៥កើត វិសាខបូជា ពុទ្ធសករាជ ២៥៥៥**

*ចងក្រងដោយ*

*ភិក្ខុ សតិវិមុត្តោ* **គួយ និមល**

# អ្នកមានឧបការក្នុងធម្មទាន

## ត្រួតពិនិត្យ

-វិនយាចារ្យ **សុចិណ្ណោ ញ៉ិប យ័ន្ត**

-ភិក្ខុ **ភទ្ទប្បញ្ញោ ឌុន គន្ធឹម**

-ភិក្ខុ **មុនីវង្សា ប៊ី សារ៉ាន**

-ភិក្ខុ **ចន្ទប្បញ្ញោ ឌិន តារា**

-ភិក្ខុ **និន្នក ជា សុខឿង**

-ភិក្ខុ **បញ្ញាបទីបោ ឡេង ធី**

-ភិក្ខុ **សុខវឌ្ឍកោ ហ៊ាត សុខហ៊ាន**

-ភិក្ខុ **សោភណត្ថេរ ឡឹម រ៉ាឌី**

-ភិក្ខុ **សោមបណ្ឌិតោ ខែម សោភ័ណ្ឌ**

-ភិក្ខុ **វិសេសោ អ៊ា ឃ៉ាវី**

-សា. **បញ្ញាបរមោ ឈាត ប៊ុនឆាត**

-សា. **សទ្ធាវិមុត្ត ជា សុខហេង**

(ព្រមទាំងសមណៈសិស្សវត្តសុវណ្ណបទុមជាច្រើនអង្គទៀតដែលមានឧបការៈ)

## ជំនួយការវាយអត្ថបទ

-ភិក្ខុ សតិសម្បន្នោ **រុន សារ៉ាយ** (ចិក)

## ជំនួយការថវិការបោះពុម្ព

**-ឧ.ស.សម សុខ -ឧ.សិ.ចាន់ ស៊ឹម**

# សារបណ្ណ


| បញ្ជីរឿង | ទំព័រ |
|---|---|
| -ឱវាទព្រះឧបាលត្ថេរឯតទគ្គៈខាង-ព្រះវិន័យ | ១ |
| -វត្ថុ៣យ៉ាងបើកទើបរុងរឿង បិទមិនរុងរឿង | ៣ |
| -លក្ខណៈវិនិច្ឆ័យសាធារណៈសិក្ខាបទ១៧-ប្រការ | ៥ |
| -សមុដ្ឋាននៃអាបត្តិទាំងអស់មាន ៦ | ១២ |
| -ឈ្មោះសមុដ្ឋានក្នុងសិក្ខាបទទាំងអសមាន-១៣ យ៉ាង | ១៣ |
| -វិនិច្ឆ័យបរិមណ្ឌលនិវាសនៈសិក្ខាបទតាម-លក្ខណៈ ១៧ ប្រការ | ១៩ |
| -វិនយ ៤ យ៉ាង | ២១ |
| -លក្ខណៈ ៣ របស់ព្រះវិនយធរ | ៣២ |
| -ត្រួតមើលឋាន ៦ យ៉ាង | ៣៩ |
| -វិធីវិនិច្ឆ័យអធិករណ៍ | ៤៣ |
| -ភិក្ខុដែលមានសីលមិនបរិសុទ្ធកម្មដ្ឋាន-មិនចម្រើន | ៤៤ |
| -ធម្មតាក្នុងការវិនិច្ឆ័យ | ៤៦ |
| -គប្បីតាំងនៅក្នុងសេចក្ដីជាធំ | ៤៦ |
| -វិន័យធរត្រូវវៀរហេតុ ២ ប្រការ | ៤៧ |
| -វិន័យទាំងអស់មានអត្ថ ៣ ប្រការ | ៤៧ |
| -ការដោះស្រាយវិន័យមិនប្រកបដោយ-ធម៌មាន ៥ ប្រការ | ៤៨ |
| -ការដោះស្រាយវិន័យប្រកបដោយធម៌-៥ ប្រការ | ៤៩ |
| -អង្គ ៥ របស់វិន័យធរ | ៤៩ |
| -អង្គ ៧ របស់វិន័យធរ | ៤៩ |
| -អង្គ ១០ របស់វិន័យធរ | ៥១ |
| -លក្ខណៈនៃការវិនិច្ឆ័យធម៌វិន័យ៨យ៉ាង | ៥២ |
| -ចូឡសង្គាម | ៥៤ |
| -អដ្ឋកថា | ៦២ |
| -មហាសង្គាម | ៧៩ |
| -អដ្ឋកថា | ១០១ |
| -អង្គ ៥ របស់ភិក្ខុដែលពោលមិនជាទី-ស្រលាញ់ | ១០៤ |
| -អដ្ឋកថា | ១០៦ |
| -ភិក្ខុចូលទៅរកសង្ឃ ត្រូវតមល់ធម៌ ៥-ប្រការក្នុងសន្តាន | ១០៨ |
| -អង្គរបស់ភិក្ខុដែលមិនគួរនិយាយក្នុង-ជុំនុំសង្ឃ | ១១០ |
| -អដ្ឋកថា | ១១៤ |
| -សារាណីយធម៌ ៦ ប្រការ | ១២១ |
| -អដ្ឋកថា | ១២៤ |
| -បរិយោសានគាថា | ១៣១ |
| -ការពិន័យអាបត្តិក្នុងខន្ធកៈ | ១៣២ |
| -អនាបត្តិក្នុងវត្តក្ខន្ធកៈ | ១៣៤ |
| -សិក្សាព្រះវិន័យបិដក | ១៣៦ |

| បញ្ជីរឿង | ទំព័រ |
|---|---|
| -សិក្សាសិក្ខាបទទី ១០ (ឱវាទវគ្គ) | ១៣៩ |
| -រឿងព្រះវិន័យធរ+ព្រះឧបាលិឧទាន | ១៤២-១៤៦ |

**ពួកធម៌ផ្សេងៗ**

| បញ្ជីរឿង | ទំព័រ |
|---|---|
| -ប្រយោជន៍នៃការសិក្សាព្រះវិន័យ | ១៤៩ |
| -ប្រយោជន៍ព្រះវិន័យ ១០ យ៉ាង | ១៥០ |
| -អានសង្សរបស់ភិក្ខុអ្នកទ្រទ្រង់ព្រះវិន័យ | ១៥២ |
| -អាការៈដែលភិក្ខុត្រូវអាបត្តិ | ១៥២ |
| -ខន្ធកៈវត្ត ១៤ | ១៥៣ |
| -ព្រះនិព្វាន ៩ បទ | ១៥៤ |
| -ពាក្យថាភិក្ខុមានវិគ្រោះថា | ១៥៥ |
| -ពាក្យថា(ភិក្ខុ)ណាមួយអធិប្បាយថា | ១៥៦ |
| -ឧបសម្បទា ៨ យ៉ាង | ១៥៧ |
| -លក្ខណៈសម្រាប់វិនិច្ឆ័យក្នុងសិក្ខាបទ-ទាំងអស់មាន ១៧ យ៉ាង | ១៥៨ |
| -ទ្វារមគ្គ ៣០ | ១៥៩ |
| -ការពោលលាសិក្ខា | ១៦០ |
| -ហេតុនាំឱ្យស្ត្រីតាំងគភ៌ ៧ យ៉ាង | ១៦២ |
| -លក្ខណៈបិទបាំងអាបត្តិ ១០ យ៉ាង | ១៦២ |
| -អន្តរាយ ១០ យ៉ាង | ១៦៣ |
| -បរិវាស ៣ យ៉ាង | ១៦៣ |
| -ភិក្ខុក្រាលកឋិនបានអានិសង្ស ៥ | ១៦៤ |
| -កឋិនដោះដោយមាតិកា ៨ | ១៦៥ |
| -ចីវរ ៦ យ៉ាង | ១៦៥ |
| -ចីវរដាច់អធិដ្ឋានដោយហេតុ ៨ យ៉ាង | ១៦៦ |
| -វត្តនិស្សគ្គិយមាន ៤ | ១៦៦ |
| -វត្ថុនៃទុក្កដមាន ១៥ | ១៦៦ |
| -អាវហារ ២៥ | ១៦៨ |
| -បុគ្គលជាទាសៈ ៣ ពួក | ១៧០ |
| -អាការៈ ៦ យ៉ាងត្រូវអាបត្តិបារាជិក | ១៧០ |
| -អាការៈ ៦ យ៉ាងត្រូវអាបត្តិថុល្លច្ច័យ-នឹងទុក្កដ | ១៧០ |
| -ប្រយោគបាណាតិបាត ៦ យ៉ាង | ១៧១ |
| -បុគ្គលដែលគួរធ្វើថ្នាំឱ្យ | ១៧១ |
| -អាបត្តិទុក្កដ ៨ យ៉ាង | ១៧២ |
| -ឧត្តរិមនុស្សធម៌ ១០ យ៉ាង | ១៧២ |
| -មហាចោរ ៥ ពួក | ១៧៣ |
| -ភិក្ខុអ្នកចូលទៅកាន់ត្រកូលរមែងមាន-ទោស ៥ យ៉ាង | ១៧៥ |
| -ភិក្ខុអ្នកចូលទៅកាន់ត្រកូល នៅច្រឡូក-ច្រឡំក្នុងត្រកូល មានទោស ៥ យ៉ាង | ១៧៦ |
| -បារាជិកទាំងអស់មាន ២៤ | ១៧៦ |
| -ហេតុនាំឱ្យសបិន្ទ ៤ យ៉ាង | ១៧៧ |
| -អាការនៃការចោទ | ១៧៧ |
| -ស្រី ១០ ជំពូក | ១៧៧ |
| -ភរិយា ១០ ជំពូក | ១៧៨ |
| -ទឹកសុក្ក ១០ យ៉ាង | ១៨០ |
| -ឧបត្ថម្ភ ៥ យ៉ាង | ១៨០ |
| -ប្រយោជន៍ ១០ យ៉ាង | ១៨១ |

**បញ្ជីរឿង** **ទំព័រ**

-អង្គប្រគេនមាន ៥ យ៉ាង....................១៨១
-ការដាច់ប្រគេនមាន ៧ យ៉ាង..............១៨២
-អនរិយវោហារ ៨ យ៉ាង.................... ១៨២
-អក្កោសវត្ថុ ១០ យ៉ាង.......................១៨៣
-ពូជ ៥ យ៉ាង................................. ១៨៤
-វត្ថុទុក្កដ ៧ យ៉ាង(បឋមសេនាសន)...... ១៨៤
-វត្ថុបាចិត្តិយ ១០ យ៉ាង(ទុតិយ..)......... ១៨៥
-ថេយ្យសំវាស ៣ យ៉ាង...................... ១៨៦
-សមណកប្បៈ ៥ យ៉ាង....................... ១៨៦
-វិធីធ្វើកប្បិយៈ................................ ១៨៦
-ត្រកូលមាន ៤ យ៉ាង......................... ១៨៧
-គ្រែ ៤ យ៉ាង..................................១៨៧
-ពូក ៥ យ៉ាង.................................. ១៨៧
-កៅអី ៤ យ៉ាង................................ ១៨៨
-ភោជន ៥ យ៉ាង...............................១៨៨
-បុព្វណ្ណជាតិ(ស្រូវ)៧ប្រការ................១៨៨
-មហាផល ៩ ប្រការ.......................... ១៨៩
-ទឹកបានៈ ៨ យ៉ាង............................ ១៨៩
-ខុទ្ទកផល(ផ្លែតូចៗ).........................១៩០
-គរុភណ្ឌ ៥ ពួក................................ ១៩១
-អធិករណ៍មាន ៤ យ៉ាង..................... ១៩៣
-វជ្ជនីយបុគ្គល ២០ ពួក.......................១៩៣
-អភព្វបុគ្គល ១១ ពួក......................... ១៩៥
-ហាមភត្តដោយអង្គ ៥....................... ១៩៥

**បញ្ជីរឿង** **ទំព័រ**

-ការមិនបានធ្វើវិន័យកម្ម ៧ យ៉ាង........១៩៦
-បវារណាមាន ៤ យ៉ាង..................... ១៩៧
-សុរា ៥ យ៉ាង...................................១៩៧
-មេរ័យ ៥ យ៉ាង............................... ១៩៨
-ឧបមាទោសរបស់កាម ១០ យ៉ាង........១៩៨
-ការវិនាស ៣ យ៉ាង .........................១៩៩
-រតន ១០ យ៉ាង................................២០០
-តិរច្ឆានកថា.................................. ២០០
-អន្តរាយិកធម៌ ៥ យ៉ាង.................... ២០៣
-ព្រះសទ្ធម្ម ៣ យ៉ាង..........................២០៣
-សង្ឃកម្ម ៤ យ៉ាង.............................២០៣
-ឧបោសថ ៩ យ៉ាង........................... ២០៤
-បវារណា ៩ យ៉ាង.............................២០៤
-ភាសិត ៤ យ៉ាង...............................២០៥
-គរុធម៌ ៨ ប្រការ............................ ២០៥
-បរិភោគ ៤ យ៉ាង.............................២០៦
-បរិសុទ្ធ ៤ យ៉ាង............................. ២០៧
-សង្ឃ ៥ ពួកដោយអំណាចកម្ម............២០៧
-សីមាមាន ២ យ៉ាង...........................២០៨
-ពទ្ធសីមាមាន ៣ យ៉ាង.....................២០៨
-អពទ្ធសីមាមាន ៣ យ៉ាង...................២០៨
-សីមាវិបត្តិ ១១ យ៉ាង.......................២០៩
-និមិត្តសីមា ៨ យ៉ាង.........................២១០
-ទិសទាំង ៨ សម្រាប់កំណត់និមិត្តសីមា.២១០

| បញ្ជីរឿង | ទំព័រ |
|---|---|
| -ញត្តិមានទោស ៥ យ៉ាង | ២១១ |
| -អនុស្សាវនាមានទោស ៥ យ៉ាង | ២១១ |
| -ភិក្ខុអ្នកចោទមានបំណងនឹងចោទភិក្ខុ | ២១២ |
| -ភិក្ខុដែលត្រូវគេចោទត្រូវតាំងនៅក្នុងធម៌ ២ | ២១៤ |
| -កុលទូសកៈ ៨ យ៉ាង | ២១៤ |
| -អន្តគ្គាហិកទិដ្ឋិ ១០ ប្រការ | ២១៥ |
| -បរិយត្តិ ៣ | ២១៦ |
| -បុគ្គលឈ្មោះថាជាអលជ្ជី | ២១៨ |
| -ទោសនៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ៥ ប្រការ | ២១៨ |

| បញ្ជីរឿង | ទំព័រ |
|---|---|
| -អានិសង្ស ៥ ប្រការ នៃបុគ្គលមានសីល ឬបរិបូរណ៍ដោយសីល | ២២០ |
| -ថេរៈគាថា.(២គាថា) | ២២២ |
| -សប្បុរិសានុស្សតិ | ២២៣ |
| -គោលធម៌ផ្សេងៗដែលជាគន្លឹះនៃការសិក្សា | ២២៣ |
| -អង្គ ៤ នៃការសិក្សាទៅជាបណ្ឌិត | ២២៣ |
| -ឥទ្ធិបាទ ៤ | ២២៤ |
| -បញ្ញា ៣ យ៉ាង | ២២៥ |
| -ហេតុនាំឱ្យចម្រើនមោហៈ(ល្ងង់) | ២២៥ |
| -សុភាសិត | ២២៧ |

# ឱវាទព្រះឧបាលិត្ថេរឯតទគ្គៈខាងព្រះវិន័យ

**សទ្ធាយ អភិនិក្ខម្ម នវបព្វជិតោ នវោ**
**មិត្តេ ភជេយ្យ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ ។**

កុលបុត្រចេញចាកផ្ទះដោយសទ្ធា ហើយបួសថ្មីជា នវភិក្ខុ គប្បីគប់រកកល្យាណមិត្តទាំងឡាយ ដែលជាអ្នកមានការចិញ្ចឹមជីវិត ដោយបរិសុទ្ធិ ជាអ្នកមិនខ្ជិលច្រអូស ។

**សទ្ធាយ អភិនិក្ខម្ម នវបព្វជិតោ នវោ**
**សង្ឃស្មឹ វិហរំ ភិក្ខុ សិក្ខេថ វិនយំ ពុធោ ។**

កុលបុត្រចេញចាកផ្ទះដោយសទ្ធា ហើយបួសថ្មីជា នវភិក្ខុ គប្បីសំណាក់អាស្រ័យនៅក្នុងពួកសង្ឃ ជាអ្នកឆ្លាតសិក្សាព្រះវិន័យ ។

**សទ្ធាយ អភិនិក្ខម្ម នវបព្វជិតោ នវោ**
**កប្បាកប្បេសុ កុសលោ ចរេយ្យ អបុរក្ខតោតិ ។**

កុលបុត្រចេញចាកផ្ទះដោយសទ្ធា ហើយបួសថ្មីជា នវភិក្ខុគប្បីជាអ្នកឈ្លាសក្នុងហេតុដែលគួរ នឹងមិនគួរទាំងឡាយ គប្បីប្រព្រឹត្តកុំឲ្យជាអ្នកយកមុខយកមាត់(តាមតណ្ហាដឹកនាំ) ។

*(សុតន្តបិដក ភាគ៥៦ ទំព័រ២០១)*

# **បរមត្ថទីបនី អដ្ឋកថា**

បណ្តាបទទាំងនោះ បទថា **សទ្ធាយ** ដោយសេចក្តីថា ព្រោះសទ្ធា អធិប្បាយថា មិនមែនដើម្បីចិញ្ចឹមជីវិត,ម្យ៉ាងទៀត បទថា **សទ្ធាយ** បានដល់ ការជឿផលកម្ម នឹងគុណព្រះរតនៈត្រៃ ។ បទថា **អភិនិក្ខម្ម** ដោយ សេចក្តីថា ចេញចាកការគ្រប់គ្រងផ្ទះ ។ បទថា **នវបព្វជិតោ** បានដល់ អ្នកបួសថ្មី គឺបួសក្នុងបឋមវ័យនោះឯង ។ បទថា **នវោ** បានដល់ នៅថ្មីគឺ នៅថ្មីក្នុងការសិក្សាសាសនា ។ បទថា **មិត្តេ ភជេយ្យ កល្យាណេ សុទ្ធាជីវេ អតន្ទិតេ** (គួរគប់រកកល្យាណមិត្ត អ្នកមាន អាជីវៈបរិសុទ្ធិ មិនខ្ជិលច្រអូស) សេចក្តីថាគួរគប់រក គឺ ចូលទៅរកកល្យាណមិត្ត អ្នកមានលក្ខណៈដូចដែលត្រាស់ទុកដោយន័យជាដើមថា ជាទីស្រលាញ់ គួរគោរពរាប់អាន ។ ឈ្មោះថា មានអាជីវៈបរិសុទ្ធិព្រោះវៀរចាកមិច្ឆាជីវៈ ។ ឈ្មោះថា មិនខ្ជិលច្រអូស ព្រោះជាអ្នកប្រារព្ធសេចក្តីព្យាយាមហើយ បានដល់ គួរគប់រក សមាគម ដោយការទទួលយកឱវាទានុសាសនីរបស់លោក ។ បទថា **សង្ឃស្មិំ វិហារំ** បានដល់ សំណាក់នៅក្នុងពួក គឺ ក្នុងជំនុំសង្ឃ ដោយការបំពេញវត្តផ្សេងៗ ។ បទថា **សិក្ខេថ វិនយំ ពុធោ** ដោយសេចក្តីថា ត្រូវជាអ្នកឆ្លាតក្នុងសេចក្តីដឹង សេចក្តីយល់ចូលចិត្ត សិក្សាបរិយត្តិគឺ ព្រះវិន័យ

ព្រោះថា ព្រះវិន័យជាអាយុ(ជីវិត) របស់ព្រះសាសនា កាលព្រះវិន័យតាំងនៅ ព្រះសាសនាក៏តាំងនៅដែរ ។ បទថា **កប្បាកប្បេសុ** មានសេចក្ដីថា ជាអ្នកច្លាតក្នុងរបស់ដែលគួរ និងមិនគួរ គឺ ជាអ្នកច្លាតឈ្លាសក្នុងរបស់ទាំងអស់នោះ ដោយអំណាច សូត្រ និងសុត្តានុលោម។ បទថា **អបុរក្ខតោ** បានដល់ មិនគួរជាអ្នកយកមុខយកមាត់ គឺមិនប្រាថ្នាក្នុងការធ្វើជាមេដឹកនាំ ដោយតណ្ហាជាដើម ។

## វត្ថុ ៣ យ៉ាងបើកទើបរុងរឿង បិទមិនរុងរឿង

**១-ចន្ទមណ្ឌលំ វិវដំ វិរោចតិ នោ បដិច្ឆន្នំ**

មណ្ឌលព្រះចន្ទបើកឡើងទើបរុងរឿង តែបិទបាំងទុកមិនរុងរឿង។

**២-សុរិយមណ្ឌលំ វិវដំ វិរោចតិ នោ បដិច្ឆន្នំ**

មណ្ឌលព្រះអាទិត្យបើកឡើងទើបរុងរឿង តែបិទបាំងទុកមិនរុងរឿង។

**៣-តថាគតប្បវេទិតោ ធម្មវិនយោ វិវដោ វិរោចតិ នោ បដិច្ឆន្នោ ។** ធម្មវិន័យដែលតថាគតសម្ដែងហើយ បើកឡើងទើបរុងរឿង បិទបាំងទុកមិនរុងរឿង។

(វិន័យបិដក ១៣/២៩)

# លក្ខណៈវិនិច្ឆ័យសាធារណៈសិក្ខាបទ ១៧ ប្រការ

និទានំ បុគ្គលំ វត្ថុំ    បញ្ញត្តិវិធិមេវ ច
អាណត្តាបត្តិនាបត្តិ-    វិបត្តី អង្គមេវ ច ។
សមុដ្ឋានវិធី កិរិយា-    សញ្ញាចិត្តេហិ នានតំ
វជ្ជកម្មប្បភេទញ្ច    តិកទ្វយវិធី តថា ។
លក្ខណំ សត្តរសធា    ឋិតំ សាធារណំ ឥទំ
ញត្វា យោជេយ្យ មេធាវី, តត្ថ តត្ថ យថារហន្តិ ។

អ្នកប្រាជ្ញត្រូវស្គាល់លក្ខណៈដែលមានទូទៅ ដែលតាំងនៅដោយអាការៈ ១៧ យ៉ាង គឺ និទាន ១ បុគ្គល ១ វត្ថុ ១ បញ្ញត្តិ ១ អាណត្តិ ១ អាបត្តិ ១ អនាបត្តិ ១ វិបត្តិ ១ អង្គ ១ សមុដ្ឋាន ១ កិរិយា ១ សញ្ញា ១ ចិត្ត ១ វជ្ជ ១ កម្ម ១ កុសលត្តិក ១ វេទនត្តិក ១ ហើយត្រូវប្រកបលក្ខណៈនេះ ក្នុងសិក្ខាបទនោះៗ តាមសមគួរចុះ ។

(កង្ខាវិតរណីបាលី ១/៥៦)

# លក្ខណៈវិនិច្ឆ័យសាធារណៈសិក្ខាបទ ១៧ ប្រការ

**១, និទានំ** = ទីកន្លែង ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិសិក្ខាបទទាំងអស់មាន៧កន្លែង គឺ នគរវេសាលី ១ នគររាជគ្រឹះ ១ នគរសាវត្ថី ១ នគរអាឡវី ១ នគរកោសម្ពី ១ ដែនសក្កៈ ១ ដែនភគ្គៈ ១ ។

ឱ, តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។

_សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលសម្រេចឥរិយាបថនៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

**២, បុគ្គលំ** = បុគ្គលដែលព្រះមានព្រះភាគទ្រង់ប្រារព្ធ ហើយបញ្ញត្តិក្នុងសិក្ខាបទនោះៗ គឺៈ

**១_សុទិន្នភិក្ខុ**,ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងបារាជិកសិក្ខាបទទី ១ ។

**២_ធនិយៈភិក្ខុ**,ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងបារាជិកសិក្ខាបទទី ២ ។

**៣_ភិក្ខុច្រើនរូបរួមគ្នា**, ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងបារាជិក សិក្ខាបទទី ៣ ជាដើម ។

**៤_ភិក្ខុនៅទៀបច្នេរស្ទឹងវគ្គុមុទា**, ជាបុគ្គលដើមបញ្ញត្តិប្រារព្ធក្នុងបារាជិកសិក្ខាបទទី ៤ ជាដើម ។

**៥_សេយ្យកភិក្ខុ**, ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងសង្ឃាទិសេសសិក្ខាបទ

ទី ១ ជាដើម ។

**៦_ឧទាយិភិក្ខុ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងសង្ឃាទិសេសសិក្ខាបទទី ២ ជាដើម ។

**៧_ភិក្ខុដែនអាឡវី,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងសង្ឃាទិសេសសិក្ខា-បទទី ៦ ជាដើម ។

**៨_ឆន្នភិក្ខុ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងសង្ឃាទិសេសសិក្ខាបទទី៧ ជាដើម ។

**៩_មេត្តិយៈ និងភុម្មជកភិក្ខុ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងសង្ឃាទិ-សេសសិក្ខាបទទី ៨ និងទី ៩ ។

**១០_ទេវទត្តភិក្ខុ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងសង្ឃាទិសេសទី ១០ ជាដើម ។

**១១_អស្សជិ និងបុនព្វសុកភិក្ខុ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងសង្ឃា-ទិសេសសិក្ខាបទ ទី១៣ ។

**១២_ឆព្វគ្គិយភិក្ខុ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងនិស្សគ្គិយបាចិត្តិយសិក្ខាបទទី១ ជាដើម ។

**១៣_ភិក្ខុឧបនន្ទសក្យបុត្រ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងនិស្សគ្គិយ-បាចិត្តិយសិក្ខាបទទី៦ ជាដើម ។

**១៤_ភិក្ខុរូបមួយ,**ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងនិស្សគ្គិយបាចិត្តិយសិក្ខា-បទ ទី១៦ ។

**១៥_ភិក្ខុហត្ថកសក្យបុត្រ,**ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងបាចិត្តិយសិក្ខា-បទ ទី១ ។

**១៦_ព្រះអនុរុទ្ធថេរៈ,**ជាបុគ្គលដើមបញ្ញត្តិ បារព្ធក្នុងបាចិត្តិយសិក្ខាបទទី៦

**១៧_សត្តរសវគ្គិយភិក្ខុ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងបាចិត្តិយសិក្ខា -បទទី ១៥ ជាដើម ។

**១៨_ព្រះចូឡបន្ថកៈ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងបាចិត្តិយសិក្ខាបទ ទី ២២ ។

**១៩_ព្រះវេឡដ្ឋសីសៈ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងបាចិត្តិយសិក្ខា-បទ ទី ៣៨ ។

**២០_ព្រះអានន្ទ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងបាចិត្តិយសិក្ខាបទទី៤១

**២១_ព្រះសាគត,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងបាចិត្តិយសិក្ខាបទទី៥១

**២២_អរិដ្ឋភិក្ខុ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងបាចិត្តិយសិក្ខាបទទី ៦៨

**២៣_ព្រះនន្ទ,** ជាបុគ្គលដើមបញ្ញត្តិ ប្រារព្ធក្នុងបាចិត្តិយសិក្ខាបទទី ៩២

**៣, វត្ថុំ** = អជ្ឈាចារ គឺការប្រព្រឹត្តអាក្រក់ របស់បុគ្គលនោះ ៗ ព្រះតថាគតហៅថា វត្ថុ ។

១. ការសេពមេថុនធម្ម របស់សុទិន្នភិក្ខុជាដើម ។

**៤, បញ្ញត្តិ** = សេចក្តីហាមប្រាម បានដល់បញ្ញត្តិ៩ប្រការ ៖

១-បឋមបញ្ញត្តិ, បញ្ញត្តិខាងដើមបង្អស់

២-អនុប្បញ្ញត្តិ, បញ្ញត្តិបន្ទាប់ពីបញ្ញត្តិខាងដើម

៣-អនុប្បន្នប្បញ្ញត្តិ , បញ្ញត្តិក្នុងទោសដែលមិនទាន់កើតឡើង គឺបញ្ញត្តិចំពោះតែគរុធម៌៨ របស់ភិក្ខុនីប៉ុណ្ណោះ

៤-សព្វត្ថប្បញ្ញត្តិ, បញ្ញត្តិនៅក្នុងប្រទេសទាំងអស់

៥-បទេសប្បញ្ញត្តិ, បញ្ញត្តិចំពោះតែក្នុងមជ្ឈិមប្រទេស មាន ៤ យ៉ាងគឺ ៖

-វិនយធរបញ្ចមេន គណេន ឧបសម្បទំ, ឧបសម្បទាដោយគណៈសង្ឃ ដែលមានព្រះវិន័យធរជាគម្រប់ ៥

-គណង្គណុបាហានំ, ពាក់ស្បែកជើង ៤ ជាន់ឡើងទៅ

-ធុវនហានំ, ស្រង់ទឹកជានិច្ច

-ចម្មានិ អត្ថរណានិ,[១] ប្រើប្រាស់កម្រាលស្បែក ។

---

(១) ប្រើបានទាំងដេកទាំងអង្គុយ គឺស្បែក កែះ , ពពែ ។ កម្រាលស្បែកមាន សត្វទ្រាយ, ស្ទាន់, ក្តាន់, ឈ្លូស, ប្រើស ,រមាំង ក៏គួរ ។ ចំណែកសត្វស្វា, ខ្លាឃ្មុំ, សរភៈ, សំពោច, មិនគួរ ។ នឹងសត្វសាហាវឯណានីមួយមាន រាជសីហ៍, ខ្លាធំ, ខ្លាដំបង, ខ្លាឃ្មុំ, ខ្លារខិន ស្បែកសត្វពួកណាព្រះមានព្រះភាគត្រាស់ថាមិនគួរ វៀរសត្វទាំងនោះចេញ សត្វទាំងឡាយដ៏សេស ដោយហោចទៅសូម្បី គោ ក្របី ទន្សាយ ឆ្មា ជាដើមរួមទាំងអស់ គប្បីជ្រាបថា សត្វសាហាវដូចគ្នា ក្នុងអត្ថនេះ ។ ពិតមែន ស្បែករបស់សត្វសាហាវទាំងអស់មិនគួរ ។ (សមន្តប្បាសាទិកា, ចម្មក្ខន្ធកៈ)

ទាំង ៤ នេះ ឈ្មោះថា បទេសប្បញ្ញត្តិ ។

៦-សាធារណប្បញ្ញត្តិ,[១] បញ្ញត្តិទូទៅ ទាំងភិក្ខុនិងភិក្ខុនី

៧-អសាធារណប្បញ្ញត្តិ,[២] បញ្ញត្តិចំពោះតែភិក្ខុ ឬភិក្ខុនី តែម្ខាងមិនទូទៅ ទាំងពីរខាង ។

៨-ឯកតោបញ្ញត្តិ,[៣] បញ្ញត្តិចំពោះតែភិក្ខុ ឬភិក្ខុនីតែម្ខាង ។

៩-ឧភតោបញ្ញត្ត, បញ្ញត្តិទាំងភិក្ខុ និងភិក្ខុនីទាំងពីរខាង ។

**៥, អាណត្តិ** ការបង្គាប់ហៅថាអាណត្តិ ។ មានពីរយ៉ាងគឺ៖

-អាណត្តិកប្បយោគ = ប្រយោគប្រើអ្នកដទៃឲ្យធ្វើ

-អនាណត្តិកប្បយោគ = ប្រយោគធ្វើខ្លួនឯង

---

(១)-បើសិក្ខាបទណាជាលោកវជ្ជៈ សាមណេរ សាមណេរី សិក្ខមានា ត្រូវប្រព្រឹត្តតាម (វិមតិ) វៀរតែព្រះអង្គអនុញ្ញាតផ្ទាល់ ដូចជារូបិយៈសិក្ខាបទជាដើម របស់សាមណេរ ។

(២)-សិក្ខាបទរបស់ភិក្ខុមាន ២២០មកកាន់ឧទ្ទេសរាល់៧ថ្ងៃឧបោសថគឺបារាជិក ៤,សង្ឃាទិសេស ១៣,អនិយតៈ២,និស្សគ្គិយ ៣០,ខុទ្ទកៈ(បាចិត្តិយ)៩២,សេក្ខិយវត្ត ៧៥ =២២០+អធិករណ ៧ = ២២៧ ។ សិក្ខាបទដែលមិនទូទៅដល់ភិក្ខុនីមាន ៤៦ សិក្ខាបទ គឺ សង្ឃាទិសេស ៦ ,អនិយតៈ ២, និស្សគ្គិយ ១២, ខុទ្ទកៈ(បាចិត្តិយ) ២២, បាដិទេសនីយ ៤ រួមជា ៤៦ សិក្ខាបទ ។

-សិក្ខាបទរបស់ភិក្ខុនីមាន៣០៤មកកាន់ឧទ្ទេសរាល់៧ថ្ងៃឧបោសថគឺបារាជិក៨,សង្ឃាទិសេស១៧, និស្សគ្គិយ៣០, ខុទ្ទកៈ(បាចិត្តិយ)១៦៦,បាដិទេសនីយ៨,សេក្ខិយវត្ត៧៥រួមជា៣០៤+អធិករណ៧ = ៣១១ ។ សិក្ខាបទដែលមិនទូទៅដល់ភិក្ខុមាន ១៣០ សិក្ខាបទ គឺ បារាជិក ៤, សង្ឃាទិសេស ១០,និស្សគ្គិយ ១២, ខុទ្ទកៈ(បាចិត្តិយ)៩៦, បាដិទេសនីយ៨, រួមជា ១៣០។ (បិដក.១៣/១២៨)

(៣)-ឯកតោបញ្ញត្តិ ដូចគ្នានឹង អសាធារណប្បញ្ញត្តិ, ឧភតោបញ្ញត្តិ ដូចគ្នានឹង សាធារណប្បញ្ញត្តិ ។

**៦, អាបត្តិ**[១] (ជាឈ្មោះនៃទោសផ្សេងៗ) មានបារាជិកាបត្តិ[២] ១ សង្ឃាទិសេសាបត្តិ ១ ថុល្លច្ចយាបត្តិ[៣] ១ បាចិត្តិយាបត្តិ ១ បាដិទេ-សនីយាបត្តិ ១ ទុក្កដាបត្តិ ១ ទុព្ភាសិតាបត្តិ ១ ។

**៧, អនាបត្តិ** វារៈដែលមិនត្រូវអាបត្តិ ។

ឧ. រូបិយសិក្ខាបទ (រឿងកាន់មាសប្រាក់) មានអនាបត្តិ ៣ គឺ ៖

-អាបត្តិមិនមានដល់ភិក្ខុដែលរើសយកដោយខ្លួនឯង ឬប្រើគេឲ្យរើសយកនូវរូបិយដែលធ្លាក់ចុះក្នុងអារាមក្តី ក្នុងលំនៅរបស់ខ្លួនក្តី ដោយគិតថា រូបិយនេះរបស់អ្នកណា អ្នកនោះនឹងនាំយកទៅចុះ ១ ដល់ភិក្ខុឆ្កួត ១ ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ១ ។

---

**(១) នវកោដិសហស្សានិ អសីតិសតកោដិយោ បញ្ញាសសតសហស្សានិឆត្តឹសា ច បុនាបរេ ឯតេ សំវរវិនយា សម្ពុទ្ធេន បកាសិតា បេយ្យាលមុខេន និទ្ទិដ្ឋា សិក្ខា វិនយសំវរេ ។**
-សំវរៈវិន័យទាំងឡាយ ដែលព្រះសម្ពុទ្ធទ្រង់ប្រកាស មានចំនួន ៩ ពាន់,១៨០ កោដិ,៥ លាន នឹងដទៃទៀត ៣លាន,៦សែនសិក្ខាបទ, សិក្ខាបទទាំងឡាយនេះព្រះអង្គទ្រង់លើកឡើងដោយប្រធានគឺបេយ្យាលៈ ក្នុងវិនយសំវរៈ ។ ក្នុងទីនេះ គណ្ឋិបទលោកឱ្យយក **សតសហស្សានិ** មកភ្ជាប់ជាមួយ **ឆត្តឹសា** មានរូបជា **សតសហស្សានិឆត្តឹសា ច** ប្រែថា ៣៦ សែន គឺ ៣ លាន ៦ សែន ។

(គណ្ឋិបទ ១/២៣៩)

(២) អាបត្តិ២កង បារាជិក និងសង្ឃាទិសេស ជាគរុកាបត្តិ ។ អាបត្តិបារាជិក ចេញចាក ដោយ (បដិញ្ញាយ) គឺការប្តេជ្ញាជាគ្រហស្ថ ។ អាបត្តិសង្ឃាទិសេសចេញចាកបានដោយ (វុដ្ឋានគាមិនី) គឺមានសង្ឃជាខាងដើម(បរិវាស) សង្ឃជាកណ្តាល(មានត្ត) នឹងមានសង្ឃជាទីបំផុត (អព្ភាន) ។

(៣) អាបត្តិ៥កង ចាប់ពីថុល្លច្ច័យ ដល់ ទុព្ភាសិត ជាលហុកាបត្តិ ចេញចាកដោយ (ទេសនាគាមិនី) គឺដោយការសម្តែង ចំពោះមុខ បុគ្គល គណៈ ឬសង្ឃ ។

**៨, វិបត្តិ** សេចក្តីវិនាសចាកសីលជាដើម មាន៤យ៉ាងគឺ៖

១_ អាបត្តិបារាជិក នឹងសង្ឃាទិសេស ហៅថា សីលវិបត្តិ ។

២_អាបត្តិថុល្លច្ច័យ បាចិត្តិយ បាដិទេសនីយ ទុក្កដ ទុព្ភាសិត ទាំង៥កងនេះ ហៅថា អាចារវិបត្តិ ។

៣_មិច្ឆាទិដ្ឋិ និងអន្តគ្គាហិកទិដ្ឋិ (ទំព័រ២១៥) ហៅថា ទិដ្ឋិវិបត្តិ ។

៤_មិច្ឆាអាជីវៈ (ការចិញ្ចឹមជីវិតខុស) ហៅថា អាជីវវិបត្តិ បាន ដល់ សិក្ខាបទ ៦ ដែលព្រះមានព្រះភាគបញ្ញត្តិព្រោះអាជីវៈជាហេតុ ព្រោះអាជីវៈជាដំណើរ គឺ ៖

១_ភិក្ខុមានសេក្តីប្រាថ្នាអាក្រក់ លុះក្នុងអំណាចសេចក្តីប្រាថ្នា ពោលអួតឧត្តរិមនុស្សធម៌ ដែលមិនមានក្នុងខ្លួន (ត្រូវអាបត្តិបារាជិក) ។

២_ភិក្ខុជាអ្នកប្រព្រឹត្តនិយាយដឹកនាំបុរសឲ្យស្ត្រី ដឹកនាំស្ត្រីឲ្យបុរស (ត្រូវអាបត្តិសង្ឃាទិសេស) ។

៣_ភិក្ខុពោលថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះឯងជា ព្រះអរហន្ត (ត្រូវអាបត្តិថុល្លច្ច័យ ព្រោះពោលបញ្ចៀតបញ្ចៀង) ។

៤_ភិក្ខុសូមបណីតភោជនទាំងឡាយ ដើម្បីប្រយោជន៍ដល់ខ្លួនមក បរិភោគ (ត្រូវអាបត្តិបាចិត្តិយ) ។

៥_ ភិក្ខុនីសូមបណីតភោជនទាំងឡាយ ដើម្បីប្រយោជន៍ដល់ខ្លួនមកបរិភោគ (ត្រូវអាបត្តិបាដិទេសនីយ) ។

៦_ភិក្ខុដែលមិនមានជំងឺ សូមសម្លក្ដី បាយក្ដី ដើម្បីប្រយោជន៍ដល់ខ្លួនឯងយកមកបរិភោគ (ត្រូវអាបត្តិទុក្កដ) ។

ព្រោះអាជីវៈជាហេតុ ព្រោះអាជីវៈជាដំណើរ ។ នេះព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ហៅថា ជា អាជីវវិបត្តិ ។

(វិនយបិដក ១៣/១២៦)

**៩, អង្គំ** អង្គជាគ្រឿងសម្រាប់វិនិច្ឆ័យអាបត្តិ [១] ។

ឧ. សញ្ចេតនិកសុក្កវិសដ្ឋិសិក្ខាបទ មានអង្គ៣ គឺ ៖

១–ចេតនា, មានចេតនាឲ្យឃ្លាតចេញ

២–ឧបក្កមោ, ព្យាយាមឲ្យឃ្លាតចេញ

៣–មោចនំ, អសុចិឃ្លាតចេញ ។

**១០, សមុដ្ឋានំ** (ហេតុជាទីតាំងនាំឲ្យត្រូវអាបត្តិ) ។

**សមុដ្ឋាននៃអាបត្តិទាំងអស់មាន ៦ យ៉ាងគឺ :**

ទី១ កាយ, ទី២ វាចា, ទី៣ កាយនិងវាចា, ទី៤ កាយនិងចិត្ត, ទី៥ វាចានិងចិត្ត, ទី៦ កាយវាចានិងចិត្ត ។

---

(១) គ្រប់អង្គទើបត្រូវអាបត្តិ មានតិចដែរទេដែលមិនគ្រប់អង្គហើយត្រូវអាបត្តិ។

ឧៈ ដូចសញ្ចរិត្តសិក្ខាបទមានអង្គ ៥ ត្រូវអាបត្តិសូម្បីអង្គ ៣ ។

សមុដ្ឋាន ៣ ខាងដើមជាអចិត្តកសមុដ្ឋាន, សមុដ្ឋាន៣ខាងចុងជាសចិត្តកសមុដ្ឋាន ។ អាបត្តិតាំងឡើងដោយសមុដ្ឋាន ១ ក៏មាន,សមុដ្ឋាន ២ ក៏មាន, សមុដ្ឋាន ៣ ក៏មាន, សមុដ្ឋាន៤ ក៏មាន, សមុដ្ឋាន៦ ក៏មាន, ដែលឈ្មោះថា សមុដ្ឋាន ៥ មិនមានទេ ។

## ឈ្មោះសមុដ្ឋានក្នុងសិក្ខាបទទាំងអស់មាន ១៣ យ៉ាងគឺ៖

១-បឋមបារាជិកសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានិងបឋមបារាជិកសិក្ខាបទ មានសមុដ្ឋាន ១ គឺ កាយនិងចិត្ត ។

២-អទិន្នាទានសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានឹងអទិន្នាទានសិក្ខាបទ មានសមុដ្ឋាន ៣ គឺ ទី១ កាយនិងចិត្ត, ទី២ វាចានិងចិត្ត, ទី៣ កាយវាចានិងចិត្ត ។

៣-សញ្ចរិត្តសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានឹងសញ្ចរិត្តសិក្ខាបទ មានសមុដ្ឋាន៦ គឺ ទី១ កាយ , ទី២ វាចា , ទី៣ កាយនិងវាចា, ទី៤ កាយនិងចិត្ត , ទី៥ វាចានិងចិត្ត, ទី៦ កាយវាចានិងចិត្ត ។

៤-សមនុភាសនសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានិងសមនុភាសនសិក្ខាបទ មានសមុដ្ឋាន១ គឺ កាយវាចា និងចិត្ត ។

៥-កឋិនសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានឹងកឋិនសិក្ខាបទមានសមុដ្ឋាន ២ គឺ ទី១ កាយនិងវាចា, ទី២ កាយវាចានិងចិត្ត ។

៦–ឯឡកលោមសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានឹងឯឡកលោមសិក្ខាបទ មានសមុដ្ឋាន ២ គឺ ទី១ កាយ, ទី២ វាចានិង ចិត្ត ។

៧–បទសោធម្មសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានឹងបទសោធម្មសិក្ខាបទ មានសមុដ្ឋាន ២គឺ ទី១ វាចា, ទី២ វាចានិងចិត្ត ។

៨–អទ្ធានសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានឹងអទ្ធានសិក្ខាបទ មានសមុដ្ឋាន ៤ គឺ ទី១ កាយ, ទី២ កាយនិងវាចា, ទី៣ កាយនិងចិត្ត ទី៤ កាយវាចា និងចិត្ត ។

៩–ថេយ្យសត្ថសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានឹងថេយ្យសត្ថសិក្ខាបទ មានសមុដ្ឋាន ២ គឺ ទី១ កាយនិងចិត្ត, ទី២ កាយ-វាចានិងចិត្ត ។

១០–ធម្មទេសនាសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានឹងធម្មទេសនាសិក្ខាបទ មានសមុដ្ឋាន ១ គឺ វាចានិងចិត្ត ។

១១–ភូតារោចនសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានឹងភូតារោចនសិក្ខាបទ មានសមុដ្ឋាន ៣ គឺ ទី១ កាយ, ទី២ វាចា, ទី៣ កាយនិងវាចា ។

១២-ចោរីវុដ្ឋានសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានឹង ចោរីវុដ្ឋាបនសិក្ខាបទ មានសមុដ្ឋាន ២ គឺ ទី១ វាចានិងចិត្ត, ទី ២ កាយវាចានិងចិត្ត ។

១៣-អននុញ្ញាតសមុដ្ឋាន អាបត្តិដែលមានសមុដ្ឋានដូចគ្នានឹងអននុញ្ញាតសិក្ខាបទ មានសមុដ្ឋាន៤គឺ ទី១ វាចា, ទី២ កាយនិងវាចា, ទី៣ វាចានិងចិត្ត , ទី៤ កាយវាចា និងចិត្ត ។

**១១, កិរិយា** អាបត្តិទាំងអស់មាន ៥ យ៉ាង ដោយអំណាចនៃកិរិយាគឺ ៖

១-អត្ថាបត្តិ កិរិយតោ សមុដ្ឋាតិ អាបត្តិកើតឡើងព្រោះការធ្វើ។ ឧ. ដូចជាអាបត្តិក្នុងការជីកដីជាដើម ។

២-អត្ថិ អកិរិយតោ អាបត្តិកើតឡើងព្រោះការមិនធ្វើនូវកម្មដែលគួរធ្វើ ។ ឧ. អាបត្តិក្នុងបឋមកឋិនសិក្ខាបទ ត្រូវអាបត្តិព្រោះមិនបានអធិដ្ឋាន ឬមិនបានវិកប្ប:ជាដើម។

៣-អត្ថិ កិរិយាកិរិយតោ អាបត្តិកើតឡើងព្រោះការធ្វើ ឬមិនធ្វើ ។ ឧ. ដូចជាចីវរប្បដិគ្គហណសិក្ខាបទ ។
(**ការធ្វើ**) ក្នុងការទទួលចីវរអំពីដៃរបស់ភិក្ខុនី ដែលមិនមែនជាញាតិ ។

(**ការមិនធ្វើ**) ព្រោះមិនធ្វើការផ្លាស់ប្តូរ ។

៤-អត្ថិ សិយា កិរិយតោ សិយា អកិរិយតោ អាបត្តិកើតឡើងព្រោះការធ្វើក្នុងកាលខ្លះ ព្រោះការមិនធ្វើក្នុងកាលខ្លះ ។ ឧ. ដូចជារូបិយសិក្ខាបទ អាបត្តិកើតឡើងព្រោះការទទួលមាសនិងប្រាក់ជាដើម ។

(**កាលខ្លះ**) ត្រូវព្រោះការទទួលខ្លួនឯងនឹងប្រើអ្នកដទៃឲ្យទទួលដើម្បីខ្លួន

(**កាលខ្លះ**) ត្រូវព្រោះមិនធ្វើការហាមឃាត់ ។

៥-អត្ថិ សិយា កិរិយតោ សិយា កិរិយាកិរិយតោ អាបត្តិកើតឡើងព្រោះការធ្វើក្នុងកាលខ្លះ ព្រោះការធ្វើ និងមិនធ្វើក្នុងកាលខ្លះ ។ ឧ. ដូចជាកុដិការសិក្ខាបទ អាបត្តិកើតឡើងក្នុងការធ្វើកុដិដែលមិនមានម្ចាស់ ។

(**កាលខ្លះ**) ត្រូវព្រោះការធ្វើកុដិធំហួសប្រមាណ ។

(**កាលខ្លះ**) ធ្វើកុដិធំហួសប្រមាណ នឹងមិនឲ្យសង្ឃសម្តែងទីឲ្យ ។

**១២, សញ្ញា** អាបត្តិទាំងអស់មាន ២ ដោយអំណាចសញ្ញាគឺ:

១-សញ្ញាវិមោក្ខ រួចផុតដោយការសម្គាល់ ។

ឧ. ភិក្ខុសំគាល់ថាស្លៀកស្បង់ជាបរិមណ្ឌល តែស្លៀកខុសពីបរិមណ្ឌល មិនជាអាបត្តិ ព្រោះសំគាល់ពិត មិនមែនក្លែងធ្វើឲ្យខុសនោះទេ ។

២-នោសញ្ញាវិមោក្ខ មិនរួចផុតដោយការសម្គាល់។

ឱ. ថ្ងៃជ្រេទៅហើយ ភិក្ខុសម្គាល់ថាថ្ងៃមិនទាន់ជ្រេ ក៏មិនរួចចាកអាបត្តិ។

**១៣, ចិត្តំ** អាបត្តិទាំងអស់មាន ២ យ៉ាងដោយអំណាចនៃចិត្ត គឺ:

១-សចិត្តកា, ប្រកបដោយចិត្ត

២-អចិត្តកា, មិនប្រកបដោយចិត្ត។

អាបត្តិណាកើតឡើងដោយអំណាចសចិត្តកសមុដ្ឋានតែម្យ៉ាង អាបត្តិនោះឈ្មោះថា សចិត្តក: ។ អាបត្តិណាកើតឡើងដោយអំណាច អចិត្តក: ឬ អចិត្តក:លាយជាមួយសចិត្តក:សមុដ្ឋាន អាបត្តិនោះឈ្មោះថាអចិត្តក: ។

**១៤, វជ្ជំ** អាបត្តិទាំងអស់មាន ២ យ៉ាង ដោយអំណាចនៃវជ្ជ: គឺ

១-លោកវជ្ជ:[(១)] (ទោសផ្លូវលោក) ចិត្តនៃអាបត្តិណាផ្នែកខាងសចិត្តក: ជាអកុសលតែម្យ៉ាង អាបត្តិនោះ ឈ្មោះថា លោកវជ្ជ: ។

២-បណ្ណត្តិវជ្ជ: (ទោសផ្លូវបញ្ញត្តិ) អាបត្តិដ៏សេសក្រៅអំពីលោកវជ្ជ: ហៅថា បណ្ណត្តិវជ្ជ: ។

**១៥, កម្មំ** អាបត្តិទាំងអស់មាន ៣ ដោយអំណាចនៃកម្ម គឺ :

១-ភិក្ខុត្រូវអាបត្តិតាមកាយទ្វារ ហៅថា **កាយកម្ម** ។

---

(១)**តត្ថ លោកវជ្ជេ អនុប្បញ្ញត្តិ ឧប្បជ្ជមានា រុន្ធន្តី ទ្វារំ បិទហន្តី សោតំ បច្ឆិន្ទមានា គាឡ្ហតរំ ការោន្តី ឧប្បជ្ជតិ**។ បណ្ដាទោសទាំងពីរនោះ(លោកវជ្ជ:,បណ្ណត្តិវជ្ជ:) អនុប្បញ្ញត្តិក្នុងសិក្ខាបទជាលោកវជ្ជ: កាលកើតឡើងរារាំង បិទទ្វារ កាត់ក្រសែ ធ្វេឱ្យមាំឡើង ជាងដើមរមែងកើតឡើង។

២_ភិក្ខុត្រូវអាបត្តិតាមវចីទ្វារ ហៅថា **វចីកម្ម** ។

៣_ភិក្ខុត្រូវអាបត្តិតាមទ្វារទាំងពីរ ហៅថា **កាយកម្ម និង វចីកម្ម**(១)

**១៦, កុសលត្តិកំ** (២) ភិក្ខុត្រូវអាបត្តិមានចិត្តជាអកុសលក៏មាន, មានចិត្តជាកុសលក៏មាន, មានចិត្តជាអព្យាកតៈក៏មាន ។

**១៧, វេទនត្តិកំ** អាបត្តិទាំងអស់មាន ៣ ដោយអំណាចនៃវេទនាៈ វេទនាមាន១ គឺ ទុក្ខវេទនា , វេទនាមាន២ គឺ សុខវេទនា និងឧបេក្ខា, វេទនាមាន ៣ គឺ ទុក្ខវេទនា សុខវេទនា និងឧបេក្ខាវេទនា។ ប្រភេទនៃវេទនាដទៃមិនមានទេ ។

វិន័យធរដែលឈ្លាស ត្រូវដឹងលក្ខណៈមានប្រការៈ១៧ យ៉ាង មាននិទានជាខាងដើម មានវេទនត្តិកៈជាទីបំផុត ត្រូវប្រកបតាមសមគួរក្នុងសិក្ខាបទនោះៗ ។ កាលបើ មិនបានប្រកបលក្ខណៈនោះៗទេ រមែងមានការដឹងច្បាស់បានដោយលំបាក ។ (មាតិកដ្ឋកថា)

**( លក្ខណៈវិនិច្ឆ័យសាធារណៈសិក្ខាបទ ១៧ ប្រការ ) ចប់**

---

(១) **មនោទ្វារេ បន អាបត្តិ នាម នត្ថិ** = ឈ្មោះថាអាបត្តិត្រូវតាមផ្លូវចិត្តតែម្យ៉ាងមិនមាន។ ( អដ្ឋកថា)

(២) **ទ្វត្តឹសេវ ហិ អាបត្តិសមុដ្ឋាបកចិត្តានិ អដ្ឋ កាមាវចរកុសលចិត្តានិ ទ្វាទស អកុសលានិ ទស កាមាវចរកិរិយាចិត្តានិ កុសលតោ ច ទ្វេ អភិញ្ញាចិត្តានីតិ** = មែនពិតចិត្តដែលនាំឱ្យត្រូវអាបត្តិក្នុងវិន័យទាំងអស មាន ៣២ ដួង គឺកាមាវចរកុសលចិត្ត ៨ ដួង, អកុសលចិត្ត ១២ ដួង, កាមាវចរកិរិយាចិត្ត ១០ ដួង, អភិញ្ញាចិត្ត ២ ដួង ដោយកុសល និងកិរិយា ។ (សមន្តបាសាទិកា. ៣/២០១)

# វិនិច្ឆ័យបរិមណ្ឌលនិវាសនៈសិក្ខាបទតាមលក្ខណៈ ១៧ ប្រការ

(ជាគ្រឿងបញ្ជាក់)

**១_និទាន** នៅក្នុងក្រុងសាវត្ថី

**២_បុគ្គល** ប្រារព្ធឆព្វគ្គីយ៍ភិក្ខុ

**៣_វត្ថុ** ស្លៀកស្បង់វយីករយាក ស្លុយមុខខ្លះស្លុយក្រោយខ្លះ

**៤_បញ្ញត្តិ** មានបញ្ញត្តិ១, ជាសព្វត្ថប្បញ្ញត្តិ, ជាសាធារណប្ប-ញ្ញត្តិ

**៥_អាណត្តិ** ជាអនាណត្តិក (ធ្វើខ្លួនឯង)

**៦_អាបត្តិ** ជាលហុកាបត្តិ (ទុក្កដាបត្តិ)

**៧_អនាបត្តិ** មាន៧ គឺ អសញ្ចិច្ច= ភិក្ខុមិនក្លែង, អសតិយា= ភិក្ខុគ្មានស្មារតី, អជានន្តស្ស = ភិក្ខុមិនដឹង, គិលានស្ស = ភិក្ខុមានជំងឺ, អាបទាសុ = ភិក្ខុមានសេចក្តីអន្តរាយ, ឧម្មត្តកស្ស = ភិក្ខុឆ្កួត, អាទិកម្មិក-ស្ស= ភិក្ខុដើមបញ្ញត្តិ ។

**៨_វិបត្តិ** ជាអាចារវិបត្តិ (ខូចមារយាទ)

**៩_អង្គ** មាន ៣ គឺ:

១_អនាទរិយំ, មិនអើពើ

២_អនាបត្តិការណាភាវោ, មិនមានហេតុនៃអនាបត្តិ

៣_អបរិមណ្ឌលនិវាសនៈ, ស្លៀកមិនជាបរិមណ្ឌល

**១០_សមុដ្ឋាន** ជាបឋមបារាជិកសមុដ្ឋាន មានសមុដ្ឋាន១ គឺ កាយ និងចិត្ត

**១១_កិរិយា** អត្ថាបត្តិ កិរិយតោ សមុដ្ឋាតិ , អាបត្តិកើតឡើងព្រោះការធ្វើ ។

**១២_សញ្ញា** ជាសញ្ញាវិមោក្ខ, ( រួចផុតដោយសំគាល់ថា ត្រូវបរិមណ្ឌល )

**១៣_ចិត្ត** ជាសចិត្តកៈ (ប្រកបដោយចិត្ត)

**១៤_វជ្ជៈ** ជាលោកវជ្ជៈ( ទោសផ្លូវលោក)

**១៥_កម្ម** ជាកាយកម្ម ( ធ្វើតាមផ្លូវកាយ)

**១៦_កុសលត្តិក** មានចិត្តមួយជាអកុសលចិត្ត ( ជាទោសៈ ព្រោះក្លែងល្មើស បញ្ញាត្តិ)

**១៧_វេទនត្តិក** មានវេទនា ១ គឺទុក្ខវេទនា ( ព្រោះទោសៈចិត្ត ជាទោមនស្សវេទនា ជាហេតុ ) ។

# វិន័យ ៤ យ៉ាង

តស្មិំ បន សិក្ខាបទេ ច សិក្ខាបទវិភង្គេ ច សកលេ ច វិនយវិនិច្ឆយេ កោសល្លំ បត្ថយន្តេន ចតុព្វិធោ វិនយោ ជានិតព្វោ ។ ព្រះវិន័យធរ ការប្រាថ្នាភាពជាអ្នកឈ្លាសក្នុងសិក្ខបទនោះៗផង ក្នុងសិក្ខាបទវិភង្គផង ក្នុងវិន័យវិនិច្ឆ័យទាំងអស់ផង គួរជ្រាបវិន័យ ៤ យ៉ាង ។

**១,សុត:** តត្ថ សុត្តន្នាម សកលវិនយបិដកេ បាលិ ។ _បណ្តាវិន័យទាំង៤យ៉ាងនោះ ដែលឈ្មោះថា **សូត្រ** បានដល់បាលីក្នុងវិន័យបិដកទាំងអស់ ។ ចែកជា៥គម្ពីរគឺ គម្ពីរមហាវិភង្គ (បិដក.១_៤), គម្ពីរភិក្ខុនីវិភង្គ (បិដក_ភាគ ៥), គម្ពីរមហាវគ្គ (បិដកភាគ៦_៨), គម្ពីរចុល្លវគ្គ (បិដកភាគ៨_១១) , គម្ពីរបរិវារ (បិដកភាគ១២_១៣) ។

**២,សុត្តានុលោម:** សុត្តានុលោមន្នាម ចត្តារោ មហាបទេសា យេ ភគវតា ឯវំ វុត្តា ។

ដែលឈ្មោះថា **សុត្តានុលោម** បានដល់មហាបទេស ៤ ដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា ៖

១-យំ ភិក្ខវេ មយា ឥទំ ន កប្បតីតិ អប្បដិក្ខិត្តំ តញ្ចេ អកប្បិយំ អនុលោមេតិ កប្បិយំ បដិពាហតិ តំ

វោ ន កប្បតិ ។

ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាមទុកថា របស់នេះមិនគួរទេ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់ដែលគួរ របស់នោះមិនគួរដល់អ្នកទាំងឡាយ ។

២-យំ ភិក្ខវេ មយា ឥទំ ន កប្បតីតិ អប្បដិក្ខិត្តំ តញ្ចេ កប្បិយំ អនុលោមេតិ អកប្បិយំ បដិពាហតិ តំ វោ កប្បតិ ។

ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាមទុកថា របស់នេះមិនគួរទេ បើរបស់នោះអនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះគួរដល់អ្នកទាំងឡាយ ។

៣-យំ ភិក្ខវេ មយា ឥទំ កប្បតីតិ អននុញ្ញាតំ តញ្ចេ អកប្បិយំ អនុលោមេតិ កប្បិយំ បដិពាហតិ តំ វោ ន កប្បតិ ។

ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគត មិនបានអនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរដល់អ្នកទាំងឡាយ ។

៤-យំ ភិក្ខវេ មយា ឥទំ កប្បតីតិ អននុញ្ញាតំ

តញ្ចេ កប្បិយំ អនុលោមេតិ អកប្បិយំ បដិពាហតិ តំ វោ កប្បតិ ។

ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានអនុញ្ញាតទុកថា របស់នេះគួរ បើរបស់ទាំងនោះអនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះគួរដល់អ្នកទាំងឡាយ ។ *(វិន័យបិដក ៧/៣៧៧)*

**៣, អាចរិយវាទ:** អាចរិយវាទោ នាម ធម្មសង្គហកេហិ បញ្ចហិ អរហន្តសតេហិ ឋបិតា បាលិវិនិមុត្តា ឱក្កន្តិកវិនិច្ឆយប្បវត្តា អដ្ឋកថាតន្តិ ។

ដែលឈ្មោះថា **អាចរិយវាទ** បានដល់បែបអដ្ឋកថាដែលពោលទុកសម្រាប់វិនិច្ឆ័យក្រៅផ្លូវរឿង ក្រៅព្រះបាលី ដែលព្រះអរហន្ត ៥00អង្គជាធម្មសង្គាហក:តាំងទុក ។

**៤, អត្តនោមតិ:** អត្តនោមតិ នាម សុត្តសុត្តានុលោម អាចរិយវាទេ មុញ្ចិត្វា អនុមានេន អត្តនោ អនុពុទ្ធិយា នយគ្គាហេន ឧបដ្ឋិតាការកថនំ ។

ដែលឈ្មោះថា **អត្តនោមតិ** បានដល់ ពាក្យដែលផុតចាកសូត្រ សុត្តានុលោម អាចរិយវាទ ពោលតាមអាការ:ដែលប្រាកដដោយអនុមាន គឺ ដោយការដឹងរបស់ខ្លួន ដោយការកាន់យកន័យ ដោយការកាន់យកសេចក្តី ។

អបិច សុត្តន្តាភិធម្មវិនយដ្ឋកថាសុ អាគតោ សព្វោបិ ថេរវាទោ អត្តនោមតិ នាម ។ ន័យម្យ៉ាងទៀត ថេរវាទសូម្បីទាំងអស់ ដែលមកក្នុងអដ្ឋកថាព្រះសូត្រ ព្រះអភិធម្ម និងព្រះវិន័យឈ្មោះថា អត្តនោមតិ ។

តំ បន អត្តនោ មតឹ គហេត្វា កថេន្តេន ន ទឡ្ហគ្គាហំ គហេត្វា វោហារិតព្វំ ការណំ សល្លក្ខេត្វា អត្ថេន បាលឹ បាលិយា ច អត្ថំ សំសន្ទេត្វា កថេតព្វំ ។

តែកុលបុត្រអ្នកអាងអត្តនោមតិនោះ មិនគួរប្រកាន់ឲ្យមាំពោលគួរ កំណត់ហេតុប្រៀបផ្ទៀបបាលីជាមួយសេចក្តី សេចក្តីជាមួយបាលីហើយទើបពោល

អត្តនោមតិ អាចរិយវាទេ ឱតារេតព្វា ។ អត្តនោមតិគួរស្ទង់មើលក្នុង អាចរិយវាទ ។

សចេ តត្ថ ឱតរតិ ចេវ សមេតិ ច គហេតព្វា ។ ប្រសិនបើចុះសម្រុងគ្នា នឹងសមគ្នា ក្នុងអាចរិយវាទនោះទើបគួរកាន់យក ។

សចេ នេវ ឱតរតិ ន សមេតិ ន គហេតព្វា ។ បើមិនចុះសម្រុងគ្នា មិនសមគ្នា មិនគួរកាន់យក ។

អយំ ហិ អត្តនោមតិ នាម សព្វទុព្វលោ ។ មែនពិត ដែលឈ្មោះថា អត្តនោមតិនេះ មានកម្លាំងខ្សោយ អន់ជាងគ្រប់យ៉ាង ។

អត្តនោមតិតោ អាចរិយវាទោ ពលវតរោ ។

អាចរិយវាទ មានកម្លាំងជាងអត្តនោមតិ គ្រប់យ៉ាង ។

អាចរិយវាទោបិ សុត្តានុលោមេ ឱតារេតព្វោ ។

សូម្បីអាចរិយវាទ ក៏គួរស្ទង់មើលក្នុង សុត្តានុលោម ។

តត្ថ ឱតរន្តោ សមេន្តោ ឯវ គហេតព្វោ ឥតរោ ន គហេតព្វោ ។ កាលចុះសម្រុងគ្នា សមគ្នា ក្នុងសុត្តានុលោមនោះ ទើបគួរកាន់យក ចំណែកដែលមិនចុះសម្រុងគ្នា មិនសមគ្នា មិនគួរកាន់យក ។

អាចរិយវាទតោ ហិ សុត្តានុលោមំ ពលវតរំ ។

ព្រោះថា សុត្តានុលោម មានកម្លាំងជាង អាចរិយវាទ ។

សុត្តានុលោមម្បិ សុត្តេ ឱតារេតព្វំ ។

សូម្បីសុត្តានុលោម ក៏គួរប្រៀបធៀបមើលក្នុងសូត្រ ។

តត្ថ ឱតរន្តំ សមេន្តមេវ គហេតព្វំ ឥតរំ ន គហេតព្វំ ។ បើចុះសម្រុងគ្នា សមគ្នា ក្នុងសូត្រនោះទើបគួរកាន់យក ចំណែក ដែលមិនចុះសម្រុងគ្នា មិនសមគ្នា មិនគួរកាន់យក ។

សុត្តានុលោមតោ ហិ សុត្តមេវ ពលវតរំ ។ ព្រោះថា សូត្រប៉ុណ្ណោះ ជាបាវចនៈមានកម្លាំងជាងសុត្តានុលោម ។

សុត្តំ ហិ អប្បដិវត្តិយំ ការកសង្ឃសទិសំ ពុទ្ធានំ ឋិតកាលសទិសំ ។ មែនពិត សូត្រប៉ុណ្ណោះជាបាវចនៈ (ពាក្យជា-ប្រធាន) ដែលអ្នកណាមួយជំទាស់មិនបាន ដូចសង្ឃអ្នកធ្វើ (សង្គាយនា) ដូចជាកាលដែលព្រះពុទ្ធទាំងឡាយទ្រង់គង់ព្រះជន្មនៅ ។

ព្រោះហេតុនោះ កាលណាភិក្ខុ ២ រូប សាកច្ឆាគ្នា សកវាទីពោលអាងសូត្រ បរវាទីពោលអាងសុត្តានុលោម ។ កាលនោះ លោកទាំង ២ រូបនោះ មិនគួរធ្វើការបោះសំដី ឬតិះដៀលគ្នានិងគ្នា គួរស្ទង់មើលសុត្តានុលោមក្នុងសូត្រ ។ បើចុះសម្រុងគ្នា សមគ្នា គួរកាន់យក បើមិនចុះសម្រុងគ្នា មិនសមគ្នា មិនគួរកាន់យក គួរតាំងនៅក្នុងសូត្រប៉ុណ្ណោះ ។ បើសកវាទីនេះពោលអាងសូត្រ បរវាទីពោលអាងអាចរិយវាទ សូម្បីទាំង ២ រូបនោះ មិនគួរធ្វើការបោះសំដី ឬតិះដៀលគ្នានិងគ្នា គួរស្ទង់មើលអាចរិយវាទក្នុងសូត្រ ។ បើចុះសម្រុងគ្នា សមគ្នា គួរកាន់យក ។ កាលអាចរិយវាទមិនចុះសម្រុងគ្នា និងមិនសមគ្នា ទាំងជាពាក្យដែលគួរតិះដៀល ក៏មិនគួរកាន់យក គួរតាំងនៅក្នុងសូត្រប៉ុណ្ណោះ ។ បើសកវាទីនេះពោលអាងសូត្រ បរវាទីពោលអាងអត្តនោមតិ សូម្បីទាំងពីររូបនោះ ក៏មិនគួរធ្វើការបោះសម្តី ឬតិះដៀលគ្នានិងគ្នា គួរស្ទង់មើលអត្តនោមតិ

ក្នុងសូត្រ បើចុះសម្រុងគ្នា សមគ្នា គួរកាន់យក បើមិនចុះសម្រុងគ្នា មិនសមគ្នា ក៏មិនគួរកាន់យក គួរតាំងនៅក្នុងសូត្រប៉ុណ្ណោះ ។ បើសកវាទីនេះ ពោលអាងសុត្តានុលោម បរវាទីពោលអាងសូត្រ គួរស្ទង់មើលសូត្រ ក្នុងសុត្តានុលោម ។ បើចុះសម្រុងគ្នា សមគ្នា ប្រាកដមានមកក្នុងព្រះបាលី ឡើងកាន់សង្គីតិទាំង ៣ ដង ទើបគួរកាន់យក បើមិនប្រាកដដូចយ៉ាងនោះ មិនចុះសម្រុងគ្នា មិនសមគ្នា ជាពាហិរកសូត្រ សិលោកសូត្រ ឬសូត្រដែលគួរតិះដៀលដទៃៗ ដែលមកអំពីបណ្តាសូត្រទាំងឡាយមានគុឡ្ហវេស្សន្តរ គុឡ្ហវិន័យ នឹងគុឡ្ហវេទល្ល:ជាដើមយ៉ាងណាមួយ មិនគួរកាន់យក គួរតាំងនៅក្នុងសុត្តានុលោមប៉ុណ្ណោះ ។ បើសកវាទីនេះពោលអាងសុត្តានុលោម បរវាទីពោលអាងអាចរិយវាទ គួរស្ទង់មើលអាចរិយវាទ ក្នុងសុត្តានុលោម បើចុះសម្រុងគ្នា សមគ្នា គួរកាន់យក បើមិនចុះសម្រុងគ្នា មិនសមគ្នា មិនគួរកាន់យក គួរតាំងនៅក្នុងសុត្តានុលោមប៉ុណ្ណោះ ។ បើសកវាទីពោលអាងសុត្តានុលោម បរវាទីពោលអាងអត្តនោមតិ គួរស្ទង់មើលអត្តនោមតិ ក្នុងសុត្តានុលោម ។ បើចុះសម្រុងគ្នា សមគ្នា គួរកាន់យក បើមិនចុះសម្រុងគ្នា មិនសមគ្នា មិនគួរកាន់យក គួរតាំងនៅក្នុងសុត្តានុលោមប៉ុណ្ណោះ ។ បើសកវាទីនេះពោលអាងអាចរិយវាទ បរវាទីពោលអាងសូត្រ គួរស្ទង់មើលសូត្រ ក្នុងអាចរិយវាទ ។ បើចុះសម្រុងគ្នា សមគ្នា គួរកាន់យក ។ សូត្រដែលគួរ

តិះដៀលក្រៅនេះ មិនគួរកាន់យកគួរតាំងនៅក្នុងអាចរិយវាទប៉ុណ្ណោះ ។ បើសកវាទីនេះ ពោលអាងអាចរិយវាទ បរវាទីពោលអាងសុត្តានុលោម គួរស្ទង់មើលសុត្តានុលោមក្នុងអាចរិយវាទ ។ កាលចុះសម្រុងគ្នា សមគ្នា ទើបគួរកាន់យក ។ ក្រៅនេះ មិនគួរកាន់យក គួរតាំងនៅក្នុងអាចរិយវាទប៉ុណ្ណោះ ។ បើសកវាទីនេះ ពោលអាងអាចរិ-យវាទ បរវាទីពោលអាងអត្តនោមតិ គួរស្ទង់មើលអត្តនោមតិក្នុងអាចរិយវាទ ។ បើចុះសម្រុងគ្នា សមគ្នា គួរកាន់យក បើមិនចុះសម្រុងគ្នា មិនសមគ្នា មិនគួរកាន់យក គួរតាំងនៅក្នុងអាចរិយវាទប៉ុណ្ណោះ ។ ការកាន់យកមតិរបស់ខ្លួនប៉ុណ្ណោះ គួរធ្វើឲ្យមានកម្លាំង (ឲ្យមានគោល) ។

ម្យ៉ាងទៀត បើសកវាទីនេះ ពោលអាងអត្តនោមតិ បរវាទីពោលអាងសូត្រ គួរស្ទង់មើលសូត្រក្នុងអត្តនោមតិ បើចុះសម្រុងគ្នា សមគ្នា គួរកាន់យក ។ សូត្រដែលគួរតិះដៀលក្រៅនេះ មិនគួរកាន់យក គួរតាំងនៅក្នុងអត្តនោមតិប៉ុណ្ណោះ ។ បើសកវាទីនេះ ពោលអាងអត្តនោមតិ បរវាទីពោលអាងសុត្តានុលោម គួរស្ទង់មើលសុត្តានុលោម ក្នុងអត្ត-នោមតិ ។ កាលចុះសម្រុងគ្នា សមគ្នា គួរកាន់យក ។ ក្រៅនេះ មិនគួរកាន់យក គួរតាំងនៅក្នុងអត្តនោមតិប៉ុណ្ណោះ ។ បើសកវាទីនេះ ពោលអាងអត្តនោមតិ បរវាទីពោលអាងអាចរិយវាទ គួរស្ទង់មើលអាចរិយវាទក្នុងអត្តនោមតិ ។ បើចុះសម្រុងគ្នា សមគ្នា គួរកាន់យក ។

អាចរិយវាទដែលគួរតិះដៀលក្រៅនេះ មិនគួរកាន់យក គួរតាំងនៅក្នុងអត្តនោមតិប៉ុណ្ណោះ ។ ការកាន់យកមតិរបស់ខ្លួននុ៎ះ គួរធ្វើឲ្យមានកម្លាំង (ឲ្យមានគោល) ។ មួ្យ៉ាងទៀត មិនគួរធ្វើការបោះសម្តី ឬតិះដៀលក្នុងទីទាំងពួង ដោយប្រការដូច្នេះ ។មួ្យ៉ាងទៀត បើសកវាទីនេះ ពោលអាងថា ជាកប្បិយៈ បរវាទីពោលអាងថា ជាអកប្បិយៈ គួរស្ទង់មើល (វត្ថុនោះៗ) ក្នុងសូត្រ នឹងសុត្តានុលោម ។ បើវត្ថុនោះ ជាកប្បិយៈ គួរតាំងនៅក្នុងវត្ថុជាកប្បិយៈ ។ បើវត្ថុនោះ ជាអកប្បិយៈ គួរតាំងនៅក្នុងវត្ថុជាអកប្បិយៈ ។ បើសកវាទីនេះ ចង្អុលប្រាប់ហេតុ នឹងពាក្យវិនិច្ឆ័យច្រើន អំពីសូត្រជាគ្រឿងអាងវត្ថុដែលជាកប្បិយៈ ដល់ចំណែកបរវាទីនោះ បរវាទីមិនជួបហេតុ គួរតាំងនៅក្នុងវត្ថុដែលជាកប្បិយៈ ។ បើបរ-វាទី ចង្អុលប្រាប់ហេតុ នឹងពាក្យវិនិច្ឆ័យច្រើន អំពីសូត្រជាគ្រឿងអាងវត្ថុដែលជាអកប្បិយៈ ដល់ចំណែកសកវាទីនោះ ។ សកវាទីនេះ មិនគួរប្រកាន់មាំ តាំងនៅថា ការកាន់យកមតិរបស់ខ្លួន (ត្រឹមត្រូវ) ។ គួរព្រមទទួលថា ល្អ ហើយតាំងនៅក្នុងវត្ថុដែលជាអកប្បិយប៉ុណ្ណោះ ។ បើស្រមោលនៃហេតុ របស់លោកទាំងពីរចំណែកប្រាកដច្បាស់ ដំណើរដែលលោកទាំងពីរចំណែកជំទាស់គ្នានុ៎ះ ជាការល្អ តែគួរតាំងនៅក្នុងវត្ថុដែលជាអកប្បិយ ។ ព្រោះថា កាលមកដល់វិន័យហើយ ដែលភិក្ខុបរិស័ទ គួរអាស្រ័យការពិចារណាវត្ថុដែលគួរ នឹងមិនគួរ ការពារទុក

គួរធ្វើការប្រកាន់ឲ្យមាំទាំ គួរកាត់ក្រសែចេញ គួរតាំងនៅក្នុងភាពជាអ្នកធ្ងន់ប៉ុណ្ណោះ ។ ម្យ៉ាងទៀត បើសកវាទីនេះ ពោលអាងថា ជាអកប្បិយ បរវាទីពោលអាងថាជា កប្បិយ គួរស្ទង់មើលវត្ថុនោះៗ ក្នុងសូត្រ និងសុត្តានុលោម ។ បើវត្ថុនោះ ជាកប្បិយ គួរតាំងនៅក្នុងវត្ថុជាកប្បិយ បើវត្ថុនោះ ជាអកប្បិយ គួរតាំងនៅក្នុងវត្ថុជាអកប្បិយ ។ បើសកវាទីនេះ ចង្អុលប្រាប់ដល់វត្ថុជាអកប្បិយ ដោយសូត្រ ពាក្យវិនិច្ឆ័យ នឹងហេតុច្រើនប្រការ បរវាទីមិនបានជួបហេតុ គួរតាំងនៅក្នុងវត្ថុដែលជាអកប្បិយ ។ បើបរវាទី ចង្អុលប្រាប់ដល់វត្ថុដែលជាកប្បិយ ដោយសូត្រ ពាក្យវិនិច្ឆ័យ នឹងហេតុច្រើនប្រការ សកវាទីនេះ មិនបានជួបហេតុ គួរតាំងនៅក្នុងវត្ថុដែលជាកប្បិយៈ ។ បើស្រមោលនៃហេតុរបស់លោកទាំងពីរ រមែងប្រាកដច្បាស់ មិនគួរលះការប្រកាន់ (មតិ) របស់ខ្លួន ។ ដូចក្នុងវត្ថុដែលជាកប្បិយៈ និងអកប្បិយៈ និងក្នុងវត្ថុជាអកប្បិយៈ និងកប្បិយៈ លោកពោលវិនិច្ឆ័យនេះទុកហើយយ៉ាងណា ក្នុងវាទថា ជាអនាបត្តិ និងអាបត្តិក្តី ក្នុងវាទថា ជាអាបត្តិនិងអនាបត្តិក្តី ក្នុងវាទថា ជាលហុកាបត្តិ និងគរុកាបត្តិក្តី ក្នុងវាទថា ជាគរុកាបត្តិ និងលហុកាបត្តិក្តី ក៏ជ្រាបវិនិច្ឆ័យដូច្នោះ ។ មែនពិត ក្នុងវាទដែលថា ជាអនាបត្តិ និងអាបត្តិជាដើមនេះ មានសេចក្តីផ្សេងគ្នា ក្នុងហេតុត្រឹមតែឈ្មោះប៉ុណ្ណោះ ក្នុងន័យនៃកាប្រកបសេចក្តី មិនមានការផ្សេងគ្នាទេ

ព្រោះហេតុនោះ កាលប្រកបសេចក្ដី លោកទើបមិនធ្វើឲ្យពិស្ដារ ។ កាលកើតពាក្យវិនិច្ឆ័យដល់វត្ថុដែលជាកប្បិយៈ និងអកប្បិយៈជាដើម យ៉ាងនេះហើយ ចំណែកណា បានជួបហេតុច្រើន ក្នុងសូត្រ សុត្តានុលោម អាចរិយវាទ នឹងអត្តនោមតិ គួរតាំងនៅក្នុងវាទរបស់ចំណែកនោះ ។ ម្យ៉ាងទៀត (ទាំងពីរចំណែក) កាលមិនបានជួបហេតុ នឹងពាក្យវិនិច្ឆ័យដោយប្រការទាំងពួង មិនគួរលះបង់សូត្រ គួរតាំងនៅក្នុងសូត្រប៉ុណ្ណោះដូច្នេះឯង ។

ព្រះវិន័យធរ ដែលប្រាថ្នាភាពជាអ្នកឈ្លាស ក្នុងសិក្ខាបទវិភង្គនៃសិក្ខាបទនោះ នឹងវិនិច្ឆ័យទាំងអស់ គួរជ្រាបវិន័យ ៤ យ៉ាងនេះ ដូចពណ៌នាមកដូច្នេះឯង ។

ក៏ឯបុគ្គលអ្នកទ្រទ្រង់វិន័យ កាលជ្រាបវិន័យ ៤ យ៉ាងនេះហើយ គួរជាអ្នកប្រកបដោយលក្ខណៈ ៣ ទៀត ។ មែនពិត លក្ខណៈនៃព្រះ-វិន័យធរ ៣ ប្រការ គួរប្រាថ្នា ។ លក្ខណៈ ៣ ប្រការ តើដូចម្ដេច ? លក្ខណៈ ៣ ប្រការ គឺ៖

## លក្ខណៈ ៣ របស់ព្រះវិន័យធរ

### ១-សុត្តញ្ចស្ស ស្វាគតំ ហោតិ សុប្បវត្តិតំ សុវិនិច្ឆិតំ សុត្តតោ អនុព្យញ្ជនសោតិ ឥទមេកំ លក្ខណំ ។

សូត្ររបស់ព្រះវិន័យធរនោះជាពុទ្ធវចនៈ ដែលមកត្រឹមត្រូវ ស្ទាត់ជំនាញល្អ វិនិច្ឆ័យល្អ ដោយសូត្រ ដោយព្យញ្ជនៈ នេះជាលក្ខណៈទី ១ ។

### បទពន្យល់លក្ខណៈទី ១

តត្ថ សុត្តន្នាម សកលំ វិនយបិដកំ តទស្ស ស្វាគតំ ហោតិ សុដ្ឋុ អាគតំ ។

បទថា សុត្តញ្ច ជាដើមនោះ បានដល់ វិន័យបិដកទាំងអស់ ឈ្មោះថា សូត្រ ។ សូត្ររបស់ព្រះវិន័យធរនោះ ជាពុទ្ធវចនៈដែលមកត្រឹមត្រូវ គឺ (ចាំ) មកដោយល្អ ។

សុប្បវត្តិតន្តិ សុដ្ឋុ បវត្តំ បគុណំ វាចុគ្គតំ ។

បទថាសុប្បវត្តិតំ បានដល់ ប្រព្រឹត្តទៅដោយល្អ គឺស្ទាត់ជំនាញរត់មាត់ ។

សុវិនិច្ឆិតំ សុត្តតោ អនុព្យញ្ជនសោតិ បាលិតោ ច បរិបុច្ឆតោ ច អដ្ឋកថាតោ ច សុវិនិច្ឆិតំ ហោតិ កង្ខាច្ឆេទំ កត្វា ឧគ្គហិតំ ។

ច្រើនបទថា សុវិនិច្ឆិតំ សុត្តតោ អនុព្យញ្ជនសោ បាន ដល់ ដែលវិនិច្ឆ័យរៀបរយ គឺដែលខ្លួនកាត់ការសង្ស័យ រៀនយកដោយ បាលី បរិបុច្ឆា និងអដ្ឋកថា ។

**២-វិនយេ ខោ បន ឋិតោ ហោតិ អសំហិរោតិ ឥទំ ទុតិយំ ។** ក៏ព្រះវិន័យធរនោះ ជាអ្នកមាំទាំ មិនកម្រើកក្នុង វិន័យ នេះជាលក្ខណៈទី ២ ។

### បទពន្យល់លក្ខណៈទី ២

វិនយេ ខោ បន ឋិតោ ហោតីតិ វិនយេ លជ្ជីភា-វេន បតិដ្ឋិតោ ហោតិ ។

បទថា វិនយេ ខោ បន ឋិតោ ហោតិ សេចក្ដីថា ព្រះវិន័យធរនោះ ជាអ្នកមាំទាំក្នុងវិន័យ ដោយភាពជាលជ្ជីភិក្ខុ ។

អលជ្ជី ហិ ពហុស្សុតោបិ សមានោ លាភគរុក-តាយ តន្តិំ វិសំវាទេត្វា ឧទ្ធម្មំ ឧព្វិនយំ សត្ថុសាសនំ ទីបេត្វា សាសនេ មហន្តំ ឧបទ្ទវំ ករោតិ សង្ឃភេទម្បិ សង្ឃរាជិម្បិ ឧប្បាទេតិ ។

ពិតមែន អលជ្ជីភិក្ខុសូម្បីជាពហុស្សូត តែព្រោះជាអ្នកធ្ងន់ក្នុង លាភ ក៏ក្លែងពោលឲ្យខុសបែប សម្ដែងសត្ថុសាសនាក្រៅធម៌ ក្រៅវិន័យ

ធ្វើឧបទ្ទវៈច្រើនប្រការក្នុងសាសនា គឺបង្កឲ្យកើតការបំបែកសង្ឃខ្លះ ប្រេះចាសង្ឃខ្លះ ។

លជ្ជី បន កុក្កុច្ចកោ សិក្ខាកាមោ ជីវិតហេតុបិ តន្តី អវិសំវាទេត្វា ធម្មមេវ វិនយមេវ ធីបេតិ សត្ថុសាសនំ គរុំ កត្វា ឋបេតិ ។

ចំណែកភិក្ខុលជ្ជី ជាអ្នកច្រើនដោយការរង្កៀស ប្រាថ្នាចំពោះការសិក្សា សូម្បីព្រោះហេតុនៃជីវិត ក៏មិនក្លែងពោលឲ្យខុសបែប សម្តែងចំពោះធម៌ចំពោះវិន័យប៉ុណ្ណោះ គឺធ្វើសត្ថុសាសនាឲ្យជាទីគោរពតាំងនៅ ។

តថាហិ បុព្វេ មហាថេរា តិក្ខត្តុំ វាចំ និច្ឆារេសុំ អនាគតេ លជ្ជី រក្ខិស្សតិ លជ្ជី រក្ខិស្សតិ លជ្ជី រក្ខិស្សតីតិ ។

ពិតណាស់ សូម្បីព្រះមហាថេរៈទាំងឡាយក្នុងកាលមុន បានបញ្ចេញវាចា ៣ ដងថា ភិក្ខុលជ្ជីនឹងរក្សាទុក ភិក្ខុលជ្ជីនឹងរក្សាទុក ភិក្ខុលជ្ជីនឹងរក្សាទុក ដូច្នេះជាដើម ។

ឯវំ យោ ច លជ្ជី សោ វិនយំ អជហន្តោ អវោក្កមន្តោ លជ្ជិភាវេន វិនយេ ឋិតោ ហោតិ បតិដ្ឋិតោតិ ។

ក៏ភិក្ខុណាជាលជ្ជី ដូចពោលមកហើយនោះ ភិក្ខុនោះមិនលះបង់

មិនល្មើសវិន័យ ជាអ្នកតាំងមាំ គឺមាំទាំនៅក្នុងវិន័យ ដោយភាពជាលជ្ជីភិក្ខុ ដូច្នោះឯង ។

អសំហិរោតិ សំហិរោ នាម យោ បាលិយា ហេដ្ឋតោ វា ឧបរិតោ វា បទប្បដិបាដិយា វា អដ្ឋកថាយ វា បុច្ឆិយមានោ វិត្ថុនាតិ វិប្ផន្ទតិ សន្តិដ្ឋិតុំ ន សក្កោតិ យំ យំ បរេន វុច្ចតិ តំ តំ អនុជានាតិ សកវាទំ ឆឌ្ឌេត្វា បរវាទំ គណ្ហាតិ ។

បទថា អសំហិរោ សេចក្តីថា បុគ្គលណាត្រូវអ្នកដទៃសួរដោយបាលី ខាងទាបខាងខ្ពស់តាមលំដាប់បទ ឬអដ្ឋកថា រមែងញាប់ញ័ររសាប់រសល់ មិនអាចតាំងមាំបាន បណ្តោយតាមពាក្យរបស់អ្នកដទៃពោល បោះបង់វាទៈរបស់ខ្លួន កាន់យកវាទៈរបស់អ្នកដទៃ បុគ្គលនោះឈ្មោះថា អ្នកមិនក្តៀវក្លា ។

យោ បន បាលិយំ វា អដ្ឋកថាយំ វា ហេដ្ឋុបរិយេន វា បទប្បដិបាដិយា វា បុច្ឆិយមានោ ន វិត្ថុនាតិ ន វិប្ផន្ទតិ ឯកេកលោមំ សណ្ឌាសេន គណ្ហន្តោ វិយ ឯវំ មយំ វទាម ឯវំ នោ អាចរិយា វទន្តីតិ វិស្សជ្ជេតិ យម្ហិ បាលិ ច បាលិវិនិច្ឆយោ ច

សុវណ្ណភាជនេ បក្ខិត្តសីហវសា វិយ បរិក្ខយំ បរិ-
យាទានំ អាគច្ឆន្តោ តិដ្ឋតិ អយំ វុច្ចតិ អសំហិរោតិ ។

ចំណែកបុគ្គលណា ត្រូវអ្នកដទៃសួរដោយបទខាងក្រោម នឹងខាងលើ ឬដោយលំដាប់បទ ក្នុងបាលីក្តី ក្នុងអដ្ឋកថាក្តី រមែងមិនញាប់ញ័រ មិនរសាប់រសល់ ប្រៀបដូចយកសណ្ឋាសចាប់រោមម្តងមួយសរសៃៗដូច្នោះ ចង្អុលប្រាប់ដល់គេថា ខ្ញុំពោលយ៉ាងនេះ អាចារ្យទាំងឡាយរបស់ខ្ញុំពោលយ៉ាងនេះ ។ ម្យ៉ាងទៀតបាលី និងវិនិច្ឆ័យបាលីតាំងនៅក្នុងបុគ្គលណា មិនដល់ការអស់ទៅដូចខ្លាញ់រាជសីហ៍ ដែលដាក់ទុកក្នុងភាជនៈមាស មិនដល់ការអស់ទៅដូច្នោះ បុគ្គលនេះ លោកហៅថា មិនកម្រើក ។

**៣-អាចរិយបរម្បរា ខោ បនស្ស សុគ្គហិតា ហោតិ សុមនសិកតា សូបធារិតាតិ ឥទំ តតិយំ ។**

ក៏លំដាប់នៃអាចារ្យ ជាលំដាប់ដែលព្រះវិន័យធរនោះ ចាំបានត្រឹមត្រូវ ធ្វើបានយ៉ាងល្អ ចាំបានត្រឹមត្រូវល្អហើយ នេះជាលក្ខណៈទី៣ ។

### បទពន្យល់លក្ខណៈទី ៣

អាចរិយបរម្បរា ខោ បនស្ស សុគ្គហិតា ហោតីតិ ថេរបរម្បរា វំសបរម្បរា អស្ស សុដ្ឋុ គហិតា ហោតិ ។

ប្រើនបទថា អាចរិយបរម្បរា ខោ បនស្ស សុគ្គ-

ហិតា ហោតិ មានសេចក្តីថា លំដាប់នៃព្រះថេរៈគឺ លំដាប់វង្ស ជា លំដាប់ដែលព្រះវិន័យធរចាំបានយ៉ាងត្រឹមត្រូវ ។

សុមនសិកតាតិ សុដ្ឋុ មនសិកតា អាវជ្ជិតមត្តេ ឧជ្ជលិតប្បទីបោ វិយ ហោតិ ។ បទថា សុមនសិកតា បានដល់ ធ្វើឲ្យប្រព្រឹត្តទៅក្នុងចិត្តយ៉ាងល្អ ល្មមតែនឹកក៏ប្រាកដបាន ដូច ប្រទីបដែលឆេះសន្ធោសន្ធៅដូច្នោះ ។

សូបធារិតាតិ សុដ្ឋុ ឧបធារិតា បុព្វាបរានុសន្ធិតោ អត្ថតោ ការណតោ ច ឧបធារិតា ។

បទថា សូបធារិតា ពិចារណាយ៉ាងល្អ គឺពិចារណាអំពីខាង ដើមខាងចុង នឹងអនុសន្ធិ ដោយផល នឹងដោយហេតុ ។

អត្តនោ មតឹ បហាយ អាចរិយសុទ្ធិយា វត្តា ហោតិ មយ្ហំ អាចរិយោ អសុកាចរិយស្ស សន្តិកេ ឧគ្គណ្ហិ សោ អសុកស្សាតិ ឯវំ សព្វំ អាចរិយបរម្បរំ ថេរវាទំ ហរិត្វា យាវ ឧបាលិត្ថេរោ សម្មាសម្ពុទ្ធស្ស សន្តិកេ ឧគ្គណ្ហីតិ បាបេត្វា ឋបេតិ ។

បុគ្គលលះមតិរបស់ខ្លួន ហើយពោលសេចក្តីបរិសុទ្ធនៃអាចារ្យ គឺ នាំលំដាប់នៃអាចារ្យ បានដល់គំណា(បែប)នៃព្រះថេរៈទាំងអស់យ៉ាងនេះ

គឺ អាចារ្យរបស់ខ្ញុំរៀនយកក្នុងសំណាក់អាចារ្យឈ្មោះឯណោះ អាចារ្យនោះរៀនយកក្នុងសំណាក់អាចារ្យឯណោះ ទៅតាំងទុករហូតឲ្យដល់ពាក្យថា ព្រះឧបាលិត្ថេរៈ រៀនយកក្នុងសំណាក់ពីព្រះពុទ្ធ ។ អាចារ្យជំនាន់ក្រោយមកបាននាំអំពីព្រះឧបាលិត្ថេរៈនោះមកគឺ បាននាំលំដាប់នៃអាចារ្យបានដល់តំណនៃព្រះថេរៈទាំងអស់ រហូតឲ្យដល់អាចារ្យរបស់ខ្លួន ហើយតាំងទុកយ៉ាងនេះថា ព្រះឧបាលិត្ថេរៈរៀនយកក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធ ព្រះទាសកត្ថេរៈ រៀនយកក្នុងសំណាក់ព្រះឧបាលិត្ថេរៈ ដែលជាឧបជ្ឈាយ៍របស់ខ្លួន ព្រះសោណកត្ថេរៈ រៀនយកក្នុងសំណាក់ព្រះទាសកត្ថេរៈ ដែលជាព្រះឧបជ្ឈាយ៍របស់ខ្លួន ព្រះសិគ្គវត្ថេរៈរៀនយកក្នុង សំណាក់ព្រះសោណកត្ថេរៈដែលជាព្រះឧបជ្ឈាយ៍របស់ខ្លួន ព្រះមោគ្គលិបុត្តតិស្សត្ថេរៈ រៀនយកក្នុងសំណាក់ព្រះសិគ្គវត្ថេរៈ នឹង ព្រះចណ្ឌវជ្ជិត្ថេរៈ ដែលជាឧបជ្ឈាយ៍របស់ខ្លួន ។ ពិតមែន លំដាប់នៃអាចារ្យ ដែលព្រះវិន័យធររៀនយកហើយយ៉ាងនេះ រមែងជាពុទ្ធវចនៈដែលចាំបានយ៉ាងត្រឹមត្រូវ ។ តែកាលមិនអាចរៀនយកយ៉ាងនេះ ក៏គួររៀនយកត្រឹម ២,៣ លំដាប់ ក៏ល្មម ។ មែនពិត ដោយន័យយ៉ាងទាបបំផុត ក៏គួរជ្រាបដូចអាចារ្យនិងអាចារ្យរបស់អាចារ្យ ពោលបាលីនិងបរិបុច្ឆាដូច្នោះ ។

# ព្រះវិន័យធរមុនវិនិច្ឆ័យអធិករណ៍ គួរត្រួតមើលឋាន ៦ យ៉ាង គឺៈ

ឥមេហិ ច បន តីហិ លក្ខណេហិ សមន្នាគតេន វិនយធរេន វត្ថុវិនិច្ឆយត្ថំ សន្និបតិតេ សង្ឃេ ឱតិណ្ណេ វត្ថុស្មឹ ចោទកេន ច ចុទិតកេន ច វុត្តេ វត្តព្វេ សហសា អវិនិច្ឆិនិត្វា ឆ ឋានានិ ឱលោកេតព្វានិ ។

ក៏ឯព្រះវិន័យធរ ដែលប្រកបដោយលក្ខណៈ៣ប្រការ យ៉ាងនេះហើយ កាលសង្ឃប្រជុំគ្នាដើម្បីវិនិច្ឆ័យរឿង ឯរឿងក៏ឈានចុះហើយ ទាំងអ្នក-ចោទ និងអ្នកឆ្លើយក៏ប្រាប់រឿងហើយ ពេលនិយាយមិនគួរប្រញាប់កាត់ក្តីពេកទេ គួរត្រួតមើលឋានទាំង៦ ប្រការសិនសឹមវិនិច្ឆ័យ ។

កតមានិ ឆ ។ ឋាន ៦ប្រការ តើដូចម្តេច ?

វត្ថុ ឱលោកេតព្វំ មាតិកា ឱលោកេតព្វា បទភាជនីយំ ឱលោកេតព្វំ តិកបរិច្ឆេទោ ឱលោកេតព្វោ អន្តរាបត្តិ ឱលោកេតព្វា អនាបត្តិ ឱលោកេតព្វា ។

ឋានៈ៦ប្រការនោះគឺ គួរត្រួតមើលរឿង ១ ត្រួតមើលមាតិកា ១ ត្រួតមើលបទភាជនីយ៍ ១ ត្រួតមើលតិកបរិច្ឆេទ ១ ត្រួតមើលអន្តរាបត្តិ ១ ត្រួតមើលអនាបត្តិ ១ ។

**១-ត្រួតមើលរឿង** ពិតមែន ព្រះវិន័យធរ កាលត្រួតមើលរឿង រមែងឃើញអាបត្តិខ្លះយ៉ាងនេះគឺ ភិក្ខុដែលមានចីវរបាត់ គួរយកស្មៅ ឬស្លឹកឈើបិទបាំងកាយសិនសឹមមក ។ មិនគួរអាក្រាតកាយមកឡើយ ភិក្ខុណាអាក្រាតកាយមក ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ព្រះវិន័យធរនោះ នាំសូត្រនោះមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

**២-ត្រួតមើលមាតិកា** ព្រះវិន័យធរកាលត្រួតមើលមាតិកា រមែងឃើញអាបត្តិ៥កងណាមួយ ដោយន័យមានជាដើមថា "ជាបាចិត្តិយព្រោះសម្បជានមុសាវាទ" លោកនាំសូត្រនោះមកអាងហើយ នឹងរម្ងាប់អធិក-រណ៍នោះបាន ។

**៣-ត្រួតមើលបទភាជនីយ៍** ព្រះវិន័យធរ កាលត្រួតមើលបទ-ភាជនីយ៍ រមែងឃើញបណ្ដាអាបត្តិ ៧ កងណាមួយ ដោយន័យជាដើមថា "ភិក្ខុសេពមេថុនធម្មក្នុងសរីរៈ ដែលសត្វនៅមិនបានខាំស៊ី ត្រូវអាបត្តិបារាជិក ។ សេពមេថុនធម្មក្នុងសរីរៈ ដែលសត្វខាំស៊ីហើយដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ" លោកនាំសូត្រ ចាកបទភាជនីយ៍មកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

**៤-ត្រួតមើលតិកបរិច្ឆេទ** ព្រះវិន័យធរ កាលត្រួតមើលតិកបរិច្ឆេទ រមែងឃើញការកំណត់តិកសង្ឃាទិសេសខ្លះ តិកបាចិត្តិយខ្លះ តិកទុក្កដខ្លះ អាបត្តិយ៉ាងណាមួយខ្លះ លោកនាំសូត្រមកអំពីបាលីតិកបរិច្ឆេទនោះមក

អាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

**៥_ត្រួតមើលអន្តរាបត្តិ** ព្រះវិន័យធរ កាលត្រួតមើលអន្តរាបត្តិ នឹងឃើញអន្តរាបត្តិ ក្នុងរវាងចន្លោះនៃសិក្ខាបទយ៉ាងនេះថា ភិក្ខុលើកឡើងនូវអង្កត់ភ្លើង ទម្លាក់ទៅទុកដូចដើមវិញត្រូវអាបត្តិទុក្កដ ។ លោកនាំសូត្រនោះមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

**៦_ត្រួតមើលអនាបត្តិ** ព្រះវិន័យធរ កាលត្រួតមើលអនាបត្តិ នឹងឃើញអនាបត្តិ ដែលលោកសម្តែងទុកហើយក្នុងសិក្ខាបទនោះៗ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មិនជាអាបត្តិដល់ភិក្ខុអ្នកមិនត្រេកអរ មិនមាន_ថេយ្យចិត្ត មិនមានបំណងនឹងឲ្យស្លាប់ មិនមានបំណងនឹងអួត មិនមានបំណងនឹងឲ្យឃ្លាត មិនដឹង មិនមានសតិដូច្នេះជាដើម ។ លោកគ្រាន់នាំសូត្រនោះមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

យោ ហិ ភិក្ខុ ចតុព្វិធវិនយកោវិទោ តិលក្ខ–ណសម្បន្នោ ឥមានិ ឆដ្ឋានានិ ឱលោកេត្វា អធិករណំ វូបសមេស្សតិ តស្ស វិនិច្ឆយោ អប្បដិវត្តិយោ ពុទ្ធេន សយំ និសីទិត្វា វិនិច្ឆិតសទិសោ ហោតិ ។

ពិតណាស់ ភិក្ខុណាជាអ្នកច្បាស់ក្នុងវិន័យ ៤ យ៉ាង បរិបូណ៌ដោយលក្ខណៈ ៣ បានត្រួតមើលឋាន ៦ យ៉ាងនេះហើយ នឹងរម្ងាប់អធិករណ៍

បាន ។ ការវិនិច្ឆ័យអធិករណ៍របស់ភិក្ខុនោះ នរណាៗ នឹងគប្បីជំទាស់ មិនបាន រមែងដូចជាការវិនិច្ឆ័យ ដែលព្រះពុទ្ធជាម្ចាស់គង់ប្រថាប់វិនិច្ឆ័យ ដោយព្រះអង្គឯង ។

*(សមន្ត.បាលីប្រែ ៣/៨៥_១០១)*

# វិធីវិនិច្ឆ័យអធិករណ៍

បើភិក្ខុណាមួយធ្វើការកន្លងល្មើសសិក្ខាបទហើយ ចូលទៅរកភិក្ខុអ្នកឈ្លាសក្នុងការវិនិច្ឆ័យនោះយ៉ាងនេះហើយ គប្បីសួរដល់សេចក្ដីវង្វៀងសង្ស័យរបស់ខ្លួន ភិក្ខុអ្នកច្លាតក្នុងការវិនិច្ឆ័យនោះ គួរកំណត់ឲ្យល្អ បើជាអនាបត្តិក៏គួរប្រាប់ថាជាអនាបត្តិ ។ តែបើជាអាបត្តិក៏គួរប្រាប់ថាជាអាបត្តិ ។ បើអាបត្តិនោះ ជាទេសនាគាមិនី ក៏គួរប្រាប់ថាជាទេសនាគាមិនី ។ បើជាវុដ្ឋានគាមិនី ក៏គួរប្រាប់ថាជាវុដ្ឋានគាមិនី ។ បើស្រមោលបារាជិកប្រាកដដល់ភិក្ខុអ្នកឈ្លាសក្នុងការវិនិច្ឆ័យនោះ មិនគួរប្រាប់ថា ជាអាបត្តិបារាជិក ។ ព្រោះហេតុអ្វី ? ព្រោះការកន្លងល្មើសមេថុនធម្ម និងការកន្លងល្មើសឧត្តរិមនុស្សធម៌ ជាកម្មគ្រោតគ្រាត ។ ចំណែកការកន្លងល្មើសអទិន្នាទាន និងមនុស្សវិគ្គហៈ ជាកម្មល្អិត ជាការរហ័សដូចចិត្តភិក្ខុរមែងត្រូវវីតិក្កមៈទាំងពីរនោះដោយអាការៈសុខុម និងរមែងរក្សាទុកដោយអាការៈសុខុមដូចគ្នា ។ ព្រោះហេតុនោះ ភិក្ខុត្រូវសួរដល់ការវង្វៀងសង្ស័យ ដែលមានសេចក្ដីល្មើសនោះជាទីតាំង ដោយវិសេស មិនគួរនិយាយថាត្រូវអាបត្តិ បើអាចារ្យលោកនៅមានជីវិត បន្ទាប់អំពីនោះ ភិក្ខុអ្នកឈ្លាសក្នុងការវិនិច្ឆ័យនោះ គួរបញ្ជូនភិក្ខុនោះទៅថា លោកចូរសួរអាចារ្យរបស់ខ្ញុំមើលចុះ។ បើលោកត្រឡប់មកប្រាប់ថា អាចារ្យរបស់លោកពិនិត្យមើលអំពីព្រះសូត្រព្រះវិន័យហើយប្រាប់ខ្ញុំថា ជាសតេកិច្ឆាបត្តិ(នៅ-

កែកុនបាន) ក្នុងពេលនោះ ភិក្ខុអ្នកឈ្លាសក្នុងការវិនិច្ឆ័យនោះ គួរនិយាយដល់លោកថាល្អៗ លោកចូរធ្វើដូចអាចារ្យនិយាយ ។ ក៏បើអាចារ្យរបស់លោកមិនមាន តែព្រះថេរៈអ្នករៀនរួមគ្នាមាន គប្បីបញ្ជូនលោកឲ្យទៅកាន់សំណាក់របស់ព្រះថេរៈនោះ ដោយបង្គាប់ថា ព្រះថេរៈអ្នករៀនជាមួយនឹងខ្ញុំជាប្រធាននៃគណៈមាន លោកចូរទៅសួរព្រះថេរៈនោះមើលចុះ ។ កាលព្រះថេរៈនោះវិនិច្ឆ័យថា ជាសតេកិច្ឆា ក៏គួរប្រាប់ដល់លោកថាល្អ លោកចូរធ្វើតាមពាក្យរបស់ព្រះថេរៈនោះឲ្យល្អចុះ ។ បើព្រះថេរៈអ្នករៀនរួមគ្នារបស់លោកមិនមាន តែភិក្ខុជាអន្តេវាសិកជាបណ្ឌិតមាន គប្បីបញ្ជូនលោកទៅកាន់សំណាក់របស់ភិក្ខុជាអន្តេវាសិកនោះថា លោកចូរទៅសួរភិក្ខុកំលោះឯណោះមើលចុះ ។ កាលភិក្ខុជាអន្តេវាសិកនោះវិនិច្ឆ័យថា ជាសតេកិច្ឆា ក៏គួរនិយាយដល់លោកថាល្អ លោកចូរធ្វើតាមពាក្យរបស់ភិក្ខុនោះដោយល្អចុះ ។ បើស្រមោលបារាជិកទុំះឯង ប្រាកដដល់ភិក្ខុកំលោះ សូម្បីភិក្ខុនោះក៏មិនគួរប្រាប់ភិក្ខុអ្នកត្រូវអាបត្តិថា លោកត្រូវអាបត្តិបារាជិកហើយ ។

## ភិក្ខុដែលមានសីលមិនបរិសុទ្ធកម្មដ្ឋានមិនចម្រើន

មែនពិតការកើតឡើងនៃព្រះពុទ្ធជាលាភបានដោយក្រ ការបព្វជ្ជានិង ឧបសម្បទជាលាភបានដោយក្រក្រៃលែងជាងនោះ ។ តែព្រះវិន័យធរគួរនិយាយយ៉ាងនេះថា លោកចូរបោសសំអាតឱកាសដែលស្ងាត់ ហើយ

អង្គុយសំរាកវេលាថ្ងៃជំរះសីលឲ្យបរិសុទ្ធ ចូរមនសិការអាការៈ ៣២ មើលសិន ។ បើសីលរបស់ភិក្ខុនោះមិនសៅហ្មងពពាលសោត កម្មដ្ឋានរមែងតក្ជាប់ សង្ខារទាំងឡាយ ក៏ជាសភាវៈប្រាកដច្បាស់ឡើង ចិត្តក៏មានអារម្មណ៍តែមួយ ដូចបានសម្រេចឧបចារៈ និងអប្បនាសមាធិដូច្នោះ ។ សូម្បីថ្ងៃកន្លងហួសទៅហើយក៏ដោយ ក៏លោកមិនជ្រាប ។ ក្នុងវេលាថ្ងៃកន្លងហួសទៅ លោកមកកាន់ទីបំរើគ្រូនិយាយយ៉ាងនេះថា ការប្រព្រឹត្តទៅនៃចិត្តរបស់លោកយ៉ាងណាដែរ ។ កាលលោកប្រាប់ថា ការប្រព្រឹត្តទៅនៃចិត្តហើយ គ្រូនិយាយប្រាប់លោកថា ដែលឈ្មោះថាបញ្ញាមានសេចក្តីបរិសុទ្ធិនៃចិត្តជាប្រយោជន៍ លោកកុំប្រមាទបំពេញសមណៈធម៌ចុះ ។ ចំណែកភិក្ខុណាមានសីលដាច់ កម្មដ្ឋានរបស់ភិក្ខុនោះមិនជាប់ត ចិត្តរមែងញាប់ញ័រ ត្រូវភ្លើងគឺសេចក្តីក្តៅក្រហាយដុតរោល ដូចត្រូវចាក់ដោយជន្លួញ ដូច្នោះ ភិក្ខុនោះរមែងក្រោកឡើងក្នុងខណៈនោះភ្លាម ដូចអង្គុយលើដុំថ្មក្តៅដូច្នោះ ។ លោកមកហើយសួរថា ការប្រព្រឹត្តទៅនៃចិត្តរបស់លោកយ៉ាងណា ដែរ ? ការលោកប្រាប់ការប្រព្រឹត្តទៅនៃចិត្តហើយគ្រូនិយាយថា ដែលឈ្មោះថា សេចក្តីអាថ៌កំបាំងរបស់អ្នកធ្វើកម្មអាក្រក់រមែងមិនមានក្នុងលោក តាមពិត បុគ្គលអ្នកធ្វើកម្មអាក្រក់រមែងដឹងដោយខ្លួនឯងមុនមនុស្សដទៃទាំងអស់ តអំពីនោះអារក្ខទេវតាទាំងឡាយ សមណៈព្រាហ្មណ៍និងទេវតាពួកដទៃអ្នកដឹងចិត្ត របស់បុគ្គលដទៃ

រមែងដឹងសេចក្តីអាក្រក់របស់លោក ឥឡូវនេះលោកចូរស្វែងរក សេចក្តីសួស្តីដោយខ្លួនឯងចុះ ។

(សមន្តប្បាសាទិកា ៣/១០៣)

## ធម្មតាក្នុងការវិនិច្ឆ័យ

វិនយវិនិច្ឆយេ ហិ អាគតេ គរុកេ ឋាតព្វំ ។ វិន័យធរគួរតាំងនៅក្នុងការវិនិច្ឆ័យដ៏ធ្ងន់ កាលការវិនិច្ឆ័យវិន័យមកដល់ហើយ ឯសា វិនយធម្មតា ការបដិបត្តិនេះ ជាធម្មតាក្នុងព្រះវិន័យ ។

(សមន្តប្បាសាទិកា ៤/ ៧៧)

## គប្បីតាំងក្នុងសេចក្តីជាធំ

អត្ថំ ហិ នាថោ សរណំ

អវោច ន ព្យញ្ជនំ

លោកហិតោ មហេសី

តស្មា អកត្វា រតិមក្ខរេសុ

អត្ថេ និវេសេយ្យ មតី មតិមា ។

ព្រះលោកនាថ ទ្រង់ស្វែងរកគុណដ៏ធំ អនុគ្រោះប្រយោជន៍ដល់សត្វលោក ទ្រង់ត្រាស់សម្តែងយកសេចក្តីជាធំ មិនបានសម្តែងយកព្យញ្ជនៈជាធំទេ ហេតុនោះអ្នកមានញាណ មិនគប្បីធ្វើសេចក្តីត្រេកអរក្នុងអក្ខរៈទេ ត្រូវតាំងទុកនូវញាណក្នុងសេចក្តីដូច្នេះឯង ។ (មាតិកដ្ឋកថា ១/៧៧)

## វិន័យធរត្រូវវៀរហេតុ ២ ប្រការ

ន ចាមិសំបិ និស្សាយ   កុំអាស្រ័យអាមិស១

ន ច និស្សាយ បុគ្គលំ   កុំអាស្រ័យបុគ្គល១[1] ។

(វិន័យបិដក ១៣/១៨៥)

## វិន័យនាំឯអស់មានអត្ថ ៣ ប្រការ

វិវិធវិសេសនយត្តា វិនយនតោ ចេវ កាយវាចានំ

វិនយត្ថវិទូហិ អយំ វិនយោ វិនយោតិ អក្ខាតោ ។

ព្រះវិន័យនេះ ដែលបណ្ឌិត អ្នកដឹងអត្ថនៃវិន័យទាំងឡាយពោលថា វិន័យព្រោះមានន័យផ្សេងៗ១ ព្រោះមានន័យវិសេស ១ និងព្រោះទូន្មាន កាយនិងវាចា ១ ។

បញ្ចវិធបាតិមោក្ខុទ្ទេសបារាជិកាទិ សត្តអាបត្តិក្ខន្ធមាតិកា វិភង្គាទិប្បភេទនយា វិសេសភូតា ច ទឡ្ហីកម្មសិថិលករណប្បយោជនា អនុប្បញ្ញត្តិនយា ។ កាយិកវាចសិកអជ្ឈាចារនិសេធនតោ ចេស កាយំ វាចញ្ច វិនេតិ ។ តស្មា វិវិធនយត្តា វិសេសនយត្តា កាយ-

---

(១) អដ្ឋកថាពន្យល់សេចក្តីថា ភិក្ខុជាវិន័យធរ មិនត្រូវលះដោយអគតិ មានឆន្ទាគតិជាដើមទេ គឺ កុំយល់មុខថា លោកនេះជាឧបជ្ឈាយ៍ ជាអាចារ្យ របស់អញជាដើម ។

វាចានំ ច វិនយនតោ ចេស វិនយោតិ អក្ខាតោ ។

ថែមនពិត ក្នុងវិន័យនេះ មានប្រភេទផ្សេងៗគឺ មានបាតិមោក្ខុទ្ទេស ៥, កងអាបត្តិ ៧ មានបារាជិកជាដើម, មាតិកា នឹងន័យមានវិភង្គជាដើម ជាប្រភេទ ។ នឹងន័យ គឺអនុប្បញ្ញត្តិជាវិសេស គឺមានន័យដែលធ្វើឲ្យមាំ នឹងឲ្យធូរជាប្រយោជន៍ ។ មួយវិញទៀត ព្រះវិន័យនេះ រមែងទូន្មានកាយ និងវាចា ព្រោះហាមនូវមារយាទអាក្រក់ ដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងវាចា ។ ព្រោះហេតុនោះ ព្រះវិន័យនេះ លោកទើបពោលថា វិន័យ ព្រោះមានន័យផ្សេងៗ ព្រោះមានន័យវិសេស នឹងព្រោះទូន្មានកាយ និងវាចា ។ *(សមន្ត. ពាហិរនិទាន ទំព័រ៣២)*

## ការដោះស្រាយវិន័យមិនប្រកបដោយធម៌ ៥ ប្រការ

ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះបង្អោន[១] នូវសភាវៈមិនមែនធម៌ ថាជាធម៌ ១ បង្អោននូវធម៌ថាមិនមែនជាធម៌ ១ បង្អោននូវសភាវៈមិនមែនវិន័យថាជាវិន័យ ១ បង្អោននូវវិន័យថាមិនមែនជាវិន័យ ១ បញ្ញត្តិនូវសិក្ខាបទដែលតថាគតមិនបានបញ្ញត្តិ ទាំងដកសិក្ខាបទដែលតថាគតបានបញ្ញត្តហើយ ១ ។ ម្នាលឧបាលិ ការដោះស្រាយវិន័យ មិនប្រកបដោយធម៌ មាន ៥ យ៉ាងនេះឯង ។

---

(១) អដ្ឋកថាថា កំណត់ សម្តែង និយាយ

## ការដោះស្រាយវិន័យប្រកបដោយធម៌ ៥ ប្រការ

ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះបង្អោនទូវសភាវៈមិនមែនធម៌ថាមិនមែនធម៌ ១ បង្អោនទូវធម៌ថាជាធម៌១ បង្អោនទូវសភាវៈមិនមែនវិន័យថាមិនមែនវិន័យ ១ បង្អោនទូវវិន័យថាជាវិន័យ ១ មិនបញ្ញត្តទូវសិក្ខាបទដែលតថាគតមិនបានបញ្ញត្ត ទាំងមិនដកសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ១ ។ ម្នាលឧបាលិ ការដោះស្រាយវិន័យប្រកបដោយធម៌មាន៥ យ៉ាងនេះឯង ។

## អង្គ ៥ របស់ព្រះវិន័យធរ

វិន័យធរដែលប្រកបដោយអង្គ ៥ ដល់នូវការរាប់ថាជាបណ្ឌិត គឺៈ រៀនទីកំណត់ភាសារបស់ខ្លួន ១ រៀនទីកំណត់ភាសារបស់ជាតិដទៃ ១ លុះរៀនទីកំណត់ភាសារបស់ខ្លួនហើយ ទើបកាត់សេចក្តីដោយត្រូវតាមធម៌ ១ លុះរៀនទីកំណត់ភាសារបស់ជាតិដទៃហើយ ទើបកាត់សេចក្តីដោយត្រូវតាមធម៌ ១ កាត់សេចក្តីត្រូវតាមពាក្យប្តេជ្ញា ១ ។

(វិនយបិដក ១៣/៦១)

## អង្គ ៧ របស់ព្រះវិន័យធរ

ភិក្ខុដែលប្រកបដោយអង្គ ៧ បានឈ្មោះថា ជាវិនយធរ(អ្នកទ្រទ្រង់វិន័យ) គឺ ភិក្ខុស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាល់លហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកមានសីលនឹងសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនឹងគោចារៈ ឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច ហើយ

សមាទានសិក្សាក្នុងសិក្ខាបទ ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានដោយមិនលំបាក បានដោយងាយនូវឈានទាំង៤ ដែលអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាឈាននាំឲ្យនៅជាសុខក្នុងបច្ចុប្បន្ន ១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈហើយ ដោយបញ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន ១ ។

ភិក្ខុដែលប្រកបដោយអង្គ ៧ ដទៃទៀត បានឈ្មោះថាវិន័យធរ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាលលហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១ ជាអ្នកចេះដឹងច្រើន ទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ធម៌ដែលពីរោះខាងដើម ពីរោះខាងកណ្តាល ពីរោះខាងចុង ប្រកាសនូវព្រហ្ម-ចរិយៈ ព្រមទាំងអត្ថនឹងព្យញ្ជនៈ ដ៏ពេញបរិបូរណ៍ បរិសុទ្ធគ្រប់គ្រាន់ទាំងអស់ ធម៌ដែលមានសភាពដូច្នោះ ភិក្ខុនោះបានចេះដឹងច្រើន បានទ្រទ្រង់ បានចេះចាំរត់មាត់ បានចូលចិត្តច្បាស់លាស់ បានយល់ជ្រាលជ្រៅដោយទិដ្ឋិគឺបញ្ញា ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា ។បេ។ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន ១ ។

ភិក្ខុដែលប្រកបដោយអង្គ ៧ ដទៃទៀត បានឈ្មោះថាវិន័យធរ គឺស្គាល់អាបត្តិ ១ ស្គាល់អនាបត្តិ ១ ស្គាលលហុកាបត្តិ ១ ស្គាល់គរុកាបត្តិ ១

ភិក្ខុនោះចេះចាំបាតិមោក្ខទាំងពីរដោយពិស្តារ ចេះចែកបទភាជនៈដោយប្រពៃ ចាំស្ទាត់រត់មាត់ដោយប្រពៃ ចេះកាត់សេចក្តីដោយប្រពៃ តាមសុត្តៈគឺខន្ធកៈនឹងបរិវារៈ តាមអនុព្យញ្ជនៈគឺអក្ខរៈនឹងបទ ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា ។ បេ ។ (ដោយឥរិយាបថទាំង៤) ក្នុងបច្ចុប្បន្ន ១ ។

(វិន័យបិដក ១៣/៨៣_៨៥...)

## អង្គ ១០ របស់វិន័យធរ

វិន័យធរដែលប្រកបដោយអង្គ ១០ ដល់នូវការរាប់ថា ជាបណ្ឌិត គឺ រៀនទីកំណត់ភាសារបស់ខ្លួន ១ រៀនទីកំណត់ភាសារបស់ជាតិដទៃ ១ លុះរៀនទីកំណត់ភាសារបស់ខ្លួនហើយ កាត់សេចក្តីត្រូវតាមធម៌ ១ លុះរៀនទីកំណត់ភាសារបស់ជាតិដទៃហើយ កាត់សេចក្តីត្រូវតាមធម៌ ១ កាត់សេចក្តីត្រូវតាមពាក្យប្តេជ្ញា ១ ស្គាល់អាបត្តិ ១ ស្គាល់មូលនៃអាបត្តិ ១ ស្គាល់សេចក្តីរលត់នៃអាបត្តិ ១ ស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់នៃអាបត្តិ ១ ។

វិន័យធរដែលប្រកបដោយអង្គ១០ដទៃទៀត ដល់នូវការរាប់ថាជាបណ្ឌិតគឺ ស្គាល់អធិករណ៍ ១ ស្គាល់មូលនៃអធិករណ៍ ១ ស្គាល់ហេតុឲ្យកើតអធិករណ៍ ១ ស្គាល់សេចក្តីរលត់អធិករណ៍ ១ ស្គាល់បដិបទាឲ្យដល់នូវសេចក្តីរលត់អធិករណ៍ ១ ស្គាល់វត្ថុ ១ ស្គាល់និទាន ១ ស្គាល់បញ្ញត្តិ ១ ស្គាល់អនុបញ្ញត្តិ ១ ស្គាល់គន្លងពាក្យដែលជាប់តគ្នា ១ ។

(វិនយបិដក ១៣/៩៦_៩៧)

# លក្ខណៈនៃការវិនិច្ឆ័យធម៌វិន័យ ៨ យ៉ាង

ម្នាលព្រះនាងគោតមី មួយវិញទៀតព្រះនាងគប្បីដឹងនូវធម៌ណាថា

១-វិរាគាយ សំវត្តន្តិ នោ សរាគាយ ប្រព្រឹត្តទៅដើម្បីការប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីការប្រកបដោយតម្រេក ។

២-វិសញ្ញោគាយ សំវត្តន្តិ នោ សញ្ញោគាយ ប្រព្រឹត្តទៅ ដើម្បីការប្រាសចាកការប្រកបក្នុងវដ្ដៈ មិនប្រព្រឹត្តទៅដើម្បីការប្រកបក្នុងវដ្ដ ។

៣-អបចយាយ សំវត្តន្តិ នោ អាចយាយ ប្រព្រឹត្តទៅដើម្បីការមិនសន្សំកិលេសវដ្ដៈ មិនប្រព្រឹត្តទៅដើម្បីការសន្សំកិលេសវដ្ដៈ

៤-អប្បិច្ឆតាយ សំវត្តន្តិ នោ មហិច្ឆតាយ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាច្រើន ។

៥-សន្តុដ្ឋិយា សំវត្តន្តិ នោ អសន្តុដ្ឋិយា ប្រព្រឹត្តទៅដើម្បីសេចក្ដីសន្ដោស មិនប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសន្ដោស ។

៦-បវិវេកាយ សំវត្តន្តិ នោ សង្គណិកាយ ប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ចាកពួក មិនប្រព្រឹត្តទៅដើម្បីការច្រឡូកច្រឡំដោយពួក ។

៧-វីរិយារម្ភាយ សំវត្តន្តិ នោ កោសជ្ជាយ ប្រព្រឹត្តទៅដើម្បីការប្រារព្ធសេចក្ដីព្យាយាម មិនប្រព្រឹត្តទៅដើម្បីសេចក្ដីខ្ជិលច្រអូស

៨-សុករាកាយ សំវត្តន្តិ នោ ទុក្ករាកាយ ប្រព្រឹត្តទៅ ដើម្បីគេចិញ្ចឹមបានដោយងាយ មិនប្រព្រឹត្តទៅដើម្បីគេចិញ្ចឹមបានដោយក្រ

ឯកំសេន គោតមិ ធារេយ្យាសិ ឯសោ ធម្មោ ឯសោ វិនយោ ឯតំ សត្ថុសាសនន្តិ ។ ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុកដោយចំណែកមួយថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តាហើយ ។

*(វិនយបិដក ១១/២៧៩)*

# ចូឡសង្គាម

ភិក្ខុអ្នកចូលទៅកាន់សង្គ្រាម(១) កាលបើចូលទៅរកជំនុំសង្ឃ គប្បីបន្ទាបបន្ទន់ចិត្តចូលទៅរកសង្ឃ គប្បីជាអ្នកមានចិត្តស្មើដោយកំណាត់សំពត់សម្រាប់ជូតនូវធូលី គប្បីជាអ្នកឈ្លាសក្នុងអាសនៈ ជាអ្នកឈ្លាសក្នុងការអង្គុយ កុំអង្គុយប្រៀតបៀតពួកភិក្ខុចាស់ កុំឃាត់អាសនៈពួកភិក្ខុខ្មី គប្បីអង្គុយលើអាសនៈតាមសមគួរ គប្បីជាអ្នកមិនពោលពាក្យឥតប្រយោជន៍ផ្សេងៗ កុំពោលពាក្យតិរច្ឆានកថា គប្បីសម្តែងធម៌ដោយខ្លួនឯងផង គប្បីនិមន្តភិក្ខុដទៃឲ្យសម្តែងធម៌ផង កុំមើលងាយព្រះអរិយៈដែលមានសភាពជាអ្នកស្ងប់ស្ងៀមផង ។ ភិក្ខុជាវិន័យធរដែលសង្ឃបានអនុម័ត(២) ហើយមានប្រាថ្នានឹងវិនិច្ឆ័យសេចក្តី មិនត្រូវសួររកឧបជ្ឈាយ៍ មិនត្រូវសួររកអាចារ្យ មិនត្រូវសួររកសទ្ធិវិហារិក មិនត្រូវសួររកអន្តេវាសិក

---

(១) ការប្រជុំសង្ឃដើម្បីរម្ងាប់ ឬវិនិច្ឆ័យនូវអធិករណ៍ លោកហៅថា សង្គ្រាម ។ ដូចពួកវជ្ជីបុត្រ ភិក្ខុក្នុងនគរវេសាលី ដែលជាសត្រូវដល់ខ្លួនផង ដល់សាសនាផង នាំគ្នាសម្តែងខុសធម៌ខុសវិន័យ ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ។ ភិក្ខុណាសង្កត់សង្កិនលទ្ធិរបស់ពួកវជ្ជីបុត្រ ដែលជាសត្រូវទាំងនោះ នឹងចូលទៅក្នុងទីនោះ ហើយធ្វើសេចក្តីវិនិច្ឆ័យឱ្យដាច់ស្រេច ដោយបំភ្លឺនូវវាទៈរបស់ខ្លួន ភិក្ខុនោះ ឈ្មោះថា ជាអ្នកចូលទៅកាន់សង្គ្រាម ដូចជាព្រះយសត្ថេរ (អដ្ឋកថា) ។ (២) យល់តាម ឬយល់ព្រម ពាក្យនេះជាពាក្យផ្លាស់ប្តូរគ្នា នឹងពាក្យអនុញ្ញាត ។

មិនត្រូវសួររកបុគ្គលដែលមានឧបជ្ឈាយ៍ស្មើគ្នា មិនត្រូវសួររកបុគ្គលដែលមានអាចារ្យស្មើគ្នា មិនត្រូវសួររកជាតិ (មានក្សត្រិយ៍ជាដើម) មិនត្រូវសួររកនាម មិនត្រូវសួររកគោត្រ មិនត្រូវសួររកអាគម (វិជ្ជាចំណេះ ថាលោកចេះពោលនិកាយ មានទីឃនិកាយជាដើម) មិនត្រូវសួររកត្រកូលនឹងប្រទេស មិនត្រូវសួររកជាតិភូមិ (ស្រុកកំណើត) ។ ព្រោះហេតុអ្វី (បានជាមិនត្រូវឲ្យសួរដូច្នេះ) ។ (ព្រោះថា ) សេចក្តីស្រលាញ់ក្តី សេចក្តីស្អប់ក្តី នឹងមានដល់បុគ្គលជាវិន័យធរនោះ កាលបើមានសេចក្តីស្រលាញ់នឹងសេចក្តីស្អប់ហើយ (វិន័យធរនោះ) មុខជាលំអៀងព្រោះស្រលាញ់ ឬលំអៀងព្រោះស្អប់ លំអៀងព្រោះវង្វេង ឬក៏លំអៀងព្រោះខ្លាច (មិនខាន) ។ ភិក្ខុជាវិន័យធរដែលសង្ឃបានអនុម័តហើយ មានប្រាថ្នានឹងវិនិច្ឆ័យសេចក្តី ត្រូវមានចិត្តធ្ងន់ក្នុងសង្ឃ កុំធ្ងន់ទៅក្នុងបុគ្គល ត្រូវមានចិត្តធ្ងន់ក្នុងព្រះសទ្ធម្ម កុំធ្ងន់ទៅក្នុងអាមិសៈ ជាអ្នកលុះក្នុងអំណាចនៃប្រយោជន៍ មិនត្រូវបណ្តែតបណ្តោយតាមសេចក្តីគាប់ចិត្តបរិសទ្យ គប្បីវិនិច្ឆ័យសេចក្តីតាមកាល កុំវិនិច្ឆ័យសេចក្តីឲ្យខុសកាល ត្រូវវិនិច្ឆ័យសេចក្តីដោយពាក្យពិត កុំវិនិច្ឆ័យដោយពាក្យមិនពិត ត្រូវវិនិច្ឆ័យសេចក្តីដោយពាក្យផ្អែមល្ហែម កុំវិនិច្ឆ័យសេចក្តីដោយពាក្យទ្រគោះ ត្រូវវិនិច្ឆ័យសេចក្តី

ដោយពាក្យដែលមានប្រយោជន៍ កុំវិនិច្ឆ័យដោយពាក្យឥតប្រយោជន៍ ត្រូវវិនិច្ឆ័យសេចក្ដីដោយមេត្តាចិត្ត កុំវិនិច្ឆ័យសេចក្ដីដោយសំអប់ កុំនិយាយខ្សឹបជិតត្រចៀក កុំស្វែងរកតែទោសខុស កុំមិចភ្នែក កុំញាក់ចិញ្ចើម កុំងក់ក្បាល កុំធ្វើវិការៈផ្សេងៗដោយដៃ កុំបង្ហាញដៃទទេ ត្រូវឈ្លាសក្នុងអាសនៈ ឈ្លាសក្នុងការអង្គុយ គប្បីសំឡឹងមើលត្រឹមតែមួយជួរនឹម ត្រូវពិចារណាសេចក្ដីសិនហើយសឹមអង្គុយលើអាសនៈរបស់ខ្លួន កុំក្រោកចាកអាសនៈ កុំធ្វើការវិនិច្ឆ័យឲ្យសាបសូន្យ កុំសេពគប់ផ្លូវខុស គឺកុំប្រកាសអាបត្តិ កុំនិយាយសំដីបោះបោក កុំនិយាយរួសរាន់ពេក កុំនិយាយរហ័សហួស កុំនិយាយអាក្រក់ ត្រូវចេះអត់ធ្មត់ ត្រូវមានមេត្តាចិត្ត មានចិត្តអនុគ្រោះចំពោះប្រយោជន៍ ត្រូវមានចិត្តប្រកបដោយករុណា ស្វែងរកនូវប្រយោជន៍ កុំពោលពាក្យរោយរាយ ត្រូវពោលពាក្យឲ្យមានទីបំផុត កុំលុះអំណាចនៃពៀរ កុំពោលពាក្យអសុរោះ ត្រូវស្ទង់មើលខ្លួន(ថាអាត្មាអញអាចនឹងវិនិច្ឆ័យសេចក្ដីបានឬទេ) ត្រូវស្ទង់មើលបុគ្គលដទៃ (ថាបរិស័ទនេះអាចសុខចិត្តដោយសេចក្ដីអៀនខ្មាសដែរឬទេ) ត្រូវស្ទង់មើលបុគ្គលអ្នកចោទ ( ថាអ្នកចោទនេះប្រកបដោយធម៌ឬទេ ) ត្រូវស្ទង់មើលអ្នកជាប់ចោទ ត្រូវស្ទង់មើលអ្នកចោទមិនត្រូវតាមធម៌ ត្រូវស្ទង់មើលអ្នកជាប់

ចោទមិនត្រូវតាមធម៌ ត្រូវសួរមើលអ្នកចោទត្រូវតាមធម៌ ត្រូវសួរមើលអ្នកជាប់ចោទត្រូវតាមធម៌ កុំបំបាត់ពាក្យអ្នកចោទនឹងអ្នកជាប់ចោទដែលនិយាយមកហើយ កុំប្រកាសផ្សាយពាក្យដែលអ្នកចោទ នឹងអ្នកជាប់ចោទមិនទាន់បាននិយាយ ត្រូវរៀនបទនឹងព្យញ្ជនៈដែលទាក់ទងគ្នា ឲ្យចេះចាំល្អ ហើយសួរបុគ្គលដទៃសិនសឹមវិនិច្ឆ័យសេចក្តីតាមពាក្យប្តេជ្ញា ត្រូវធ្វើអ្នកមានបញ្ញាទន់ឲ្យរីករាយ ត្រូវធ្វើអ្នកដែលមានសេចក្តីភិតភ័យឲ្យស្រួលចិត្ត ត្រូវគំរាមបុគ្គលដែលកាច ត្រូវឲ្យបុគ្គលដែលជាអលជ្ជីសម្តែងអាបត្តិចេញ ត្រូវមានចិត្តត្រង់ មានចិត្តទន់ កុំលុះឆន្ទាគតិ កុំលុះទោសាគតិ កុំលុះមោហាគតិ កុំលុះភយាគតិ ត្រូវជាអ្នកមានខ្លួនតាំងនៅជាកណ្តាលចំពោះធម៌ផង ចំពោះបុគ្គលផង ។ កាលបើវិន័យធរបានវិនិច្ឆ័យតាមទំនងយ៉ាងនេះហើយ ឈ្មោះថា ជាអ្នកធ្វើសាសនារបស់ព្រះសាស្តា (ឲ្យរុងរឿង) ផង ឈ្មោះថាជាទីស្រលាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ នៃសព្រហ្មចារីបុគ្គលទាំងឡាយ ដែលជាអ្នកចេះដឹងផង ។

[១៦៧] សុត្តៈគឺឧភតោវិភង្គ (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍នឹងប្រៀបធៀប (នូវអាបត្តិនឹងអនាបត្តិ) សេចក្តីឧបមា (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍នឹងពន្យល់សេចក្តីឲ្យច្បាស់ អត្ថ (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍

នឹងឲ្យដឹងច្បាស់ បដិបុច្ឆា (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍នឹងដម្កល់ទុក (នូវបុគ្គល) ឱកាសកម្ម(ប្រព្រឹត្តទៅ)ដើម្បីប្រយោជន៍ដល់ការចោទ ការចោទ(ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍នឹងរំលឹក(នូវទោសតូចនឹងទោសធំ) ការរំលឹកទោស ដើម្បីប្រយោជន៍នឹងធ្វើ (បុគ្គលនោះ) ឲ្យមានមាត់ពាក្យ អំពើដែលធ្វើឲ្យមានមាត់ពាក្យ ដើម្បីប្រយោជន៍ដល់ការកង្វល់ ការកង្វល់ ដើម្បីប្រយោជន៍នឹងដម្កល់ទុកនូវការវិនិច្ឆ័យសេចក្តី ការវិនិច្ឆ័យដើម្បីប្រយោជន៍ពិចារណា (នូវទោសតូចនឹងទោសធំ) ការពិចារណាដើម្បីប្រយោជន៍នឹងដឹងនូវហេតុគួរនឹងមិនគួរ (ដឹងអាបត្តិ នឹង អនាបត្តិ គរុកាបត្តិ នឹងលហុកាបត្តិ) ការដឹងនូវហេតុគួរនឹងមិនគួរ ដើម្បីប្រយោជន៍សង្កត់សង្កិន ពួកបុគ្គលដែលមិនមានសេចក្តីអៀនខ្មាស នឹងដើម្បីប្រយោជន៍លើកដម្កើងនូវពួកភិក្ខុដែលមានសីលជាទីស្រលាញ់ ជំនុំសង្ឃ ដើម្បីប្រយោជន៍ទទួលនូវការវិនិច្ឆ័យ បុគ្គល គឺពួកភិក្ខុដែលសង្ឃអនុញ្ញាតហើយ គួរដល់តំណែងជាធំតាមចំណែក នឹងគួរដល់តំណែងជាអ្នកពោលពាក្យពិត ។ វិន័យ ដើម្បីប្រយោជន៍ដល់សេចក្តីសង្រួម សេចក្តីសង្រួម ដើម្បីប្រយោជន៍ដល់សេចក្តីមិនក្តៅក្រហាយចិត្ត ។ សេចក្តីមិនក្តៅក្រហាយចិត្ត ដើម្បីប្រយោជន៍ដល់បាមុជ្ជៈ គឺ សេចក្តីរីករាយទន់ ។

មុជ្ជៈដើម្បីប្រយោជន៍ដល់បីតិគឺសេចក្ដីរីករាយដ៏ក្លា បីតិដើម្បីប្រយោជន៍ដល់បស្សទ្ធិ គឺសេចក្ដីស្ងប់រម្ងាប់ ។ បស្សទ្ធិដើម្បីប្រយោជន៍ដល់សុខៈ សុខៈដើម្បីប្រយោជន៍ដល់សមាធិ សមាធិដើម្បីប្រយោជន៍ដល់យថាភូតញ្ញាណទស្សនៈ គឺតរុណវិបស្សនា (វិបស្សនាទន់ខ្សី) យថាភូតញ្ញាណទស្សនៈដើម្បីប្រយោជន៍ដល់និព្វិទា គឺ ពលវវិបស្សនា (វិបស្សនាមានកម្លាំង) ។ និព្វិទាដើម្បីប្រយោជន៍ដល់វិរាគៈ គឺ អរិយមគ្គ ។ វិរាគៈដើម្បីប្រយោជន៍ដល់វិមុត្តិ គឺ អរហត្តផល ។ វិមុត្តិ ដើម្បីប្រយោជន៍ដល់វិមុត្តិញ្ញាណទស្សនៈគឺ បច្ចវេក្ខណញ្ញាណ ។ វិមុត្តិញ្ញាណទស្សនៈដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន គឺ រំលត់មិនឲ្យមានបច្ច័យជាគ្រឿងប្រកាន់តទៅ ។ ព្រះអរហន្តផល ឬព្រះនិព្វានជាគ្រឿងរួចចាកសេចក្ដីសៅហ្មងនៃចិត្ត ព្រោះមិនមានឧបាទានជាគ្រឿងប្រកាន់ណា ការពោលនូវព្រះវិន័យមានព្រះអរហត្តផល ឬព្រះព្រះនិព្វានទុំះជាប្រយោជន៍ ការប្រឹក្សានូវវិន័យ មានព្រះអរហត្តផល ឬព្រះនិព្វានទុំះជាប្រយោជន៍ ការពិចារណានូវវិន័យមានព្រះអរហត្តផល ឬព្រះនិព្វានទុំះជាប្រយោជន៍ ការប្រុងស្ដាប់នូវវិន័យ ក៏មានព្រះអរហត្តផល ឬព្រះនិព្វានទុំះជាប្រយោជន៍ ។

[១៦៨] ចូរអ្នកពិចារណានូវវត្តដែលគួរប្រព្រឹត្ត តាមដែលអនុលោមតាមនូវសិក្ខាបទ ដែលព្រះលោកនាថជាអ្នកប្រាជ្ញ មានបញ្ញា

វាងវែនាំមកដឹកលទុក នឹងបញ្ញត្តទុកដោយប្រពៃ ធ្វើដំណើររបស់ខ្លួន ដែលប្រព្រឹត្តទៅក្នុងបរលោកកុំឲ្យវិនាស ភិក្ខុណាមិនស្គាល់វត្ថុផង មិនស្គាល់វិបត្តិផង មិនស្គាល់អាបត្តិផង មិនស្គាល់និទានផង មិនឈ្លាសក្នុងអាការ គឺហេតុនឹងមិនមែនហេតុផង មិនស្គាល់ពាក្យខាងដើមនឹងពាក្យខាងចុងផង មិនស្គាល់កម្មគួរធ្វើនឹងមិនគួរធ្វើដោយស្មើផង មិនស្គាល់កម្មផង មិនស្គាល់អធិករណ៍ផង មិនឈ្លាសក្នុងសមថៈផង ជាអ្នកត្រេកអរស៊ប់ជាដើមផង ជាអ្នកប្រទូស្តផង ជាអ្នកលង្វង់ផង លំអៀងព្រោះខ្លាចផង ព្រោះភ្លេចស្មារតីផង មិនឈ្លាសក្នុងការប្រកាសឲ្យអ្នកដទៃយល់ព្រមផង មិនឈ្លាសក្នុងការពិចារណានូវហេតុ នឹងមិនមែនហេតុផង តែងជាអ្នកបានប័ក្ខពួក (ស្មើនឹងខ្លួន) ជាអ្នកមិនមានសេចក្តីខ្មាស ប្រកបដោយកម្មខ្មៅ មិនអើពើ (ក្នុងធម៌នឹងបុគ្គល) ភិក្ខុបែបនោះ លោកហៅថាបុគ្គលដែលបណ្ឌិតលែងរាប់អាន ។ ភិក្ខុណាស្គាល់វត្ថុ ស្គាល់វិបត្តិ ស្គាល់អាបត្តិ ស្គាល់និទាន ឈ្លាសក្នុងអាការ ដឹងច្បាស់នូវពាក្យខាងដើម នឹងពាក្យខាងចុង ដឹងនូវកម្មដែលគួរធ្វើនឹងមិនគួរធ្វើដោយស្មើ ដឹងកម្មផង ដឹងអធិករណ៍ផង ឈ្លាសក្នុងសមថៈផង មានចិត្តមិនបានត្រេកអរ មិនបានប្រទូស្ត មិនបានវង្វេង មិនលំអៀងព្រោះខ្លាច មិនលំអៀងព្រោះវង្វេងស្មារតី ឈ្លាសក្នុងការពន្យល់ឲ្យអ្នកដទៃយល់ ឈ្លាសក្នុងការពិចារណាមើលហេតុនឹងមិនមែនហេតុ តែងជាអ្នកបានប័ក្ខពួក(ស្មើនឹង-

ខ្លួន) ជាអ្នកមានចិត្តខ្មាសបាប ប្រកបដោយកម្មស ប្រកបដោយសេចក្ដីគោរព ភិក្ខុបែបនោះឯង លោកហៅថាបុគ្គលដែលបណ្ឌិតគប្បីរាប់រក ។

*(គម្ពីរបរិវារ ១៣/១៩០_១៩៧)*

**ចប់ ចូឡសង្គាម**

## អដ្ឋកថា

វិនិច្ឆ័យក្នុងចូឡសង្គាម គប្បីជ្រាបដូច្នេះ ៖

ប្រជុំសង្ឃដើម្បីប្រយោជន៍ដល់ការវិនិច្ឆ័យនូវអធិករណ៍ ហៅថា សង្គ្រាម ក្នុងពាក្យថា ភិក្ខុដែលចូលសង្គ្រាម ។ ពិតមែន ភិក្ខុទាំងឡាយដែលជាសត្រូវដល់ខ្លួន និងជាសត្រូវចំពោះព្រះសាសនា រមែងប្រជុំគ្នា សម្តែងសត្ថុសាសនាក្រៅធម៌ក្រៅវិន័យក្នុងទីប្រជុំសង្ឃនោះ ដូចយ៉ាងភិក្ខុវជ្ជីបុត្រអ្នកក្រុងវេសាលីដូច្នោះ ។ ភិក្ខុណា ញាំញីលទ្ធិរបស់ភិក្ខុដែលជាសត្រូវទាំងនោះចេញ ចូលក្នុងទីប្រជុំសង្ឃនោះដើម្បីប្រយោជន៍ដល់ការសម្តែងវាទៈរបស់ខ្លួន ដាក់អំណាច ញ៉ាំងការវិនិច្ឆ័យឲ្យប្រព្រឹត្តទៅ អ្នកនោះឈ្មោះថា អ្នកចូលសង្គ្រាម ដូចជាព្រះយសត្ថេរដូច្នោះ ។ ភិក្ខុដែលចូលសង្គ្រាមនោះកាលចូលរកសង្ឃគប្បីជាអ្នកមានចិត្តកោតក្រែងចូលរកសង្ឃ។

បទថា **នីចចិត្តេន : គប្បីបន្ទាបបន្ទន់ចិត្ត** បានដល់ អ្នកដកទង់ គឺ មានះចេញ មានចិត្តដែលបានកម្ចាត់មានះចេញហើយ ។

បទថា **រជោហរណសមេន : ស្មើដោយកំណាត់សំពត់សម្រាប់ជូតនូវធូលី** បានដល់ មានចិត្តស្មើដោយសំពត់ជូតជើង, អធិប្បាយថា កាលជើងប្រឡាក់ ឬមិនប្រឡាក់ដែលបុគ្គលជូតហើយ សេចក្តីត្រេកអរ សេចក្តី

ប្រទូសរ៉ាយ រមែងមិនមានដល់សំពត់ជូតជើងយ៉ាងណា, គប្បីជាអ្នកមាន ចិត្តមិនត្រេកអរ មិនប្រទូសរ៉ាយក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍យ៉ាងនោះ។

ពីរបទថា **យថាបដិរូបេ អាសនេ : លើអាសនៈតាមសមគួរ** មានសេចក្ដីថា គប្បីដឹងអាសនៈតាមដែលសមគួរអង្គុយ ក្នុងទីដែលត្រូវដល់ខ្លួន មិនត្រឡប់ក្រោយឲ្យភិក្ខុទាំងឡាយដែលជាថេរៈ ។

បទថា **អនានាកថិកោន : មិនពោលពាក្យឥតប្រយោជន៍ផ្សេងៗ** បានដល់ មិនពោលពាក្យដែលមិនមានប្រយោជន៍នោះៗ ដែលមានប្រការផ្សេងៗ ។

បទថា **អតិរច្ឆានកថិកោន : កុំពោលពាក្យតិរច្ឆានកថា** បានដល់ មិនពោលតិរច្ឆានកថា មានរឿងព្រះរាជាជាដើម ដែលបានឃើញក្ដី បានស្ដាប់ក្ដី បានជ្រាបក្ដី ។

ច្រើនបទថា **សាមំ វា ធម្មោ ភាសិតព្វោ : គប្បីសម្ដែងធម៌ដោយខ្លួនឯងផង** មានសេចក្ដីថា ពាក្យដែលអាស្រ័យរឿងដែលគួរ និងមិនគួរ ឬដែលអាស្រ័យរូបារូបបរិច្ឆេទ និងលំដាប់នៃសមថៈ លំដាប់នៃវិបស្សនា វត្តក្នុងការឈរនិងអង្គុយជាដើមក្នុងទីប្រជុំសង្ឃ ឈ្មោះថា ធម៌ ។ ធម៌បែបនេះ គប្បីពោលខ្លួនឯងក៏បាន អារាធនាភិក្ខុដទៃពោលក៏បាន ។

ភិក្ខុណាអាចពោលពាក្យបែបនោះ ភិក្ខុនោះដែលខ្លួនគប្បីអារាធនាថា អ្នកមានអាយុ បញ្ហាកើតឡើងហើយនៅកណ្តាលជំនុំសង្ឃ លោកគប្បីពោល ។

ត្រើនបទថា **អរិយោ វា តុណ្ហីភាវោ ឆាតិមញ្ញិតព្វោ : កុំមើលងាយព្រះអរិយៈដែលមានសភាពជាអ្នកស្ងប់ស្ងៀមផង** មានសេចក្តីថា ព្រះអរិយៈទាំងឡាយកាលអង្គុយស្ងៀម មិនបានអង្គុយដូចជាពាលបុថុជ្ជនទេ រមែងកាន់យកកម្មដ្ឋានយ៉ាងណាមួយអង្គុយ, ព្រះអរិយៈដែលមានភាពស្ងៀមជាប្រក្រតី ។ ដោយអំណាចធ្វើកម្មដ្ឋានទុកក្នុងចិត្ត យ៉ាងនេះ ឈ្មោះថា មានភាពស្ងៀមជាប្រក្រតី ។ ព្រះអរិយៈនោះ ដែលភិក្ខុចូលសង្គ្រាមមិនគប្បីមើលងាយថា មានប្រយោជន៍អ្វីដោយការព្យាយាម ក្នុងកម្មដ្ឋាន,អធិប្បាយថា ខ្លួនគប្បីកាន់យកកម្មដ្ឋានដែលសមគួរដល់ខ្លួនអង្គុយ ។

ពីរបទថា **ឆ ឧបជ្ឈាយោ បុច្ឆិតព្វោ : មិនត្រូវសួររកឧបជ្ឈាយ៍** មានសេចក្តីថា មិនគួរសួរថា ឧបជ្ឈាយ៍របស់លោកឈ្មោះអ្វី ? ក្នុងបទទាំងពួងក៏ន័យនេះឯង ។

បទថា **ឆ ជាតិ : មិនរកជាតិ** មានសេចក្តីថា មិនគួរសួរដល់ជាតិយ៉ាងនេះថា លោកជាជាតិក្សត្រិយ៍ឬ ? លោកជាជាតិព្រាហ្មណ៍ឬ ?

បទថា **ឆ អាគមោ : មិនរកអាគម** មានសេចក្តីថា មិនគួរ

សួរដល់បរិយត្តិដែលរៀនយ៉ាងនេះថា លោកពោលទីឃនិកាយឬ ? លោកពោលមជ្ឈិមនិកាយឬ ?

ត្រកូលនិងប្រទេសគប្បីជ្រាបដោយអំណាចត្រកូលក្សត្រិយ៍ជាដើម ។ ច្រើនបទថា **អត្រស្ស បេមំ វា ទោសោ វា : សេចក្តីស្រឡាញ់ក្តី សេចក្តីស្អប់ក្តី នឹងមានដល់វិន័យធរនោះ** មានសេចក្តីថា សេចក្តីស្រឡាញ់ ឬសេចក្តីស្អប់ក្នុងបុគ្គលនោះ គប្បីមានដោយអំណាចនៃហេតុទាំងនោះ យ៉ាងណាមួយ ។

ពីរបទថា **ន បរិសកប្បិយេន : មិនត្រូវបណ្តែតបណ្តោយតាមសេចក្តីគាប់ចិត្តបរិស័ទ** មានសេចក្តីថា មិនគប្បីជាអ្នកឃើញដល់បរិស័ទ គឺ បណ្តោយតាមបរិស័ទ , អធិប្បាយថា វត្ថុណាពេញចិត្តបរិស័ទ វត្ថុនោះឯងមិនគប្បីតាំងចិត្ត គឺ ចិត្តប៉ងនឹងពោល ។

ពីរបទថា **ន ហត្ថមុទ្ទា ទស្សេតព្វា : កុំធ្វើវិការផ្សេងៗដោយដៃ** មានសេចក្តីថា មិនគប្បីធ្វើវិការនៃដៃ ដើម្បីសម្គាល់ដឹងក្នុងន័យដែលគួរពោល និងមិនគួរពោល ។

ពីរបទថា **អត្ថំ អនុវិធិយន្តេន : ត្រូវពិចារណាសេចក្តីសិន** មានសេចក្តីថា គប្បីកំណត់ឲ្យដឹងរហូតអស់កាលវិនិច្ឆ័យប៉ុណ្ណោះ គឺ គប្បី

អង្គុយពិចារណាដោយល្អិតល្អន់យ៉ាងនេះថា សូត្រនេះអាងបាន យើងនឹងពោលសូត្រនេះក្នុងវិនិច្ឆ័យនេះ ។

ប្រើនបទថា **ន ច អាសនា វុដ្ឋាតព្វំ : កុំក្រោកចាកអាសនៈ** មានសេចក្តីថា មិនគប្បីក្រោកចាកទីអង្គុយត្រាច់ទៅក្នុងបរិវេណទីជំនុំ ។ ព្រោះថា កាលព្រះវិន័យធរក្រោក បរិស័ទទាំងពួងរមែងក្រោក ។

បទថា **ន វីតិហាតព្វំ : កុំធ្វើការវិនិច្ឆ័យឲ្យសាបសូន្យ** មានសេចក្តីថា មិនគប្បីឲ្យវិនិច្ឆ័យសាបសូន្យ ។

ពីរបទថា **ន កុម្មគ្គោ សេវិតព្វោ : កុំសេពគប់ផ្លូវខុស** មានសេចក្តីថា មិនគប្បីចង្អុលបង្ហាញអាបត្តិ ។

ពីរបទថា **អសាហសិកេន ភវិតព្វំ : កុំនិយាយរហ័សរហួន** មានសេចក្តីថា មិនគប្បីជាអ្នកធ្វើដោយប្រញាប់ប្រញាប់ , អធិប្បាយថា មិនគប្បីពោលពាក្យឲ្យខុសភ្លាត់ដោយសេចក្តីប្រញាប់ប្រញាប់ ។

បទថា **វចនក្ខមេន : ត្រូវចេះអត់ធ្មត់** មានសេចក្តីថា គប្បីជាអ្នកមានប្រក្រតីអត់ធន់បាននូវពាក្យដែលគ្រោតគ្រាត ។

បទថា **ហិតបរិសក្កិនា : ស្វែងរកនូវប្រយោជន៍** មានសេចក្តីថា គប្បីជាអ្នកស្វែងរកប្រយោជន៍ គឺខ្វល់ខ្វាយដើម្បីប្រយោជន៍ ។ ក្នុងបទទាំង ២ មានអធិប្បាយដូច្នេះថា ករុណាជាចំណែកខាងដើម

នៃករុណា ដែលភិក្ខុចូលសង្គ្រាមគប្បីឲ្យចូលទៅតាំងទុក ។

បទថា **អនសុរុត្តេន : កុំពោលពាក្យអសុរោះ** បានដល់ មិនគប្បីជាអ្នកពោលពាក្យគ្រោតគ្រាត ។ អធិប្បាយថា ពាក្យដែលមិនល្អពោល គឺ ពាក្យនាំឲ្យវិវាទ ហៅថា ពាក្យដែលគ្រោតគ្រាត ពាក្យដែលគ្រោតគ្រាតនោះ ដែលភិក្ខុចូលសង្គ្រាមមិនគួរពោល ។

ពីរបទថា **អត្តា បរិគ្គហេតព្វោ : ត្រូវស្ទង់មើលខ្លួន** មានសេចក្តីថា គប្បីត្រួតមើលខ្លួនយ៉ាងនេះថា យើងអាចនឹងវិនិច្ឆ័យ គឺ រម្ងាប់អធិករណ៍ឬទេហ្ន៎ ? អធិប្បាយថា គប្បីដឹងប្រមាណខ្លួន ។

ពីរបទថា **បរោ បរិគ្គហេតព្វោ : ត្រូវស្ទង់មើលអ្នកដទៃ** មានសេចក្តីថា គប្បីត្រួតមើលអ្នកដទៃយ៉ាងនេះថា បរិស័ទនេះជាលជ្ជីឬហ្ន៎ ? ដែលយើងអាចនឹងឲ្យយល់ព្រមឬទេ ?

ពិរបទថា **ចោទកោ បរិគ្គហេតព្វោ : ត្រូវស្ទង់មើលអ្នកចោទ** មានសេចក្តីថា គប្បីត្រួតមើលអ្នកចោទយ៉ាងនេះថា អ្នកនេះជាអ្នកចោទដោយធម៌ ឬទេហ្ន៎?

ពីរបទថា **ចុទិតកោ បរិគ្គហេតព្វោ :ត្រូវស្ទង់មើលអ្នកជាប់ចោទ** មានសេចក្តីថា គប្បីត្រួតមើលអ្នកជាប់ចោទយ៉ាងនេះថា អ្នកនេះ

ជាអ្នកជាប់ចោទដោយធម៌ឬទេ ?

ពីរបទថា **អធម្មចោទកោ បរិគ្គហេតព្វោ : ត្រូវស្ទង់មើលអ្នកចោទមិនត្រូវតាមធម៌** មានសេចក្តីថា គប្បីដឹងប្រមាណអ្នកចោទនោះ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះឯង ។

ពីរបទថា **វុត្តំ អហាបេន្តេន : កុំបំបាត់ពាក្យដែលនិយាយមកហើយ** មានសេចក្តីថា មិនគប្បីញុាំងពាក្យដែលអ្នកចោទ និងអ្នកជាប់ចោទ ពោលឲ្យចេញមក ។

ពីរបទថា **អវុត្តំ អប្បកាសេន្តេន : កុំប្រកាសផ្សាយពាក្យដែលមិនទាន់បាននិយាយ** មានសេចក្តីថា មិនគប្បីរុករកសេចក្តីដែលមិនបានចូលដល់ចំណុចសំខាន់ ។

ពីរបទថា **មន្ទោ ហាសេតព្វោ : ត្រូវធ្វើអ្នកមានបញ្ញាទន់-ឲ្យរីករាយ** មានសេចក្តីថា អ្នកចោទ ឬអ្នកជាប់ចោទជាអ្នកទន់ខ្សោយ គឺជាអ្នកល្ងង់ខ្លៅ គប្បីជួយ គឺ គប្បីដាស់ចិត្តឲ្យអាចហ៊ានថា លោកជាបុត្ររបស់ត្រកូលមិនមែនឬ ? ហើយចង្អុលបង្ហាញទំនៀមក្នុងការសាកសួរ ហើយចាប់ការសាកសួរដល់អ្នកល្ងង់ខ្លៅនោះ ។

ពីរបទថា **ភីរុ អស្សាសេតព្វោ : ត្រូវធ្វើអ្នកដែលភិតភ័យឲ្យស្រួលចិត្ត** មានសេចក្តីថា អ្នកចោទឬអ្នកជាប់ចោទណា កើតសេចក្តីខ្លាច

ក្រែងឡើង ព្រោះមិនធ្លាប់ចូលកាន់កណ្តាលជំនុំសង្ឃ ឬកណ្តាលគណៈ, ភិក្ខុដូច្នោះ ដែលភិក្ខុពោលអត្ថក្តី គប្បីនិយាយលួងលោមថា លោកកុំខ្លាច ឡើយ ចូរដាក់ចិត្តធ្វើយចុះ, ពួកយើងនឹងជាអ្នកជិតដិតនឹងលោក ដូច្នេះក៏បាន ហើយចង្អុលបង្ហាញទំនៀមក្នុងការសាកសួរ ។

ពីរបទថា **ចណ្ឌោ និសេធេតព្វោ : ត្រូវគម្រាមបុគ្គលដែលកាច** មានសេចក្តីថា ជាអ្នកប្រទូសរ៉ាយ គប្បីរុករានចេញ គឺគប្បីបង្រាបចេញ ។

ពីរបទថា **អសុចិ វិភាវេតព្វោ : ត្រូវឲ្យបុគ្គលដែលជាអលជ្ជីសម្តែងអាបត្តិចេញ** មានសេចក្តីថា ជាអលជ្ជីគប្បីប្រកាសហើយឲ្យសម្តែងអាបត្តិចេញ ។

ពីរបទថា **ឧជុ មទ្ទវេន : ត្រូវមានចិត្តត្រង់ មានចិត្តទន់** មានសេចក្តីថា ភិក្ខុណាជាអ្នកត្រង់ មានសីល វៀរចាកសេចក្តីថ្នាំថ្នង កោងផ្លូវកាយជាដើម, ភិក្ខុនោះ ដែលអ្នកពោលអត្ថក្តី គប្បីប្រព្រឹត្តដោយសេចក្តីទន់ភ្លន់ប៉ុណ្ណោះ ។

ក្នុងពាក្យថា **ធម្មេសុ ច បុគ្គលេសុ ច : ចំពោះធម៌ផង ចំពោះបុគ្គលផង**នេះ ភិក្ខុណាធ្ងន់ក្នុងធម៌ មិនបានធ្ងន់ក្នុងបុគ្គល, ភិក្ខុនេះឯងគប្បីជ្រាបថា អ្នកដាក់ខ្លួនជាកណ្តាល ទាំងក្នុងធម៌ ទាំងក្នុងបុគ្គល ។

## ប្រយោជន៍នៃសូត្រជាដើម

[១៦៧] វិនិច្ឆ័យក្នុងពាក្យថា **សុត្តំ សំសន្ទនត្ថាយ : សុត្តៈ ដើម្បីនឹងប្រៀបធៀប** ជាដើម គប្បីជ្រាបដូច្នេះ ៖

ក៏ប៉ុន្តែថា ភិក្ខុអ្នកត្រួតពិនិត្យក្តី ជាទីស្រឡាញ់ពេញចិត្ត ជាទីគោរព និង ជាទីរាប់អានរបស់សព្រហ្មចារីយ៉ាងនេះ គប្បីជ្រាបថា ក្នុងបណ្តាសូត្រជាដើម ដែលអាងសូត្រមក ដើម្បីប្រយោជន៍ដល់ការប្រៀបធៀប គឺដើម្បីប្រយោជន៍ដល់ការដេញដោលសួរអាបត្តិ និងអនាបត្តិ ។

ពីរបទថា **ឱបម្មំ និទស្សនត្ថាយ : សេចក្តីឧបមា ដើម្បីប្រយោជន៍នឹងពន្យល់សេចក្តីឲ្យជាក់ច្បាស់** មានសេចក្តីថា ការឧបមា ដើម្បីប្រយោជន៍ដល់ការចង្អុលបង្ហាញនូវសេចក្តី ។

ពីរបទថា **អត្ថោ វិញ្ញាបនត្ថាយៈ អត្ថ ដើម្បីប្រយោជន៍នឹងឲ្យជាក់ច្បាស់** មានសេចក្តីថា អត្ថន័យដើម្បីប្រយោជន៍ដល់ការពន្យល់ឲ្យយល់ ។

ពីរបទថា **បដិបុច្ឆា ឋបនត្ថាយ : បដិបុច្ឆា ដើម្បីប្រយោជន៍នឹងតម្កល់ទុក(នូវបុគ្គល)** មានសេចក្តីថា ការសាកសួរដើម្បីប្រយោជន៍ដល់សេចក្តីរឹងមាំរបស់បុគ្គល ។

ពីរបទថា **ឱកាសកម្មំ ចោទនត្ថាយ : ឱកាសកម្មដើម្បីប្រយោជន៍ដល់ការចោទ** មានសេចក្តីថា (ការសូមឱកាស) ដើម្បីប្រយោជន៍

ដល់ការចោទដោយវត្ថុ ឬដោយអាបត្តិ ។

ពីរបទថា **ចោទនា សារណត្ថាយ : ការចោទដើម្បីប្រយោជន៍នឹងរំលឹក** មានសេចក្ដីថា (ការចោទ) ដើម្បីប្រយោជន៍អ្នកជាប់ចោទរលឹកដល់ទោសតូចធំ ។

ពីរបទថា **សារណា សវចនីយត្ថាយ : ការរំលឹកដើម្បីប្រយោជន៍នឹងធ្វើ(បុគ្គលនោះ)ឲ្យមានមាត់ពាក្យ** មានសេចក្ដីថា ការដែលឲ្យអ្នកជាប់ចោទ រលឹកដល់ទោសតូចទោសធំ ដើម្បីប្រយោជន៍ជាអ្នកមានពាក្យដែលខ្លួនគប្បីឆ្លើយ ។

ពីរបទថា **សវចនីយំ បលិពោធត្ថាយ : អំពើដែលធ្វើឲ្យមានមាត់ពាក្យដើម្បីប្រយោជន៍ដល់ការកង្វល់** មានសេចក្ដីថា ជាអ្នកមានពាក្យដែលខ្លួនគប្បីឆ្លើយ ដើម្បីប្រយោជន៍ដល់ការឃាត់ទុកយ៉ាងនេះថា លោកកុំឈានចេញទៅ សូម្បីតែមួយជំហានចាកអាវាសនេះ ។

ពីរបទថា **បលិពោធោ វិនិច្ឆយត្ថាយ : ការកង្វល់ដើម្បីប្រយោជន៍នឹងតម្កល់ទុកនូវការវិនិច្ឆ័យ** មានសេចក្ដីថា (ការឃាត់ទុក) ដើម្បីប្រយោជន៍ដល់ការតាំងវិនិច្ឆ័យ ។

ពីរបទថា **វិនិច្ឆយោ សន្តីរណត្ថាយ : ការវិនិច្ឆ័យដើម្បីប្រយោជន៍ដល់ការពិចារណា** មានសេចក្ដីថា ការវិនិច្ឆ័យដើម្បីប្រយោជន៍ដល់ការរិះគិត គឺ ពិចារណាទោស និងមិនមែនទោស ។

ការរិះគិត ដើម្បីប្រយោជន៍ដល់ការស្ថាបស្ថប់ឋានៈ និង អឋានៈ គឺ ដើម្បី ប្រយោជន៍ស្គាល់អាបត្តិ អនាបត្តិ គរុកាបត្តិ លហុកាបត្តិ ។

ពីរបទថា **សង្ឃោ សម្បរិគ្គហសម្បដិច្ឆនត្ថាយ : ជំនុំសង្ឃដើម្បីប្រយោជន៍ទទួលការវិនិច្ឆ័យ** មានសេចក្តីថា ដើម្បីប្រយោជន៍ដល់ការទទួលរងវិនិច្ឆ័យ និងដើម្បីប្រយោជន៍ឲ្យបានដឹងថា អធិករណ៍នោះ ដែលអ្នកពោលអត្ថក្តី វិនិច្ឆ័យត្រឹមត្រូវ ឬមិនត្រឹមត្រូវ ។

ពីរបទថា **បច្ចេកដ្ឋាយិនោ អវិសំវាទកដ្ឋាយិនោ : គួរដល់តំណែងជាធំតាមចំណែក និងគួរដល់តំណែងជាអ្នកពោលពាក្យពិត** មានសេចក្តីថា បុគ្គលទាំងនោះ ដែលតាំងនៅក្នុងតំណែងជាធំ ដោយភាពជាឥស្សរិយាធិបតី និងក្នុងឋានៈនៃអ្នកមិនពោលក្លែងឲ្យខុសដែលសង្ឃមិនគប្បីរុកកួន ។

## ប្រយោជន៍នៃវិន័យជាដើម

ឥឡូវនេះ ព្រះឧបាលីថេរៈពោលពាក្យថា វិន័យដើម្បីប្រយោជន៍ដល់សំវរៈជាដើម ដើម្បីសម្តែងសេចក្តី ដើម្បីបិទឱកាសនៃពាក្យរបស់ជនទាំងឡាយអ្នកមានបញ្ញាខ្សោយ ដែលនឹងគប្បីពោលយ៉ាងនេះថា ឈ្មោះថា **វិន័យ** តើមានប្រយោជន៍អ្វី ។

បណ្តាបទទាំងនោះ ពីរបទថា **វិនយោ សំវរត្ថាយ : វិន័យដើម្បីប្រយោជន៍ដល់សេចក្តីសង្រួម** មានសេចក្តីថា វិន័យបញ្ញត្តិសូមទាំង-

អស់ ដើម្បីប្រយោជន៏ដល់សេចក្ដីសង្រួមកាយទ្វារនិងវចីទ្វារ គឺជាឧប-និស្ស័យ អធិប្បាយថា ជាបច្ច័យដល់សីលមានអាជីវបារិសុទ្ធិសីលជាទីបំផុត ។ ក្នុងបទទាំងពួង ក៏ន័យនេះឯង ។ម្យ៉ាងទៀត ក្នុងធម៌ទាំងឡាយ មានសេចក្ដីមិនក្ដៅក្រហាយចិត្តជាដើមនេះ មានពាក្យអធិប្បាយថា ការមិនមានសេចក្ដីក្ដៅក្រហាយនៃចិត្ត ដោយអំណាចនៃបុណ្យដែលបានធ្វើទុក និងបាបដែលមិនបានធ្វើទុក ឈ្មោះថា **សេចក្ដីមិនក្ដៅក្រហាយចិត្ត** ។

បីតិទន់ខ្សោយមិនខ្លាំងក្លា ឈ្មោះថា **បាមោជ្ជៈ** ។ បីតិខ្លាំងក្លាមានកម្លាំង ឈ្មោះថា **បីតិ** ។ សេចក្ដីរម្ងាប់សេចក្ដីខ្វល់ខ្វាយក្នុងកាយនិងចិត្ត ឈ្មោះថា **បស្សទ្ធិ** ។ សុខផ្លូវកាយផ្លូវចិត្ត ឈ្មោះថា **សុខៈ** ។ ពិតមែនសុខទាំង ២ យ៉ាងនោះ រមែងជាឧបនិស្សយប្បច្ច័យនៃសមាធិ ។ ចិត្តដែលមានអារម្មណ៏តែមួយ ឈ្មោះថា **សមាធិ** ។ វិបស្សនាយ៉ាងខ្សោយ ឈ្មោះថា **យថាភូតញ្ញាណទស្សនៈ** ។ យថាភូតញ្ញាណទស្សនៈនេះ ជាឈ្មោះរបស់ញាណដែលដឹងសេចក្ដីកើត និងសេចក្ដីសាបសូន្យ ។ ពិតមែន សេចក្ដីដែលចិត្តមានអារម្មណ៏តែមួយ រមែងជាឧបនិស្សយប្បច្ច័យនៃវិបស្សនាទន់ខ្សោយ ។ វិបស្សនាយ៉ាងខ្លាំងក្លា ដែលចាត់ជាកំពូល ជាហេតុឲ្យដល់ការដកខ្លួនចេញ ឈ្មោះថា **និព្វិទា** ។ អរិយមគ្គ ឈ្មោះថា **វិរាគៈ** ។ អរហត្តផលឈ្មោះថា **វិមុត្តិ** ។ ពិតមែន អរិយមគ្គទាំង ៤ យ៉ាង រមែងជាឧបនិស្សយប្បច្ច័យនៃអរហត្ត ។ បច្ចវេក្ខណញ្ញាណ ឈ្មោះថា

**វិមុត្តិញាណទស្សនៈ** ។

ពីរបទថា **វិមុត្តិញាណទស្សនំ អនុបាទាបរិនិព្វានត្ថាយ : វិមុត្តិញាណទស្សនៈ ដើម្បីប្រយោជន៍ដល់អនុបាទាបរិព្វាន** មានសេចក្តីថា វិមុត្តិញាណទស្សនៈ ដើម្បីប្រយោជន៍ដល់សេចក្តីរលត់អស់ មិនមានសេសសល់បច្ច័យ ។ ពិតមែន វិមុត្តិញាណទស្សនៈនោះ ឈ្មោះថាជាបច្ច័យដល់សេចក្តីរលត់អស់មិនមានបច្ច័យ ព្រោះកាលវិមុត្តិញាណទស្សនៈ ដែលយោគាវចរសម្រេចដោយលំដាប់ហើយ កិលេសនិងកងទុក្ខ គប្បីរលត់អស់ពិតប្រាកដដូច្នេះឯង ។

ពីរបទថា **ឯតទត្ថា កថា : ការពោលនូវព្រះវិន័យមានអរហត្តផល ឬនិព្វានទុំះជាប្រយោជន៍** មានសេចក្តីថា ធម្មតាវិន័យកថានេះ មានអនុបាទាបរិនិព្វាននោះ ជាប្រយោជន៍ ។ ការប្រឹក្សាវិន័យនុ៎ះឯង ឈ្មោះថា **មន្តនា** : ការប្រឹក្សា ។

បទថា **ឧបនិសា : ការពិចារណា** មានសេចក្តីថា សូម្បីភាពជាធម៌ជាបច្ច័យបន្តគ្នាទៅជាដើមថា វិន័យដើម្បីប្រយោជន៍ដល់សំវរៈនេះ ក៏ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាននោះ ។ សេចក្តីផ្ទៀងសោតៈស្តាប់ពាក្យដែលជាបច្ច័យបន្តគ្នាទៅនេះ ឈ្មោះថា សេចក្តីផ្ទៀងសោតៈស្តាប់ ។ ញាណណាកើតឡើងព្រោះបានស្តាប់សេចក្តីនេះ ញាណសូម្បី

នោះ ក៏ដើម្បីប្រយោជន៏ដល់អនុបាទាបរិនិព្វាននោះ ។

ច្រើនបទថា **យទិទំ អនុបាទា ចិត្តស្ស វិមោក្ខោ : ព្រះអរហត្តផល ឬនិព្វានជាគ្រឿងរួចចាកសេចក្ដីសៅហ្មង់នៃចិត្ត ព្រោះមិនមានឧបាទានជាគ្រឿងប្រកាន់ណា** មានសេចក្ដីថា សេចក្ដីផុតពិសេសនៃចិត្ត ព្រោះមិនប្រកាន់មាំដោយឧបាទាន ៤ ពោលគឺ អរហត្តផលនេះ, សេចក្ដីផុតពិសេសនៃចិត្ត សូម្បីនោះក៏ដើម្បីប្រយោជន៏នេះ គឺ ដើម្បីប្រយោជន៏ដល់បរិនិព្វានដែលមិនមានបច្ច័យទុំះឯង ។

## អនុយោគវត្តគាថា

[១៦៨] បណ្ដាអនុយោគវត្តគាថាទាំងឡាយ គាថាដើមមានសេចក្ដីដូចពោលហើយនុ៎ះឯង ។

ក្នុងពាក្យថា **វត្ថុំ វិបត្តឹ អាបត្តឹ និទានំ អាការអកោ-វិទោ បុព្វាបរំ ន ជានាតិ :** ភិក្ខុណាមិនស្គាល់វត្ថុផង មិនស្គាល់វិបត្តិផង មិនស្គាល់អាបត្តិផង មិនស្គាល់និទានផង មិនឈ្លាសក្នុងអាការគឺហេតុនិងមិនមែនហេតុផង មិនស្គាល់ពាក្យខាងដើម និងពាក្យខាងចុងផង គប្បីធ្វើការភ្ជាប់បទថា **វត្ថុំ** ជាដើម ដោយបទថា **ន ជានាតិ** ។ គប្បីធ្វើការភ្ជាប់បទថា **អកោវិទោ** ដោយបទថា **ស វេតាទិសកោ**

នេះ ។ ព្រោះហេតុនោះ គប្បីជ្រាបថា វាចាគ្រឿងប្រកបក្នុងពាក្យថា **វត្ថុំ** ជាដើមនេះ ដូចតទៅនេះ៖

ភិក្ខុណា មិនស្គាល់វត្ថុនៃវីតិក្កមៈមានបារាជិកជាដើម, មិនដឹងវិបត្តិ ៤ យ៉ាង, មិនដឹងអាបត្តិ ៧ យ៉ាង, មិនដឹងនិទានយ៉ាងនេះថា សិក្ខាបទនេះទ្រង់បញ្ញត្តិហើយ ក្នុងនគរឈ្មោះឯណោះ, មិនស្គាល់ខាងដើមនិងខាងចុងថា នេះជាពាក្យមុន នេះជាពាក្យក្រោយ, មិនស្គាល់កម្មដែលធ្វើហើយ ឬមិនទាន់បានធ្វើ ថានេះធ្វើហើយ នេះមិនទាន់បានធ្វើ ។

ក្នុងបទថា **សមេន ច : ដោយស្មើផង** មានពាក្យអធិប្បាយថា មិនស្គាល់កម្មដែលធ្វើហើយ ឬមិនទាន់បានធ្វើ ដោយសេចក្តីមិនដឹងជានិច្ចរបស់ភិក្ខុមិនដឹងខាងដើម និងខាងចុងនោះឯង ។ គប្បីជ្រាបការភ្ជាប់នឹងបទថា **ន ជានាតិ** យ៉ាងនេះមុន ។

ក៏ឯវិនិច្ឆ័យក្នុងពាក្យថា **អាការអកោវិទោ : ឈ្លាសក្នុងអាការៈ** ដែលព្រះមានព្រះភាគត្រាស់ទុកគប្បីជ្រាបដូច្នេះ ៖

បទថា **អាការអកោវិទោ** បានដល់ អ្នកមិនយល់ហេតុ និងមិនមែនហេតុ ។ ភិក្ខុណា មិនដឹងវត្ថុជាដើម និងមិនយល់អាការ, ភិក្ខុ

ដូច្នោះឯង ព្រះមានព្រះភាគត្រាស់ថា អ្នកមិនគួរជ្រើសរើសដោយប្រការដូច្នេះ ។

គប្បីធ្វើការភ្ជាប់បទសម្បីទាំងនេះថា **កម្មញ្ញុ អធិករណញ្ញុ** ដោយបទថា **ឆ ជាឆាតិ** នុ៎ះឯង ។

ក៏ឯវាចាសម្រាប់ប្រកបក្នុងពាក្យថា **កម្មញ្ញុ** ជាដើមនោះដូចតទៅនេះ ៖

ភិក្ខុណា មិនស្គាល់កម្ម និងមិនស្គាល់អធិករណ៍ យ៉ាងនោះឯង, ទាំងមិនយល់សមថៈ ៧ ប្រការផង, មួយទៀត ដែលមានតម្រេកហើយ ខឹងក្រោធហើយ និងវង្វេងហើយ ព្រោះកិលេសមានរាគៈជាដើម រមែងលំអៀងព្រោះខ្លាចដោយសេចក្ដីខ្លាច រមែងលំអៀងព្រោះខ្លៅ ដោយសេចក្ដីល្ងង់, មួយទៀត ព្រោះហេតុដែលខ្លួនជាអ្នកមានតម្រេក និងព្រោះហេតុដែលខ្លួនជាអ្នកខឹងក្រោធ ទើបលំអៀងព្រោះសេចក្ដីពេញចិត្ត ព្រោះសេចក្ដីស្អប់ ។

មួយទៀត មិនជាអ្នកឆ្លាតក្នុងបញ្ញត្តិទេ ព្រោះមិនជាអ្នកអាចនឹងញុំាងអ្នកដទៃឲ្យយល់ព្រម ។ មួយទៀត មិនឆ្លាតក្នុងការគូសបញ្ជាក់ ព្រោះជាអ្នកមិនអាចក្នុងការចង្អុលហេតុ នឹងមិនមែនហេតុ ។ ឈ្មោះថា

អ្នកបានបក្ខពួក ព្រោះបានបរិស័ទជាបក្ខពួកខ្លួន, ឈ្មោះថា អ្នកមិនមានសេចក្ដីខ្មាស ព្រោះជាអ្នកឆ្ងាយចាកហិរិ, ឈ្មោះថា អ្នកមានកម្មខ្មៅ ព្រោះជាអ្នកព្រមព្រៀងដោយកម្មខ្មៅទាំងឡាយ, ឈ្មោះថា អ្នកមិនអើពើ ព្រោះមិនមានសេចក្ដីអើពើក្នុងធម៌ និងសេចក្ដីអើពើក្នុងបុគ្គល ។ ភិក្ខុមាន-សភាពបែបនោះឯង ព្រះមានព្រះភាគត្រាស់ថា អ្នកមិនគួរជ្រើសរើស។ គឺ សង្ឃមិនគួរពិចារណា បានដល់ មិនគួរក្រឡេកមើល, អធិប្បាយថា មិនគួរសន្មតតាំងទុកក្នុងតំណែងជាអ្នកធំ ដោយភាពជាឥស្សរិយាធិបតី។ យោជនាន័យ សូម្បីនៃគាថាចំណែកស ក៏គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។

*(អដ្ឋកថា គម្ពីរបរិវារៈ)*

**ចូឡសង្គាមវណ្ណនា ចប់**

# មហាសង្គ្រាម

ភិក្ខុអ្នកចូលទៅកាន់សង្គ្រាម កាលបើនិយាយក្នុងជំនុំសង្ឃ ត្រូវស្គាល់វត្ថុ ស្គាល់វិបត្តិ ស្គាល់អាបត្តិ ស្គាល់និទាន ស្គាល់អាការៈ ស្គាល់ពាក្យខាងដើម នឹងពាក្យខាងចុង ស្គាល់កម្មដែលគួរធ្វើនឹងមិនគួរធ្វើ ស្គាល់កម្ម ស្គាល់អធិករណ៍ ស្គាល់សមថៈ កុំលុះឆន្ទាគតិ កុំលុះទោសាគតិ កុំលុះមោហាគតិ កុំលុះភយាគតិ ត្រូវពន្យល់អ្នកដទៃឲ្យយល់ព្រមក្នុងទីដែលគួរឲ្យយល់ ត្រូវពិចារណាហេតុនឹងមិនមែនហេតុ ក្នុងទីដែលគួរពិចារណា សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល ត្រូវញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទីដែលគួរឲ្យជ្រះថ្លា កុំគប្បីមើលងាយពួកជនដទៃដោយគិតថា អាត្មាអញបានបក្ខពួកហើយ កុំមើលងាយអ្នកចេះដឹងតិចដោយគិតថា អាត្មាអញជាអ្នកចេះដឹងច្រើន កុំមើលងាយភិក្ខុខ្ចីដោយគិតថា អាត្មាអញជាថេរៈចាស់ជាង កុំពោលនូវហេតុដែលមិនទាន់មកដល់ កុំញុំាំងហេតុដែលមកដល់ហើយឲ្យវិនាសចាកធម៌ចាកវិន័យ អធិករណ៍នោះរម្ងាប់ដោយធម៌ណាដោយវិន័យណា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាណា គប្បីរម្ងាប់អធិករណ៍នោះ ដោយធម៌ជាដើមនោះៗចុះ ។

[១៧១] ពាក្យថា ត្រូវស្គាល់វត្ថុ គឺត្រូវស្គាល់វត្ថុនៃបារាជិក ៨ ស្គាល់វត្ថុនៃសង្ឃាទិសេស ២៣ ស្គាល់វត្ថុនៃអនិយតៈ ២ ស្គាល់វត្ថុនៃ

និស្សគ្គិយៈ ៤២ ស្គាល់វត្ថុនៃបាចិត្តិយៈ ១៨៨ ស្គាល់វត្ថុនៃបាដិទេសនីយៈ ១២ ស្គាល់វត្ថុនៃទុក្កដទាំងឡាយ ស្គាល់វត្ថុនៃទុព្ភាសិតទាំងឡាយ ។

[១៧២] ពាក្យថា ត្រូវស្គាល់វិបត្តិ គឺត្រូវស្គាល់សីលវិបត្តិ ស្គាល់អាចារៈវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិ ស្គាល់អាជីវៈវិបត្តិ ។

[១៧៣] ពាក្យថា ត្រូវស្គាល់អាបត្តិ គឺត្រូវស្គាល់អាបត្តិបារាជិក ស្គាល់អាបត្តិសង្ឃាទិសេស ស្គាល់អាបត្តិថុល្លច្ច័យ ស្គាល់អាបត្តិបាចិត្តិយៈ ស្គាល់អាបត្តិបាដិទេសនីយៈ ស្គាល់អាបត្តិទុក្កដ ស្គាល់អាបត្តិទុព្ភាសិត ។

[១៧៤] ពាក្យថា ត្រូវស្គាល់និទាន គឺត្រូវស្គាល់និទានរបស់បារាជិកទាំង ៨ ស្គាល់និទានរបស់សង្ឃាទិសេសទាំង ២៣ ស្គាល់និទានរបស់អនិយតៈទាំង ២ ស្គាល់និទានរបស់និស្សគ្គិយៈទាំង ៤២ ស្គាល់និទានរបស់បាចិត្តិយៈ ១៨៨ ស្គាល់និទានរបស់បាដិទេសនីយៈទាំង ១២ ស្គាល់និទានរបស់ទុក្កដទាំងឡាយ ស្គាល់និទានរបស់ទុព្ភាសិតទាំងឡាយ ។

[១៧៥] ពាក្យថា ត្រូវស្គាល់អាការៈ គឺត្រូវស្គាល់សង្ឃដោយអាការៈ ស្គាល់គណៈដោយអាការៈ ស្គាល់បុគ្គលដោយអាការៈ ស្គាល់អ្នកចោទដោយអាការៈ ស្គាល់អ្នកជាប់ចោទដោយអាការៈ ។ ពាក្យថា ត្រូវស្គាល់សង្ឃដោយអាការៈ គឺ ត្រូវស្គាល់សង្ឃដោយអាការៈយ៉ាងនេះថា សង្ឃនេះអាចរម្ងាប់អធិករណ៍នេះតាមធម៌តាមវិន័យ តាមពាក្យប្រៀន-

ប្រដៅរបស់ព្រះសាស្តា ឬមិនអាចរម្ងាប់បានទេ ។ ពាក្យថា ត្រូវស្គាល់គណៈដោយអាការៈ គឺ ស្គាល់គណៈដោយអាការៈយ៉ាងនេះថា គណៈនេះអាចនឹងរម្ងាប់អធិករណ៍នេះ តាមធម៌តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ឬមិនអាចរម្ងាប់បានទេ ។ ពាក្យថា ត្រូវស្គាល់បុគ្គលដោយអាការៈ គឺ ស្គាល់បុគ្គលដោយអាការៈយ៉ាងនេះថា បុគ្គលនេះអាចនឹងរម្ងាប់អធិករណ៍នេះតាមធម៌តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ឬ មិនអាចរម្ងាប់បានទេ ។ ពាក្យថា ត្រូវស្គាល់អ្នកចោទដោយអាការៈ គឺ ស្គាល់អ្នកចោទដោយអាការៈយ៉ាងនេះថា លោកដ៏មានអាយុនេះ តម្កល់នៅក្នុងធម៌ទាំង ៥ ទើបចោទបុគ្គលដទៃ ឬមិនបានតម្កល់ទេ ។ ពាក្យថា ស្គាល់អ្នកជាប់ចោទដោយអាការៈ គឺ ស្គាល់អ្នកជាប់ចោទដោយអាការៈយ៉ាងនេះថា លោកដ៏មានអាយុនេះ តម្កល់នៅក្នុងធម៌ទាំង ២ គឺ សច្ចៈវាចា ១ អកុប្បធម៌ ១ ឬមិនបានតម្កល់ទេ ។

[១៣៦] ពាក្យថា ត្រូវស្គាល់ពាក្យខាងដើម នឹងពាក្យខាងចុង គឺ ត្រូវស្គាល់ពាក្យខាងដើម នឹងពាក្យខាងចុងយ៉ាងនេះថា លោកដ៏មានអាយុនេះកន្លងនូវវត្ថុដោយវត្ថុផង កន្លងនូវវិបត្តិដោយវិបត្តិផង កន្លងនូវអាបត្តិដោយអាបត្តិផង គេចកែហើយប្តេជ្ញាផង ប្តេជ្ញាហើយគេចកែផង បំពាននូវពាក្យដទៃដោយពាក្យដទៃផង ឬមិនបានកន្លងគេចកែបំពានទេ។

[១៧៧] ពាក្យថា ត្រូវស្គាល់កម្មដែលគួរធ្វើនឹងមិនគួរធ្វើ គឺត្រូវមេថុនធម្ម ស្គាល់អនុលោមរបស់មេថុនធម្ម ស្គាល់បុព្វភាគ (ចំណែកខាងដើម) របស់មេថុនធម្ម ។ ពាក្យថា ត្រូវស្គាល់មេថុនធម្ម គឺត្រូវស្គាល់ការជួបប្រសព្វរបស់ជនពីរៗនាក់ ។ ពាក្យថា ត្រូវស្គាល់អនុលោមរបស់មេថុនធម្ម គឺ បានដល់ ភិក្ខុបៀមអង្គជាតរបស់ភិក្ខុដទៃ ដោយមាត់របស់ខ្លួន ។ ពាក្យថា ត្រូវស្គាល់បុព្វភាគរបស់មេថុនធម្ម គឺត្រូវស្គាល់ទឹកសុក្កៈមានពណ៌ នឹងមិនមានពណ៌ ការចាប់ពាល់កាយស្រី និយាយពាក្យអាក្រក់ចំពោះទ្វារមគ្គស្រី និយាយល្បួងស្រ្តីឱ្យបំរើខ្លួនដោយកាម និយាយដឹកនាំបុរសនឹង ស្រីឱ្យបានគ្នាជាប្តីប្រពន្ធ (សិក្ខាបទទាំង ៥ នេះជាបុព្វភាគរបស់មេថុនធម្ម) ។

[១៧៨ ] ពាក្យថា ត្រូវស្គាល់កម្ម គឺត្រូវស្គាល់កម្ម ១៦ យ៉ាងគឺ ស្គាល់អបលោកនកម្ម ៤ ស្គាល់ញត្តិកម្ម ៤ ស្គាល់ញត្តិទុតិយកម្ម ៤ ស្គាល់ញត្តិចតុត្ថកម្ម ៤ ។

[១៧៩ ] ពាក្យថា ត្រូវស្គាល់អធិករណ៍ គឺ ត្រូវស្គាល់អធិករណ៍ទាំង ៤ យ៉ាងគឺ ស្គាល់វិវាទាធិករណ៍ ១ ស្គាល់អនុវាទាធិករណ៍ ១ ស្គាល់អាបត្តាធិករណ៍ ១ ស្គាល់កិច្ចាធិករណ៍ ១ ។

[១៨០] ពាក្យថា ត្រូវស្គាល់សមថៈ គឺត្រូវស្គាល់សមថៈ ៧ យ៉ាង

គឺត្រូវស្គាល់សម្មុខាវិន័យ ១ ស្គាល់សតិវិន័យ ១ ស្គាល់អមូឡ្ហវិន័យ ១ ស្គាល់បដិញ្ញាតករណៈ ១ ស្គាល់យេភុយ្យសិកា ១ ស្គាល់តស្សបាបិយ-សិកា ១ ស្គាល់តិណវត្ថារកៈ ១ ។

[១៨១] ពាក្យថា កុំលុះឆន្ទាគតិ សេចក្ដីថា ភិក្ខុដែលលុះឆន្ទាគតិ តើលុះឆន្ទាគតិដូចម្ដេច ។ ភិក្ខុជាវិន័យធរពួកខ្លះ ក្នុងសាសនានេះ យោគយល់ថា បុគ្គលនេះជាឧបជ្ឈាយ៍ឬអាចារ្យ ជាសទ្ធិវិហារិកឬអន្តេ-វាសិក ជាភិក្ខុមានឧបជ្ឈាយ៍ស្មើគ្នា ឬភិក្ខុដែលមានអាចារ្យស្មើគ្នា ជាមិត្តធ្លាប់ឃើញគ្នាម្ដងៗ ឬជាមិត្តធ្លាប់ស្និទ្ធស្នាលគ្នាមាំ ពុំនោះជាញាតិសា-លោហិតរបស់អាត្មាអញ ដូច្នេះហើយក៏សម្ដែងនូវសភាវៈមិនមែនជាធម៌ថាជាធម៌ សម្ដែងនូវធម៌ថាមិនមែនធម៌ សម្ដែងនូវសភាវៈមិនមែនវិន័យថាជាវិន័យ សម្ដែងនូវវិន័យថាមិនមែនជាវិន័យ សម្ដែងនូវពាក្យដែលព្រះតថាគតមិនបានសំដែងមិនបានពោលថា ជាពាក្យដែលព្រះតថាគតបានសម្ដែងបានពោល សម្ដែងនូវពាក្យដែលព្រះតថាគតបានសំដែងបានពោលថា ជាពាក្យដែលព្រះតថាគតមិនបានសម្ដែងមិនបានពោល សម្ដែងនូវកិច្ចវត្តដែលព្រះតថាគតមិនបានសន្សំមក ថាព្រះតថាគតធ្លាប់សន្សំមក សម្ដែងនូវកិច្ចវត្តដែលព្រះតថាគតធ្លាប់សន្សំមកថាព្រះតថាគតមិនបានសន្សំមក សម្ដែងនូវសិក្ខាបទដែលព្រះតថាគតមិនបានបញ្ញត្តិ ថាព្រះ-

តថាគតបានបញ្ញត្តិ សម្តែងនូវសិក្ខាបទដែលព្រះតថាគតបានបញ្ញត្តិ ថាព្រះតថាគតមិនបានបញ្ញត្តិ សម្តែងនូវអនាបត្តិថាជាអាបត្តិ សម្តែងនូវអាបត្តិថាជាអនាបត្តិ សម្តែងនូវលហុកាបត្តិថាជាគរុកាបត្តិ សម្តែងនូវគរុកាបត្តិថាជាលហុកាបត្តិ សម្តែងនូវសាវសេសាបត្តិ ថាជាអនវសេ-សាបត្តិ សម្តែងនូវអនវសេសាបត្តិ ថាជាសាវសេសាបត្តិ សម្តែងនូវទុដ្ឋុល្លាបត្តិថាជាអទុដ្ឋុល្លាបត្តិ សម្តែងនូវអទុដ្ឋុល្លាបត្តិថាជាទុដ្ឋុល្លាបត្តិ ដូច្នេះ ព្រោះអនុគ្រោះដល់បុគ្គលនោះៗ ព្រោះកិរិយារក្សាដល់បុគ្គលនោះៗ ភិក្ខុជាវិន័យធរ កាលដែលលុះឆន្ទាគតិដោយវត្ថុទាំងឡាយ ១៨ ប្រការនេះ ក៏ឈ្មោះថា ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនជាសុខដល់ជនច្រើនគ្នា ដើម្បីមិនមែនជាសេចក្តីចម្រើនដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតានឹងមនុស្សទាំងឡាយ ភិក្ខុជាវិន័យធរ កាលបើលុះឆន្ទាគតិដោយវត្ថុទាំង ១៨ ប្រការនេះ ក៏ឈ្មោះថា រក្សាខ្លួនដែលមានកុសលធម៌ជីកគាស់រំលើងចោលចេញផង ឈ្មោះថា ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថា រងនូវអកុសលកម្មដ៏ច្រើនផង ភិក្ខុជាវិន័យធរកាលបើលុះឆន្ទាគតិ ក៏រមែងលុះទៅខាងឆន្ទាគតិ ដោយអាការៈយ៉ាងនេះ ។

[១៨២] ពាក្យថា កុំលុះទោសាគតិ សេចក្តីថា កាលដែលភិក្ខុជាវិន័យធរលុះទោសាគតិ តើលុះទោសាគតិដូចម្តេច ។ ភិក្ខុជាវិន័យធរពួកខ្លះក្នុងសាសនានេះ ចងគំនុំថា(បុគ្គលនេះ)បានប្រព្រឹត្តធ្វើនូវសេចក្តីវិនាសដល់អាត្មាអញ ចងគំនុំថា(បុគ្គលនេះ) កំពុងតែប្រព្រឹត្តធ្វើនូវកម្មមិនជាប្រយោជន៍ដល់អត្មាអញ ចងគំនុំថា (បុគ្គលនេះ)មុខជានឹងប្រព្រឹត្តធ្វើនូវកម្មមិនជាប្រយោជន៍ដល់អាត្មាអញ ចងគំនុំថា (បុគ្គលនេះ) បានប្រព្រឹត្តធ្វើនូវកម្មមិនជាប្រយោជន៍ កំពុងប្រព្រឹត្តធ្វើនូវកម្មមិនជាប្រយោជន៍មុខជានឹងប្រព្រឹត្តធ្វើនូវកម្មមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រលាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ចងគំនុំថា(បុគ្គលនេះ)បានប្រព្រឹត្តធ្វើនូវកម្មជាប្រយោជន៍ កំពុងប្រព្រឹត្តធ្វើនូវកម្មជាប្រយោជន៍ មុខជានឹងប្រព្រឹត្តធ្វើនូវកម្មជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រលាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ភិក្ខុជាវិន័យធរកាលបើចងគំនុំខឹង មានសេចក្តីក្រេវក្រោធគ្របសង្កត់ដោយអាឃាតវត្ថុទាំង៩ប្រការនេះហើយ រមែងសម្តែងនូវសភាវៈមិនមែនធម៌ថាជាធម៌ សម្តែងនូវធម៌ថាមិនមែនធម៌ ។បេ។ សម្តែងនូវទុដ្ឋុល្លាបត្តិថាជាអទុដ្ឋុល្លាបត្តិ សម្តែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិដូច្នេះ ព្រោះអនុគ្រោះដល់បុគ្គលនោះៗ ព្រោះកិរិយារក្សាដល់បុគ្គលនោះៗ ភិក្ខុជាវិន័យធរ កាលបើលុះទោសាគតិដោយវត្ថុទាំង

១៨ប្រការនេះ ក៏ឈ្មោះថា ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនមែនជាសុខដល់ជនច្រើនគ្នា ដើម្បីសេចក្ដីមិនចម្រើនដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខដល់ទេវតានឹងមនុស្សទាំងឡាយ ភិក្ខុជាវិន័យធរកាលបើលុះទៅខាងទោសាគតិ ដោយវត្ថុទាំង ១៨ ប្រការនេះ ក៏ឈ្មោះថា រក្សាខ្លួនដែលខ្លួនមានកុសលធម៌ជីកគាស់រំលើងចោលហើយផង ឈ្មោះថា ជាអ្នកប្រកបដោយទោសផងប្រកបដោយសេចក្ដីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថារងនូវអកុសលកម្មច្រើនផង ភិក្ខុជាវិន័យធរ កាលបើលុះទៅខាងទោសាគតិក៏រមែងលុះទៅខាងទោសាគតិ ដោយអាការៈយ៉ាងនេះ ។

[១៨៣] ពាក្យថា កុំគប្បីលំអៀងដោយមោហាគតិ សេចក្ដីថា ភិក្ខុជាវិន័យធរ កាលដែលលំអៀងដោយមោហាគតិ តើលំអៀងដោយមោហាគតិដូចម្ដេច ។ ភិក្ខុជាវិន័យធរមានចិត្តត្រេកអរ លុះដោយអំណាចរាគៈ មានចិត្តប្រទូស្ត លុះដោយអំណាចទោសៈ មានសេចក្ដីវង្វេង លុះដោយអំណាចមោហៈ មានទិដ្ឋិជាគ្រឿងស្ទាបអង្អែល លុះដោយអំណាចទិដ្ឋិ វង្វេងភាន់ភាំងស្មារតីត្រូវមោហៈគ្របសង្កត់ ក៏សម្ដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ សម្ដែងនូវធម៌ថាមិនមែនធម៌ ។ បេ ។ សម្ដែងនូវទុដ្ឋុល្លាបត្តិថាជាអទុដ្ឋុល្លាបត្តិ សម្ដែងនូវអទុដ្ឋុល្លាបត្តិ ថាជា

ទុដ្ឋុល្លាបត្តិ កាលបើភិក្ខុជាវិន័យធរ លំអៀងដោយមោហាគតិដោយវត្ថុ ១៨ប្រការនេះ ក៏ឈ្មោះថា ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនជាសុខដល់ជនច្រើនគ្នា ដើម្បីសេចក្តីមិនចម្រើនដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតានឹងមនុស្សទាំងឡាយ ភិក្ខុជាវិន័យធរកាលបើលំអៀងដោយមោហាគតិ ដោយវត្ថុទាំង១៨ប្រការនេះ ក៏ឈ្មោះថា រក្សាខ្លួនដែលខ្លួនមានកុសលធម៌ជីកគាស់រំលើងចោលហើយផង ឈ្មោះថា ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថា រងនូវអកុសលកម្មដ៏ច្រើនផង ភិក្ខុជាវិន័យធរ កាលលំអៀងដោយមោហាគតិ រមែងលំអៀងដោយមោហាគតិ ដោយអាការៈយ៉ាងនេះ ។

[១៨៤] ពាក្យថា កុំលំអៀងដោយភយាគតិ សេចក្តីថា ភិក្ខុដែលលំអៀងដោយភយាគតិ តើលំអៀងដោយភយាគតិដូចម្តេច ។ ភិក្ខុជាវិន័យធរពួកខ្លះក្នុងសាសនានេះគិតថា បុគ្គលនេះអាស្រ័យនូវកម្ម មានកាយកម្មជាដើមមិនស្មើក្តី អាស្រ័យនូវព្រៃស្បាត គឺ មិច្ឆាទិដ្ឋិនឹងអន្តគ្គាហិកទិដ្ឋិក្តី អាស្រ័យនូវភិក្ខុមានកម្លាំងក្តី ជាអ្នករឹងរូសអាក្រក់ នឹងធ្វើនូវសេចក្តីអន្តរាយដល់ជីវិតក្តី នូវសេចក្តីអន្តរាយដល់ព្រហ្មចរិយៈក្តី ហើយតក់ស្លុត ព្រោះខ្លាចបុគ្គលនោះ ក៏សម្តែងនូវសភាវៈមិនមែនធម៌ថាជាធម៌

សម្តែងនូវធម៌ថាមិនមែនធម៌ ។ បេ ។ សម្តែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សម្តែងនូវអទុដ្ឋុល្លាបត្តិថាជាទុដ្ឋុល្លាបត្តិ កាលបើភិក្ខុជាវិន័យធរលំអៀងដោយភយាគតិ ដោយវត្ថុទាំង ១៨ ប្រការនេះ ក៏ឈ្មោះថា ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនជាសុខដល់ជនច្រើនគ្នា ដើម្បីសេចក្តីមិនចម្រើនដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតានឹងមនុស្សទាំងឡាយ ភិក្ខុជាវិន័យធរ កាលបើលំអៀងដោយភយាគតិដោយវត្ថុទាំង ១៨ ប្រការនេះ ក៏ឈ្មោះថា រក្សាខ្លួនដែលមានកុសលធម៌ជីកគាស់រំលើងចោលហើយផង ឈ្មោះថា ជាបុគ្គលប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថារងនូវអកុសលកម្មច្រើនផង ភិក្ខុជាវិន័យធរកាលដែលលំអៀងដោយភយាគតិរមែងលំអៀងដោយភយាគតិដោយអាការៈយ៉ាងនេះ ។

[១៨៥] បុគ្គលណាប្រព្រឹត្តកន្លងនូវធម៌ ព្រោះសេចក្តីស្រលាញ់ព្រោះស្អប់ ព្រោះខ្លាច ព្រោះវង្វេង យសសក្តិ៍របស់បុគ្គលនោះឯង រមែងសាបសូន្យទៅ ដូចព្រះចន្ទក្នុងកាឡបក្ខ គឺខាងរនោច ។

[១៨៦_១៨៩] វិន័យធរដែលមិនមានអគតិ៤គប្បីជ្រាបដោយន័យផ្ទុយគ្នាចុះ ។

[១៩០] បុគ្គលណាមិនប្រព្រឹត្តកន្លងនូវធម៌ ព្រោះសេចក្តីស្រលាញ់ ព្រោះស្អប់ ព្រោះខ្លាច ព្រោះវង្វេង យសសក្តិ៍របស់បុគ្គលនោះឯង រមែងពេញបរិបូរណ៍ ដូចព្រះចន្ទក្នុងសុក្កប័ក្ខ គឺ ចំណែកខាងខ្នើត ។

[១៩១] សួរថា ភិក្ខុជាវិន័យធរពន្យល់ក្នុងទីដែលគួរពន្យល់នោះ តើដូចម្តេច ។ ឆ្លើយថា ភិក្ខុជាវិន័យធរ កាលសំដែងនូវសភាវៈមិនមែនធម៌ថាមិនមែនធម៌ ឈ្មោះថាពន្យល់ក្នុងទីដែលគួរពន្យល់ ។ កាលសំដែងនូវធម៌ថាធម៌ ឈ្មោះថាពន្យល់ក្នុងទីដែលគួរពន្យល់ ។ បេ ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិថាទុដ្ឋុល្លាបត្តិ ឈ្មោះថាពន្យល់ក្នុងទីដែលគួរពន្យល់ ។ កាលសំដែងនូវអទុដ្ឋុល្លាបត្តិថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថាពន្យល់ក្នុងទីដែលគួរពន្យល់ ។ ភិក្ខុជាវិន័យធរពន្យល់ក្នុងទីដែលគួរពន្យល់ ដោយអាការៈយ៉ាងនេះ ។

[១៩២] សួរថា ភិក្ខុជាវិន័យធរពិចារណាក្នុងទីដែលគួរពិចារណា តើដូចម្តេច ។ ឆ្លើយថា ភិក្ខុជាវិន័យធរ កាលសំដែងនូវសភាវមិនមែនធម៌ថាមិនមែនធម៌ ឈ្មោះថាពិចារណាក្នុងទីដែលគួរពិចារណា ។ កាលសំដែងនូវធម៌ថាធម៌ ឈ្មោះថាពិចារណាក្នុងទីដែលគួរពិចារណា ។ បេ ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិថាទុដ្ឋុល្លាបត្តិ ឈ្មោះថាពិចារណាក្នុងទីដែលគួរពិចារណា ។ កាលសំដែងនូវអទុដ្ឋុល្លាបត្តិថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថា

ពិចារណាក្នុងទីដែលគួរពិចារណា ។ ភិក្ខុពិចារណាក្នុងទីដែលគួរពិចា-
រណា ដោយអាការៈយ៉ាងនេះ ។

[១៩៣] សួរថា ភិក្ខុសំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល តើ
ដូចម្ដេច ។ ឆ្លើយថា ភិក្ខុកាលសំដែងឡើងនូវសភាវៈមិនមែនធម៌ថា
មិនមែនធម៌ ឈ្មោះថា សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល ។ កាល
សំដែងនូវធម៌ថាធម៌ ឈ្មោះថា សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល ។
បេ ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិថាទុដ្ឋុល្លាបត្តិ ឈ្មោះថា សំឡឹងមើល
ក្នុងទីដែលគួរសំឡឹងមើល ។ កាលសំដែងនូវអទុដ្ឋុល្លាបត្តិថាជាអទុដ្ឋុ-
ល្លាបត្តិ ឈ្មោះថា សំឡឹងមើលក្នុងទីដែលគួរសំឡឹងមើល ។ ភិក្ខុសំឡឹង
មើលក្នុងទីដែលគួរសំឡឹងមើលដោយអាការៈយ៉ាងនេះ។

[១៩៤] សួរថា ភិក្ខុញុំាងបុគ្គលដទៃឲ្យជ្រះថ្លា ក្នុងទីដែលគួរ
ជ្រះថ្លា តើដូចម្ដេច ។ ឆ្លើយថា ភិក្ខុកាលសំដែងនូវសភាវៈមិនមែនធម៌
ថាមិនមែនធម៌ ឈ្មោះថាញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា។
កាលសំដែងនូវធម៌ថាជាធម៌ ឈ្មោះថា ញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទី
ដែលគួរជ្រះថ្លា ។ បេ ។ កាលសំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ
ឈ្មោះថា ញុំាងបុគ្គលដទៃឲ្យជ្រះថ្លាក្នុងទីដែលគួរជ្រះថ្លា កាលសំដែង
នូវអទុដ្ឋុល្លាបត្តិថាជាអទុដ្ឋុល្លាបត្តិ ឈ្មោះថា ញុំាងបុគ្គលដទៃឲ្យជ្រះថ្លា

ក្នុងទីដែលគួរជ្រះថ្លា ។ ភិក្ខុញុំាងបុគ្គលដទៃឲ្យជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ដោយអាការៈយ៉ាងនេះ ។

[១៩៥] សួរថា ភិក្ខុមើលងាយនូវពួកភិក្ខុដទៃដោយគិតថា អាត្មាអញបានបក្ខពួកហើយតើដូចម្ដេច ។ ឆ្លើយថា ភិក្ខុពួកមួយក្នុងសាសនានេះ ជាអ្នកបានបក្ខពួក បានបរិវារ មានបក្ខពួក មានញាតិ ហើយមើលងាយបុគ្គលនោះថា បុគ្គលនេះមិនបានបក្ខពួក មិនបានបរិវារ គ្មានបក្ខពួក គ្មានញាតិទេ ក៏សំដែងនូវសភាវៈមិនមែនធម៌ថាធម៌ សំដែងនូវធម៌ថាមិនមែនធម៌ ។បេ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិថាជាទុដ្ឋុល្លាបត្តិ មើលងាយនូវបក្ខពួកដទៃ ដោយគិតថា អាត្មាអញបានបក្ខពួកដោយអាការៈយ៉ាងនេះ ។

[១៩៦] សួរថា ភិក្ខុមើលងាយនូវបុគ្គលដែលចេះដឹងតិច ដោយគិតថា អាត្មាអញជាអ្នកចេះដឹងច្រើនតើដូចម្ដេច ។ ឆ្លើយថា ភិក្ខុពួកមួយក្នុងសាសនានេះ ជាអ្នកចេះដឹងច្រើន ចាំនូវសុតៈ សន្សំនូវសុតៈ រមែងមើលងាយបុគ្គលអ្នកចេះដឹងតិចនោះថា បុគ្គលនេះស្ដាប់តិច ជាអ្នកចេះដឹងនិកាយតិច ចាំតិច ក៏សំដែងនូវសភាវៈមិនមែនធម៌ ថាជាធម៌ សំដែងនូវធម៌ថាមិនមែនធម៌ ។បេ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុមើលងាយនូវបុគ្គលដែល

ចេះដឹងតិច ដោយគិតថា អាត្មាអញជាអ្នកចេះដឹងច្រើន ដោយអាការៈយ៉ាងនេះ ។

[១៩៧] សួរថា ភិក្ខុមើលងាយភិក្ខុដែលខ្ចីជាង ដោយគិតថា អាត្មាអញជាថេរៈចាស់ជាង តើដូចម្ដេច ។ ឆ្លើយថា ភិក្ខុពួកមួយក្នុងសាសនានេះជាថេរៈ ជាអ្នកដឹងរាត្រី (វែង) បួសមកជាយូរហើយ រមែងមើលងាយភិក្ខុខ្ចីនោះថា ភិក្ខុនេះនៅខ្ចីមិនសូវល្បីល្បាញ ជាអ្នកចេះដឹងតិច មិនចេះច្បាប់ទម្លាប់ អាត្មាអញនឹងមិនធ្វើតាមពាក្យរបស់ភិក្ខុនេះទេ ដូច្នេះក៏សំដែងនូវសភាវៈមិនមែនធម៌ថាជាធម៌ សំដែងនូវធម៌ថាមិនមែនធម៌ ។ បេ ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុមើលងាយភិក្ខុខ្ចីជាងដោយគិតថា អាត្មាអញជាថេរៈចាស់ជាង ដោយអាការៈយ៉ាងនេះ ។

[១៩៨] ពាក្យថា កុំពោលនូវហេតុដែលមិនទាន់មកដល់ គឺកុំនិយាយនូវពាក្យដែលមិនទាន់ធ្លាក់ដល់មក ។ ពាក្យថា កុំគប្បីញុាំងហេតុដែលមកដល់ហើយ ឲ្យសាបសូន្យចាកធម៌ចាកវិន័យ គឺបានដល់សង្ឃដែលប្រជុំគ្នាដោយសេចក្ដីណា កុំញុាំងសេចក្ដីនោះឲ្យសាបសូន្យចាកធម៌ ចាកវិន័យឡើយ ។

[១៩៩] ពាក្យថា ដោយធម៌ណា គឺដោយវត្ថុដែលពិតប្រាកដ ។

ពាក្យថា ដោយវិន័យណា គឺដះតឿនគ្រើនរំលឹក ។ ពាក្យថា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាណា គឺដោយញត្តិសម្បទា នឹងអនុស្សាវនសម្បទា ។ ពាក្យថា អធិករណ៍រម្ងាប់ដោយធម៌ណា ដោយវិន័យណា ដោយពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាណា គប្បីរម្ងាប់អធិករណ៍នោះដោយធម៌នោះៗ សេចក្តីថា វិន័យធរគប្បីសួរអ្នកចោទថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនោះដោយហេតុណា លោកឃាត់បវារណានោះដោយហេតុអ្វី លោកឃាត់ដោយសីលវិបត្តិ ឬឃាត់ដោយអាចារៈវិបត្តិ ឬក៏ឃាត់ដោយទិដ្ឋិវិបត្តិ ។ បើអ្នកចោទនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំឃាត់ដោយសីលវិបត្តិផង ឃាត់ដោយអាចារៈវិបត្តិ ឃាត់ដោយទិដ្ឋិវិបត្តិផង ។ វិន័យធរត្រូវនិយាយនឹងភិក្ខុអ្នកចោទនោះយ៉ាងនេះថា ចុះលោកដ៏មានអាយុស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរឬ ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំស្គាល់សីលវិបត្តិ ស្គាល់អាចារវិបត្តិ ស្គាល់ទិដ្ឋិវិបត្តិដែរ ។ វិន័យធរត្រូវសួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ ចុះសីលវិបត្តិដូចម្តេច អាចារៈវិបត្តិដូចម្តេច ទិដ្ឋិវិបត្តិដូចម្តេច ។ បើភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា បារាជិក ៤ សង្ឃាទិសេស ១៣ នេះហៅថាសីលវិបត្តិ ថុល្លច្ច័យ បាចិត្តិយៈ បាដិទេសនីយៈ ទុក្កដ ទុព្ភាសិត នេះហៅថា

អាចារវិបត្តិ មិច្ឆាទិដ្ឋិ នឹងអន្តគ្គាហិកទិដ្ឋិ នេះហៅថា ទិដ្ឋិវិបត្តិ ។ វិន័យធរត្រូវសួរភិក្ខុអ្នកចោទយ៉ាងនេះថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនេះដោយហេតុណា លោកឃាត់ដោយបានឃើញ ឬឃាត់ដោយបានឮ ឬក៏ឃាត់ដោយបានរង្កៀស ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ខ្ញុំឃាត់ដោយបានឃើញផង ឃាត់ដោយបានឮផង ឃាត់ដោយបានរង្កៀសផង ។ វិន័យធរត្រូវសួរភិក្ខុអ្នកចោទយ៉ាងនេះថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនេះដោយបានឃើញ ដោយហេតុណា លោកបានឃើញដូចម្តេចខ្លះ លោកបានឃើញអំពីហេតុដូចម្តេច លោកបានឃើញពីកាលណា លោកបានឃើញក្នុងទីណា កាលភិក្ខុនេះត្រូវអាបត្តិបារាជិកលោកបានឃើញដែរឬ កាលត្រូវសង្ឃាទិសេស លោកបានឃើញដែរឬ កាលត្រូវថុល្លច្ច័យ លោកបានឃើញដែរឬ កាលត្រូវបាចិត្តិយៈ លោកបានឃើញដែរឬ កាលត្រូវបាដិទេសនីយៈ លោកបានឃើញដែរឬ កាលត្រូវទុក្កដ លោកបានឃើញដែរឬ កាលត្រូវទុព្ភាសិត លោកបានឃើញដែរឬ ចុះលោកនៅក្នុងទីណា ចំណែកភិក្ខុនេះនៅត្រង់ទីណា លោកកំពុងធ្វើអ្វី ភិក្ខុនេះកំពង់ធ្វើអ្វី ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនបានឃាត់បវារណារបស់ភិក្ខុនេះដោយបានឃើញទេ ខ្ញុំឃាត់បវារណាដោយគ្រាន់តែបានឮទេ ។ វិន័យធរត្រូវ

សួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ អ្នកឃាត់បវារណារបស់ភិក្ខុនេះ ដោយបានឮដោយហេតុណា លោកបានឮដូចម្តេចខ្លះ លោកបានឮដោយហេតុដូចម្តេច លោកបានឮពីកាលណា លោកបានឮក្នុងទីណា លោកបានឮថាភិក្ខុនេះត្រូវបារាជិក ឬលោកបានឮថាភិក្ខុនេះត្រូវ សង្ឃា-ទិសេស លោកបានឮថាភិក្ខុនេះត្រូវថុល្លច្ច័យ លោកបានឮថាភិក្ខុនេះត្រូវបាចិត្តិយៈ លោកបានឮថាភិក្ខុនេះត្រូវបាដិទេសនីយៈ លោកបានឮថាភិក្ខុនេះត្រូវទុក្កដ លោកបានឮថាភិក្ខុនេះត្រូវទុព្ភាសិត លោកបានឮពាក្យភិក្ខុ លោកបានឮពាក្យភិក្ខុនី លោកបានឮពាក្យសិក្ខមានា លោកបានឮពាក្យសាមណេរ លោកបានឮពាក្យសាមណេរី លោកបានឮពាក្យឧបាសក លោកបានឮពាក្យឧបាសិកា លោកបានឮព្រះបន្ទូលនៃពួកស្តេច លោកបានឮពាក្យនៃពួករាជមហាមាត្រ លោកបានឮពាក្យនៃពួកតិរ្ថិយ ឬបានឮពាក្យនៃពួកសាវ័ករបស់តិរ្ថិយ ។ បើភិក្ខុអ្នកចោទនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនបានឃាត់បវារណារបស់ភិក្ខុនេះដោយបានឮទេ ខ្ញុំឃាត់បវារណាដោយ គ្រាន់តែរង្កៀសទេ ។ វិន័យធរត្រូវសួរភិក្ខុអ្នកចោទនោះយ៉ាងនេះថា ម្នាលអាវុសោ លោកឃាត់បវារណារបស់ភិក្ខុនេះដោយរង្កៀសដោយហេតុណា លោករង្កៀសដោយហេតុដូចម្តេចខ្លះ លោករង្កៀសអំពីហេតុដូចម្តេច លោករង្កៀសពីកាលណា លោករង្កៀសក្នុងទី

ណា លោករង្កៀសថាភិក្ខុនេះត្រូវបារាជិក ឬលោករង្កៀសថា ភិក្ខុនេះត្រូវសង្ឃាទិសេស លោករង្កៀសថាភិក្ខុនេះត្រូវថុល្លច្ច័យ លោករង្កៀសថាភិក្ខុនេះត្រូវបាចិត្តិយៈ លោករង្កៀសថាភិក្ខុនេះត្រូវបាដិទេសនីយៈ លោករង្កៀសថាភិក្ខុនេះត្រូវទុក្កដ លោករង្កៀសថាភិក្ខុនេះត្រូវទុព្ភាសិត លោករង្កៀសព្រោះពុំពាក្យភិក្ខុ លោករង្កៀសព្រោះពុំពាក្យភិក្ខុនី លោករង្កៀសព្រោះពុំពាក្យសិក្ខមានា លោករង្កៀសព្រោះពុំពាក្យសាមណេរ លោករង្កៀសព្រោះពុំពាក្យសាមណេរី លោករង្កៀសព្រោះពុំពាក្យឧបាសក លោករង្កៀសព្រោះពុំពាក្យឧបាសិកា លោករង្កៀសព្រោះពុំព្រះបន្ទូលនៃពួកស្តេច លោករង្កៀសព្រោះពុំពាក្យនៃពួកមហាមាត្ររបស់ស្តេច លោករង្កៀសព្រោះពុំពាក្យនៃពួកតិរ្ថិយ ឬលោករង្កៀសព្រោះពុំពាក្យពួកសាវ័កនៃតិរ្ថិយ។

[២០០] ហេតុដែលអ្នកចោទបានឃើញ សមដោយហេតុដែលបានឃើញមែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលអ្នកចោទបានឃើញដោយហេតុដែលបានឃើញ (នោះ) ភិក្ខុអ្នកជាប់ចោទ មិនទាន់ដល់ (បារាជិក) ព្រោះអាស្រ័យនូវហេតុ ដែលអ្នកចោទបានឃើញនៅឡើយទេ ឈ្មោះថា អ្នកចោទមានសេចក្តីរង្កៀសមិនបរិសុទ្ធ (រង្កៀសគ្មានមូល) វិន័យធរ គប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញារបស់បុគ្គល គឺ ភិក្ខុជាអ្នកជាប់ចោទ

នោះ ហើយធ្វើបវារណាជាមួយនឹងភិក្ខុនោះចុះ ។ ហេតុដែលអ្នកចោទបានឮសមដោយហេតុដែលបានឮមែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលអ្នកចោទបានឮ ដោយហេតុដែលបានឮ (នោះ) ភិក្ខុអ្នកជាប់ចោទនោះមិនទាន់ដល់(បារាជិក)ព្រោះអាស្រ័យនូវហេតុ ដែលអ្នកចោទបានឮនៅឡើយទេ ឈ្មោះថាអ្នកចោទមានសេចក្តីវង្វៀសមិនបរិសុទ្ធ វិន័យធរគប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញារបស់បុគ្គល គឺ ភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើបវារណាជាមួយនឹងភិក្ខុនោះចុះ ។ ហេតុដែលអ្នកចោទបានប៉ះ-ពាល់ សមដោយហេតុដែលបានប៉ះពាល់មែន វិន័យធរគប្បីប្រៀបធៀបនូវហេតុដែលអ្នកចោទបានប៉ះពាល់ ដោយហេតុដែលបានប៉ះពាល់(នោះ) ភិក្ខុអ្នកជាប់ចោទនោះមិនទាន់ដល់ (បារាជិក) ព្រោះអាស្រ័យនូវហេតុដែលអ្នកចោទបានប៉ះពាល់នៅឡើយទេ ឈ្មោះថាអ្នកចោទមានសេចក្តីវង្វៀសមិនបរិសុទ្ធ វិន័យធរគប្បីវិនិច្ឆ័យតាមពាក្យប្តេជ្ញារបស់បុគ្គល គឺ ភិក្ខុអ្នកជាប់ចោទនោះ ហើយគប្បីធ្វើបវារណាជាមួយនឹងភិក្ខុនោះចុះ ។

[២០១] ត្រង់ពាក្យថា អ្នកបានឃើញដូចម្តេច គឺ បានដល់ពាក្យសួរថាដូចម្តេច ត្រង់ពាក្យថា អ្នកបានឃើញអំពីហេតុដូចម្តេច គឺបានដល់ពាក្យសួរថាដូចម្តេច ត្រង់ពាក្យថា អ្នកបានឃើញពីកាលណា គឺបានដល់ពាក្យសួរថាដូចម្តេច ត្រង់ពាក្យថា អ្នកបានឃើញក្នុងទីណា គឺបាន

ដល់ពាក្យសួរថាដូចម្តេច ។

[២០២] ត្រង់ពាក្យដែលថាបានឃើញដូចម្តេច គឺបានដល់វត្ថុបុច្ឆា ១ វិបត្តិបុច្ឆា ១ អាបត្តិបុច្ឆា ១ អជ្ឈាចារបុច្ឆា ១ ។ ត្រង់ពាក្យថាវត្ថុបុច្ឆា គឺបានដល់ពាក្យសួរអំពីវត្ថុនៃបារាជិក ៨ សួរវត្ថុនៃសង្ឃាទិសេស ២៣ សួរវត្ថុនៃអនិយតៈ ២ សួរវត្ថុនៃនិស្សគ្គិយៈ ៤២ សួរវត្ថុនៃបាចិត្តិយៈ ១៨៨ សួរវត្ថុនៃបាដិទេសនីយៈ ១២ សួរវត្ថុនៃទុក្កដទាំងឡាយ សួរវត្ថុនៃទុព្ភាសិតទាំងឡាយ ។ ត្រង់ពាក្យថា វិបត្តិបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីសីលវិបត្តិ សួរអំពីអាចារៈវិបត្តិ សួរអំពីទិដ្ឋិវិបត្តិ សួរអំពីអាជីវៈវិបត្តិ ។ ត្រង់ពាក្យថា អាបត្តិបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីអាបត្តិបារាជិក សួរអំពីអាបត្តិសង្ឃាទិសេស សួរអំពីអាបត្តិថុល្លច្ច័យ សួរអំពីអាបត្តិបាចិត្តិយៈ សួរអំពីអាបត្តិបាដិទេសនីយៈ សួរអំពីអាបត្តិទុក្កដ សួរអំពីអាបត្តិទុព្ភាសិត ។ ត្រង់ពាក្យថា អជ្ឈាចារបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីការប្រសព្វរបស់ជនពីរៗនាក់ ។

[២០៣] ត្រង់ពាក្យថា លោកបានឃើញអំពីហេតុដូចម្តេច គឺបានដល់លិង្គបុច្ឆា ១ ឥរិយាបថបុច្ឆា ១ អាការៈបុច្ឆា ១ វិប្បការបុច្ឆា ១ ។ ត្រង់ពាក្យថា លិង្គបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីភេទខ្ពស់ ឬទាប ខ្មៅ ឬស ។ ត្រង់ពាក្យថា ឥរិយាបថបុច្ឆានោះ គឺបានដល់ពាក្យសួរអំពី បុគ្គល

ដើរ ឬឈរ អង្គុយ ឬដេក ។ ត្រង់ពាក្យថា អាការៈបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីភេទគ្រហស្ថ ឬភេទតិរ្ថិយ ឬភេទបព្វជិត ។ ត្រង់ពាក្យថា វិប្បការបុច្ឆានោះ គឺបានដល់ ពាក្យសួរអំពីបុគ្គលកំពុងដើរ ឬឈរ កំពុងអង្គុយ ឬដេក ។

[២០៤] ត្រង់ពាក្យថា លោកបានឃើញពីកាលណា គឺបានដល់កាលបុច្ឆា ១ សមយបុច្ឆា ១ ទិវសបុច្ឆា ១ ឧតុបុច្ឆា ១ ។ ត្រង់ពាក្យថា កាលបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីពេលព្រឹក ឬពេលថ្ងៃត្រង់ ឬថ្ងៃរសៀល ។ ត្រង់ពាក្យថា សមយបុច្ឆា គឺបានដល់ពាក្យសួរអំពីសម័យព្រឹក ឬសម័យថ្ងៃត្រង់ ឬក៏សម័យថ្ងៃរសៀល ។ ត្រង់ពាក្យថា ទិវសបុច្ឆា គឺបានដល់ពាក្យសួរអំពីវេលាមុនភត្ត វេលាក្រោយភត្ត វេលាយប់ វេលាថ្ងៃ ខាងរនោច ឬខ្នើត ។ ត្រង់ពាក្យថា ឧតុបុច្ឆានោះ គឺ បានដល់ពាក្យសួរអំពី ហេមន្តរដូវ គិម្ហរដូវ ឬវស្សានរដូវ ។

[២០៥ ] ត្រង់ពាក្យថា លោកបានឃើញក្នុងទីណា គឺបានដល់ឋានបុច្ឆា ១ ភូមិបុច្ឆា ១ ឱកាសបុច្ឆា ១ បទេសបុច្ឆា ១ ។ ត្រង់ពាក្យថា ឋានបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីភូមិ ប្រឋពី ធរណី ឬផែនដី ។ ត្រង់ពាក្យថា ភូមិបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីភូមិ ភ្នំ ថ្ម ឬប្រាសាទ ។ ត្រង់ពាក្យថា ឱកាសបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីឱកាសខាងកើត

ឱកាសខាងលិច ឱកាសខាងជើង ឱកាសខាងត្បូង ។ ត្រង់ពាក្យថា បទេសបុច្ឆានោះ គឺបានដល់ពាក្យសួរអំពីប្រទេសខាងកើត ឬប្រទេសខាងលិច ប្រទេសខាងជើង ឬប្រទេសខាងត្បូង ។

*(គម្ពីរបរិវារ ១៣/១៩៩_២២៥)*

**មហាសង្គ្រាម ចប់**

# អដ្ឋកថា

វិនិច្ឆ័យក្នុងមហាសង្គ្រាម គប្បីជ្រាបដូច្នេះ ៖

[១៧៦] ត្រើនបទថា **វត្ថុតោ វា វត្ថុំ សង្កមតិ : កន្លងនូវវត្ថុដោយវត្ថុផង** មានសេចក្តីថា អ្នកចោទពោលថា វត្ថុនៃបឋមបារាជិក ដែលខ្ញុំបានឃើញហើយ ឬថាវត្ថុនៃបឋមបារាជិក ដែលខ្ញុំបានស្តាប់ហើយ កាត្រូវសួរ គឺ ត្រូវបង្ខំថែមទៀត ត្រឡប់ពោលថា វត្ថុនៃបឋមបារាជិក ខ្ញុំមិនបានឃើញ មិនបានឮ វត្ថុនៃទុតិយបារាជិក ដែលខ្ញុំបានឃើញហើយ ឬថាវត្ថុនៃទុតិយបារាជិក ដែលខ្ញុំបានឮហើយ ។ គប្បីជ្រាបការប្តូរវត្ថុដ៏សេស ការប្តូរវិបត្តិចាកពីវិបត្តិ និងការប្តូរអាបត្តិចាកអាបត្តិ ដោយន័យនេះឯង ។

ចំណែកភិក្ខុណាពោលថា ខ្ញុំមិនបានឃើញទេ មិនបានឮទេ ដូច្នេះហើយ ខាងក្រោយពោលថា រឿងនោះ សូម្បីខ្ញុំក៏បានឃើញ ឬថារឿងនោះ សូម្បីខ្ញុំក៏បានឮ ពោលថា ខ្ញុំបានឃើញ ឬថាខ្ញុំបានឮ ដូច្នេះហើយ ខាងក្រោយត្រឡប់ពោលថា ខ្ញុំមិនបានឃើញទេ មិនបានឮទេ ភិក្ខុនោះ គប្បីជ្រាបថា បដិសេធហើយត្រឡប់ប្តេជ្ញា ប្តេជ្ញាហើយត្រឡប់បដិសេធ ។ ភិក្ខុនេះឯង ឈ្មោះថា បង្វែនូវរឿងដទៃដោយរឿងដទៃ ។

[១៧៧] សុក្កវិស្សដ្ឋិសិក្ខាបទ ដោយអំណាចពណ៌មានពណ៌ខៀវជាដើម និងជាអ្នកមិនមានរោគ លោកពោលថា **វណ្ណា អវណ្ណា : ស្គាល់ទឹកសុក្ក:មានពណ៌ និងមិនមានពណ៌** ។ សញ្ចរិតសិក្ខាបទ លោកពោលថា **វណ្ណាមនុប្បាទនំ : និយាយដឹកនាំបុរសនិងស្ត្រីឲ្យបានគ្នាជាប្តីប្រពន្ធ** (ញុំាងការសូមឲ្យកើតឡើង ) ៣ សិក្ខាបទមានកាយសំសគ្គសិក្ខាបទជាដើម លោកពោលតាមរូបដើមនុ៎ះឯង ។ ៤ សិក្ខាបទនេះ គប្បីជ្រាបថា ជាបុព្វភាគ គឺបុព្វប្រយោគរបស់មេថុនធម្ម ដោយប្រការដូច្នេះ ។

[១៧៨] អបលោកនកម្ម ៤ នោះ បានដល់ កម្មជាពួក មិនប្រកបដោយធម៌ជាដើម ។ សូម្បីក្នុងកម្មដ៏សេស ក៏ន័យនេះឯង ។ ពួកបួន ៤ពួក ទើបរួមជា ១៦ ដោយប្រការដូច្នេះ ។

[១៨១] ច្រើនបទថា **ពហុជនាហិតាយ បដិបន្នោ ហោតិ: ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា** មានសេចក្តីថា ពិតមែនកាលអធិករណ៍ដែលព្រះវិន័យធរ វិនិច្ឆ័យដោយឆន្ទាគតិយ៉ាងនោះ សង្ឃក្នុងវត្តនោះរមែងបែកគ្នាជា ២ ពួក ។ សូម្បីភិក្ខុនីទាំងឡាយ ដែលអាស្រ័យឱវាទរស់នៅ ក៏រមែងជា ២ ពួក ។ ពួកឧបាសកក្តី ឧបាសិកាក្តី ក្មេងប្រុសក្តី ក្មេងស្រីក្តី រមែងជា២ពួក សូម្បីពួកអារក្ខទេវតារបស់ជន

ទាំងនោះ ក៏រមែងបែកគ្នាជា ២ ពួកដូចគ្នា ។ តពីនោះ ទេវតាទាំងឡាយរាប់ភុម្មទេវតាជាដើម ដរាបដល់អកនិដ្ឋព្រហ្ម រមែងចែកជា ២ ពួកដែរ ។ ដោយហេតុនោះ លោកទើបពោលថា ភិក្ខុដែលលំអៀងដោយឆន្ទាគតិជាដើម រមែងជាអ្នកបដិបត្តិដើម្បីមិនប្រយោជន៍ដល់ជនជាច្រើន ។ ល ។ ជាអ្នកបដិបត្តិ ដើម្បីមិនជាប្រយោជន៍ ដើម្បីមិនជាសុខ ដើម្បីទុក្ខ ដល់ជនជាច្រើន ទាំងទេវតា និងមនុស្សទាំងឡាយ ។

[១៨៤] បទថា **វិសមនិស្សិតោ : អាស្រ័យនូវកម្មមិនស្មើ** បានដល់ អ្នកអាស្រ័យកាយកម្មជាដើម ដែលមិនរៀបរយ ។

បទថា **គហននិស្សិតោ : អាស្រ័យនូវព្រៃស្បាត** បានដល់ អ្នកអាស្រ័យសេចក្ដីប្រកាន់ ពោលគឺ មិច្ឆាទិដ្ឋិ និងអន្តគាហិកទិដ្ឋិ ។

បទថា **ពលវនិស្សិតោ : អាស្រ័យនូវភិក្ខុដែលមានកម្លាំង** បានដល់ អ្នកអាស្រ័យភិក្ខុដែលមានឈ្មោះបោះសម្លេងដែលមានកម្លាំង ។

[១៩៥] ពីរបទថា **តស្ស អវជានន្តោ : ហើយមើលងាយបុគ្គលនោះ** បានដល់ មើលងាយពាក្យរបស់ភិក្ខុនោះ ។ ម្យ៉ាងទៀត បទថា **តស្ស** នោះ ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។ អធិប្បាយថា មើលងាយភិក្ខុនោះ ។

[១៩៨] ពីរបទថា **យំ អត្ថាយ : ដើម្បីសេចក្ដីណា** មានសេចក្ដីថា ដើម្បីប្រយោជន៍ណា ។

ពីរបទថា **តំ អត្ថំ : ញ៉ាំងសេចក្ដីនោះ** មានសេចក្ដីថា ប្រយោជន៍នោះ ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

**មហាសង្គាមវណ្ណនា ចប់**

## អង្គ ៥ របស់ភិក្ខុដែលពោលមិនជាទីស្រលាញ់

[១៥០] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលប្រកបដោយអង្គប៉ុន្មាន ពោលក្នុងកណ្ដាលជំនុំសង្ឃ នាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ ពោលក្នុងកណ្ដាលជំនុំសង្ឃ នាំមិនឲ្យជនច្រើនគ្នាត្រេកអរផង នាំមិនឲ្យជនច្រើនគ្នាគាប់ចិត្តផង នាំមិនឲ្យជនច្រើនគ្នាចូលចិត្តផង ។

អង្គ ៥ តើដូចម្ដេច ?

**ក_អង្គ ៥ គឺ**

_ភិក្ខុជាអ្នកនិយាយប្រកបដោយលោភៈជាដើម ១ ជាអ្នកពោលអាងអ្នកដទៃ ១ ជាអ្នកមិនឈ្លាសក្នុងភាសានឹងវិនិច្ឆ័យ ១ ជាអ្នកមិនចោទភិក្ខុផងគ្នាឲ្យសមគួរតាមធម៌ សមគួរតាមវិន័យ សមគួរតាមអាបត្តិ ១ ជាអ្នកមិនកាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ ។

**ខ_អង្គ ៥ ដទៃទៀតគឺ**

_ភិក្ខុជាអ្នកអួតអាងសរសើរលើកបុគ្គលដទៃ ១ ជាអ្នកផ្ចញ់ផ្ចាល់គេ ១ ប្រកាន់យកហេតុដែលមិនមែនជានិយ្យានិកធម៌ ១ ឃាត់ហេតុដែលជានិយ្យានិកធម៌ ១ និយាយពាក្យច្រើនឥតប្រយោជន៍ ១ ។

**គ_ អង្គ ៥ ដទៃទៀតគឺ**

_ភិក្ខុជាអ្នកនិយាយសង្កត់សង្កិន(ព្រោះអាស្រ័យមានះ) ១ មិនបានសូមឱកាសជាមុនក៏ស្រាប់តែនិយាយ ១ មិនចោទភិក្ខុដទៃឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ មិនកាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ ឲ្យសមគួរតាមអាបត្តិ ១ មិនព្យាករដោយសមគួរតាមសេចក្តីយល់របស់ខ្លួន ១ ។

ចំណែកអង្គ កាលនិយាយក្នុងកណ្ដាលជំនុំសង្ឃ តែងនាំឲ្យជនច្រើនគ្នាត្រេកអរផង នាំឲ្យជនច្រើនគ្នាពេញចិត្តផង នាំឲ្យជនច្រើនគ្នាចូលចិត្តផង ។ គប្បីជ្រាបដោយន័យដូចគ្នាពីអង្គខាងលើ ។

(គម្ពីរបរិវារៈ១៣/២៦៥_២៦៨)

## អដ្ឋកថា

[២៥០] បទថា **ឧស្សិតមន្តី ច : ភិក្ខុនិយាយពាក្យប្រកបដោយលោភៈជាដើម ១** មានសេចក្ដីថា អ្នកមានសេចក្ដីប្រាថ្នាច្រើន ច្រើនតែពោលវាចា ដែលក្រាស់ដោយលោភៈ ទោសៈ និងមានះ មានវាចាកខ្វក់ មិនសម្ដែងប្រយោជន៍ ។

បទថា **និស្សិតជប្បី : ជាអ្នកពោលអាងអ្នកដទៃ ១** មានសេចក្ដីថា មិនអាចនឹងពោលពាក្យឲ្យសមដល់សេចក្ដី មានសេចក្ដីដឹងច្រើនតាមធម្មតារបស់ខ្លួន ។ ដោយពិត រមែងអាងអ្នកដទៃ ពោលយ៉ាងនេះថា ព្រះរាជាបានត្រាស់នឹងយើងយ៉ាងនេះ មហាអាមាត្រឯណោះពោលយ៉ាងនេះ អាចារ្យ ឬឧបជ្ឈាយ៍របស់យើងឈ្មោះឯណោះ សម្ដែងយ៉ាងនេះ ព្រះថេរៈអ្នកទ្រទ្រង់ព្រះត្រៃបិដក និយាយនឹងយើងយ៉ាងនេះ ។

បទថា **ន ច ភាសានុសន្ធិកុសលោ : ជាអ្នកមិនឈ្លាសក្នុងភាសា និងការវិនិច្ឆ័យ ១** មានសេចក្ដីថា ជាអ្នកមិនថ្លាតក្នុងពាក្យដែលជាដំណើររបស់រឿងរ៉ាវ និងក្នុងពាក្យដែលជាដំណើររបស់ពាក្យវិនិច្ឆ័យ ។

ពីរបទថា **ន យថាធម្មំ យថាវិនយេ : មិនឲ្យសមគួរតាមធម៌ សមគួរតាមវិន័យ** មានសេចក្តីថា មិនជាអ្នកចោទដាស់តឿន ឲ្យរលឹកដល់អាបត្តិ ដោយវត្ថុដែលពិត ។

ពីរបទថា **ឧស្សាទេតា ហោតិ : ជាអ្នកអួតអាងសរសើរលើកបុគ្គលដទៃ** មានសេចក្តីថា រមែងលើកអ្នកខ្លះឡើងអាង ដោយន័យជាដើមថា អាចារ្យរបស់ខ្ញុំជាអ្នកទ្រទ្រង់ព្រះត្រៃបិដកយ៉ាងច្រើន ជាធម្មកថិកដ៏កំពូល។

វិនិច្ឆ័យក្នុងទុតិយបទ គប្បីជ្រាបដូច្នេះ៖

រមែងរុករានមនុស្សខ្លះ ដោយន័យជាដើមថា គេនឹងដឹងអ្វី ។

ពីរបទថា **អធម្មំ គណ្ហាតិ : ប្រកាន់យកហេតុដែលមិនមែនជានិយ្យានិកធម៌** បានដល់ ប្រកាន់ធម៌ដែលជាចំណែកនាំចេញចាកទុក្ខ ។

ពីរបទថា **ធម្មំ បដិពាហតិ : ឃាត់ហេតុដែល មិនមែនជានិយ្យានិកធម៌** បានដល់ ជំទាស់ធម៌ដែលជាចំណែកនាំចេញចាកទុក្ខ ។

ច្រើនបទថា **សម្ផញ្ចំ ពហុំ ភាសតិ : និយាយពាក្យច្រើនឥតប្រយោជន៍** បានដល់ ពោលពាក្យដែលគ្មានប្រយោជន៍ជាច្រើន ។

ច្រើនបទថា **បសយ្ហ បវត្តា ហោតិ : ជាអ្នកនិយាយសង្កត់សង្កិន** មានសេចក្តីថា ជាអ្នកដែលព្រះសង្ឃថេរៈ មិនបានអារាធនា

កាលភារៈដែលលោកមិនបានប្រគល់ឲ្យ ម្យ៉ាងស្រ័យសេចក្តីប្រកាន់ខ្លួន អាចឲ្យពោលក្នុងកាលមិនមែនឱកាស ។

ពីរបទថា **អនោកាសកម្មំ ការាបេត្វា: មិនបានសុំឱកាសជាមុន** មានសេចក្តីថា ជាអ្នកមិនឲ្យភិក្ខុដទៃឲ្យឱកាសជាមុនទេ ក៏ពោល ។

ច្រើនបទថា **ន យថាទិដ្ឋិយា ព្យាកតា ហោតិ : មិនព្យាករដោយសមគួរតាមសេចក្តីយល់របស់ខ្លួន** មានសេចក្តីថា ជាអ្នកមិនព្យាករណ៍អះអាងសេចក្តីឃើញរបស់ខ្លួន ត្រឡប់ជាអ្នកវៀរសេចក្តីឃើញ (របស់ខ្លួន) ចេញ មានសេចក្តីឃើញថា ជាធម៌ជាដើម ក្នុងអធម៌ជាដើម ពោលមិនត្រង់តាមពិត ។

## ភិក្ខុចូលទៅរកសង្ឃត្រូវតម្កល់ធម៌ ៥ ប្រការក្នុងសន្តាន

ម្នាលឧបាលិ ភិក្ខុជាអ្នកចូលទៅកាន់សង្គ្រាម កាលបើចូលទៅរកសង្ឃ ត្រូវមានចិត្តឱនលំទោនសឹមចូលទៅរកសង្ឃ គប្បីជាអ្នកមានចិត្តស្មើដោយ សំពត់សម្រាប់ជូតធូលី ជាអ្នកឈ្លាសក្នុងអាសនៈ ឈ្លាសក្នុងការអង្គុយ ១ មិនត្រូវចូលទៅច្រៀតបៀតពួកភិក្ខុជាថេរៈ មិនត្រូវឃាត់អាសនៈពួកភិក្ខុខ្ចី អង្គុយលើអាសនៈតាមសមគួរ ១ មិនត្រូវជាអ្នកនិយាយពាក្យផ្តេសផ្តាស មិនត្រូវនិយាយតិរច្ឆានកថា ១ ត្រូវពោលធម៌ដោយខ្លួនឯង ឬអារាធនាអ្នកដទៃឲ្យពោលធម៌ ១ មិនត្រូវមើលងាយ

ព្រះអរិយៈបុគ្គលដែលលោកគង់ស្ងៀម ១ ម្នាលឧបាលិ បើសង្ឃធ្វើកម្ម ទាំងឡាយ ដែលសង្ឃគប្បីធ្វើ ដោយសេចក្តីព្រមព្រៀងគ្នា ម្នាលឧបាលិ បើមានភិក្ខុមិនគាប់ចិត្តនឹងកម្មនោះ ភិក្ខុនោះត្រូវធ្វើទិដ្ឋិឲ្យច្បាស់ប្រាកដ សឹមតម្កល់សាមគ្គី ។ សេចក្តីនោះតើព្រោះហេតុអ្វី ។ ព្រោះថា ភិក្ខុ នោះត្រូវតាំកល់សាមគ្គីដោយគិតថា អាត្មាអញមិនត្រូវមានខ្លួនបែកអំពី សង្ឃទេ ។ ម្នាលឧបាលិ ភិក្ខុជាអ្នកចូលទៅកាន់សង្គ្រាម កាលបើចូល ទៅរកសង្ឃត្រូវតម្កល់ធម៌ទាំង ៥ នេះក្នុងសន្តានសិន សឹមចូលទៅរក សង្ឃ ។

*(គម្ពីរបរិវារៈ ១៣/២៦៣_២៦៤)*

## អង្គរបស់ភិក្ខុដែលមិនគួរនិយាយក្នុងជុំនុំសង្ឃ

[២៥៣] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុ ប្រកបដោយអង្គប៉ុន្មាន ដែលមិនត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ មិនត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃ ។ អង្គ ៥ តើដូចម្ដេច ?

### ក_ អង្គ៥របស់ភិក្ខុដែលមិនគួរនិយាយក្នុងសង្ឃគឺ

_ភិក្ខុមិនស្គាល់អាបត្តិ ១ មិនស្គាល់សមុដ្ឋាននៃអាបត្តិ ១ មិនស្គាល់ប្រយោគរបស់អាបត្តិ ១ មិនស្គាល់ការរម្ងាប់អាបត្តិ ១ មិនឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ ១ ។ ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវនិយាយក្នុងកណ្ដាលជំនុំសង្ឃឡើយ ។

### ខ_ អង្គ៥ដទៃទៀត

_ភិក្ខុមិនស្គាល់អធិករណ៍ ១ មិនស្គាល់សមុដ្ឋាននៃអធិករណ៍ ១ មិនស្គាល់ប្រយោគរបស់អធិករណ៍ ១ មិនស្គាល់ការរម្ងាប់អធិករណ៍ ១ មិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍ ១ ។ បេ ។

### គ_អង្គ៥ដទៃទៀត

_ភិក្ខុជាអ្នកនិយាយសង្កត់សង្កិនគេ ១ មិនសូមឱកាសជាមុនស្រាប់តែនិយាយ ១ មិនចោទភិក្ខុផងគ្នាឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ

សមគួរតាមអាបត្តិ ១ មិនកាត់សេចក្តីឲ្យសមគួរតាមធម៌ ឲ្យសមគួរតាមវិន័យ សមគួរតាមអាបត្តិ ១ មិនព្យាករតាមសេចក្តីយល់របស់ខ្លួន ១ ។ បេ ។

## ឃ- អង្គ៥ដទៃទៀត

-ភិក្ខុមិនស្គាល់អាបត្តិនឹងអនាបត្តិ ១ មិនស្គាល់លហុកាបត្តិនឹងគរុកាបត្តិ ១ មិនស្គាល់សាវសេសាបត្តិ នឹងអនវសេសាបត្តិ ១ មិនស្គាល់ទុដ្ឋុល្លាបត្តិ នឹងអទុដ្ឋុល្លាបត្តិ ១ មិនស្គាល់សប្បដិកម្មាបត្តិ[១] នឹងអប្បដិកម្មាបត្តិ[២] ១ ។បេ។

## ង- អង្គ៥ដទៃទៀត

ភិក្ខុមិនស្គាល់កម្ម (៧ប្រការ[៣] មានតជ្ជនីយកម្មជាដើម) ១ មិនស្គាល់ការធ្វើកម្ម ១ មិនស្គាល់វត្ថុរបស់កម្ម ១ មិនស្គាល់វត្តរបស់កម្ម ១ មិនស្គាល់ការរម្ងាប់របស់កម្ម១ ។ បេ ។

---

(១)សប្បដិកម្មាបត្តិ ប្រែថា អាបត្តិដែលនៅកែបាននៅឡើយ បានដល់អាបត្តិ ៦កង តាំងពីសង្ឃាទិសេស រៀងដល់ទុព្ភាសិត ។ (២) អប្បដិកម្មាបត្តិ ប្រែថាអាបត្តិកែមិនបាន គឺបានដល់ អាបត្តិបារាជិក ។

(៣) កម្ម៧យ៉ាងគឺ តជ្ជនីយកម្ម ១ និយស្សនីយកម្ម ១ បព្វាជនីយកម្ម ១ បដិសារណីយកម្ម ១ ឧក្ខេបនីយកម្ម ១ បត្តនិក្កុជ្ជនកម្ម ១ បត្តឧក្កុជ្ជនកម្ម ១ រួមជា ៧ យ៉ាង ។

**ច_អង្គ៥ដទៃទៀត**

_ភិក្ខុមិនស្គាល់វត្ថុ (នៃអាបត្តិទាំង៧) ១ មិនស្គាល់និទាន គឺរឿងរ៉ាវដែលទ្រង់បញ្ញត្តិសិក្ខាបទ ១ មិនស្គាល់បញ្ញត្តិ ១ មិនស្គាល់សេចក្តីខាងចុងខាងដើមបទ[១] ១ មិនស្គាល់គន្លងពាក្យដែលជាប់តគ្នា ១។ បេ ។

**ឆ_អង្គ៥ដទៃទៀត**

_ភិក្ខុលំអៀងទៅខាងឆន្ទាគតិ ១ លំអៀងទៅខាងទោសាគតិ ១ លំអៀងទៅខាងមោហាគតិ ១ លំអៀងទៅខាងភយាគតិ ១ មិនខ្មាសបាប ១ ។ បេ ។

**ជ_ អង្គ៥ដទៃទៀត**

_ភិក្ខុលំអៀងទៅខាងឆន្ទាគតិ ១ លំអៀងទៅខាងទោសាគតិ ១ លំអៀងទៅខាងមោហាគតិ ១ លំអៀងទៅខាងភយាគតិ ១ មិនឈ្លាសក្នុងវិន័យ ១ ។ បេ ។

**ឈ_អង្គ៥ដទៃទៀត**

_ភិក្ខុមិនស្គាល់ញត្តិ ១ មិនស្គាល់ការធ្វើដោយញត្តិ ១ មិនស្គាល់វិធីសូត្រដោយញត្តិ ១ មិនស្គាល់សមថៈដោយញត្តិ ១

---

(១) អដ្ឋកថា ថាមិនស្គាល់សេចក្តីខាងចុង នឹងខាងដើមបទនោះ គឺដូចជាគេធ្លាប់ សូត្រថា ពុទ្ធោ ភគវា ត្រឡប់ជាសូត្រ ភគវា ពុទ្ធោ ដូច្នេះវិញ ។

មិនស្គាល់ការរម្ងាប់ដោយ ញត្តិ ១ ។ បេ ។

## ញ_ អង្គ៥ដទៃទៀត

_ភិក្ខុមិនចេះសុត្តៈ គឺ ឧភតោវិភង្គ ១ មិនចេះសុត្តានុលោម គឺ មហាបទេសទាំងបួន ១ មិនចេះវិន័យ គឺ ខន្ធកៈនឹងបរិវារៈ ១ មិនចេះវិនយានុលោម គឺមហាបទេសទាំងបួន ១ មិនឈ្លាសក្នុងហេតុដែលគួរ នឹងមិនគួរ ១ ។ បេ ។

## ដ_អង្គ៥ដទៃទៀត

_ភិក្ខុមិនចេះធម៌ ១ មិនចេះធម្មានុលោម គឺ មហាបទេសប៉ែកខាងព្រះសូត្រ ១ មិនចេះវិន័យ ១ មិនចេះវិនយានុលោម ១ មិនឈ្លាសក្នុងពាក្យខាងដើម នឹងពាក្យខាងចុង ១ ។

ម្នាលឧបាលិ ភិក្ខុដែលប្រកបដោយអង្គ ៥ នេះឯង មិនត្រូវនិយាយក្នុងកណ្តាលជំនុំសង្ឃឡើយ ។

អង្គ ៥ (បញ្ចកៈ) ដែលអាចនិយាយក្នុងកណ្តាលជំនុំសង្ឃបាន គប្បីជ្រាបដោយន័យផ្ទុយគ្នា ចាប់ពីបញ្ចកៈដំបូងមក ។

(បរិវារ ១៣ / ២៦៩ _ ២៣៧)

**អដ្ឋកថា**

[២៥៣] ប្រែនបទថា **អាបត្តិយា បយោគំ ន ជានាតិ : មិនស្គាល់ប្រយោគរបស់អាបត្តិ** បានដល់ មិនដឹងថា អាបត្តិនេះជាកាយប្រយោគ អាបត្តិនេះជាវចីប្រយោគ ។

ប្រែនបទថា **អាបត្តិយា វូបសមំ ន ជានាតិ : មិនស្គាល់ការរម្ងាប់អាបត្តិ** បានដល់ មិនដឹងថា អាបត្តិនេះរម្ងាប់ដោយការសម្តែង, អាបត្តិនេះរម្ងាប់ដោយការចេញ អាបត្តិនេះមិនរម្ងាប់ដោយការសម្តែង មិនរម្ងាប់ដោយការចេញ ។

ប្រែនបទថា **ន អាបត្តិយា វិនិច្ឆយកុសលោ ហោតិ : មិនឈ្លាសក្នុងការវិនិច្ឆ័យអាបត្តិ** បានដល់ មិនដឹងថាអាបត្តិនេះមានក្នុងវត្ថុនេះ គឺ មិនអាចដើម្បីលើកអាបត្តិឡើងអះអាង តាមសមគួរដល់ទោស ។

ពីរបទថា **អធិករណសមុដ្ឋានំ ន ជានាតិ : មិនស្គាល់សមុដ្ឋាននៃអធិករណ៍** បានដល់ មិនដឹងថាអធិករណ៍នេះ អាស្រ័យភេទករវត្ថុ ១៨ តាំងឡើង, អធិករណ៍នេះ អាស្រ័យវិបត្តិ ៤ តាំងឡើង, អធិករណ៍នេះ អាស្រ័យកងអាបត្តិ ៥ ឬ ៧ តាំងឡើង, អធិករណ៍នេះ អាស្រ័យសង្ឃកិច្ច ៤ យ៉ាង តាំងឡើង ។

ពីរបទថា **បយោគំ ន ជានាតិ : មិនស្គាល់ប្រយោគ** បានដល់ មិនដឹងថា អធិករណ៍នេះ មានប្រយោគជាខាងដើម ១២, អធិករណ៍នេះមានប្រយោគជាខាងដើម ១៤, អធិករណ៍នេះ មានប្រយោគជាខាងដើម ៦, អធិករណ៍នេះមានប្រយោគជាខាងដើម ១, អធិប្បាយថា ពិតមែន ខាងដើម តាមដែលជារបស់ខ្លួននុ៎ះឯង នៃអធិករណ៍ទាំងឡាយ ចាត់ជាប្រយោគ, មិនស្គាល់ប្រយោគសូម្បីទាំងពួងនោះ ។

ពីរបទថា **វូបសមំ ន ជានាតិ : មិនស្គាល់ការរម្ងាប់** បានដល់ មិនដឹងថា អធិករណ៍នេះ រម្ងាប់ដោយសមថៈ ២, អធិករណ៍នេះ រម្ងាប់ដោយសមថៈ ៤, អធិករណ៍នេះ រម្ងាប់ដោយសមថៈ ៣, អធិករណ៍នេះ រម្ងាប់ដោយ សមថៈ ១ ។

ច្រើនបទថា **ន អធិករណស្ស វិនិច្ឆយកុសលោ ហោតិ : មិនឈ្លាសក្នុងការវិនិច្ឆ័យអធិករណ៍** បានដល់ មិនដឹងដើម្បីវិនិច្ឆ័យអធិករណ៍ ឲ្យដល់សេចក្ដីរម្ងាប់ ។

ពីរបទថា **កម្មំ ន ជានាតិ : មិនស្គាល់កម្ម** បានដល់ មិនស្គាល់កម្ម ៧ យ៉ាង មានតជ្ជនីយកម្មជាដើម ។

ច្រើនបទថា **កម្មស្ស ករណំ ន ជានាតិ : មិនស្គាល់ការធ្វើកម្ម** បានដល់ មិនដឹងថាកម្មនេះគួរធ្វើដោយឧបាយនេះ ។

ច្រើនបទថា **កម្មស្ស វត្ថុំ ន ជានាតិ : មិនស្គាល់វត្ថុរបស់កម្ម** បានដល់ មិនដឹងថា នេះជាវត្ថុនៃតជ្ជនីយកម្ម នេះជាវត្ថុនៃនិយស្សកម្ម ជាដើម ។

ច្រើនបទថា **កម្មស្ស វត្តំ ន ជានាតិ : មិនស្គាល់វត្តរបស់កម្ម** បានដល់ មិនស្គាល់វត្ត ១៨ ប្រការនៃកម្ម ៤ ក្នុងកាលក្រោយក្នុងកម្ម ៧ ប្រភេទ និងវត្ត ៤៣ ប្រការ នៃឧក្ខេបនីយកម្ម ៣ យ៉ាង ។

ច្រើនបទថា **កម្មស្ស វូបសមំ ន ជានាតិ : មិនស្គាល់ការរម្ងាប់របស់កម្ម** បានដល់ មិនដឹងថា ភិក្ខុណាប្រព្រឹត្តវត្តហើយសូម កម្មរបស់ភិក្ខុនោះដែលសង្ឃគួររម្ងាប់ , ទោសដែលសង្ឃគប្បីឲ្យសម្តែង ។

ពីរបទថា **វត្ថុំ ន ជានាតិ : មិនស្គាល់វត្ថុ** បានដល់ មិនស្គាល់វត្ថុនៃកងអាបត្តិ ៧ កង ។

ពីរបទថា **និទានំ ន ជានាមិ : មិនស្គាល់និទាន គឺរឿងរ៉ាវដែលទ្រង់បញ្ញត្តិសិក្ខាបទ** បានដល់ មិនដឹងថាសិក្ខាបទនេះព្រះមានព្រះ-ភាគ ទ្រង់បញ្ញត្តិក្នុងនគរនេះ សិក្ខាបទនេះ ទ្រង់បញ្ញត្តិក្នុងនគរនោះ ។

ពីរបទថា **បញ្ញត្តឹ ន ជានាតិ : មិនស្គាល់បញ្ញត្តិ** បានដល់ មិនស្គាល់បញ្ញត្តិទាំងបីយ៉ាង ដោយអំណាចបញ្ញត្តិ អនុប្បញ្ញត្តិ អនុប្ប-ន្នប្បញ្ញត្តិ ។

ពីរបទថា **បទបច្ចាភង្គំ ន ជានាតិ : មិនស្គាល់សេចក្តីខាងចុងខាងដើមបទ** បានដល់ មិនស្គាល់បទដែលគួរចាត់ទុកខាងមុខ គឺកាលខ្លួនគួរនឹងពោលថា **ពុទ្ធោ ភគវា** ត្រឡប់ប្រកបឲ្យផ្លាស់មុខផ្លាស់ក្រោយចេញថា **ភគវា ពុទ្ធោ** វិញ ។

ច្រើនបទថា **អកុសលោ ច ហោតិ វិនយេ : មិនឈ្លាសក្នុងវិន័យ** បានដល់ ជាអ្នកមិនឈ្លាសក្នុងបាលី និងអដ្ឋកថានៃព្រះវិន័យ ។

ច្រើនបទថា **ញត្តឹ ន ជានាតិ : មិនស្គាល់ញត្តិ** មានសេចក្តីថា ក៏ដោយសង្ខេបញត្តិមាន ២ យ៉ាង គឺ ញត្តិដែលសម្តែងយ៉ាងនេះថា **ឯសា ញត្តិ** ១ ញត្តិដែលមិនសម្តែង ១ ។ ក្នុងញត្តិ ២ យ៉ាងនោះ ញត្តិណាមិនសម្តែងយ៉ាងនោះ, ញត្តិនោះចាត់ជាកម្មញត្តិ ។ ញត្តិណាសម្តែង, ញត្តិនោះចាត់ជាកម្មបាទញត្តិ មិនស្គាល់ញត្តិនោះដោយប្រការទាំងពួង ។

ច្រើនបទថា **ញត្តិយា ករណំ ន ជានាតិ : មិនស្គាល់ការធ្វើដោយញត្តិ** បានដល់ មិនស្គាល់ការធ្វើកម្មញត្តិក្នុង ៩ ស្ថាន, មិនស្គាល់ការធ្វើកម្មបាទញត្តិ ក្នុង២ស្ថាន ។

ពីរបទថា **ញត្តិយា អនុស្សាវនំ : មិនស្គាល់វិធីសូធ្យដោយញត្តិ** បានដល់ មិនដឹងថាញត្តិនេះមានអនុស្សាវនា ១ ញត្តិនេះ

មានអនុស្សាវនា ៣ ។

ប្រើនបទថា **ញត្តិយា សមថំ ន ជានាតិ : មិនស្គាល់សមថ:ដោយញត្តិ** មានសេចក្ដីថា សមថ: ៤ យ៉ាងនេះ គឺ សតិវិន័យ អមូឡ្ហវិន័យ តស្សបាបិយសិកា តិណវត្ថារក: មិនវៀរចាកញត្តិ មិនស្គាល់សមថ:នោះថា រម្ងាប់ដោយញត្តិ ។

ប្រើនបទថា **ញត្តិយា វូបសមំ ន ជានាតិ : មិនស្គាល់ការរម្ងាប់ញត្តិ** មានសេចក្ដីថា អធិករណ៍ណារម្ងាប់ដោយញត្តិ សមថ: ៤ យ៉ាងនេះ មិនស្គាល់សេចក្ដីរម្ងាប់នោះ នៃអធិករណ៍នោះថា សេចក្ដីរម្ងាប់នេះ ធ្វើដោយញត្តិ ។

ពីរបទថា **សុត្តំ ន ជានាតិ : មិនចេះសុត្ត:** បានដល់ មិនស្គាល់ឧភតោវិភង្គ ។

ពីរបទថា **សុត្តានុលោមំ ន ជានាតិ : មិនចេះសុត្តានុលោម** បានដល់ មិនស្គាល់មហាបទេស ៤ ។

ពីរបទថា **វិនយំ ន ជានាតិ : មិនចេះវិន័យ** បានដល់ មិនស្គាល់ ខន្ធក: និងបរិវារ: ។

ពីរបទថា **វិនយានុលោមំ ន ជានាតិ : មិនចេះវិនយានុលោម** បានដល់ មិនស្គាល់មហាបទេសនុ៎ះឯង ។

ពីរបទថា **ន ច ឋានាឋានកុសលោ : មិនឈ្លាសក្នុងហេតុដែលគួរនិងមិនគួរ ១** បានដល់ ជាអ្នកមិនថ្លាតក្នុងហេតុ និងមិនមែនហេតុ ។

ពីរបទថា **ធម្មំ ន ជានាតិ : មិនចេះធម៌** បានដល់មិនស្គាល់បិដក ២ ដ៏សេស ក្រៅអំពីវិន័យបិដក ។

ពីរបទថា **ធម្មានុលោមំ ន ជានាតិ : មិនចេះធម្មានុលោម** បានដល់ មិនស្គាល់មហាបទេស ៤ ផ្នែកសុត្តន្តៈ ។

ពីរបទថា **វិនយំ ន ជានាតិ : មិនចេះវិន័យ** បានដល់ មិនស្គាល់ខន្ធកៈ និងបរិវារៈនុ៎ះឯង ។

ពីរបទថា **វិនយានុលោមំ ន ជានាតិ : មិនចេះវិនយានុលោម** បានដល់ មិនស្គាល់មហាបទេស ៤ ។

ក៏ឧភតោវិភង្គ ជាការដែលលោកមិនសង្គ្រោះ ក្នុងសេចក្តីថា មិនស្គាល់វិន័យ ព្រោះហេតុនោះ ពាក្យណាដែលលោកពោលទុកក្នុងកុរុន្ទីថា បទថា **វិនយំ** បានដល់ មិនស្គាល់វិន័យបិដកទាំងអស់ ពាក្យនោះគួរកាន់យក ។

ពីរបទថា **ន ច បុព្វាបរកុសលោ ហោតិ : មិនឈ្លាសក្នុងពាក្យខាងដើម និងពាក្យខាងចុង** បានដល់ ជាអ្នកមិនឈ្លាសក្នុងពាក្យដើម និងពាក្យក្រោយ ។

ពាក្យដ៏សេសក្នុងបទទាំងពួងរាប់ថា ងាយយល់ទាំងអស់ ព្រោះជាពាក្យដែលគួរជ្រាបដោយបដិបក្ខន័យ ចំពោះពាក្យដែលពោលហើយ និងព្រោះជាពាក្យដែលបានបើកបង្ហាញហើយ ក្នុងកាលមុន ដូច្នេះឯង ។

# សារាណីយធម៌ ៦ ប្រការ

( ធម៌ដែលសព្រហ្មចារីនឹករលឹកដល់ )

១_ភិក្ខុក្នុងសាសនានេះ បានតាំងកាយកម្មប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្ដីស្រលាញ់ ឈ្មោះថា ធ្វើនូវសេចក្ដីគោរពដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្ដីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។

២_មានពាក្យតទៅទៀតថា ភិក្ខុ(ក្នុងសាសនានេះ) បានតាំងវចីកម្មប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្ដីស្រលាញ់ ឈ្មោះថា ធ្វើនូវសេចក្ដីគោរព ដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្ដីសង្គ្រោះ ដើម្បីសេចក្ដីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។

៣_ មានពាក្យតទៅទៀតថា ភិក្ខុ ( ក្នុងសាសនានេះ ) បានតាំងមនោកម្មប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារីបុគ្គលទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯងឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្ដីស្រលាញ់ ឈ្មោះថា ធ្វើនូវសេចក្ដីគោរព

ដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្ដីសង្គ្រោះ ដើម្បីសេចក្ដីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។

៤_មានពាក្យតទៅទៀតថា លាភណាដែលប្រកបក្នុងធម៌ បានមកដោយធម៌ ដោយហោចទៅ សូម្បីគ្រាន់តែអាហារបិណ្ឌបាត ភិក្ខុអ្នកមិនទាន់បានបរិភោគ ទាំងមិនទាន់បានចែកលាភដូច្នោះនៅឡើយ ជាអ្នកបរិភោគសាធារណៈ (ជាមួយ) នឹងសព្រហ្មចារីបុគ្គល អ្នកមានសីលទាំងឡាយ ធម៌នេះឯង ឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្ដីស្រលាញ់ ឈ្មោះថា ធ្វើនូវសេចក្ដីគោរព ដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។

៥_មានពាក្យតទៅទៀតថា សីលណា ដែលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះ ជាសីលល្អ ជាសីលដែលអ្នកប្រាជ្ញតែងសរសើរ ជាសីលដែលតណ្ហា នឹងទិដ្ឋិ មិនបានប៉ះពាល់ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ [១] ភិក្ខុជាអ្នកមានសីលស្មើគ្នា ក្នុងសីលទាំងឡាយ មានសភាពដូច្នោះ ជាមួយនឹងសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ធម៌នេះឯងឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្ដីស្រលាញ់ ឈ្មោះថាធ្វើនូវសេចក្ដីគោរព ដល់សព្រហ្មចារី_

---

(១) អដ្ឋកថា ថាប្រព្រឹត្តទៅដើម្បីឧបចារៈសមាធិ នឹងអប្បនាសមាធិ ។

បុគ្គល ប្រព្រឹត្តទៅដើម្បីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់ ។

៦_ពាក្យតទៅទៀតថា ទិដ្ឋិណាដ៏ប្រសើ ជាទីនាំសត្វចេញចាកវដ្តទុក្ខ របស់បុគ្គលអ្នកធ្វើយ៉ាងនោះ ដើម្បីជាទីអស់ទៅនៃកងទុក្ខដោយប្រពៃ ភិក្ខុប្រកបដោយសេចក្តីយល់ឃើញស្មើគ្នា ដោយទិដ្ឋិមានសភាពដូច្នេះ (ជាមួយ) នឹងសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុង_ទីកំបាំងមុខ ធម៌នេះឯងឈ្មោះថា ជាធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថាធ្វើនូវសេចក្តីស្រលាញ់ ឈ្មោះថា ធ្វើនូវសេចក្តីគោរពដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ នេះជាសារាណីយធម៌ ៦ ។

*(គម្ពីរបរិវារៈ ១២/៣៧៣)*

# អដ្ឋកថា

វិនិច្ឆ័យក្នុងសាធារណីយធម្មនិទ្ទេស ដូច្នេះ ៖

កាយកម្ម ដែលធ្វើដោយចិត្តប្រកបដោយមេត្តា ឈ្មោះថា មេត្តាកាយកម្ម ។

ពីរបទថា **អាវិ ចេវ រហោ ច : ក្នុងទីស្រឡះផង ក្នុងទីស្ងាត់ផង** បានដល់ ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ។ ក្នុងកាយកម្ម ២ យ៉ាង ដោយអំណាចនៃចំពោះមុខ និងកំបាំងមុខនោះ ការដល់ភាពជាសម្លាញ់ ក្នុងការងារទាំងឡាយ មានចីវរកម្មជាដើម របស់ភិក្ខុថ្មីទាំងឡាយ ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។ ចំណែកសាមីចិកម្មទាំងពួង សូម្បីផ្សេងដោយកិច្ចមានលាងជើង និងបក់ផ្លិតជាដើម ឲ្យព្រះថេរៈទាំងឡាយ ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។ ការរក្សាទុកដាក់ភណ្ឌៈទាំងឡាយ មានភណ្ឌៈឈើជាដើម ដែលភិក្ខុថ្មីនិងព្រះថេរៈទាំង ២ ពួក រក្សាទុកដាក់មិនល្អ មិនធ្វើសេចក្តីមើលងាយក្នុងភិក្ខុថ្មី និងព្រះថេរៈទាំងនោះ ដូចជារក្សាទុកដាក់នូវវត្ថុដែលខ្លួនរក្សាទុកមិនល្អដូច្នោះ ឈ្មោះថា មេត្តាកាយកម្មកំបាំងមុខ ។

ពាក្យថា **អយម្បិ ធម្មោ សារាណីយោ : ធម៌នេះឯង**

**ដែលបុគ្គលគប្បីរលឹក** មានសេចក្ដីថា ធម៌ ពោលគឺ មេត្តាកាយកម្មនេះ ដែលសព្រហ្មចារីទាំងឡាយគប្បីរលឹកដល់ ។ អធិប្បាយថា បុគ្គលណាញុំាងសតិឲ្យកើតធ្វើធម៌ ពោលគឺ មេត្តាកាយកម្មនោះ ធម៌គឺ មេត្តាកាយកម្មនោះ ជាធម៌ដែលបុគ្គលនោះធ្វើហើយដល់ជនពួកណា ជនទាំងនោះមានចិត្តជ្រះថ្លាហើយ រមែងរលឹកដល់បុគ្គលនោះថា អ្នកនេះជាសប្បុរសពិត ។

បទថា **បិយករណោ : ឈ្មោះថា ធ្វើនូវសេចក្ដីស្រឡាញ់** មានសេចក្ដីថា ធម៌ គឺ មេត្តាកាយកម្មនោះ រមែងធ្វើបុគ្គលនោះ ឲ្យជាទីស្រឡាញ់របស់សព្រហ្មចារីទាំងឡាយ ។

បទថា **គរុករណោ : ឈ្មោះថា ធ្វើនូវសេចក្ដីគោរព** មានសេចក្ដីថា ធម៌នោះរមែងធ្វើបុគ្គលនោះ ឲ្យជាទីគោរពរបស់សព្រហ្មចារីទាំងឡាយ។

វិនិច្ឆ័យក្នុងពាក្យថា **សង្គហាយ : ប្រព្រឹត្តទៅដើម្បីសេចក្ដីសង្គ្រោះ** ជាដើម គប្បីជ្រាបដូច្នេះ ៖

ធម៌នោះប្រព្រឹត្តទៅដើម្បីបានភាពជាអ្នកដែលសព្រហ្មចារីទាំង-ឡាយ គប្បីជួយសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីជាអ្នកព្រមព្រៀងគ្នា ជា

ពួកតែមួយ រួមជាមួយនឹងសព្រហ្មចារីទាំងនោះ ។

វិនិច្ឆ័យក្នុងពាក្យថា **មេត្តំ វចីកម្មំ : វចីកម្មប្រកបដោយមេត្តា** ជាដើម គប្បីជ្រាបដូច្នេះ ៖

ការពោលសរសើរយ៉ាងនេះថា ព្រះទេវត្ថេរៈ ព្រះតិស្សត្ថេរៈ ឈ្មោះថា មេត្តាវចីកម្មចំពោះមុខ ។ ចំណែកការពោលពាក្យដែលសម្តែងសេចក្តីស្រឡាញ់របស់បុគ្គលដែលសាកសួរដល់លោក ក្នុងកាលលោកមិននៅក្នុងសំណាក់យ៉ាងនេះថា លោកម្ចាស់ទេវត្ថេរៈរបស់ពួកយើង ទៅណា ? លោកម្ចាស់តិស្សត្ថេរៈរបស់ពួកយើងទៅណា ? កាលណាហ្ន៎ លោកម្ចាស់នឹងមក ? ដូច្នេះ ឈ្មោះថា មេត្តាវចីកម្មកំបាំងមុខ ។ ក៏ការបើកភ្នែកដ៏ស្និទ្ធ ជិតជាប់ទៅដោយសេចក្តីស្រឡាញ់ ពោលគឺ មេត្តា ក្រឡេកមើលដោយមុខដែលរីករាយ ឈ្មោះថា មេត្តាមនោកម្មចំពោះមុខ ។ ការនឹករលឹកដល់ជានិច្ចថា លោកម្ចាស់ទេវត្ថេរៈ លោកម្ចាស់តិស្សត្ថេរៈ ចូរជាអ្នកមិនមានរោគ មានអាពាធតិច ឈ្មោះថា មេត្តាមនោកម្មកំបាំងមុខ ។

បទថា **អប្បដិវិភត្តភោគី : ភិក្ខុអ្នកមិនទាន់បរិភោគទាំងមិនទាន់បានចែក** មានសេចក្តីថា រមែងបែងចែកអាមិសទុកសម្រាប់ខ្លួន

ហើយបរិភោគសោះទេ  បែងចែកទុកចំពោះបុគ្គលហើយបរិភោគក៏មិនមែនដែរ ។ ក៏ភិក្ខុណា  រមែងបែងចែកទុកបរិភោគថា  យើងនឹងឲ្យដល់ភិក្ខុពួកដទៃប៉ុណ្ណេះ  នឹងបរិភោគដោយខ្លួនឯងប៉ុណ្ណេះ  ឬថាយើងនឹងឲ្យដល់ភិក្ខុឯណោះ  នឹងភិក្ខុឯណោះប៉ុណ្ណេះ  នឹងបរិភោគដោយខ្លួនឯងប៉ុណ្ណេះៈ ភិក្ខុនេះឈ្មោះថា អ្នកបែងចែកបរិភោគដោយចំពោះ ។ ចំណែកភិក្ខុដែលតាំងនៅក្នុងសារាណីយធម៌នេះ មិនធ្វើយ៉ាងនោះ ថ្វាយបិណ្ឌបាតដែលខ្លួននាំមកតាំងពីព្រះថេរៈ  ហើយចាន់ចំណែកដ៏សេសពីដែលព្រះ-ថេរៈទទួលយកទុក ។

ព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា សូម្បីមិនឲ្យដល់បុគ្គលទ្រុស្ត-សីលក៏គួរ ព្រោះព្រះបាលីថា **សីលវន្តេហិ : អ្នកមានសីលទាំងឡាយៈ** តែភិក្ខុដែលបំពេញសារាណីយធម៌  គប្បីឲ្យដល់អ្នកមានសីល  នឹងអ្នកទ្រុស្តសីលទាំងពួងតែម្តង ។

សូម្បីជ្រើសរើសឲ្យដល់អ្នកអាពាធ  និងអ្នកព្យាលជម្ងឺ  អាគន្តុកៈ អ្នកត្រៀមនឹងទៅ នឹងអ្នកខ្វល់ខ្វាយក្នុងការងារ មានចីវរកម្មជាដើម ក៏គួរ ។ ព្រោះថា ភិក្ខុជ្រើសរើសបុគ្គលទាំងនោះហើយឲ្យ នឹងឈ្មោះថា ធ្វើការបែងចែកបុគ្គលក៏ទេ ។ ពិតមែន ព្រោះភិក្ខុទាំងឡាយបែបនេះ ជាអ្នកមាន

លាភសក្ការៈ ទើបគួរធ្វើឲ្យជាចំណែកពិសេសពិត ព្រោះហេតុនោះ បុគ្គលបំពេញសារាណីយធម៌នេះ ទើបធ្វើការជ្រើសរើសឲ្យ ។

វិនិច្ឆ័យក្នុងបទថា **អខណ្ឌានិ : ដែលមិនដាច់** ជាដើម គប្បីជ្រាបដូច្នេះ៖

បណ្ដាអាបត្តិ ៧ កង សិក្ខាបទរបស់ភិក្ខុណាដាច់ខាងដើម ឬដាច់ខាងចុង សីលរបស់ភិក្ខុនោះ ឈ្មោះថា **ខណ្ឌានិ : ដាច់** ប្រៀបដូចសំពត់ដាច់ជាយដោយជុំវិញដូច្នោះ ។

ចំណែកសិក្ខាបទរបស់ភិក្ខុណាធ្លាយត្រង់កណ្ដាល សីលរបស់ភិក្ខុនោះ ឈ្មោះថា **ឆិទ្ទានិ : ធ្លុះ** ប្រៀបដូចសំពត់ដែលមានប្រហោងធ្លុះនៅត្រង់កណ្ដាលដូច្នោះ ។

សិក្ខាបទរបស់ភិក្ខុណាធ្លុះធ្លាយ ២_៣ សិក្ខាបទដោយលំដាប់ សីលរបស់ភិក្ខុនោះ ឈ្មោះថា **សពលានិ : ពពាល** ប្រៀបដូចមេគោដែលមានពណ៌ខ្មៅ និងក្រហមជាដើម យ៉ាងណាមួយ ច្លាស់គ្នានឹងពណ៌ដែលមិនដូចគ្នា ដែលប្រាកដឡើងត្រង់ខ្នង ឬត្រង់ពោះដូច្នោះ ។

សិក្ខាបទរបស់ភិក្ខុណា ធ្លាយក្នុងចន្លោះៗ សីលរបស់ភិក្ខុនោះ

ឈ្មោះថា **កម្មាសានិ : ពព្រុះ** ប្រៀបដូចមេគោដែលពាសពេញដោយពណ៌មិនដូចគ្នាក្នុងចន្លោះៗ ដូច្នោះ ។

ចំណែកសីលរបស់ភិក្ខុណា មិនធ្លាយដោយប្រការទាំងពួង សីលទាំងនោះរបស់ភិក្ខុនោះ ឈ្មោះថា មិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ។

ក៏សីលទាំងនេះ ដែលព្រះមានព្រះភាគត្រាស់ថា **ភុជិស្សានិ : ជាសីលរួចខ្លួន** ព្រោះធ្វើខ្លួនមិនឲ្យជំពាក់បំណុល **វិញ្ញុប្បសត្ថានិ : ជាសីលដែលអ្នកប្រាជ្ញសរសើរ** ព្រោះជាសីលដែលលោកអ្នកដឹង លើកតម្កើង ។ **អបរាមដ្ឋានិ : ជាសីលដែលកិលេសមិនបានប៉ះពាល់** ព្រោះជាសីលដែលតណ្ហា និងទិដ្ឋិមិនបានពាល់ត្រូវ ប្រព្រឹត្តទៅដើម្បីសមាធិ ព្រោះញុំាំងឧបចារសមាធិ ឬអប្បនាសមាធិឲ្យប្រព្រឹត្តទៅព្រម ។

ពីរបទថា **សីលសាមញ្ញគតា វិហរតិ : ភិក្ខុជាអ្នកមានសីលស្មើគ្នានៅ** មានសេចក្តីថា អ្នកមានសីលចូលដល់ភាពជាអ្នកស្មើគ្នានឹងភិក្ខុទាំងឡាយ អ្នកមានសីលល្អ ដែលនៅក្នុងទិសាភាគ ទាំងនោះៗ ។

ពីរបទថា **យាយំ ធិដ្ឋិ : ទិដ្ឋិណា** បានដល់ សម្មាទិដ្ឋិដែលសម្បយុត្តដោយមគ្គ ។

បទថា **អរិយា : ដ៏ប្រសើរ** បានដល់ មិនមានទោស ។

បទថា **និយ្យាតិ : ជាទីនាំសត្វចេញចាកវដ្តទុក្ខ** បានដល់ នាំចេញទៅ ។

បទថា **តក្ករស្ស : របស់បុគ្គលអ្នកធ្វើយ៉ាងនោះ** បានដល់ អ្នកមានប្រក្រតីធ្វើយ៉ាងនោះ ។

បទថា **ទុក្ខក្ខយាយ : ដើម្បីជាទីអស់ទៅនៃកងទុក្ខដោយប្រពៃ** បានដល់ ដើម្បីអស់ទៅនៃទុក្ខទាំងពួង ។

ពាក្យដ៏សេស រហូតដល់ប្រភេទសមថ:ជាទីបំផុត មានសេចក្តីងាយយល់ទាំងអស់ ។

## បរិយោសានគាថា

មហាអ្នកប្រាជ្ញមាននាមថា ទីប: ជាអ្នកទ្រទ្រង់សុត: គឺ ព្រះត្រៃ-បិដក មានប្រាជ្ញាជាគ្រឿងពិចារណា បានសាកសួរផ្លូវនៃអាចារ្យជាន់ដើមក្នុងបាលីបទេសនោះៗហើយ គិតឲ្យចារិកសេចក្តីពិស្តារនឹងសង្ខេបនេះ ដែលជាហេតុនាំមកឲ្យបានសេចក្តីស្រួលងាយដល់ពួកសិស្សានុសិស្ស ទុកក្នុងមជ្ឈិមបទេស តាមផ្លូវស្វាធ្យាយ ។ វត្ថុណាដែលបានពោលថា បរិវារ: ដូច្នេះ វត្ថុទាំងអស់នោះប្រកបដោយលក្ខណ: កាលបើព្រះសទ្ធម្ម ដែលព្រះពុទ្ធបញ្ញត្តិនូវអត្ថដ៏សមគួរតាមអត្ថហើយ ទ្រង់បញ្ញត្តិនូវធម៌ដ៏សមគួរតាមធម៌ហើយ តែងចោមរោមអមសាសនា ដូចសាគរដែលព័ទ្ធជុំវិញជម្ពូទ្វីប ។ កាលបើកុលបុត្រមិនចេះបរិវារ:ហើយ នឹងចេះវិនិច្ឆ័យធម៌អាចដូចម្តេចកើត ។ សេចក្តីសង្ស័យអំពីវិបត្តិក្តី វត្ថុក្តី បញ្ញត្តិក្តី អនុប្បញ្ញត្តិក្តី បុគ្គលក្តី ឯកតោបញ្ញត្តិក្តី ឧភតោបញ្ញត្តិក្តី លោកវជ្ជ:ក្តី បណ្ណត្តិវជ្ជ:ក្តី កើតឡើងដល់កុលបុត្រណា កុលបុត្រនោះ នឹងកាត់សេចក្តីសង្ស័យបានដោយបរិវារ: ស្តេចចក្រតែងល្អរុងរឿងក្នុងកណ្តាលទីប្រជុំមហាសេនា កេសររាជសីហ៍ល្អរុងរឿងក្នុងកណ្តាលហ្វូងម្រឹគ ព្រះអាទិត្យមានរស្មីភ្លឺច្បាស់(ល្អរុងរឿងលើអាកាស) ព្រះចន្ទល្អរុងរឿងក្នុងកណ្តាលពពួកផ្កាយ ព្រហ្មជានាយកតែងល្អរុងរឿងក្នុងកណ្តាលពួកនៃព្រហ្មជាបរិសទ្យ យ៉ាងណាមិញ ព្រះសទ្ធម្មនឹងព្រះវិន័យ ក៏ល្អរុងរឿងដោយបរិវារ: យ៉ាងនោះដែរ ។

## ការពិន័យអាបត្តិក្នុងខន្ធកៈ

### ក្នុងគម្ពីរសមន្តប្បាសាទិកា :

ឥតោ បដ្ឋាយ ច បន យត្ថ យត្ថ ន ការេន បដិសេធោ ករិយតិ, សព្វត្ថ ទុក្កដាបត្តិ វេទិតព្វា, អយំ ហិ ខន្ធកធម្មតា ។

ចាប់ផ្ដើមតាំងពីត្រង់ (ឧបជ្ឈាយ៏វត្តទី១៧) នេះទៅ ក្នុងទីណាៗក៏ដោយ លោកធ្វើការហាមទុកដោយ ន អក្សរ(ដែលប្រែថា មិន ឬ កុំ) ក្នុងទីគ្រប់កន្លែងគប្បីជ្រាបថា ពិន័យជាអាបត្តិទុក្កដ, ពិតមែនការពិន័យអាបត្តិទុក្កដក្នុងទីមាន ន អក្សរនេះ ជាធម្មតារបស់ខន្ធកៈ ។

### ក្នុងគម្ពីរសារត្ថទីបនីដីកា ៣/២៨២ :

សព្វត្ថ ទុក្កដាបត្តិ វេទិតព្វាតិ ឦទិសេសុ គិលានោ ន មុច្ចតីតិ ទស្សនត្ថំ វុត្តំ អញ្ញត្ថ ហិ យថាវុត្តំ ឧបជ្ឈាយវត្តំ អនាទរិយេន អករោន្តស្ស អគិលានស្ស វត្តភេទេ សព្វត្ថ ទុក្កដមេវ ។ ពាក្យថា ក្នុងទីនោះគ្រប់កន្លែងគប្បីជ្រាបថាពិន័យអាបត្តិទុក្កដ លោកពោលទុកដើម្បីសម្ដែងថា ក្នុងឋានៈដែលមាន ន អក្សរ (មិននូវជាប់បទ) ដូច្នេះ សូម្បីភិក្ខុឈឺក៏មិនរួចចាកអាបត្តិ ភិក្ខុមិនមានជម្ងឺមិនធ្វើឧបជ្ឈាយ៏វត្ត តាមដែលពោលហើយ

សូម្បីដទៃ (អំពីវត្ថុដែលមាន ន អក្សរ) ដោយសេចក្តីមិនអើពើ ពិន័យអាបត្តិទុក្កដគ្រប់កន្លែងព្រោះវត្ថុភេទនោះឯង ។

**ក្នុងគម្ពីរវិមតិវិនោទនីដីកា ២/១៣២ :**

ឥតោ បដ្ឋាយាតិ ន ឧបជ្ឈាយស្ស ភណមាណស្សាតិ ឯត្ថ ន ការតោ បដ្ឋាយ តេន ឆាតិទូរេតិអាទីសុ ន ការបដិសិទ្ធេសុ អាបត្តិ នត្ថីតិ ទស្សេតិ ។

ពាក្យថា ចាប់ផ្តើមតាំងពីខនេះទៅ បានដល់ផ្តើមដោយ ន អក្សរ ក្នុងខវត្ថុថា ន ឧបជ្ឈាយស្ស ភណមាណស្ស ជាដើមទៅដោយពាក្យនោះ រមែងសម្តែងថា មិនមានអាបត្តិក្នុងវត្ថុដែលមាន ន អក្សរ ដែលនៅជាប់ជាបទសម្រេចរូបជាបទមួយជាដើមថា ឆាតិទូរេ មិនត្រូវដើរឲ្យឆ្ងាយ (ពីឧបជ្ឈាយ៍) ពេក (ក្នុងវត្ថុទី១៤) ។

**ក្នុងគម្ពីរអដ្ឋកថាបរិវារៈសម្តែងថា :**

អាបត្តិ នាម បញ្ចន្នំ សហធម្មិកានំ ហោតិ ។ តត្ថ ទ្វិន្នំ និប្បរិយាយេន អាបត្តិ យេវ ។ សិក្ខមានសាមណេរសាមណេរីនំ បន អកប្បិយតា ន វដ្តតីតិ ឥមិនា បរិយាយេន អាបត្តិ ។ តេ អាបត្តឹ ន ទេសាបេតព្វា ។ ទណ្ឌកម្មំ បន តេសំ កាតព្វំ ។

ដែលឈ្មោះថាអាបត្តិរមែងមានដល់សហធម្មិកទាំង ៥ ។ បណ្ដាលសហធម្មិកទាំង៥នោះ អាបត្តិបើសម្ដែងដោយនិប្បរិយាយរមែងមានដល់ភិក្ខុនិងភិក្ខុនីតែពីរពួកប៉ុណ្ណោះ ។ តែអាបត្តិបើសម្ដែងដោយបរិយាយវិញ ពាក្យក្នុងវិន័យត្រង់ណាក៏ដោយ ដែលថា **អកប្បិយ:**(ភាពជារបស់មិនគួរ) **ន វដ្តតិ** (មិនគួរ) អាបត្តិរមែងមានដល់សិក្ខមានា សាមណេរ សាមណេរី, សហធម្មិកទាំង៣ ភិក្ខុមិនគប្បីឲ្យសម្ដែងអាបត្តិចេញទេ តែគប្បីដាក់ទណ្ឌកម្មដល់ពួកលោកវិញ ។

## អនាបត្តិក្នុងវត្តក្ខន្ធកៈ

## ក្នុងគម្ពីរវិមតិវិនោទនីដីកា ២/១៣៣ សម្ដែងថា:

វត្តំ ន បូរេយ្យាតិ វត្តករណាកាលោតិ វត្តុវិជាន-នវសេន ញត្វា មានកោសជ្ជាទិវសេន វា ឧបជ្ឈាយាទីសុ អនាទរេន វា អកាតុំ ន វដ្តតីតិ អជានតាយ វា ន ករេយ្យ ទុក្កដមេវ ។ ពាក្យថា មិនបំពេញវត្ត (ឲ្យបរិបូរណ៍) សេចក្ដីថា ភិក្ខុដឹងដោយអំណាចនៃកិរិយាដឹងវត្តុថា ពេលនេះជាពេលធ្វើវត្តហើយ មិនធ្វើ(វត្ត)ដោយមានះ និងការខ្ជិលជាដើមក្ដី ដោយមិនអើពើក្នុងឧបជ្ឈាយវត្តជាដើមក្ដី ដោយភាពនៃកិរិយាមិនដឹងថា ការមិនធ្វើ(វត្ត) មិនគួរក្ដី រមែងត្រូវអាបត្តិទុក្កដ ។

អសញ្ចិច្ច អសតិយាតិអាទីហិ ច អករោន្តស្ស បន អនាបត្តិ សព្វានិ ហិ វត្ថានិ សេខិយានេវ តស្មា សេខិយេសុ វុត្តនយេនេវេត្ថ សព្វោបិ វិនិច្ឆយោ វេទិតព្វោ ។ មិនជាអាបត្តិ ដល់ភិក្ខុអ្នកមិនធ្វើនូវ(វត្ត) ព្រោះមិនក្លែងក្តី មិនមានសតិជាដើមក្តី ។ មែនពិត(ខន្ធកៈ)វត្តទាំងអស់គឺជាសេខិយវត្តនោះឯង ព្រោះហេតុនោះ សេចក្តីវិនិច្ឆ័យក្នុង(ខន្ធកៈ)ទាំងអស់នោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងសេខិយវត្តហ្នឹងឯង ។

# សិក្សាព្រះវិន័យបិដក

ក្នុងវិនយបិដកចែកចេញជា **និទាន** (ទីកន្លែងបញ្ញត្តិសិក្ខាបទ) **បុគ្គល** (បុគ្គលដែលទ្រង់ប្រារព្ធហើយបញ្ញត្តិសិក្ខាបទ) **វត្ថុ** (អជ្ឈាចារគឺការប្រព្រឹត្តអាក្រក់របស់បុគ្គលនោះៗ) **បទបញ្ញត្តិ** (សេចក្ដីហាមប្រាម) **បទភាជនីយ៍** (បទពង្រីកក្នុងបទបញ្ញត្តិ) **ចក្ក** (សម្ដែងដោយជុំវិញ) **អនាបត្តិ** (វារៈដែលមិនត្រូវអាបត្តិ) ។

**១–និទានជាដើម** ជាដំបូងត្រូវតាមដានរឿងរ៉ាវក្នុង **និទាន បុគ្គល វត្ថុ** ពីខាងដើមឲ្យយល់ជាក់ច្បាស់ជាមុនសិន ព្រោះរឿងរ៉ាវទាំងអស់នោះ ច្រុះបញ្ឆាំងទៅលើបទបញ្ញត្តិ ហើយធ្វើឲ្យយើងដឹងថាហេតុនាំឲ្យទ្រង់បញ្ញត្តិសិក្ខាបទនេះ ព្រោះរឿងយ៉ាងនេះ ។

**២–បញ្ញត្តិ** ចំណុចសំខាន់ដែលត្រូវផ្ដោតគំនិត យកចិត្តទុកដាក់សិក្សា នោះគឺ បទបញ្ញត្តិ ឬបទអនុបញ្ញត្តិនីមួយៗ ហើយត្រូវដឹងរាល់ចំនុចដែលព្រះអង្គទ្រង់ហាមក្នុងបទបញ្ញត្តិ ឬបទអនុបញ្ញត្តិនោះៗ ។

**៣–បទភាជនីយ៍**[១] ដើម្បីឲ្យកាន់តែយល់អត្ថន័យ ក្នុងបទបញ្ញត្តិ

---

(១) ភាជនីយ៍ និង វិភង្គ ខុសគ្នាត្រង់ វិភង្គ ជាឈ្មោះសរុបសិក្ខាបទទាំងអស់ គឺ ភិក្ខុវិភង្គ និងភិក្ខុនី-វិភង្គ ។ ឯបទភាជនីយ៍ ជាបទពង្រីកចំនុចនីមួយៗ ក្នុងបទបញ្ញត្តិ ឧ. **បទភាជនីយំ ឱលោកេតព្វំ**= ត្រួតមើលបទភាជនីយ៍, ភិក្ខុសេពមេថុនធម្មក្នុងសរីរៈ ដែលសត្វនៅមិនបានខាំស៊ី ត្រូវអាបត្តិបារាជិក ។ សេពមេថុនធម្មក្នុងសរីរៈ ដែលសត្វខាំស៊ីហើយដោយច្រើន ត្រូវអាបត្តថុល្លច្ច័យ ។

ទូលំទូលាយថែមទៀត ត្រូវសិក្សាក្នុងបទភាជនីយ៍ នៅក្នុងសិក្ខាបទនោះៗ ដែលជាបទពង្រីកក្នុងចំនុចនីមួយៗ ក្នុងបទបញ្ញត្តិ ។

**៨-តិកបរិច្ឆេទ** គឺជាការសម្តែងចែកជា តិកៈសង្ឃាទិសេសខ្លះ, តិកៈបាចិត្តិយខ្លះ, ឬទុកៈសង្ឃាទិសេសខ្លះ, ទុកៈបាចិត្តិយខ្លះ, ទុកៈ-ទុក្កដខ្លះ មានទៅតាមសិក្ខាបទនីមួយៗ ដោយការសម្គាល់ខុស ដោយការសង្ស័យ និងការសម្គាល់ត្រូវ (ក្នុងសិក្ខាបទវិភង្គ) ។

**៩-ចក្ក** ការសិក្សាចក្ក ដំបូងយើងត្រូវស្គាល់ឈ្មោះនៃចក្កដើម្បីកុំឲ្យច្រឡំគ្នា ដូចជាខណ្ឌចក្ក ឬពទ្ធចក្កជាដើម ព្រោះចក្កខ្លះវិលទៅមុខខ្លះវិលថយក្រោយ ខ្លះខ្លួនឯងវិលជុំវិញគេ ខ្លះទៀតខ្លួនឯងប្រកបជាមួយគេហើយ វិលជុំវិញគេទៀតដូច្នេះជាដើម ។ បន្ទាប់មកធ្វើវង្វង់នៃចក្កសរសេរឈ្មោះធម៌ ដែលព្រះអង្គសម្តែងជាចក្ក ហើយចាប់ផ្តើមអានចក្កខាងដើម ក្នុងបិដកឲ្យយល់ជាមុនសិន បើមិនដូច្នោះទេ នឹងពិបាកយល់តើបទណា ប្រកបជាមួយបទណា ហើយកំណត់ចំណាំក្នុងវង្វង់ចក្កដែលគូរហើយ ទើបចាប់ផ្តើមអានចក្កទីពីរទៀត តាមលំដាប់តទៅហើយកំណត់ចំណាំក្នុងវង្វង់ចក្កមួយៗ រហូតទៅដល់ទីបំផុត ។ ក្នុងការគូរវង្វង់ចក្កនេះ ដើម្បីងាយស្រួលដល់អ្នកពិបាកយល់ ។ តែសម្រាប់អ្នកមានការគិតលឿនរហ័ស គេមិនចាំបាច់គូរវង្វង់ចក្កក៏បាន ការសម្តែងចក្កមានតែក្នុងបារាជិក និងសង្ឃាទិសេសប៉ុណ្ណោះ ។

**៦-វិនីតវត្ថុ** គឺជារឿងរ៉ាវដែលសម្តែងបញ្ជាក់ពី ព្រះសម្មាសម្ពុទ្ធផ្ទាល់ ក៏ជាការបំភ្លឺដល់សិក្ខាបទ ឲ្យកាន់តែច្បាស់លាស់ឡើងបន្ថែមទៀតក្នុងចំណុចខ្លះៗផងដែរ ។ ក្នុងវិនីតវត្ថុនេះ មានសម្តែងតែនៅក្នុងសិក្ខាបទមួយចំនួនខ្លះៗ តែប៉ុណ្ណោះគឺ បារាជិក និងសង្ឃាទិសេស ។

**៧-អនាបត្តិ** វារៈដែលមិនត្រូវអាបត្តិ មានសម្តែងក្នុងគម្ពីរស្រាប់ហើយ ចំនែកវគ្គទាំងឡាយក្នុងខន្ធកៈទាំងអស់ មានអនាបត្តិ ៧ ដោយន័យដូចសេខិយវគ្គ ។

(នេះជាសេចក្តីយល់ដឹងធ្លាប់បានសិក្សាក្នុងបិដក និងអដ្ឋកថាខ្លះៗមក)

# សិក្ខាបទទី ១០

(ក្នុងឱវាទវគ្គ មកជាគ្រឿងបញ្ជាក់)

[៨៤]សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់ អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី (និទាន) ។ សម័យនោះឯងស្ត្រីជាគូរពីដើមរបស់ឧទាយិដ៏មានអាយុ បួសក្នុងសំណាក់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីនោះ តែងមកក្នុងសំណាក់ឧទាយិដ៏មានអាយុរឿយៗ ។ ចំណែកខាងឧទាយិដ៏មានអាយុ (បុគ្គល) តែងទៅក្នុងសំណាក់ភិក្ខុនីនោះរឿយ ។ គ្រានោះ ឧទាយិដ៏មានអាយុម្នាក់ឯង អង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនីនោះតែម្នាក់ឯង (វត្ថុ) ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំង-ឡាយនោះ ពោលទោសតិះដៀល បន្ទោសបង្អាប់ថា ចុះហេតុអ្វីបានជាឧទាយិដ៏មានអាយុម្នាក់ឯង សម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនីតែម្នាក់ឯង ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឧទាយិ ឮថាអ្នកឯងតែម្នាក់ឯង សម្រេចការអង្គុយ ក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនីតែម្នាក់ឯងពិតមែនឬ ។ ឧទាយិភិក្ខុ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងតែម្នាក់ឯងមិន គួរនឹងសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងភិក្ខុនីតែម្នាក់ឯងទេ នែមោឃបុរស ការនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំជនទាំងឡាយ ដែលជ្រះថ្លាហើយ ឲ្យរឹងរិតតែជ្រះថ្លាក្រៃលែងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែង

ឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយសម្រេចការអង្គុយ ក្នុងទីស្ងាត់ជាមួយនឹងភិក្ខុនីតែម្នាក់ និងម្នាក់ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ (បញ្ញត្តិ) ។

[៨៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថាភិក្ខុនី គឺ ស្រីដែលបានឧបសម្បទាក្នុងសំណាក់ឧភតោសង្ឃ ។ ពាក្យថា ជាមួយ គឺក្នុងទីជាមួយ ។ ពាក្យថាតែម្នាក់នឹងម្នាក់ គឺភិក្ខុនឹងភិក្ខុនី ។ ដែលហៅថា ទីស្ងាត់គឺទីកំបាំងភ្នែក ១ ទីកំបាំងត្រចៀក១ ។ ដែលហៅថាទីកំបាំងភ្នែក គឺទីដែលគេមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី ក៏មិនអាចនឹងមើលឃើញបាន ។ ដែលហៅថាទីកំបាំងត្រចៀក គឺទីដែលគេមិនអាចដើម្បីស្តាប់ពាក្យពោលជាប្រក្រតីបាន ។ ពាក្យថា សម្រេចការអង្គុយ សេចក្តីថាកាលភិក្ខុនីអង្គុយ ភិក្ខុអង្គុយជិតក្តី ដេកជិតក្តី ត្រូវអាបត្តិបាចិត្តិយ ។ កាលភិក្ខុអង្គុយភិក្ខុនីអង្គុយជិតក្តីដេកជិតក្តី ត្រូវអាបត្តិបាចិត្តិយ ។ ជនទាំងពីររូប (គឺភិក្ខុនឹងភិក្ខុនី) អង្គុយក្តី ជនទាំងពីររូប(គឺភិក្ខុនិងភិក្ខុនី) ដេកក្តី ត្រូវអាបត្តិបាចិត្តិយ ។ (បទភាជនីយ៍)

[៨៦] ទីស្ងាត់ ភិក្ខុក៏សម្គាល់ថាទីស្ងាត់ ហើយអង្គុយជាមួយនឹងភិក្ខុនី តែមួយនឹងមួយ ត្រូវអាបត្តិបាចិត្តិយ ។ ទីស្ងាត់តែភិក្ខុសង្ស័យហើយអង្គុយជាមួយនឹងភិក្ខុនីតែម្នាក់នឹងមួយម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ ទីស្ងាត់ភិក្ខុសម្គាល់ថាមិនស្ងាត់ ហើយអង្គុយជាមួយនឹងភិក្ខុនីតែម្នាក់នឹងម្នាក់ត្រូវ

អាបត្តិបាចិត្តិយ ។ ទីមិនស្ងាត់ ភិក្ខុសម្គាល់ថា ទីស្ងាត់ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងទីមិនស្ងាត់ ត្រូវអាបត្តិទុក្កដ ។ទីមិនស្ងាត់ភិក្ខុក៏សម្គាល់ថា មិនស្ងាត់ មិនត្រូវអាបត្តិឡើយ ។ (តិកៈបរិច្ឆេទ)

[៨៧] អាបត្តិមិនមាន ដល់ភិក្ខុដែលមានបុរសណាទីមួយ ដែលដឹងសេចក្តីនៅជាពីរនាក់នឹងខ្លួន ១ ដល់ភិក្ខុដែលឈរមិនអង្គុយ ១ ដល់ភិក្ខុដែលមានបំណងនូវទីមិនស្ងាត់ ហើយ(អង្គុយ) ១ ដល់ភិក្ខុដែលមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃអង្គុយនៅ ១ ដល់ភិក្ខុឆ្កួត ១ ដល់ភិក្ខុជាដើមបញ្ញត្តិ ១ (អនាបត្តិ) ។

*(វិន័យបិដក.៤/៨២)*

*(ក្នុងសិក្ខាបទនេះ មិនមានសម្តែងអំពីចក្ក ឬវិនីតវត្ថុទេ ព្រោះបើលើកយកសិក្ខាបទសម្តែងអំពីចក្ក នឹងវិនីតវត្ថុមក វែងឆ្ងាយពេក ដូច្នេះសូមសិក្សាតាមគម្ពីរចុះ )*

# រឿងការវិនិច្ឆ័យរបស់វិន័យធរ

## ព្រះចូឡសុមនត្ថេរ

បានឮមកថា ក្នុងរជ្ជកាលនៃព្រះបាទភាតិយរាជ្យ មានភិក្ខុមួយរូបពាក់សម្ពត់កាសាវៈពណ៌លឿងបណ្តោយ ៧ហត្ថ លើចង្កូយស្មាហើយចូលទៅកាន់លៀនព្រះចេតិយអំពីខាងត្បូង ដើម្បីបូជាចេតិយ ។ ខណៈនោះឯង សូម្បីព្រះរាជាក៏ស្តេចមកដើម្បីថ្វាយបង្គំព្រះចេតិយដែរ ។ វេលានោះកាលដំណើរគេចជៀសនៃមហាជនប្រព្រឹត្តទៅ សេចក្តីវឹកវរនៃមហាជនបៀតបៀនហើយ មើលមិនទាន់នូវសំពត់កាសាវៈ ដែលរបូតធ្លាក់អំពីចង្កូយស្មាឡើយ បានដើរចេញទៅ ។ ក៏គ្រាដើរចេញទៅហើយ កាលមិនឃើញសំពត់កាសាវៈ ក៏ដាក់ធុរៈថា អ្នកណានឹងរកឃើញសំពត់កាសាវៈក្នុងកាលពួកជនវឹកវរបែបនេះ ឥឡូវនេះ សំពត់កាសាវៈនោះមិនមែនជារបស់យើង រួចក៏ដើរចេញទៅ ។ គ្រានោះ មានភិក្ខុដទៃដើរមកខាងក្រោយ បានឃើញនូវសំពត់កាសាវៈនោះ ក៏កាន់យកដោយចិត្តលួចតែត្រឡប់មានសេចក្តីក្តៅក្រហាយឡើង កាលកើតចិត្តគិតឡើងថា ឥឡូវនេះ យើងមិនមែនជាសមណៈទេ យើងនឹងសឹក តែបានគិតថានឹងសាកសួរព្រះវិន័យធរទាំងឡាយមើល ទើបដឹងបាន ។ ក៏ក្នុងសម័យនោះ មានភិក្ខុអ្នកទ្រទ្រង់បរិយត្តិទាំងពួង ឈ្មោះចូឡសុមនត្ថេរ ជាបាតិមោក្ខាចារ្យផ្នែកព្រះវិន័យ សម្រាកនៅក្នុងមហាវិហារ ។ ភិក្ខុនោះចូលទៅរក

ព្រះថេរៈ ហើយថ្វាយបង្គំសូមឱកាសលោក ហើយបានទូលសួរសេចក្ដីសង្ស័យរបស់ខ្លួន ។ ព្រះថេរៈ ជ្រាបដំណើរនៃសំពត់កាសាវៈដែលភិក្ខុអ្នកមកខាងក្រោយនោះកាន់យកនូវសំពត់កាសាវៈនេះ ក៏បានពោលថាបើលោកនាំភិក្ខុជាម្ចាស់សំពត់កាសាវៈមកបាន ខ្ញុំអាចធ្វើទីពឹងឲ្យលោកបាន ។ ភិក្ខុនោះប្រាប់ថា លោកម្ចាស់ ខ្ញុំនឹងរកឃើញភិក្ខុនោះបានដូចម្ដេច ? ព្រះថេរៈប្រាប់ថា លោកចូរទៅពិនិត្យមើលក្នុងទីនោះៗចុះ ។ ភិក្ខុនោះរកមើលមហាវិហារ ៥ កន្លែង ក៏មិនបានជួបឡើយ ។ គ្រានោះព្រះថេរៈសួរភិក្ខុនោះថា ពួកភិក្ខុមកពីទិសណាច្រើន ? ភិក្ខុប្រាប់ថាមកពីទិសខាងត្បូងលោកម្ចាស់ ព្រះថេរៈប្រើថា បើដូច្នោះលោកចូរវាស់សំពត់កាសាវៈទាំងបណ្ដោយទាំងទទឹង ហើយរក្សាទុកចុះ គ្រាទុកហើយចូររកមើលតាមលំដាប់វិហារទិសខាងត្បូង ហើយនាំភិក្ខុនោះមក ។ ភិក្ខុនោះធ្វើតាមពាក្យបង្គាប់នោះហើយ ក៏បានជួបភិក្ខុនោះហើយ នាំមកកាន់សំណាក់ព្រះថេរ ។ ព្រះថេរៈសួរថា នេះជាសំពត់កាសាវៈរបស់លោកឬ? ភិក្ខុម្ចាស់សំពត់ឆ្លើយថា ជារបស់ខ្ញុំលោកម្ចាស់ ។ ព្រះថេរសួរថា លោកធ្វើឲ្យធ្លាក់ក្នុងទីណា ភិក្ខុនោះឆ្លើយប្រាប់រឿងទាំងអស់ហើយ ។ ព្រះថេរបានស្ដាប់ការដាក់ធុរៈដែលលោកធ្វើហើយ ទើបសួរភិក្ខុក្រៅនេះថា លោកបានឃើញសំពត់នេះទីណា ទើបបានកាន់យក ? សូម្បីភិក្ខុអ្នកកាន់យកនេះ ក៏បានប្រាប់រឿងទាំងអស់ ។ តអំពីនោះព្រះ-

ថេរៈ បានពោលនឹងភិក្ខុអ្នកកាន់សំពត់នោះថា បើលោកកាន់យកដោយ ចិត្តបរិសុទ្ធ លោកមិនត្រូវអាបត្តិឡើយ តែព្រោះលោកកាន់យកដោយ ចិត្តលួច លោកក៏ត្រូវអាបត្តិទុក្កដ កាលលោកសម្តែងអាបត្តិនោះហើយ នឹងជាអ្នកមិនមានអាបត្តិ មួយទៀត លោកចូរធ្វើសំពត់កាសាវៈនេះ ឲ្យ ជារបស់ខ្លួន ថ្វាយដល់ភិក្ខុនោះចុះ ។ ភិក្ខុនោះបានប្រសព្វសេចក្តី ស្រោលចិត្ត យ៉ាងក្រៃលែង ដូចបានស្រោចដោយទឹកអម្រឹតដូច្នោះ ។

(រឿងព្រះវិន័យធរចូឡសុមនត្ថេរ ) ចប់

## ព្រះអាភិធម្មិកគោធត្ថេរៈ

បានឮថា ក្នុងប្រទេសច្រាំងសមុទ្រ មានភិក្ខុមួយរូបបានដូងមាន សណ្ឋានស្អាត ទើបឲ្យក្រឡឹងធ្វើផ្តិលទឹក ដែលគួរពេញចិត្ត ដូចជាផ្តិល សំបកស័ង្ខ រួចទុកដាក់ត្រង់ប្រទេសនោះឯង បានទៅកាន់ចេតិយ-គិរីវិហារ ។ គ្រានោះ មានភិក្ខុដទៃ បានទៅកាន់ប្រទេស តាមច្រាំង សមុទ្រ សម្រាកក្នុងវិហារនោះ ឃើញផ្តិលនោះ ។ ក៏កាន់យកដោយ ថេយ្យចិត្ត ហើយមកកាន់ចេតិយគិរីវិហារនុ៎ះឯង ។ កាលលោកចាន់ យាគូនៅក្នុងចេតិយគិរីវិហារនោះ ភិក្ខុម្ចាស់ផ្តិល បានឃើញផ្តិលនោះ ទើបពោលថា លោកបានផ្តិលនេះមកពីណា? ភិក្ខុកាន់យកនោះ ឆ្លើយថា ខ្ញុំនាំមកពីប្រទេសក្បែរច្រាំងសមុទ្រ ។ ភិក្ខុម្ចាស់ផ្តិលនោះពោលថា ផ្តិល នេះមិនមែនជារបស់លោកទេ លោកកាន់យកដោយថេយ្យចិត្ត ទើបបាន

ទាញទៅកណ្ដាលសង្ឃ ។ ក្នុងចេតិយគិរីវិហារនោះ ភិក្ខុទាំងឡាយក៏មិនបានទទួលការវិនិច្ឆ័យ ទើបនាំគ្នាត្រឡប់មកកាន់មហាវិហារ ។ ភិក្ខុទាំងឡាយឲ្យវាយស្គរ ប្រកាសក្នុងមហាវិហារ ហើយធ្វើការប្រជុំក្នុងមហាចេតិយផ្ដើមវិនិច្ឆ័យ ។ ព្រះថេរៈទ្រទ្រង់វិន័យទាំងឡាយ ក៏បានបញ្ញត្តិវោហារ ក៏ភិក្ខុឈ្លាសក្នុងវិន័យឈ្មោះ អាភិធម្មិកគោទត្តត្ថេរ ក៏នៅក្នុងសន្និបាតនោះដែរ ។ ព្រះថេរនោះពោលយ៉ាងនេះថា ភិក្ខុនេះលួចផ្ដិលនេះក្នុងទីណា ? ភិក្ខុទាំងឡាយប្រាប់ថា លោកលួចឯប្រទេសក្បែរប្រាំងសមុទ្រ ។ ព្រះថេរៈសួរថា ក្នុងប្រទេសនោះ ផ្ដិលនេះមានតម្លៃប៉ុន្មាន ? ភិក្ខុទាំងឡាយឆ្លើយថា មិនមានតម្លៃឡើយ ។ ព្រះថេរពោលថា តាមការពិត ក្នុងប្រទេសនោះ ពួកមនុស្សបកសំបកដូងបរិភោគហើយ ចោលត្រឡោក ក៏ត្រឡោកនោះ សម្រេចប្រយោជន៍ជាឱស ។ ភិក្ខុទាំងឡាយឆ្លើយថា មានតម្លៃ ១ មាសកៈ ឬតិចជាង១មាសកៈ ព្រះថេរៈសួរថា តើមានក្នុងទីណាខ្លះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តិបារាជិក ព្រោះទ្រព្យ ១ មាសកៈ ឬតិចជាង ១ មាសកៈ ? កាលព្រះថេរៈពោលយ៉ាងនេះហើយ ក៏មានសម្លេងសាធុការព្រមគ្នាថា សាធុ! សាធុ! ព្រះថេរៈពោលត្រឹមត្រូវហើយ វិនិច្ឆ័យត្រឹមត្រូវហើយ ។ គ្រានោះសូម្បីព្រះបាទភាតិយរាជ ក៏ស្ដេចចេញអំពីព្រះនគរដើម្បីថ្វាយបង្គំព្រះចេតិយ បានស្ដាប់សម្លេងនោះ ទើបត្រាស់សួរថា នោះជាសម្លេងអ្វី ? លុះបាន

ស្តាប់រឿងទាំងអស់តាមលំដាប់ហើយ ទើបទ្រង់ត្រាស់ឲ្យត្រាច់វាយស្គរប្រកាសក្នុងព្រះនគរ ជាហេតុឲ្យដឹងថា កាលយើងនៅមានជីវិត អធិករណ៍របស់ពួកភិក្ខុក្តី ពួកភិក្ខុនីក្តី ពួកគ្រហស្ថក្តី ដែលព្រះអាភិធម្មិកគោទត្តេរ កាត់ក្តីហើយ ជាការវិនិច្ឆ័យត្រឹមត្រូវ យើងនឹងដាក់អាជ្ញាដល់អ្នកដែលមិនតាំងនៅក្នុងក្តីរបស់លោក ។ (អដ្ឋកថា ទុតិយបារាជិក)

(រឿងព្រះអាភិធម្មិកគោទត្តត្ថេរ) ចប់

រឿងទាំងអស់នេះទាក់ទងនិងអទិន្នាទានសិក្ខាបទ ខ្ញុំព្រះករុណាស្រង់មកដើម្បីឆ្លុះបញ្ចាំង ពីសេចក្តីឆ្លាតឈ្លាសក្នុងការវិនិច្ឆ័យ នឹងអានិសង្ស របស់ភិក្ខុអ្នកទ្រទ្រង់ព្រះវិន័យ ដែលអាចធ្វើជាទីពឹងដល់ពួកភិក្ខុដែលមានសេចក្តីសង្ស័យបាន ។

## ព្រះឧបាលិឧទានគាថា

**វិនយម្ហិ មហាត្ថេសុ បេសលានំ សុខាវហោ និគ្គហានញ្ច បាបិច្ឆេ លជ្ជីនំ បគ្គហេសុ ច សាសនាធារណោ ចេវ សព្វញ្ញុជិនគោចរេ អនញ្ញវិសយេ ខេមេ សុប្បញ្ញត្តេ អសំសយេ ខន្ធកេ វិនយេ ចេវ បរិវារេ ច មាតិកេ យថាត្ថការី កុសលោ បដិបជ្ជតិ យោនិសោ ។**

-កាលបើព្រះវិន័យមានប្រយោជន៍ដ៏ធំ នាំមកនូវសេចក្ដីសុខ ដល់ភិក្ខុមានសីលជាទីស្រលាញ់ទាំងឡាយ ជាសភាវៈទ្រទ្រង់ទុកនូវសាសនាផង ជាទីគោចររបស់ព្រះជិនស្រីជាសព្វញ្ញូផង មិនមែនជាវិស័យនៃបុគ្គលដទៃ ជាទីក្សេមក្សាន្ត ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយដោយប្រពៃ ដើម្បីសង្កត់សង្កិននូវពួកភិក្ខុដែលមានសេចក្ដីប្រាថ្នាលាមកផង ដើម្បីតម្កល់តម្កើងនូវពួកភិក្ខុដែលមានសេចក្ដីខ្មាសផង ដោយឥតសង្ស័យ អ្នកប្រាជ្ញដែលមានប្រក្រតីធ្វើនូវប្រយោជន៍ដ៏សមគួរ តែងប្រតិបត្តិដោយឧបាយក្នុងខន្ធកៈវិន័យផង ក្នុងបរិវារៈផង ព្រមទាំងមាតិកា ។

**យោ គវំ ន វិជានាតិ ន សោ រក្ខតិ គោគណំ**
**ឯវំ សីលំ អជានន្តោ កឹ សោ រក្ខេយ្យ សំវរំ ។**

បុគ្គលណាមិនស្គាល់គោ បុគ្គលនោះនឹងរក្សាហ្វូងគោដូចម្ដេចបាន យ៉ាងណាមិញ ភិក្ខុណាមិនស្គាល់សីល ភិក្ខុនោះ នឹងរក្សាសេចក្ដីសង្រួមក្នុងសីលដូចម្ដេចបាន យ៉ាងនោះដែរ ។

**បមុដ្ឋម្ហិ ច សុត្តន្តេ អភិធម្មេ ច តាវទេ**
**វិនយេអវិនដ្ឋម្ហិ បុន តិដ្ឋតិ សាសនំ ។**

បើទុកជាព្រះសូត្រ និងព្រះអភិធម្មសាបសូន្យអស់ទៅហើយ តែបើព្រះវិន័យមិនទាន់វិនាសនៅឡើយទេ ព្រះពុទ្ធសាសនា ឈ្មោះថា ឋិតនៅតទៅទៀតបាន ។ (វិនយបិដក ៦/៣២៤)

# ពួកធម៌ផ្សេងៗ

## សម្រាប់សូត្រ និង ជាគោលសម្រាប់ចងចាំខ្លះៗ

# ប្រយោជន៍នៃការសិក្សាព្រះវិន័យ

វិនយោ សំវរត្ថាយ,វិន័យដើម្បីប្រយោជន៍ដល់សេចក្តីសង្រួម

សំវរោ អវិប្បដិសារត្ថាយ, សេចក្តីសង្រួមដើម្បីប្រយោជន៍ដល់សេចក្តីមិនក្តៅក្រហាយចិត្ត ។

អវិប្បដិសារោ បាមុជ្ជត្ថាយ, សេចក្តីមិនក្តៅក្រហាយចិត្តដើម្បី ប្រយោជន៍ដល់បាមុជ្ជៈ គឺសេចក្តីរីករាយទន់ ។

បាមុជ្ជំ បីតត្ថាយ, បាមុជ្ជៈដើម្បីប្រយោជន៍ដល់បីតិគឺសេចក្តីរីករាយដ៏ក្លា

បីតិ បស្សទ្ធត្ថាយ, បីតិដើម្បីប្រយោជន៍ដល់បស្សទ្ធិ គឺសេចក្តីស្ងប់រម្ងាប់ ។

បស្សទ្ធិ សុខត្ថាយ, បស្សទ្ធិដើម្បីប្រយោជន៍ដល់សុខៈ គឺសេចក្តីសុខកាយសប្បាយចិត្ត ។

សុខំ សមាធត្ថាយ, សុខៈដើម្បីប្រយោជន៍ដល់សមាធិ គឺតម្កល់ចិត្តមាំ ។

សមាធិ យថាភូតញ្ញាណទស្សនត្ថាយ, សមាធិដើម្បីប្រ-យោជន៍ដល់យថាភូតញ្ញាណទស្សនៈ គឺតរុណវិបស្សនា (វិបស្សនាទន់ខ្ចី)

យថាភូតញ្ញាណទស្សនំ និព្វិទត្ថាយ, យថាភូតញ្ញាណ-

ទស្សនៈដើម្បីប្រយោជន៍ដល់និព្វិទា គឺ ពលវៈវិបស្សនា (វិបស្សនាមានកម្លាំង) ។

និព្វិទា វិរាគត្ថាយ, និព្វិទាដើម្បីប្រយោជន៍ដល់វិរាគៈ គឺ អរិយមគ្គ ។

វិរាគោ វិមុត្តត្ថាយ, វិរាគៈដើម្បីប្រយោជន៍ដល់វិមុត្តិ គឺ អរហត្តផល ។

វិមុត្តិ វិមុត្តិញ្ញាណទស្សនត្ថាយ, វិមុត្តិដើម្បីប្រយោជន៍ដល់វិមុត្តិញ្ញាណទស្សនៈគឺ បច្ចវេក្ខណញ្ញាណ ។

វិមុត្តិញ្ញាណទស្សនំ អនុបាទាបរិនិព្វានត្ថាយ, វិមុត្តិញ្ញាណទស្សនៈ ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន គឺ រំលត់មិនឲ្យមានបច្ច័យជាគ្រឿងប្រកាន់តទៅ ។

(វិនយបិដក ១៣/១៩៤)

## ប្រយោជន៍ព្រះវិន័យ ១០ យ៉ាង

សត្ថា សាវកានំ សិក្ខាបទំ បញ្ញាបេតិ ទស អត្ថវសេ បដិច្ច, ព្រះបរមសាស្តាទ្រង់ត្រាស់បញ្ញត្តិសិក្ខាបទដល់សាវ័កទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍១០ យ៉ាង គឺ ៖

១-សង្ឃសុដ្ឋុតាយ , ដើម្បីសេចក្តីល្អដល់សង្ឃ

២-សង្ឃផាសុតាយ, ដើម្បីការនៅសប្បាយដល់សង្ឃ

៣-ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ, ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលទ្រុស្តសីល

៤-បេសលានំ ភិក្ខូនំ ផាសុវិហារាយ, ដើម្បីកិរិយានៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រលាញ់

៥-ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ, ដើម្បីរារាំងនូវអាសវៈធម៌ទាំងឡាយក្នុងបច្ចុប្បន្ន

៦-សម្បរាយិកានំ អាសវានំ បដិឃាតាយ, ដើម្បីកំចាត់បង់នូវអាសវៈធម៌ទាំងឡាយក្នុងបរលោក ។

៧-អប្បសន្នានំ បសាទាយ, ដើម្បីញុំាងបុគ្គលទាំង-ឡាយ ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ។

៨-បសន្នានំ ភិយ្យោភាវាយ, ដើម្បីញុំាងបុគ្គលទាំង-ឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើង

៩-សទ្ធម្មដ្ឋិតិយា, ដើម្បីឲ្យព្រះសទ្ធម្មតម្កល់នៅមាំ

១០-វិនយានុគ្គហាយ, ដើម្បីអនុគ្រោះដល់ព្រះវិន័យ ។

(វិនយបិដក ១៣/១១០)

## អានិសង្សរបស់ភិក្ខុអ្នកទ្រទ្រង់ព្រះវិន័យ

វិនយធរស្ស បញ្ចានិសំសា, អានិសង្ស ៥ របស់ភិក្ខុអ្នកទ្រទ្រង់ព្រះវិន័យ ៖

១-អត្តនោ សីលក្ខន្ធោ សុគុត្តោ ហោតិ សុរក្ខិតោ សីលក្ខន្ធរបស់ខ្លួន ឈ្មោះថាភិក្ខុនោះបានគ្រប់គ្រងរក្សាដោយល្អ ។

២-កុក្កុច្ចប្បកតានំ បដិសរណំ ហោតិ, ភិក្ខុនោះតែងជាទីពឹងនៃពួកភិក្ខុដែលមានសេចក្តីសង្ស័យជាប្រក្រតី ។

៣-វិសារទោ សង្ឃមជ្ឈេ វោហរតិ, ភិក្ខុនោះជាអ្នកក្លៀវក្លានិយាយក្នុងកណ្តាលជំនុំសង្ឃ ។

៤-បច្ចត្ថិកេ សហធម្មេន សុនិគ្គហិតំ និគ្គណ្ហាតិ,

ភិក្ខុនោះរមែងសង្កត់សង្កិនដោយល្អ នូវពួកសត្រូវដោយសហធម៌ គឺសិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិទុក ។

៥-សទ្ធម្មដ្ឋិតិយា បដិបន្នោ ហោតិ, ភិក្ខុនោះឈ្មោះថាជាអ្នកប្រតិបត្តិដើម្បីញុំាងព្រះសទ្ធម្មឲ្យតាំងនៅមាំ ។

(វិនយបិដក ១៣/៧៣)

## អាការៈដែលភិក្ខុត្រូវអាបត្តិ

អាបត្តាបជ្ជនាការ, អាការៈដែលភិក្ខុនឹងត្រូវអាបត្តិទាំងអស់មាន ៦ យ៉ាង ៖

១-អលជ្ជិតា, ត្រូវដោយមិនមានសេចក្ដីអៀនខ្មាស

២-អញ្ញាណតា , ត្រូវដោយការមិនស្គាល់អាបត្តិ

៣-កុក្កុច្ចប្បកតត្តា , ត្រូវដោយសង្ស័យហើយចេះតែធ្វើ

៤-អកប្បិយេ កប្បិយសញ្ញិតា, ត្រូវដោយសម្គាល់ថាគួរក្នុងរបស់ដែលមិនគួរ

៥-កប្បិយេ អកប្បិយសញ្ញិតា , ត្រូវដោយសម្គាល់ថាមិនគួរ ក្នុងរបស់ដែលគួរ ។

៦-សតិសម្មោសា , ត្រូវដោយភ្លេចស្មារតី ។

(កង្ខាវិតរណី ១/៤១)

## ខន្ធកៈវត្ត ១៤

១-អាគន្តុកវត្ត, វត្តរបស់ភិក្ខុអ្នកមកដល់ថ្មី

២-អាវាសិកវត្ត, វត្តរបស់ភិក្ខុអ្នកចៅអាវាស

៣-គមិកវត្ត, វត្តរបស់ភិក្ខុអ្នកធ្វើដំណើរទៅ

៤-អនុមោទនាវត្ត, វត្តរបស់ភិក្ខុអ្នកធ្វើអនុមោទនាក្នុងរោងចាន់

៥-ភត្តគ្គវត្ត, វត្តរបស់ភិក្ខុអ្នកចូលទៅកាន់រោងចាន់

៦-បិណ្ឌបាតិកវត្ត,វត្តរបស់ភិក្ខុអ្នកត្រាច់ទៅដើម្បីបិណ្ឌបាត

៧-អារញ្ញិកវត្ត, វត្តរបស់ភិក្ខុអ្នកនៅក្នុងព្រៃ

៨-សេនាសនវត្ត, វត្តរបស់ភិក្ខុត្រូវធ្វើចំពោះទីសេនាសនៈ

៩-ជន្តាឃរវត្ត, វត្តរបស់ភិក្ខុត្រូវធ្វើចំពោះផ្ទះជាទីរក្សាកាយ

១០-វច្ចកុដិកវត្ត, វត្តរបស់ភិក្ខុត្រូវធ្វើចំពោះបង្គន់

១១-ឧបជ្ឈាយវត្ត, វតរបស់សទ្ធិវិហារិកត្រូវធ្វើចំពោះព្រះ-ឧបជ្ឈាយ៍

១២-សទ្ធិវិហារិកវត្ត, វត្តរបស់ឧបជ្ឈាយ៍ត្រូវធ្វើចំពោះសទ្ធិវិហារិក

១៣-អាចរិយវត្ត, វត្តរបស់អន្តេវាសិកត្រូវធ្វើចំពោះអាចារ្យ

១៤-អន្តេវាសិកវត្ត,វត្តរបស់អាចារ្យត្រូវធ្វើចំពោះអន្តេវាសិក ។

*( វិនយបិដក ១១/៩៤...)*

## ព្រះនិព្វាន ៩ បទ

១-មទនិម្មទនោ ... 

២-មទនិម្មទនាយ, ដើម្បីញាំញីនូវសេចក្តីស្រវឹង

៣-បិបាសវិនយាយ, ដើម្បីកម្ចាត់បង់នូវសេចក្តីស្រេកឃ្លានក្នុងកាម

៤-អាលយសមុគ្ឃាតាយ, ដើម្បីដកចេញនូវសេចក្តីអាល័យក្នុងកាម

៥–វដ្ដុបច្ឆេទាយ, ដើម្បីផ្ដាច់បង់នូវវដ្ដៈ

៦–តណ្ហាក្ខយាយ, ដើម្បីអស់ទៅនៃតណ្ហា

៧–វិរាគាយ, ដើម្បីប្រាសចាកតម្រេក

៨–និរោធាយ, ដើម្បីរំលត់

៩–និព្វានាយ, ដើម្បីព្រះនិព្វាន ។

( វិនយបិដក ១/៦២)

## ពាក្យថាភិក្ខុមានវិគ្រោះថា

១–ភិក្ខកោតិ ភិក្ខុ, សមណៈណាជាអ្នកសូម សមណៈនោះហៅថា ភិក្ខុ

២–ភិក្ខាចរិយំ អជ្ឈុបគតោតិ ភិក្ខុ, សមណៈណាចូលទៅអាស្រ័យនូវភិក្ខាចរិយវត្ត សមណៈនោះហៅថា ភិក្ខុ

៣–ភិន្នបដធរោតិ ភិក្ខុ, ជនណាទ្រទ្រង់នូវសម្ពត់ដែលគេកាត់ហើយ ជននោះហៅថា ភិក្ខុ

៤–សាមញ្ញាយ ភិក្ខុ, ជនដែលហៅថាភិក្ខុ ព្រោះហេតុវោហារបញ្ញត្តិថា សមណៈ

៥–បដិញ្ញាយ ភិក្ខុ, ដែលហៅថាភិក្ខុព្រោះបានប្ដេជ្ញាខ្លួន

៦–ឯហិភិក្ខូតិ ភិក្ខុ, ហៅថាភិក្ខុព្រោះសម្រេចជាឯហិភិក្ខុ

៧-តីហិ សរណាគមនេហិ ឧបសម្បន្នោតិ ភិក្ខុ, ហៅថា ភិក្ខុ ព្រោះបានឧបសម្បទាដោយសរណគមន៍ ៣

៨-ភទ្រោតិ ភិក្ខុ, ហៅថាភិក្ខុព្រោះហេតុជាអ្នកចម្រើន

៩-សារោតិ ភិក្ខុ, ហៅថាភិក្ខុព្រោះមានសារធម៌

១០-សេក្ខោតិ ភិក្ខុ , ហៅថាភិក្ខុព្រោះជាអ្នកសិក្សា

១១-អសេក្ខោតិ ភិក្ខុ, ហៅថាភិក្ខុព្រោះមិនបាច់សិក្សា

១២-សមគ្គេន សង្ឃេន ញត្តិចតុត្ថេន កម្មេន អកុប្បេន ឋានារហេន ឧបសម្បន្នោតិ ភិក្ខុ, ហៅថាភិក្ខុ ព្រោះបានឧបសម្បទាដោយញត្តិចតុត្ថកម្មវាចា ដ៏សមគួរដល់ហេតុដែលមិនមានសេចក្តីអន្តរាយ ដោយសង្ឃដែលព្រមព្រៀងហើយ ។

(វិនយបិដក ១/៧៣)

## ពាក្យថា (ភិក្ខុ) ណាមួយអធិប្បាយថា

យោ បនាតិ, យោ យាទិសោ, យថាយុត្តោ, យថាជច្ចោ, យថានាមោ, យថាគោត្តោ, យថាសីលោ, យថាវិហារី យថាគោចរោ, ថេរោ វា, នវោ វា, មជ្ឈិមោ វា, ឯសោ វុច្ចតិ យោ បនាតិ ។

ត្រង់ពាក្យថា (ភិក្ខុ) ណាមួយ អធិប្បាយថា ភិក្ខុជាថេរៈក្តី ភិក្ខុបួសថ្មីក្តី ភិក្ខុកណ្តាលក្តីឯណា គឺថាតាមតែភិក្ខុរូបណា ដែលប្រកបក្នុងកម្មយ៉ាងណា មានជាតិយ៉ាងណា មានឈ្មោះយ៉ាងណា មានគោត្តយ៉ាងណា មានប្រក្រតីយ៉ាងណា មានគ្រឿងនៅយ៉ាងណា មានគោចរយ៉ាងណាក៏ដោយ ភិក្ខុនេះតថាគតហៅថា (ភិក្ខុ) ណាមួយ ។

(វិនយបិដក ១/៧៣)

## ឧបសម្បទា ៨ យ៉ាង

១-ឯហិភិក្ខុឧបសម្បទា , គឺឧបសម្បទាដោយព្រះតម្រាស់ថា អ្នកចូរជាភិក្ខុចុះ

២-សរណាគមនឧបសម្បទា, គឺ ឧបសម្បទាដោយសរណ-គមន៍៣

៣-ឱវាទប្បដិគ្គហណឧបសម្បទា, គឺឧបសម្បទាដោយទទួលឱវាទ

៤-បញ្ហាព្យាករណឧបសម្បទា, គឺ ឧបសម្បទាដោយការដោះស្រាយបញ្ហាព្យាករណ៍

៥-គរុធម្មប្បដិគ្គហណឧបសម្បទា, គឺ ឧបសម្បទាដោយគរុធម៌

៦-ទូតេនឧបសម្បទា , គឺ ឧបសម្បទាដោយទូត

៧-អដ្ឋវាចិកាឧបសម្បទា, គឺឧបសម្បទាដោយឧភតោសង្ឃ គឺ សង្ឃទាំងពីរចំណែក

៨-ញត្តិចតុត្ថកម្មឧបសម្បទា, គឺឧបសម្បទាដោយញត្តិ-ចតុត្ថកម្មវាចា ។

(កង្ខាវិតរណី ១/៥០)

## លក្ខណៈសម្រាប់វិនិច្ឆ័យក្នុងសិក្ខាបទទាំងអស់មាន ១៧ យ៉ាង

១-និទានំ, ទីកន្លែងដែលទ្រង់បញ្ញត្តិសិក្ខាបទ

២-បុគ្គលំ, បុគ្គលដែលទ្រង់ប្រារព្ធហើយបញ្ញត្តិសិក្ខាបទ

៣-វត្ថុំ , អជ្ឈាចារគឺការប្រព្រឹត្តិអាក្រក់របស់បុគ្គលនោះៗ

៤-បញ្ញត្តិ, សេចក្តីបញ្ញត្តិហាមប្រាម

៥-អាណត្តិ, ប្រយោគធ្វើខ្លួនឯង ឬឲ្យគេធ្វើ

៦-អាបត្តិ, ជាឈ្មោះនៃទោសផ្សេងៗ

៧-អនាបត្តិ, វារៈដែលមិនត្រូវអាបត្តិ

៨-វិបត្តិ, ការវិនាសចាកសីលជាដើម

៩-អង្គំ , អង្គជាគ្រឿងសម្រាប់វិនិច្ឆ័យអាបត្តិ

១០-សមុដ្ឋានំ, ហេតុជាទីតាំងនាំឲ្យត្រូវអាបត្តិ

១១-កិរិយា, អាបត្តិត្រូវព្រោះធ្វើ ឬមិនធ្វើ

១២-សញ្ញា, គឺសញ្ញាវិមោក្ខ និងនោសញ្ញាវិមោក្ខ

១៣-ចិត្តំ, ត្រូវអាបត្តិប្រកបដោយចិត្ត ឬមិនប្រកបដោយចិត្ត

១៤-វជ្ជំ, ទោសផ្លូវលោក ឬផ្លូវបញ្ញត្តិ

១៥-កម្មំ, ជាអំពើធ្វើតាមផ្លូវកាយ ឬវាចាហើយត្រូវអាបត្តិ

១៦-កុសលត្តិកំ, ត្រូវអាបត្តិព្រោះកុសលចិត្តជាដើម

១៧-វេទនត្តិកំ, ត្រូវអាបត្តិព្រោះសុខវេទនាជាដើម។

(កង្ខាវិតរណី ១ /៦៥)

## **ទ្វារមគ្គ ៣០**

| | ស្រី | ប្រុស | ខ្ទើយ | ភេទពីរ |
|---|---|---|---|---|
| មនុស្ស | ៣ | ២ | ២ | ៣ |
| អមនុស្ស | ៣ | ២ | ២ | ៣ |
| តិរច្ឆាន | ៣ | ២ | ២ | ៣ |
| សរុប ៣០ | ៩ | ៦ | ៦ | ៩ |

# ការពោលលាសិក្ខា

១-ពុទ្ធំ បច្ចក្ខាមិ, ខ្ញុំសូមលាព្រះពុទ្ធ

២-ធម្មំ បច្ចក្ខាមិ, ខ្ញុំសូមលាព្រះធម៌

៣-សង្ឃំ បច្ចក្ខាមិ, ខ្ញុំសូមលាព្រះសង្ឃ

៤-សិក្ខំ បច្ចក្ខាមិ, ខ្ញុំសូមលាសិក្ខា

៥-វិនយំ បច្ចក្ខាមិ, ខ្ញុំសូមលាវិន័យ

៦-បាតិមោក្ខំ បច្ចក្ខាមិ, ខ្ញុំសូមលាបាតិមោក្ខ

៧-ឧទ្ទេសំ បច្ចក្ខាមិ, ខ្ញុំសូមលាឧទ្ទេស

៨-ឧបជ្ឈាយំ បច្ចក្ខាមិ, ខ្ញុំសូមលាព្រះឧបជ្ឈាយ៍

៩-អាចរិយំ បច្ចក្ខាមិ, ខ្ញុំសូមលាអាចារ្យ

១០-សទ្ធិវិហារិកំ បច្ចក្ខាមិ, ខ្ញុំសូមលាសទ្ធិវិហារិក

១១-អន្តេវាសិកំ បច្ចក្ខាមិ, ខ្ញុំសូមលាអន្តេវាសិក

១២-សមានុបជ្ឈាយកំ បច្ចក្ខាមិ, ខ្ញុំសូមលាបព្វជិតដែលមាន ឧបជ្ឈាយ៍ស្មើគ្នា

១៣-សមានាចរិយកំ បច្ចក្ខាមិ, ខ្ញុំសូមលាបព្វជិតដែលមាន អាចារ្យស្មើគ្នា

១៤-សព្រហ្មចារិំ បច្ចក្ខាមិ, ខ្ញុំសូមលាសព្រហ្មចារី

# ៨ បទដទៃទៀត

១-គហីតិ មំ ធារេហិ, លោកចូរចាំទុកនូវខ្ញុំថា ជាគ្រហស្ថចុះ

២-ឧបាសកោតិ មំ ធារេហិ, លោកចូរចាំទុកនូវខ្ញុំថាជាឧបាសក

៣-អារាមិកោតិ មំ ធារេហិ, លោកចូរចាំទុកនូវខ្ញុំថាជាអារាមិជន

៤-សាមណេរោតិ មំ ធារេហិ, លោកចូរចាំទុកនូវខ្ញុំថាជាសាមណេរ

៥-តិត្ថិយោតិ មំ ធារេហិ, លោកចូរចាំទុកនូវខ្ញុំថាជាតិរ្ថិយ

៦-តិត្ថិយសាវកោតិ មំ ធារេហិ, លោកចូរចាំទុកនូវខ្ញុំថាជាសាវ័ករបស់តិរ្ថិយ

៧-អស្សមណោតិ មំ ធារេហិ, លោកចូរចាំទុកនូវខ្ញុំថា មិនមែនជាសមណៈ

៨-អសក្យបុត្តិយោតិ មំ ធារេហិ, លោកចូរចាំទុកនូវខ្ញុំថាមិន-មែនជាសក្យបុត្តចុះ ។

-ការពោលលា រមែងមានដោយអំណាចបទជាវេវចនៈនោះពិតរមែងមិនមានដល់ភិក្ខុ កាលពោលពាក្យអតីត ពាក្យអនាគត ពាក្យ-បរិកប្បៈជាដើមថា ៖

១-បច្ចក្ខាសឹ, ខ្ញុំលះបង់ហើយក្តី

២-បច្ចក្ខិស្សំ, ខ្ញុំនឹងលះបង់ក្តី

៣-មំ ធារេសិ, លោកគប្បីចាំទុកនូវខ្ញុំក្តី

៤-មំ ធារេស្សសិ, លោកនឹងចាំទុកនូវខ្ញុំក្តី

៥-យន្នូនាហំ បច្ចក្ខេយ្យំ, ធ្វើដូចម្តេចហ្ន៎ ខ្ញុំព្រះករុណាគប្បីលះបង់ក្តី ។

## ហេតុនាំឱ្យស្ត្រីតាំងគភ៌ ៧ យ៉ាង

ព្រោះការស្ទាបអង្អែលកាយ ១ ព្រោះការចាប់សម្លត់(ស្លៀកដណ្តប់) ១ ព្រោះការផឹកទឹកអសុចិ ១ ព្រោះការស្ទាបអង្អែលផ្ចិត (របស់ស្ត្រី) ១ ព្រោះការសម្លឹងមើលរូប ១ ព្រោះសម្លេង ១ ព្រោះក្លិន ១ ។

(អដ្ឋកថា បឋមបារាជិក)

## លក្ខណៈមិនចាំងអាបត្តិ ១០ យ៉ាង

១-អាបត្តិ ច ហោតិ, អាបត្តិមាន

២-អាបត្តិសញ្ញី ច, ភិក្ខុសម្គាល់ថា មានអាបត្តិ

៣-បកតត្តោ ច ហោតិ, ភិក្ខុមានខ្លួនជាប្រក្រតី

៤-បកតត្តសញ្ញី ច, ភិក្ខុសម្គាល់ថា មានខ្លួនជាប្រក្រតី

៥-អនន្តរាយិកោ ច ហោតិ, អន្តរាយមិនមាន

៦-អនន្តរាយិកសញ្ញី ច, ភិក្ខុសម្គាល់ថា អន្តរាយមិនមាន

៧-បហុ ច ហោតិ, អាច

៨-បហុសញ្ញី ច,   ភិក្ខុសម្គាល់ថាអាច

៩-ជានេត្ុកាមោ ច ហោតិ,   មានបំណងនឹងលាក់អាបត្តិ

១០-ជានេតិ ច,   លាក់អាបត្តិ ។ (កង្ខា ១/១៥៤)

## អន្តរាយ ១០ យ៉ាង

១-រាជន្តរាយោ,   អន្តរាយអំពីព្រះរាជា

២-ចោរន្តរាយោ,   អន្តរាយអំពីចោរ

៣-អគ្យន្តរាយោ,   អន្តរាយអំពីភ្លើង

៤-ឧទកន្តរាយោ,   អន្តរាយអំពីទឹក

៥-មនុស្សន្តរាយោ,   អន្តរាយអំពីមនុស្ស

៦-អមនុស្សន្តរាយោ,   អន្តរាយអំពីអមនុស្ស

៧-វាឡន្តរាយោ,   អន្តរាយអំពីសត្វសាហាវ

៨-សិរីសបន្តរាយោ,   អន្តរាយអំពីសត្វមានពិស

៩-ជីវិតន្តរាយោ,   អន្តរាយដល់ជីវិត

១០-ព្រហ្មចរិយន្តរាយោ,   អន្តរាយដល់ព្រហ្មចរិយ ។ (កង្ខា.១/១៥៤.)

## បរិវាស ៣ យ៉ាង

១-បដិច្ឆន្នបរិវាស,   បរិវាសដែលសង្ឃគប្បីឲ្យដោយអាបត្តិ (សង្ឃាទិសេស) ដែលភិក្ខុបិទបាំងទុក

២-សុទ្ធន្តបរិវាស, បរិវាសដែលសង្ឃគប្បីឲ្យ តាមកំណត់កាល ដែលមានបរិសុទ្ធជាទីបំផុត

៣-សមោធានបរិវាស, បរិវាសដែលសង្ឃគប្បីឲ្យដោយការប្រជុំអាបត្តិ ។

(កង្ខា ១/១៥៦)

## ភិក្ខុក្រាលកឋិនបានអានិសង្ស ៥

១-អនាមន្តចារោ, ត្រាច់ទៅណាមិនចាំបាច់លាភិក្ខុផងគ្នា (ចារិត្តសិក្ខាបទ)

២-អសមាទានចារោ, ត្រាច់ទៅណាមិនបាច់យកចីវរគ្រប់ប្រដាប់ទៅ

៣-យាវទត្ថចីវរំ, ទុកដាក់អតិរេកចីវរតាមត្រូវការ មិនបាច់អធិដ្ឋាន ឬវិកប្ប

៤-គណភោជនំ, ឆាន់គណៈភោជនបាន

៥-យោ ច តត្ថ ចីវរុប្បាទោ តស្មឹ អាវាសេ សង្ឃស្ស ឧប្បន្នចីវរំ, ចីវរណាកើតឡើងក្នុងអាវាសនោះ គឺចីវរដែលកើតឡើងដល់សង្ឃក្នុងអាវាសនោះ រមែងបានដល់លោក ។

(កង្ខា.១/១៧២)

## កឋិនដោះដោយមាតិកា ៨

១-បក្កមនន្តិកា, មានការចៀសចេញទៅជាកំណត់

២-និដ្ឋានន្តិកា, មានការធ្វើចីវរសម្រេចជាកំណត់

៣-សន្និដ្ឋានន្តិកា, មានសេចក្តីសន្និដ្ឋានជាកំណត់

៤-នាសនន្តិកា, មានចីវរវិនាសទៅជាកំណត់

៥-សវនន្តិកា, មានការឮដំណឹងជាកំណត់

៦-អសាវច្ឆេទិកា, អស់សេចក្តីសង្ឃឹម

៧-សីមាតិក្កមនន្តិកា, មានការកន្លងខេត្តកឋិនជាកំណត់

៨-សហុព្ភារា, សង្ឃព្រមព្រៀងគ្នាដោះកឋិន ។

## ចីវរ ៦ យ៉ាង

១-ខោមំ, សំពត់សំបកឈើ

២-កប្បាសិកំ, សំពត់កប្បាស

៣-កោសេយ្យំ, សំពត់សូត្រ

៤-កម្ពលំ, សំពត់រោមសត្វ

៥-សាណំ, សំពត់សំបកធ្មៃ

៦-ភង្គំ, សំពត់ដែលលាយដោយអំបោះទាំង៥

មានអំបោះសំរេចដោយសំបកឈើជាដើម ។ (កង្ខា.១/១៧៣)

## ចីវរដាច់អធិដ្ឋានដោយហេតុ ៨ យ៉ាង

១-អញ្ញស្ស ទានេន, ដោយឲ្យដល់ជនដទៃ

២-អច្ឆិន្ទិត្វា គហណេន, ដោយពួកចោរជាដើមដណ្ដើមយក

៣-វិស្សាសគ្គហណេន, ដោយការកាន់យកជារបស់ស្និទ្ធស្នាល

៤-ហីនាយាវត្តនេន, ដោយត្រឡប់ទៅរកភេទដ៏ថោកទាប គឺសឹក

៥-សិក្ខាបច្ចក្ខានេន, ដោយតាំងនៅក្នុងភាវៈ ជាភិក្ខុហើយពោលលាសិក្ខា

៦-កាលកិរិយាយ, ដោយធ្វើមរណៈកាល

៧-លិង្គបរិវត្តនេន, ដោយត្រឡប់ភេទ

៨-បច្ចុទ្ធរណេន, ដោយដក(ពិន្ទុ) ។

## វត្ថុនិស្សគ្គិយមាន ៤

១-សុវណ្ណំ, មាស

២-រជតំ, ប្រាក់

៣-កហាបណោ, កហាបណៈ

៤-មាសកោ, មាសកៈ

## វត្ថុនៃទុក្កដមាន ១៥

១-មុត្តា, កែវមុក្តា

២-មណិ,　　　　　កែវមណិ

៣-វេឡុរិយោ ,　　កែវពៃទូរ

៤-សង្ខោ ,　　　　សង្ខ

៥-សិលា ,　　　　កែវសិលា

៦-បវាឡំ,　　　　កែវបវាឡ

៧-លោហិតង្គោ,　　កែវក្រហម(កែវទទឹម)

៨-មសារគល្លំ,　　　កែវមរកត(កែវពព្រុះ)

៩-សត្ត ធញ្ញានិ,　　ស្រូវ ៧ ប្រភេទ

១០-ទាសី,　　　　ខ្ញុំស្រី

១១-ទាសា ,　　　　ខ្ញុំប្រុស

១២-ខេត្តំ,　　　　ស្រែ

១៣-វត្ថុ,　　　　　ចំការ

១៤-បុប្ផារាមោ,　　សួនផ្កា

១៥-ផលារាមោ ,　　សួនផ្លែជាដើម ជាវត្ថុនៃអាបត្តិទុក្កដ ។

ភិក្ខុមិនគួរទទួលដើម្បីប្រយោជន៍ខ្លួន ឬដើម្បីប្រយោជន៍ដល់ចេតិយ សង្ឃ គណៈ ឬបុគ្គលឡើយ ។

(កង្ខាវិតរណី ១/២១៨)

## អវហារ ២៥

(អាការៈលួច ២៥)

ចែកជាពួកមាន ៥ពួកគឺ:

~នានាភណ្ឌបញ្ចកៈពួក ១ ~ឯកភណ្ឌបញ្ចកៈពួក ១

~សាហត្ថិកបញ្ចកៈពួក ១ ~បុព្វប្បយោគបញ្ចកៈពួក ១

~ថេយ្យាវហារបញ្ចកៈពួក ១

### នានាភណ្ឌបញ្ចកៈពួកទី ១

១–អាទិយេយ្យ, គប្បីដណ្តើមយក

២–ហរេយ្យ, គប្បីនាំទៅ

៣–អវហរេយ្យ, គប្បីចបោយក

៤–ឥរិយាបថ វិកោបេយ្យ, គប្បីញុាំងឥរិយាបថឲ្យកម្រើក

៥–ឋានាចាវេយ្យ, គប្បីឲ្យឃ្លាតចាកឋាន ។

### ឯកភណ្ឌបញ្ចកៈពួកទី ២

ឯកភណ្ឌបញ្ចកៈ មាន៥ ដូចគ្នានឹងនានាភណ្ឌបញ្ចកៈពួកទី១ដែរ ប៉ុន្តែឯកភណ្ឌបញ្ចកៈនេះ សំដៅយក ការលួចទ្រព្យដែលមានវិញ្ញាណតែម្យ៉ាង ។

### សាហត្ថិកបញ្ចកៈពួកទី ៣

១–សាហត្ថិកា, ការលួចដោយដៃខ្លួនឯង

២-អាណត្តិក, ការលួចដោយប្រើគេ

៣-និស្សគ្គិយ, ការលួចដោយបោះ ឬគ្រវែងទៅ

៤-អត្ថសាធក, ការលួចដោយញ៉ាំងប្រយោជន៍ឲ្យសម្រេច

៥-ធុរនិក្ខេប, ការលួចកំណាត់ដោយការដាក់ធុរៈ។

## បុព្វប្បយោគបញ្ចកៈពួកទី ៤

១-បុព្វប្បយោគ, ប្រយោគខាងដើម

២-សហប្បយោគ, ប្រយោគព្រមគ្នា

៣-សំវិធាវហារ, ការបបួលរួមគ្នាលួច

៤-សង្កេតកម្ម, ធ្វើការកំណត់

៥-និមិត្តកម្ម, ធ្វើនិមិត្ត។

## ថេយ្យាវហារបញ្ចកៈពួកទី ៥

១-ថេយ្យាវហារ, លួចដោយភាពជាចោរ

២-បសយ្ហាវហារ, លួចដោយការសង្កត់សង្កិន

៣-បរិកប្បាវហារ, លួចតាមការកំណត់ទុក

៤-បដិច្ឆន្នាវហារ, លួចដោយការបិទបាំង

៥-កុសាវហារ, លួចដោយការផ្លាស់ប្តូរស្លាក ។

(អដ្ឋកថា ទុតិយបារាជិក/ កង្ខា ១/៨១)

## បុគ្គលជាទាសៈ ៣ ពួក

១–អន្តោជាតកា, ទាសៈដែលកើតក្នុងផ្ទៃរបស់នាងទាសី

២–ធនក្កីតកា, ទាសៈដែលទិញមកដោយទ្រព្យ

៣–ករមរានីត, អ្នកដែលកៀងប្រមូលមកអំពីប្រទេសផ្សេងៗ ហើយចូលដល់ភាពជាទាសៈ(ឈ្លើយ) ។ (អដ្ឋកថា អទិន្នាទានសិក្ខាបទ)

## អាការៈ ៦ យ៉ាងត្រូវអាបត្តិបារាជិក

១_មិនបានសម្គាល់ថាជារបស់ខ្លួន

២_មិនបានកាន់យកដោយវិស្សាសៈ

៣_មិនបានកាន់យកជារបស់ខ្ចី

៤_បរិក្ខារមានតម្លៃច្រើនប្រមាណ៥មាសកៈឬលើស៥មាសកៈ

៥_មានថេយ្យចិត្តតាំងឡើងប្រាកដ

៦_ញាំងរបស់នោះឲ្យឃ្លាតផុតចាកទីត្រូវបារាជិក ។

## អាការៈ ៦ យ៉ាងត្រូវអាបត្តិថុល្លច្ច័យនិងទុក្កដ

_អាការៈ ៦ យ៉ាងត្រូវអាបត្តិថុល្លច្ច័យខុសតែអាការៈ ១ គឺបរិក្ខារមានតម្លៃតិចប្រមាណលើសពី ១ មាសកៈឬថយពី ៥ មាសកៈមក ។

_អាការៈ ៦ យ៉ាងត្រូវអាបត្តិទុក្កដខុសតែអាការៈ ១ គឺ បរិក្ខារមានតម្លៃតិចប្រមាណ ១ មាសកៈឬថយពី ១ មាសកៈមក ។

(វិន័យបិដក.១/១៧៧)

# ប្រយោគនៃបាណាតិបាត ៦ យ៉ាង

១-សាហត្ថិកបយោគ, ប្រយោគផ្ទាល់ដៃខ្លួន

២-និស្សគ្គិយបយោគ, ប្រយោគផ្លោង(ចោល)

៣-អាណត្តិកបយោគ, ប្រយោគប្រើគេ

៤-ថាវរបយោគ, ប្រយោគប្រចាំការ(មាំមួន)

៥-វិជ្ជាមយបយោគ, ប្រយោគសម្រេចដោយវិជ្ជា

៦-ឥទ្ធិមយបយោគ, ប្រយោគសម្រេចដោយឫទ្ធិ ។

(កង្ខាវិតរណី ១/៩៥)

# បុគ្គលដែលគួរធ្វើថ្នាំឱ្យ

## សហធម្មិកទាំង ៥ គឺ

ភិក្ខុ ១ ភិក្ខុនី ១ សិក្ខមានា ១ សាមណេរ ១ សាមណេរី ១ ។

## ៥ពួកដទៃទៀត

មាតា ១ បិតា ១ អ្នកបំរើមាតាបិតា ១ វេយ្យាវច្ចៈរបស់ខ្លួន ១ បណ្ឌុបលាស ១

## ៧ ពួកដទៃទៀត គឺ

អាគន្តុកៈ ១ ចោរ ១ អ្នកច្បាំងបរាជ័យ ១ អ្នកជាធំ ១ មនុស្សកំព្រាដែលពួកញាតិលះបង់ ១ អ្នកត្រៀមនឹងទៅ ១ ជាអ្នកមានជម្ងឺចូលទៅកាន់វិហារ ១ ។ ភិក្ខុមិនប្រាថ្នាការតបស្នង គួរធ្វើថ្នាំដល់មនុស្សទាំងនោះ ។

## ញាតិ១០ពួកដទៃទៀត

(គួរយកថ្នាំរបស់ញាតិនោះធ្វើ ឬឲ្យជារបស់ខ្ចី បើគេគ្មានគួរតាំងចិត្តឲ្យ-ជារបស់ខ្ចី) គឺ:

បងប្រុស ១ ប្អូនប្រុស ១ បងស្រី ១ ប្អូនស្រី ១ ម្តាយមីង (មីងខាងម្តាយ) ១ ម្តាយធំ(អ៊ំស្រីខាងម្តាយ) ១ ឪពុកមា(ពូខាងឪពុក) ១ ឪពុកធំ (អ៊ំប្រុសខាងឪពុក) ១ ម្តាយមីង(មីងខាងឪពុក) ១ ឪពុកធំ (អ៊ំប្រុស-ខាងម្តាយ) ១ ។

## អាបត្តិទុក្កដ ៨ យ៉ាង

បុព្វប្បយោគទុក្កដ ១ សហប្បយោគទុក្កដ ១ អនាមាសទុក្កដ ១ ទុរុបចិណ្ណទុក្កដ ១ វិនយទុក្កដ ១ ញាតទុក្កដ ១ ញត្តិទុក្កដ១ បដិស្សវទុក្កដ១ ។ (សាមន្ត.ទុតិយបារាជិក)

## ឧត្តរិមនុស្សធម៌ ១០ យ៉ាង

១-ឈាន, គុណជាតិសម្រាប់ដុតបង់នូវកិលេស

២-វិមោក្ខ, គុណធម៌ដែលផុតស្រលះចាករាគៈជាដើម

៣-សមាធិ, សភាពដែលតម្កល់ចិត្តស្មើមាំល្អក្នុងអារម្មណ៍

៤-សមាបត្តិ, គុណជាតិដែលដល់ព្រម

៥-ញាណទស្សន, កិរិយាឃើញដោយបញ្ញា

៦-មគ្គភាវនា, កិរិយាចម្រើននូវមគ្គ

៧-ផលសច្ឆិកិរិយាយ, ដំណើរធ្វើឲ្យច្បាស់លាស់នូវផល

៨-កិលេសប្បហាន, កិរិយាលះបង់កិលេស

៩-វិនីវរណតា ចិត្តស្ស, ចិត្តមាននីវរណៈធម៌ប្រាសហើយ

១០-សុញ្ញាគារេ អភិរតិ, សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ ។

(វិន័យបិដក. ១/៣០០)

## មហាចោរ ៥ ពួក

ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះរបស់ភិក្ខុបាបខ្លះ ដែលមានក្នុងសាសនានេះក៏យ៉ាងនោះដែរ (ត្រិះរិះ) ថា បើដល់កាលណាអញបានបរិសទ្យ ១ រយ ឬ ១ ពាន់ ចោមរោមជាគ្នាហើយ និងត្រាច់ទៅកាន់ចារិកក្នុងស្រុក និគម រាជធានី ក៏នឹងបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលពួកគ្រហស្ថក្តី ពួកបព្វជិតក្តី ធ្វើសក្ការៈគោរពរាប់អានបូជាកោតក្រែង ។ លុះដល់សម័យខាងក្រោយមក ភិក្ខុបាបនោះបានបរិសទ្យ ១រយ ឬ ១ពាន់ចោមរោមជាគ្នាហើយ ក៏ត្រាច់ទៅកាន់ចារិកក្នុងស្រុកនិគមរាជធានី បានចីវរ បិណ្ឌបាត សេនាសន គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលពួកគ្រហស្ថក្តី ពួកបព្វជិតក្តី ធ្វើសក្ការគោរពរាប់អានបូជាកោតក្រែង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា **មហាចោរទី ១** ដែលមានប្រាកដក្នុងលោក ។

ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ

មានភិក្ខុបាបខ្លះ រៀនសូត្រធម្មវិន័យដែលតថាគតបានសម្តែងហើយ ដុតកំដៅខ្លួនឯងចោល(១) ម្នាលភិក្ខុទាំងឡាយនេះហៅថា **មហាចោរទី ២** ដែលមានប្រាកដក្នុងលោក ។

ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះ ពោលចោទភិក្ខុដែលប្រព្រឹត្តធម៌ប្រសើរដ៏ស្អាត ដែលកំពុងប្រព្រឹត្តធម៌ប្រសើរដ៏បរិសុទ្ធ ចោទដោយការប្រព្រឹត្តមិនប្រសើរ(២) រកមូលគ្មាន(៣)។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា **មហាចោរទី ៣** មានប្រាកដក្នុងលោក។

ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះសង្រ្គោះផ្គាប់ផ្គុនគ្រហស្ថដោយគ្រឿងគរុភណ្ឌរបស់សង្ឃ ឬគ្រឿងគរុបរិក្ខារ គ្រឿងគរុភណ្ឌគឺអ្វីខ្លះ គ្រឿងគរុភណ្ឌនោះគឺគុម្ពផ្កានិងដើមឈើ១ ទីដែលសម្រាប់ដាំគុម្ពផ្កានឹងដើមឈើ ១ កុដិ១ ទីដែលសម្រាប់សង់កុដិ ១ គ្រែ ១ តាំង ១ ពូក ១ ខ្នើយ ១ ច្នាំងលោហ: ១ ស្នូកលោហ: ១

---

(១) ក្នុងអដ្ឋកថាអធិប្បាយថា ភិក្ខុដែលចេះប្រៀបធៀបបាលី នឹងអដ្ឋកថាក្នុងកណ្ដាលបរិស័ទ ហើយប្រសប់ធ្វើសម្លេងទេសនាផ្លូវព្រះសូត្រឱ្យយ៉ាងពីរោះ កាលបើចប់ធម៌ហើយមានគេសួរថា លោកម្ចាស់រៀនពីគ្រូអាចារ្យណាមក ភិក្ខុនោះក៏លាក់មិនប្រាប់នាមគ្រូអាចារ្យ ឆ្លើយថា អាត្មាគ្មានគ្រូអាចារ្យណាអាចនឹងបង្រៀនបានទេ រៀនចេះដឹងតែខ្លួនឯង យ៉ាងនេះហៅថាដុតកំដៅខ្លួនឯងចោល ។

(២) អដ្ឋកថាអធិប្បាយថា ចោទដល់ទីមេថុនធម្ម ។

(៣) ចោទដោយមិនបានឃើញនឹងភ្នែក មិនបានឮនឹងត្រចៀក ឬមិនបានរង្កៀសក្នុងចិត្ត ។

ក្អមលោហៈ ១ ជើងលោហៈ[១] ១ កាំបិត ១ ពូថៅ ១ ដឹង ១ ចប ១ ពន្លាក(ឬដែកកណ្ដារ) ១ វល្លិ៍ប្រវែងមួយលូកឡើងទៅ ១ ឫស្សីប្រវែង៨ ធ្នាប់ឡើងទៅ ១ ស្មៅជំណោកទន្សាយ ១ ស្មៅយាប្លង់ ១ ស្មៅធម្មតា ១ ដីស្អិត១ គ្រឿងធ្វើនឹងឈើ ១ គ្រឿងធ្វើនឹងដី ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា **មហាចោរទី ៤** មានប្រាកដក្នុងលោក ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាពោលអួតឧត្តរិមនុស្សធម្មដែលមិនមានមិនប្រាកដក្នុងខ្លួន ភិក្ខុនេះជា **មហាចោរទី៥** ជាចោរធំបំផុតក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេស ហេតុអ្វីបានជាតថាគតពោលដូច្នោះ ម្នាលភិក្ខុទាំងឡាយ ពីព្រោះដុំបាយរបស់ជនអ្នកនៅក្នុងដែន គឺភិក្ខុនោះឯង លួចយកមកបរិភោគ ។

(វិនយបិដក ១/២៩៣)

## ភិក្ខុអ្នកទៅកាន់ត្រកូលស្តេចមានទោស ៥ យ៉ាង

ត្រូវអាបត្តិ ព្រោះមិនបានប្រាប់ភិក្ខុ ដែលមាននៅក្នុងអាវាសហើយត្រេចទៅ ១ ត្រូវអាបត្តិព្រោះអង្គុយក្នុងទីស្ងាត់ ១ ត្រូវអាបត្តិក្នុងអាសនៈដែលកំបាំង ១ សម្តែងធម៌ដល់មាតុគ្រាមលើសជាងប្រាំ ប្រាំមួយមាត់ឡើងទៅត្រូវអាបត្តិ ១ មានសេចក្ដីត្រិះរិះជាច្រើនក្នុងកាមគុណ ១ ។

---

(៣) ពាក្យថាលោហៈ ជាពាក្យសម្រាប់ហៅ ពួកគ្រឿងដែក ស្ពាន់ ទង់ដែងជាដើម ។

## ភិក្ខុអ្នកចូលទៅកាន់ត្រកូល នៅច្រឡូកច្រឡំក្នុងត្រកូល ហួសវេលា រមែងមានទោស ៥ យ៉ាង

ក្រឡេកមើលមាតុគ្រាមរឿយៗ ១ កាលបើមើលហើយនឹងមានសេចក្តីជាប់ជំពាក់ ១ កាលបើមានសេចក្តីជាប់ជំពាក់ហើយ នឹងកើតសេចក្តីស្និទ្ធស្នាល ១ កាលបើមានសេចក្តីស្និទ្ធស្នាលហើយនឹងមានរាគៈគ្របសង្កត់ចិត្ត ១ ទោសជាតិនេះតែងកើតមានចំពោះតែភិក្ខុដែលមានចិត្តត្រូវរាគៈគ្របសង្កត់ហើយ គឺ ភិក្ខុនោះនឹងប្រព្រឹត្តព្រហ្មចរិយៈធម៌ទាំងសេចក្តីអផ្សុក ឬនឹងត្រូវអាបត្តិដែលសៅហ្មងឯណានីមួយ ឬនឹងពោលលាសិក្ខាត្រឡប់មកកាន់ភេទគ្រហស្ថវិញ ១ ។

(វិន័យបិដក ១៣/៧១_៧២)

## បារាជិកទាំងអស់មាន ២៤ គឺ

បារាជិករបស់ភិក្ខុ៤ +បារាជិករបស់ភិក្ខុនីជាអសាធារណៈ៤ + អភព្វបុគ្គល១១ + បារាជិកភិក្ខុនីចង់សឹកប្រាថ្នាជាគ្រហស្ថ ១ = ២០ អាចារ្យទាំងឡាយ ពោលថាអនុលោមបារាជិកសូម្បីដទៃ ៤ ទៀតគឺ ភិក្ខុមានអង្គជាតិយា (បញ្ចូលអង្គជាតិទៅវច្ចៈមគ្គរបស់ខ្លួន) ១ ភិក្ខុមានខ្នងទន់ (បៀមអង្គជាតិរបស់ខ្លួន) ១ ភិក្ខុយកមាត់បៀមអង្គជាតិរបស់បុគ្គលដទៃ ១ ភិក្ខុអង្គុយសង្កត់លើអង្គជាតិរបស់បុគ្គលដទៃ ១ ។ អ្នកសិក្សាគប្បីបូករួមបារាជិក៤នេះ និងបារាជិក២០ខាងដើម ហើយគប្បីជ្រាបបារាជិកទាំងអស់តែម្តងថាជា ២៤ ដោយប្រការដូច្នេះ ។កង្ខា១/១០៣

## ហេតុនាំឱ្យស្រមៃ ៤ យ៉ាង

-ព្រោះធាតុកម្រើក ១ -ព្រោះធ្លាប់ជ្រាបមកពីមុន ១

-ព្រោះទេវតាបណ្ដាល ១ -ព្រោះបុព្វនិមិត្ត ១

(អដ្ឋកថា សុក្កវិស្សដ្ឋិសិក្ខាបទ)

## អាការៈនៃការចោទ

-ចោទ ២ យ៉ាង ( ដោយកាយ ១ ដោយវាចា ១ )

-ចោទ ៣ យ៉ាង (ដោយឃើញ ១ ដោយឮ ១ ដោយរង្កៀស ១ )

-ចោទ ៤ យ៉ាង ( ដោយសីលវិបត្តិ ១ ដោយអាចារវិបត្តិ ១ ដោយទិដ្ឋិវិបត្តិ ១ ដោយអាជីវៈវិបត្តិ ១ ) ។

(អដ្ឋកថា អមូលកសិក្ខាបទ)

## ស្រី ១០ ពួក

១-មាតុរក្ខិតា, ស្រីដែលមានមាតាគ្រប់គ្រងរក្សា

២-បិតុរក្ខិតា, ស្រីដែលមានបិតាគ្រប់គ្រងរក្សា

៣-មាតាបិតុរក្ខិតា, ស្រីដែលមានមាតាបិតាគ្រប់គ្រងរក្សា

៤-ភាតុរក្ខិតា, ស្រីដែលមានបងប្អូនប្រុសគ្រប់គ្រងរក្សា

៥-ភគិនីរក្ខិតា, ស្រីដែលមានបងប្អូនស្រីគ្រប់គ្រងរក្សា

៦-ញាតិរក្ខិតា, ស្រីដែលមានញាតិគ្រប់គ្រងរក្សា

៧-គោត្តរក្ខិតា, ស្រីដែលមានគោត្តគ្រប់គ្រងរក្សា

៨–ធម្មរក្ខិតា , ស្រីដែលមានអ្នកប្រព្រឹត្តធម៌ត្រូវគ្នាគ្រប់គ្រងរក្សា

៩–សារក្ខា, ស្រីដែលប្រកបដោយកិរិយារក្សា គឺស្រីដែលគេនិយាយប្រកាន់ទុករួចហើយ

១០–សបរិទណ្ឌា, ស្រីដែលប្រកបដោយអាជ្ញា គឺស្រីដែលព្រះរាជាដាក់អាជ្ញា មិនឲ្យនរណាប្រព្រឹត្តកន្លងតាមអំពើចិត្ត ឬមិនឲ្យនរណាមួយប្រព្រឹត្តកន្លង ។

## ភរិយា ១០ ជំពូក

១១–ធនក្កីតា, ស្រីដែលគេទិញ ឬលោះដោយទ្រព្យ ទោះតិចក្តីច្រើនក្តី យកមកធ្វើជាភរិយា ឬត្រឹមតែលោះមកប៉ុណ្ណោះ គេមិនបានយកទៅធ្វើជាភរិយាក៏ដោយ

១២–ឆន្ទវាសិនី, ស្រីដែលរត់តាមទៅនៅធ្វើជាភរិយារបស់បុរសដោយសេចក្តីពេញចិត្តរបស់ខ្លួន ហើយបុរសទទួលព្រមផង

១៣–ភោគវាសិនី, ស្រីដែលទៅនៅធ្វើជាភរិយារបស់បុរស ព្រោះតែភោគគឺ ស្រីដែលបានភោគយ៉ាងហោចត្រឹមតែអង្រែ និងត្បាល់ជាដើមអំពីបុរសណា ក៏ទៅនៅជាភរិយារបស់បុរសនោះ

១៤–បដវាសិនី, ស្រីដែលទៅនៅធ្វើជាភរិយារបស់បុរសព្រោះតែសម្លត់គឺទ័លខ្សត់ គ្រាន់តែសម្លត់ស្លៀកឬសម្លត់ដណ្តប់ក៏ក្រដែរ ទើបសុខចិត្តចូលទៅធ្វើជាភរិយាគេ

១៥–ឳទបត្តកិនី, ស្រីដែលគេផ្គោបដៃជាមួយនឹងបុរស ជ្រលក់ទៅនឹងផ្តិលទឹកមួយហើយគេពោលថា អ្នកនាងទាំងឡាយចូលប្រទ្បំគ្នា ចូរកុំបែកបាក់គ្នាឲ្យដូចជាទឹកនេះ គឺស្រីដែលគេផ្សំផ្គុំឲ្យជាភរិយា របស់បុរសដោយវិធីបែបនេះ

១៦–ឳភតចុម្ពដា, ស្រីដែលគេជួយដាក់ទ្រនូលចុះអំពីក្បាល គឺស្រីរកឧសជាដើមដែលបុរសណាមួយ ជួយដាក់ទ្រនូលអំពីក្បាលហើយនាំយកទៅធ្វើជាភរិយា

១៧–ទាសី ច ភរិយា ច, ស្រីដែលជាទាសីផង ជាភរិយាផង គឺស្រីដែលជាទាសីរបស់បុរសណាមួយ ហើយបុរសនោះយកធ្វើជាភរិយា ។

១៨–កម្មការី ច ភរិយា ច, ស្រីដែលជាកូនឈ្នួលផង ជាភរិយាផង គឺ ស្រីដែលចូលទៅនៅធ្វើការរកស៊ីឈ្នួលបុរសណាមួយ ហើយបុរសនោះយកធ្វើជាភរិយា ។

១៩-ធជាហដា, ស្រីដែលកងសេនានាំយកដោយទង់ជ័យគឺស្រីដែលកងសេនា ដំឡើងទង់ជ័យលើកទ័ពទៅច្បាំងដណ្តើមដែនរបស់ស្តេចដទៃកៀរយកបានមកហើយ បុរសណាមួយយកធ្វើជាភរិយា ។

២០–មុហុត្តិកា, ស្រីដែលបុរសគប់ប្រសប់តែមួយស្របក់ គឺស្រីដែលជាសហាយស្មន់របស់បុរសណាមួយ ។

ស្រីទាំង២០ជំពូកនេះ ជាអគមនីយដ្ឋានរបស់បុរស, បើបុរសណាទៅគប់រកដោយអស្សទ្ធម្មត្រូវជាច់កាមេសុមិច្ឆាចារ ។ ស្រី៨ជំពូកខាងដើម មានមាតុរក្ខិតាជាដើម រហូតដល់ធម្មរក្ខិតា បើទៅគប់រកបុគ្គលណា ស្រីនោះមិនដាច់កាមេសុមិច្ឆាចារឡើយ ព្រោះមាតាជាដើមនោះគ្រាន់តែរក្សានូវកេរ្តិ៍ឈ្មោះប៉ុណ្ណោះ មិនមែនរក្សាសម្ផស្សឡើយ ។ ឯស្រី១២ជំពូកខាងចុង មានសារក្ខាជាដើម រហូតដល់មហុត្តិកា បើទៅគប់រកបុរសណាមួយ ត្រូវដាច់កាមេសុមិច្ឆាចារ ព្រោះស្រីនោះមានស្វាមីថែរក្សាសម្ផស្សហើយ ។

## ទឹកសុក្ក ១០ យ៉ាង

ទឹកសុក្កពណ៌ខៀវ ១ ទឹកសុក្កពណ៌លឿង ១ ទឹកសុក្កពណ៌ក្រហម ១ ទឹកសុក្កពណ៌ស ១ ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ១ ទឹកសុក្កពណ៌ដូចទឹក ១ ទឹកសុក្កពណ៌ដូចប្រេង ១ ទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ១ ទឹកសុក្កពណ៌ដូចទឹកដោះជូរ ១ទឹកសុក្កពណ៌ដូចទឹកដោះថ្លា ១។ បិ.២/៧

## ឧបត្ថម ៥ យ៉ាង

១-រាគូបត្ថម្ភ, ឧបត្ថម្ភដោយរាគ

២-វច្ចូបត្ថម្ភ, ឧបត្ថម្ភដោយល្មក់

៣-បស្សាវច្ចូបត្ថម្ភ, ឧបត្ថម្ភដោយមូត្រ

៤-វាតូបត្ថម្ភ, ឧបត្ថម្ភដោយខ្យល់

៥-ឧច្ចាលិង្គប្បាណកានជ្ជបត្តម, ឧបត្តម្ភដោយជង្គុំវរមាស់រោល ។ បិ.២/៨

## ប្រយោជន៍ ១០ យ៉ាង

(ក្នុងសិក្ខាបទសុក្កវិស្សដ្ឋិ)

ដើម្បីប្រយោជន៍មិនឲ្យមានរោគ ១ ដើម្បីប្រយោជន៍ឲ្យបានសេចក្ដីសុខ ១ ដើម្បីប្រយោជន៍ត្រូវការជាភេសជ្ជៈ ១ ដើម្បីប្រយោជន៍ដល់ទាន ១ ដើម្បីប្រយោជន៍ដល់បុណ្យ ១ ដើម្បីប្រយោជន៍ដល់ការបូជា ១ ដើម្បីប្រយោជន៍ដល់ស្ថានសួគ៌ ១ ដើម្បីប្រយោជន៍ដល់ពូជ ១ ដើម្បីប្រយោជន៍ដល់ការល្បងមើល ១ ដើម្បីប្រយោជន៍ដល់ការលេង ១ ។ បិ.២/៩

## អង្គប្រគេនមាន ៥ យ៉ាង

១-ថាមមជ្ឈិមស្ស បុរិសស្ស ឧច្ចារណមត្តំ ហោតិ, របស់ល្មមបុរសមានកម្លាំងយ៉ាងកណ្ដាលលើករួច

២-ហត្ថបាសោ បញ្ញាយតិ, ហត្ថបាសប្រាកដ (**ទាយកោ អឌ្ឍតេយ្យហត្ថប្បមាណេ ឱកាសេ ហោតិ,** ទាយកស្ថិតនៅក្នុងឱកាសប្រមាណ ២ ហត្ថ ១ ចំអាម ឈ្មោះថា ហត្ថបាសប្រគេន )

៣-អភិហារោ បញ្ញាយតិ, គេបង្អោនប្រាកដ(រុញ,ផ្អៀង, លើកចូលទៅ...)

៤-ទេវោ វា មនុស្សោ វា តិរច្ឆានគតោ វា ទេតិ, ទេវតាក្តី មនុស្សក្តី សត្វតិរច្ឆានក្តីប្រគេន

៥-តំ បន ភិក្ខុ កាយេន វា កាយប្បដិពទ្ធេន វា បដិគ្គណ្ហាតិ, ភិក្ខុទទួលរបស់នោះដោយកាយក្តី ឬរបស់ជាប់ដោយកាយក្តី ។ (សមន្ត ៤/២២៥)

## ការដាច់ប្រគេនមាន ៧ យ៉ាង

១-លិង្គបរិវត្តេន, ព្រោះភេទត្រឡប់

២-កាលកិរិយាយ, ព្រោះមរណៈភាព

៣-សិក្ខាបច្ចក្ខានេន, ព្រោះលាសិក្ខា

៤-ហីនាយាវត្តនេន, ព្រោះវិលទៅរកភេទដ៏ថោកទាប

៥-អនុបសម្បន្នស្ស ទានេន, ព្រោះឲ្យដល់អនុប្បសម្បន្ន

៦-អនបេក្ខវិស្សជ្ជនេន, ព្រោះមិនស្តាយលះបង់

៧-អច្ឆិន្ទិត្វា គាហេន ច វិជហាតិ, ព្រោះត្រូវចោរដណ្តើមយកទៅ ។ (អដ្ឋកថា ៣/២១៤)

## អនរិយវោហារ ៨ យ៉ាង

(ការនិយាយមិនមែនរបស់ព្រះអរិយៈគឺរបស់បុថុជ្ជន)

១-អទិដ្ឋំ ទិដ្ឋំ មេតិ, មិនឃើញ និយាយថា អញឃើញ

២-អសុតំ សុតំ មេតិ, មិនឮ និយាយថា អញឮ

៣-អមុតំ មុតំ មេតិ, មិនបានពាល់ត្រូវ និយាយថា អញបានពាល់ត្រូវ ( ពាលត្រូវដោយអាយតនៈ ៣ គឺ ច្រមុះ អណ្តាត និង កាយ )

៤-អវិញ្ញាតំ វិញ្ញាតំ មេតិ, មិនដឹងច្បាស់ និយាយថា អញដឹងច្បាស់

៥-ទិដ្ឋំ អទិដ្ឋំ មេតិ, ឃើញ និយាយថា អញមិនឃើញ

៦-សុតំ អសុតំ មេតិ, ឮ និយាយថា អញមិនឮ

៧-មុតំ អមុតំ មេតិ, បានពាល់ត្រូវ និយាយថា អញមិន បានពាល់ត្រូវ

៨-វិញ្ញាតំ អវិញ្ញាតំ មេតិ, ដឹងច្បាស់ និយាយថា អញមិនដឹងច្បាស់ ។ *(វិន័យបិដក.៣/២២៤)*

## អក្កោសវត្ថុ ១០ យ៉ាង

១-ជាតិយាបិ, ដោយជាតិ

២-នាមេនបិ, ដោយនាម (ឈ្មោះ)

៣-គោត្តេនបិ, ដោយគោត្ត (ត្រកូល)

៤-កម្មេនបិ, ដោយការងារ

៥-សិប្បេនបិ, ដោយសិល្បសាស្ត្រ

៦–អាពាធេនបិ, ដោយអាពាធ

៧–លិង្គេនបិ, ដោយភេទ

៨–កិលេសេនបិ, ដោយកិលេស

៩–អាបត្តិយាបិ, ដោយអាបត្តិ

១០–ហីនេនបិ, ដោយពាក្យជេរដ៏ថោកទាប ។ បិ.៣/២៤០

## ពូជ ៥ យ៉ាង

១–មូលពីជំ, ពូជកើតពីមើម ឬឫស

២–ខន្ធពីជំ, ពូជកើតពីដើម

៣–ផឡុពីជំ, ពូជកើតពីថ្នាំង

៤–អគ្គពីជំ, ពូជកើតពីចុង ឬគល់

៥–ពីជពីជំ, ពូជកើតពីពូជ (ផ្លែ) ។ បិ.៣/៣៤៩

## វត្ថុឧក្កដមាន ៧ យ៉ាង

(ប្រើក្នុងទីវាលមិនរើមកទុកដាក់)

១–ចិមិលិកំ, គ្រឿងទ្រនាប់

២–ឧត្តរត្ថរណំ, គ្រឿងកម្រាលគ្រែ ឬតាំង

៣–ភុម្មត្ថរណំ, គ្រឿងកម្រាលផែនដី

៤–តដ្ដិកំ, កន្ទេលទន់

៥–ចម្មខណ្ឌំ ,　　ប្រមខណ្ឌ

៦–ធានបុញ្ឆនី,　　គ្រឿងសម្រាប់ជូតជើង

៧–ជលកបីឋំ,　　តាំងដែលគេធ្វើដោយផែនក្តារ ។

( វិន័យបិដក .៣/៣៧៣)

## វត្ថុបាចិត្តិយ ១០ យ៉ាង

( ប្រើក្នុងទីសេនាសនៈ មិនរើមកទុកដាក់ )

១–ភិសិ ,　　ពូក

២–ចិមិលិកា,　　គ្រឿងទ្រនាប់

៣–ឧត្តរត្ថរណំ,　　គ្រឿងកម្រាលគ្រែ ឬតាំង

៤–ភុម្មត្ថរណំ,　　កម្រាលផែនដី

៥–តដ្ដិកា ,　　កន្ទេលទន់

៦–ចម្មខណ្ឌោ ,　　ប្រមខណ្ឌ(កំណាត់ស្បែក)

៧–និសីទនំ,　　និសីទនៈ(សំពត់សម្រាប់ទ្រាប់អង្គុយ)

៨–បច្ចត្ថរណំ,　　កម្រាល

៩–តិណសន្ថារោ ,　　កម្រាលដែលគេធ្វើដោយស្មៅ

១០–បណ្ណសន្ថារោ,　　កម្រាលដែលគេធ្វើដោយស្លឹកឈើ ។

( វិន័យបិដក .៣/៣៧៧)

## ថេយ្យសំវាស ៣ យ៉ាង

(បុគ្គលលួចសំវាស)

១-លិង្គត្ថេនកោ, បុគ្គលលួចភេទ (គ្រហស្ថលួចបួសខ្លួនឯង)

២-សំវាសត្ថេនកោ, បុគ្គលលួចសំវាស (សាមណេរក្លែងរាប់-វស្សា ត្រេកអរនឹងការថ្វាយបង្គំភិក្ខុចាស់ខ្ចីជាដើម)

៣-ឧភយត្ថេនកោ, បុគ្គលលួចទាំងភេទទាំងសំវាស ។

## សមណកប្បៈ ៥ យ៉ាង

១-អគ្គិបរិចិតំ, ផ្លែឈើដែលអុចដោយភ្លើង

២-សត្ថបរិចិតំ, ផ្លែឈើដែលចាក់ដោយកាំបិត

៣-នខបរិចិតំ, ផ្លែឈើដែលចុចដោយក្រចក (រៀរក្រចកស្អុយ)

៤-អពីជំ, ផ្លែឈើដែលមិនមានពូជដុះតទៅ (ផ្លែឈើខ្ចី)

៥-និព្វដ្ដពីជំ, ផ្លែឈើដែលបន្ទេចគ្រាប់ចេញបាន ។

(បិ.១០/១៣៨)

## វិធីធ្វើកប្បិយៈ

(ធ្វើពីជគាម (ពូជ៥យ៉ាង) ឲ្យជារបស់គួរ)

-ភិក្ខុថា កប្បិយំ ករោហិ, ចូរធ្វើរបស់នេះឲ្យគួរ

-(អនុបសម្បន្ន) ធ្វើនឹងថាឲ្យស្មើគ្នាថា កប្បិយំ ភន្តេ គួរលោកម្ចាស់

(សមន្ត.៤/៣៧)

# ត្រកូលមាន ៤ យ៉ាង

១-ខត្តិយកុលំ, ត្រកូលក្សត្រ

២-ព្រាហ្មណកុលំ, ត្រកូលព្រាហ្មណ៍

៣-វេស្សកុលំ, ត្រកូលអ្នកជំនួញ

៤-សុទ្ទកុលំ, ត្រកូលអ្នកគ្រួ ។ (បិ.៤/១១៥)

# ក្រែ ៤ យ៉ាង

១-មសារកោ, គ្រែដែលគេបញ្ចូលមេទៅក្នុងដំណាប់ជើង

២-ពុន្ទិកាពន្ធោ, គ្រែដែលមានមេជាប់នឹងជើង ។

៣-កុលិរបាទកោ, គ្រែដែលមានជើងដូចជាជើងក្ដាម[១] ។

៤-អាហច្ចបាទកោ, គ្រែដែលមានជើងចុច ឬគ្រែដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ ។ (សូម្បីតាំងក៏ដូចគ្រែដែរ) ។ បិ.៣/៣៧០

# ពូក ៥ យ៉ាង

១-ឧណ្ណាភិសិ, ពូកដែលគេញាត់ដោយរោមសត្វ

២-ចោលភិសិ, ពូកដែលគេញាត់ដោយសំបកឈើ

៣-ចោលភិសិ, ពូកដែលគេញាត់ដោយកំណាត់សំពត់

៤-តិណភិសិ, ពូកដែលគេញាត់ដោយស្មៅ ។

---

១-គ្រែដែលមានជើងដូចជាជើងសេះ ជើងពពែជាដើម

៥-បណ្ឌុភិសិ, ពូកដែលគេញាត់ដោយស្លឹកឈើ ។ បិ.៣/៣៧១

## គោវអី ៤ យ៉ាង

១-វាកមយំ , កៅអីដែលគេធ្វើដោយសំបកឈើ

២-ឧសីរមយំ, កៅអីដែលគេធ្វើដោយស្បូវភ្លាំង

៣-មុញ្ជមយំ, កៅអីដែលគេធ្វើដោយស្មៅយ៉ាប្លង

៤-បព្វជមយំ, កៅអីដែលគេធ្វើដោយស្មៅជំណោកទន្សាយ ។

( វិន័យបិដក .៣/៣៧១)

## ភោជន ៥ យ៉ាង

១-ឱទនោ , បាយ

២-កុម្មាសោ, នំស្រស់

៣-សត្តុ, នំក្រៀម

៤-មច្ឆោ, ត្រី

៥-មំសំ , សាច់ ។ (បិ.៤/១២៣)

## បុព្វណ្ណជាតិ (ស្រូវ) ៧ប្រការ

១-សាលិ, ស្រូវសាលី

២-វីហិ, ស្រូវខ្សាយ

៣-យវោ, ស្រូវជំណើប

៤-គោធុមោ, ស្រវ៉ៃ

៥-កន្ទុ, ថ្មៅ

៦-វរកោ, ស្កួយ ឬពោត

៧-កុទ្រូសកោ, ស្មៅគែលលក ។ (កង្ខា ២/៣៣)

## មហាផល ៩ ប្រការ

១-តាល, ផ្លែត្នោត

២-នាឡិកេរ, ផ្លែដូង

៣-បនស, ខ្នុរណាំង

៤-លពុជ, ខ្នុរសម្ល

៥-អលាពុ, ឃ្លោក

៦-កុម្ភណ្ឌ, ល្ពៅ

៧-បុសជល, ត្រសក់

៨-តិបុស, ឪឡឹក

៩-ឯលាឡុក, ត្រឡាច ។ (កង្ខា.២/៦៤)

## ទឹកបាន ៨ យ៉ាង

១-អម្ពបានំ, ទឹកផ្លែស្វាយ

២-ជម្ពុបានំ, ទឹកផ្លែព្រីង

៣-ចោចបានំ, ទឹកផ្លែចេកមានគ្រាប់

៤-មោចបានំ , ទឹកផ្លែចេកឥតគ្រាប់

៥-មធុកបានំ, ទឹកផ្លែស្រគំ

៦-មុទ្ទិកបានំ , ទឹកផ្លែច័ន្ទ

៧-សាលុកបានំ, ទឹកក្រអៅឈូក

៨-ផារុសកបានំ, ទឹកផ្លែមាក់ប្រាង ។ (កង្ខា២/៦៥)

## ខុទ្ទកផល

(ផ្លែតូចៗ)

១-វេត្តបានំ, ទឹកផ្លែផ្ដៅ

២-តិន្តិណិកបានំ, ទឹកផ្លែអំពិល

៣-មាតុលុង្គបានំ, ទឹកផ្លែក្រូចឯម

៤-កបិដ្ឋបានំ, ទឹកផ្លែខ្វិត

៥-កោសម្ពបានំ, ទឹកផ្លែសង្ឃ័រ

៦-ករមន្ទបានំ, ទឹកផ្លែក្រូចកខ្វែងជាដើម ដែលអនុលោមចូលទឹកបាន:ទាំង ៨ ។ (វៀរមហាផល៩ បុព្វណ្ណជាតិ អបរណ្ណជាតិចេញធ្វើទឹកបាន:បានទាំងអស់ ។ បើលាយទឹក គឺទឹកត្រជាក់ ។ ចំពោះផ្លែស្រគំត្រូវលាយទឹកតែម្យ៉ាង) ។

# គរុភណ្ឌ ៥ ពួក

**ពួកទី ១ មាន ២ គឺ:**

១-អារាមោ, សួនច្បារ សួនផ្លែ

២-អារាមវត្ថុ, ទីសម្រាប់ដាំសួនច្បារ ។

**ពួកទី ២ មាន ២ គឺ:**

១-វិហារោ, លំនៅ

២-វិហារវត្ថុ, ទីដីសម្រាប់សង់លំនៅ ។

**ពួកទី ៣ មាន ៤ គឺ:**

១-មញ្ចោ, គ្រែ

២-បីឋំ, តាំង ឬកៅអី

៣-ភិសិ, ពូក

៤-ពិម្ពោហនំ, ខ្នើយ ។

**ពួកទី ៤ មាន ៩ គឺ:**

១-លោហកុម្ភី, ច្នាំងធ្វើពីជាតិលោហ:

២-លោហភាណកំ, ខ្ទះលោហ:

៣-លោហវារកោ, ក្អមលោហ:

៤-លោហកដាហំ, ដើងលោហ:

៥–ភាសិ,    កាំបិត

៦–ផរសុ,    ពូថៅ

៧–កុឋារិ,    ដឹងចាំងឈើ

៨–កុទ្ទាលោ,    ចប

៩–និខាទនំ,    ពន្លាក ។

**ពួកទី ៥ មាន ៨ គឺ:**

១–វល្លិ,    វល្លិ៍

២–វេឡុ,    ឫស្សី

៣–មុញ្ជ,    ស្មៅដំណេកទន្សាយ

៤–បព្វជំ,    ស្មៅយ៉ាប្លង

៥–តិណំ,    ស្មៅធម្មតា

៦–មត្តិកា,    ដីស្អិត

៧–ទារុភណ្ឌំ,    គ្រឿងឈើ

៨–មត្តិកាភណ្ឌំ,    គ្រឿងដី ។

ក៏ឯគរុភណ្ឌទាំង ៥ ពួកនុ៎ះ ជារបស់សង្ឃ មិនគួរលះ ឬចែកដល់សង្ឃ គណ: បុគ្គលទាំងឡាយសោះឡើយ ។ សូម្បីលះហើយ ឬចែកហើយ ក៏នៅជារបស់សង្ឃដដែល ។ (កង្ខា ២/១៤៩_១៥០)

## អធិករណ៍មាន ៤ យ៉ាង

១-វិវាទាធិករណ៍, ជម្លោះព្រោះភេទករវត្ថុ ១៨

២-អនុវាទាធិករណ៍, ជម្លោះព្រោះតិះដៀល ឬចោទអាបត្តិដោយវិបត្តិ ៤ យ៉ាង ណាមួយ

៣-អាបត្តាធិករណ៍ , ជម្លោះដោយអាបត្តិ ៧ កង

៤-កិច្ចាធិករណ៍, ជម្លោះព្រោះហេតុនៃកម្ម ៤ យ៉ាង មានអបលោកនកម្មជាដើម ។

## វជ្ជនីយបុគ្គល ២០ ពួក

១-ភិក្ខុនី , នាងភិក្ខុនី

២-សិក្ខមានា , នាងសិក្ខមានា

៣-សាមណេរោ , សាមណេរ

៤-សាមណេរី, នាងសាមណេរី

៥-សិក្ខាបច្ចក្ខាតកោ, បុគ្គលដែលពោលលាសិក្ខា

៦-អន្តិមវត្ថុអជ្ឈាបន្នកោ, ភិក្ខុត្រូវអន្តិមវត្ថុ (បារាជិក)

៧-អាបត្តិយា អទស្សនេ ឧក្ខិត្តកោ, ភិក្ខុដែលសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិ

៨-អាបត្តិយា អប្បដិកម្មេ ឧក្ខិត្តកោ, ភិក្ខុដែលសង្ឃ

លើកវត្តព្រោះមិនសម្តែងអាបត្តិ

៩-ធាបិកាយ ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកោ , ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនលះបង់ទិដ្ឋិដ៏លាមក

១០-បណ្ឌកោ, មនុស្សខ្ទើយ

១១-ថេយ្យសំវាសកោ, បុគ្គលលួចសង្វាស

១២-តិត្ថិយបក្កន្តកោ , បុគ្គលដែលចូលអន្យតិរ្ថិយ

១៣-តិរច្ឆានគតោ , សត្វតិរច្ឆាន

១៤-មាតុឃាតកោ , អ្នកសម្លាប់មាតា

១៥-បិតុឃាតកោ , អ្នកសម្លាប់បិតា

១៦-អរហន្តឃាតកោ, អ្នកសម្លាប់ព្រះអរហន្ត

១៧-ភិក្ខុនីទូសកោ, អ្នកប្រទូស្តចំពោះភិក្ខុនី

១៨-សង្ឃភេទកោ , អ្នកបំបែកសង្ឃ

១៩-លោហិតុប្បាទកោ , អ្នកធ្វើលោហិតព្រះពុទ្ធឲ្យពុះពង

២០-ឧភតោព្យញ្ជនកោ, អ្នកមានភេទពីរ ។

វជ្ជនីបុគ្គលទាំងនេះ ដែលសង្ឃគប្បីវៀរ ដោយអំណាចការធ្វើឲ្យនៅខាងក្រៅហត្ថបាស ( ហត្ថបាសសង្ឃកម្ម ឆិយឌ្ឍហត្ថប្បមាណោ = ១ហត្ថ ១ ចំអាម ) ។

# អភព្វបុគ្គល ១១ ពួក

១-បណ្ឌកោ, មនុស្សខ្ទើយ

២-ថេយ្យសំវាសកោ, បុគ្គលលួចសង្វាស

៣-តិត្ថិយបក្កន្តកោ, បុគ្គលដែលចូលអន្យតិរ្ថិយ

៤-តិរច្ឆានគតោ, សត្វតិរច្ឆាន

៥-មាតុឃាតកោ, អ្នកសម្លាប់មាតា

៦-បិតុឃាតកោ, អ្នកសម្លាប់បិតា

៧-អរហន្តឃាតកោ, អ្នកសម្លាប់ព្រះអរហន្ត

៨-ភិក្ខុនីទូសកោ, អ្នកប្រទូស្តចំពោះភិក្ខុនី

៩-សង្ឃភេទកោ, អ្នកបំបែកសង្ឃ

១០-លោហិតុប្បាទកោ, អ្នកធ្វើព្រះលោហិតឲ្យពុះពង

១១-ឧភតោព្យញ្ជនកោ, អ្នកមានភេទពីរ ។

# ហាមភត្តដោយអង្គ ៥

១-អសនំ បញ្ញាយតិ, ភិក្ខុកំពុងឆាន់

២-ភោជនំ បញ្ញាយតិ, គេយកភោជនមកប្រគេនទៀត

៣-ហត្ថបាសេ ឋិតោ, គេនៅក្នុងហត្ថបាស (២ហត្ថ១ចំអាម)

៤-អភិហរតិ, គេបង្អោនភោជនមកចំពោះ

៥-បដិក្ខេបោ បញ្ញាយតិ, ភិក្ខុហាមភោជន ។

(វិន័យបិដក.៤/១២១)

## ការមិនបានធ្វើវិន័យកម្ម ៧ យ៉ាង

(ក្នុងការហាមភត្តហើយ)

១-អកប្បិយកតំ ហោតិ, របស់ដែលគេមិនបានធ្វើឲ្យជាវត្ថុគួរ

២-អបដិគ្គហិតកតំ ហោតិ, របស់ដែលភិក្ខុមិនបានទទួលហើយធ្វើឲ្យជារបស់គួរ

៣-អនុច្ចារិតកតំ ហោតិ, របស់ដែលភិក្ខុមិនបានលើកឡើង(ឬ)មិនបានបង្អោនចូលទៅជិតដើម្បីឲ្យភិក្ខុធ្វើឲ្យជារបស់គួរ

៤-អហត្ថបាសេ កតំ ហោតិ, ភិក្ខុមិនឋិតនៅក្នុងហត្ថបាសហើយធ្វើ

៥-អភុត្តាវិនា កតំ ហោតិ, ភិក្ខុមិនទាន់បានឆាន់ហើយធ្វើ

៦-ភុត្តាវិនា បវារិតេន អាសនាវុដ្ឋិតេន កតំ ហោតិ, ភិក្ខុឆាន់ហើយបានហាមភោជនហើយ ក្រោកចាកអាសនៈហើយធ្វើ ។

៧-អលមេតំ សព្វន្តិ អវុត្តំ ហោតិ, របស់ដែលភិក្ខុមិនពោលថា របស់ទាំងអស់នេះគួរហើយ ។ (អដ្ឋកថា)

## បវារណាមាន ៤ យ៉ាង

១-អត្ថិ បវារណា ភេសជ្ជបរិយន្តា ន រត្តិបរិយន្តា, បវារណាកំណត់ភេសជ្ជៈ មិនកំណត់រាត្រី

២-អត្ថិ បវារណា រត្តិបរិយន្តា ន ភេសជ្ជបរិយន្តា, បវារណាកំណត់រាត្រី មិនកំណត់ភេសជ្ជៈ

៣-អត្ថិ បវារណា ភេសជ្ជបរិយន្តា ច រត្តិបរិយន្តា ច, បវារណាកំណត់ទាំងភេសជ្ជៈ កំណត់ទាំងរាត្រី

៤-អត្ថិ បវារណា នេវ ភេសជ្ជបរិយន្តា ន រត្តិបរិយន្តា, បវារណាមិនកំណត់ទាំងភេសជ្ជៈ មិនកំណត់ទាំងរាត្រី ។

*( វិន័យបិដក.៤/១៨៨)*

## សុរា ៥ យ៉ាង

១-បិដ្ឋសុរា, សុរាធ្វើដោយម្សៅ

២-បូវសុរា, សុរាធ្វើដោយនំ

៣-ឱទនសុរា, សុរាធ្វើដោយបាយ

៤-កិណ្ណបក្ខិត្តា, សុរាដែលគេដាក់ពូជសុរា

៥-សម្ភារសំយុត្តា, សុរាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ។ បិ.៤/២០៩

## មេរ័យ ៥ យ៉ាង

១–បុប្ផាសវោ ,　　ទឹកត្រាំដែលគេធ្វើដោយផ្កាឈើ

២–ផលាសវោ ,　　ទឹកត្រាំដែលគេធ្វើដោយផ្លែឈើ

៣–មធ្វាសវោ,　　ទឹកត្រាំដែលគេធ្វើដោយផ្លែចន្ទន៍ ឬគេធ្វើ ដោយទឹកឃ្មុំ

៤–គុឡាសវោ,　　ទឹកត្រាំដែលគេធ្វើដោយទឹកអំពៅ

៥–សម្ភារសំយុត្តោ,　ទឹកត្រាំដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ។　　( វិន័យបិដក .៤/២០៩)

## ឧបមាទោសរបស់កាម ១០ យ៉ាង

១–អដ្ឋិកង្កលូបមា កាមា,　　កាមទាំងឡាយមានឧបមាដោយរាងឆ្អឹង

២–មំសបេសូបមា កាមា,　　កាមទាំងឡាយមានឧបមាដោយដុំសាច់

៣–តិណុក្កូបមា កាមា ,　　កាមទាំងឡាយមានឧបមាដោយ គប់ភ្លើងធ្វើពីស្មៅ

៤–អង្គារកាសូបមា កាមា,　　កាមទាំងឡាយមានឧបមាដោយរណ្តៅរងើកភ្លើង

៥-សុបិនកូបមា កាមា, កាមទាំងឡាយមានឧបមា ដោយអ្នកយល់សប្តិ

៦-យាចិតកូបមា កាមា, កាមទាំងឡាយមានឧបមា ដោយរបស់ដែលខ្ចីគេ

៧-រុក្ខផលូបមា កាមា, កាមទាំងឡាយមានឧបមា ដោយផ្លែឈើ

៨-អសិសូនូបមា កាមា, កាមទាំងឡាយមានឧបមា ដោយកាំបិត និងជ្រញ់

៩-សត្តិសូលូបមា កាមា, កាមទាំងឡាយមានឧបមា ដោយលំពែង និងដែកស្រួច

១០-សប្បសិរូបមា កាមា, កាមទាំងឡាយមានឧបមា ដោយក្បាលពស់ ។ បិ.៤/២៧៧

## ការវិនាស ៣ យ៉ាង

១-សំវាសនាសនា, វិនាសដោយការនៅរួម (សង្ឃកម្ម)

២-លិង្គនាសនា, វិនាសចាកភេទ

៣-ទណ្ឌកម្មនាសនា, វិនាសដោយធ្វើទណ្ឌកម្ម។

(កង្ខាវិតរណី ២/១១៩)

## រតន ១០ យ៉ាង

១-មុត្តា, កែវមុក្តា

២-មណិ, កែវមណី

៣-វេឡុរិយោ, កែវពៃទូរ

៤-សង្ខោ, សង្ខ

៥-សិលា, កែវសិលា

៦-បវាឡំ, កែវបវាឡ

៧-រជតំ, ប្រាក់

៨-ជាតរូបំ, មាស

៩-លោហិតង្កោ, កែវក្រហម(កែវទទឹម)

១០-មសារគល្លំ, កែវមរកដ(កែវពព្រូស)។

(វិន័យបិដក.៤/៣៧០)

## តិរច្ឆានកថា

(ពាក្យនិយាយទទឹងសួគ៌និព្វាន)

១-រាជកថំ, ពោលអំពីរឿងស្តេច

២-ចោរកថំ, ពោលអំពីចោរ

៣-មហាមត្តកថំ, ពោលអំពីមហាមាត្យ

៤-សេនាកថំ, ពោលអំពីសេនាទាហាន

៥-ភយកថំ, ពោលអំពីភ័យ

៦-យុទ្ធកថំ, ពោលអំពីចម្បាំង

៧-អន្នកថំ, ពោលអំពីបាយ

៨-បានកថំ, ពោលអំពីទឹក

៩-វត្ថកថំ, ពោលអំពីសំពត់

១០-សយនកថំ, ពោលអំពីទីដេក

១១-មាលាកថំ, ពោលអំពីផ្កាកម្រង

១២-គន្ធកថំ, ពោលអំពីគ្រឿងក្រអូប

១៣-ញាតិកថំ, ពោលអំពីញាតិ

១៤-យានកថំ, ពោលអំពីយាន

១៥-គាមកថំ, ពោលអំពីស្រុក

១៦-និគមកថំ, ពោលអំពីនិគម

១៧-នគរកថំ, ពោលអំពីក្រុង

១៨-ជនបទកថំ, ពោលអំពីជនបទ

១៩-ឥត្ថីកថំ, ពោលអំពីស្រី

២០-សុរាកថំ, ពោលអំពីសុរា

២១-ទិសិវាកថំ, ពោលអំពីច្រក

២២-កុម្ភដ្ឋានកថំ, ពោលអំពីទីតម្កល់ក្អម (កំពង់ទឹក)

២៣-បុព្វបេ្បតកថំ, ពោលអំពីញាតិដែលស្លាប់ទៅបរលោក

២៤-នានត្តកថំ, ពោលអំពីរឿងផ្សេងៗដែលឥតប្រយោជន៍

២៥-លោកក្ខាយិកំ, ពោលអំពីលោក(លទ្ធិកុហកក្នុងលោក)

២៦-សមុទ្ទក្ខាយិកំ, ពោលអំពីសមុទ្រ

២៧-ឥតិភវាភវកថំ, ពោលអំពីភវៈ(១) និងអភវៈ(២) ។

(វិន័យបិដក.៤/៣៧៣)

**ក្នុងបិដកភាគ ៧ ថែម ២ ទៀតគឺ:**

២៨-បុរិសកថំ, ពោលអំពីបុរស

២៩-សូរកថំ, ពោលអំពីបុគ្គលក្លៀវក្លា

តែនៅក្នុងដីកាវិសុទ្ធិមគ្គ ពោលថា កថាពោលដោយ ព្រៃភ្នំ ទន្លេ និង កោះ សូម្បីថាមិនបានពោលបញ្ជាក់ទុកក្នុងព្រះបាលីនោះ លោកក៏សង្គ្រោះទុកដោយឥតិស័ព្ទពោលថា ជាតិរច្ឆានកថា៣២ប្រការ ព្រោះភាពដែលហាមឃាត់ ការទៅកាន់សួគ៌ និងការរួចផុត គឺ (ព្រះនិព្វាន) ។

---

(១) ភវៈ គឺ សស្សតទិដ្ឋិ ។ (២) អភវៈ គឺ ឧច្ឆេទទិដ្ឋិ ម្យ៉ាងទៀត ភវៈ គឺសេចក្ដីចម្រើន អភវៈ គឺសេចក្ដីសាបសូន្យ ឬភវៈ គឺសេចក្ដីសុខក្នុងកាម អភវៈ គឺសេចក្ដីព្យាយាមធ្វើខ្លួនឱ្យលំបាកឥតប្រយោជន៍ ។

## អន្តរាយិកធម៌ ៥ យ៉ាង

១-កម្ម, ភិក្ខុនីទូសកកម្ម (មគ្គផលហាម តែមិនហាមសួគ៌)

២-កិលេស, និយតមិច្ឆាទិដ្ឋិ (ទៀងទៅកាន់លោកកន្តរនរក)

៣-វិបាក, ការបដិសន្ធិរបស់ពួក បណ្ឌក: តិរច្ឆាន នឹង ឧភតោព្យញ្ជនក:(មគ្គផលហាម តែមិនហាមសួគ៌)

៤-ឧបវាទ (អរិយូបវាទ), ពោលតិះដៀលព្រះអរិយ: (ក្រោយពីការសូមខមាទោសហើយ ទើបរួចពីអន្តរាយិកធម៌នេះបាន)

៥-អាណាវិតិក្កម (បញ្ញត្តិវិតិក្កម), អន្តរាយិកធម៌ ព្រោះរំលងល្មើសសិក្ខាបទ (ក្រោយពីបដិញ្ញាឈប់ជាភិក្ខុ ឬសម្តែងទោស តាមទោស ទៅតាមសិក្ខាបទនោះៗមិនជាអន្តរាយិកធម៌ដល់សួគ៌និព្វានឡើយ)

(អដ្ឋកថា អរិដ្ឋសិក្ខាបទ)

## ព្រះសទ្ធម្ម ៣ យ៉ាង

១-បរិយត្តិសទ្ធម្ម, ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក

២-បដិបត្តិសទ្ធម្ម, ធុតង្គគុណ ១៣ ខន្ធក:វត្ត១៤ មហាវត្ត៨២ សីល សមាធិ និងវិបស្សនា

៣-អធិគមសទ្ធម្ម, មគ្គ៤ ផល៤ និព្វាន១ ។

## សង្ឃកម្ម ៤ យ៉ាង

១-អបលោកនកម្ម, ការប្រកាសសង្ឃតាមការគាប់ចិត្ត

២-ញត្តិកម្ម, កម្មដែលធ្វើដោយញត្តិតែម្យ៉ាង

៣-ញត្តិទុតិយកម្ម, កម្មដែលធ្វើដោយអនុស្សាវនា ១ មាន ញត្តិជាគម្រប់ ២

៤-ញត្តិចតុត្ថកម្ម, កម្មដែលធ្វើដោយអនុស្សាវនា ៣ មាន ញត្តិជាគម្រប់៤ ។ (កង្ខា. ២/១៣៣)

## ឧបោសថ ៩ យ៉ាង

១_ចាតុទ្ទសីឧបោសថ ២_បណ្ណរសីឧបោសថ

៣_សាមគ្គីឧបោសថ ៤_សង្ឃឧបោសថ

៥_គណឧបោសថ ៦_បុគ្គលឧបោសថ

៧_សុត្តុទ្ទេសឧបោសថ ៨_បារិសុទ្ធិឧបោសថ

៩_អធិដ្ឋានឧបោសថ ។

## បវារណា ៩ យ៉ាង

១_ចាតុទ្ទសីបវារណា ២_បណ្ណរសីបវារណា

៣_សាមគ្គីបវារណា ៤_សង្ឃបវារណា

៥_គណបវារណា ៦_បុគ្គលបវារណា

៧_តេវាចិកាបវារណា ៨_ទ្វេវាចិកាបវារណា

៩_សមានវស្សិកាបវារណា ។

(អដ្ឋកថា វិវេខនសិក្ខាបទ)

## ភាសិត ៤ យ៉ាង

១–ពុទ្ធភាសិត, (វិន័យបិដកទាំងអស់ អភិធម្មបិដក ធម្មបទ ចរិយាបិដក ឧទាន ឥតិវុត្តកៈ ជាតក សុត្តនិបាត វិមានវត្ថុ បេតវត្ថុ និង ព្រះសូត្រទាំងឡាយ មានព្រហ្មជាលសូត្រជាដើម)

២–សាវកភាសិត, (ធម៌ដែលពួកសាវកសម្ដែង ដែលរាប់ បញ្ចូលក្នុងបរិស័ទទាំង៤ភាសិតទុក មានអនង្គណសូត្រ សម្មាទិដ្ឋិសូត្រ អនុមានសូត្រ ចូឡវេទល្លសូត្រ មហាវេទល្លសូត្រជាដើម)

៣–ឥសីភាសិត, (ធម៌ដែលពួកបរិព្វាជកខាងក្រៅពោលទុក មានជាដើមយ៉ាងនេះ គឺ បរិព្វាជកវគ្គទាំងអស់ ពាក្យបុច្ឆារបស់ព្រាហ្មណ៍ ១៦នាក់ ដែលជាអន្តេវាសិករបស់ព្រាហ្មណ៍ ឈ្មោះពាវរី)

៤–ទេវតាភាសិត, (ធម៌ដែលពួកទេវតាពោលទុក មានទេវ-តាសំយុត្ត ទេវបុត្តសំយុត្ត មារសំយុត្ត ព្រហ្មសំយុត្ត និងសក្កសំយុត្តជាដើម)

(បិដក.៤/៤៣៨ +អដ្ឋកថា)

## គរុធម៌ ៨ ប្រការ

១_ភិក្ខុនីសូម្បីមានវស្សា ១០០ហើយ ក៏ត្រូវថ្វាយបង្គំភិក្ខុដែលទើប នឹងឧបសម្បទា (សូម្បី) ក្នុងថ្ងៃនោះ ។

២_ភិក្ខុនីមិនត្រូវនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុទេ ។

៣_ភិក្ខុនីត្រូវប្រាថ្នាធម៌ ២ ប្រការ គឺ សួរឧបោសថ ចូលទៅស្ដាប់

ឱវាទអំពីសំណាក់ភិក្ខុសង្ឃរាល់កន្លះខែ ។

៤_ភិក្ខុនីនៅចាំវស្សារួចហើយ ត្រូវបវារណាក្នុងសំណាក់សង្ឃទាំងពីរពួក ។

៥_ភិក្ខុនីត្រូវគរុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខ:មានត្តក្នុងសំណាក់សង្ឃ ទាំងពីរពួក ។

៦_ភិក្ខុនីត្រូវជួយស្វែងរកឧបសម្បទា ក្នុងសំណាក់សង្ឃទាំងពីរពួក ដល់សិក្ខមានាដែលបានសិក្សាសិក្ខាក្នុងធម៌ទាំង ៦ ប្រការ (សិក្ខាបទ ៦ ចាប់ពីបាណាតិបាត ដល់ វិកាលភោជនសិក្ខាបទ ) គ្រប់ពីរឆ្នាំហើយ ។

៧_ភិក្ខុនីមិនត្រូវជេរ មិនត្រូវប្រទេចភិក្ខុ ដោយបរិយាយណាមួយឡើយ ។

៨_តាំងពីថ្ងៃ (ដែលបានឧបសម្បទានេះទៅ) ភិក្ខុនីត្រូវស្តាប់បង្គាប់ភិក្ខុ ឯភិក្ខុមិនត្រូវស្តាប់បង្គាប់ភិក្ខុនីវិញទេ ។ (បិដក.១១/២៦៧)

## បរិភោគ ៤ យ៉ាង

១–ថេយ្យបរិភោគ, បរិភោគដូចជាចោរ ( ការបរិភោគរបស់អ្នកទ្រុស្តសីល)

២–ឥណបរិភោគ, បរិភោគដូចជាអ្នកជាប់បំណុល (បានដល់ការបរិភោគដោយមិនបានពិចារណា របស់អ្នកមានសីល)

៣–ទាយជ្ជបរិភោគ, បរិភោគដូចជាអ្នកទទួលមត៌ក

(បានដល់ការបរិភោគរបស់ព្រះអរិយៈបុគ្គល ៧ ពួក)

៤-សាមីបរិភោគ, បរិភោគដូចជាម្ចាស់របស់ (ការបរិភោគរបស់ព្រះខីណាស្រព)

## បរិសុទ្ធ ៤ យ៉ាង

១-ទេសនាសុទ្ធិ, បរិសុទ្ធដោយការសម្ដែង (បាតិមោក្ខសំវរៈសីល)

២-សំវរសុទ្ធិ, បរិសុទ្ធដោយការសង្រួម (ឥន្ទ្រិយសំវរៈសីល)

៣-បរិយេដ្ឋិសុទ្ធិ, បរិសុទ្ធដោយការស្វែងរក (អាជីវៈបារិសុទ្ធិសីល)

៤-បច្ចវេក្ខណាសុទ្ធិ, បរិសុទ្ធដោយការពិចារណា (បច្ចយសន្និស្សិតសីល)

(អដ្ឋកថា រូបិយសិក្ខាបទ)

## សង្ឃ ៥ ពួកដោយអំណាចកម្ម

១-សង្ឃចតុវគ្គ, (ភិក្ខុ៤អង្គ) គួរក្នុងសង្ឃកម្មទាំងអស់ វៀរតែឧបសម្បទាកម្ម បវារណាកម្ម និងអព្ភានកម្មចេញ ។

២-សង្ឃបញ្ចវគ្គ, (ភិក្ខុ៥អង្គ) គួរក្នុងសង្ឃកម្មទាំងអស់ វៀរតែឧបសម្បទាកម្មក្នុងមជ្ឈិមបទេស និងអព្ភានកម្មចេញ ។

៣-សង្ឃទសវគ្គ, (ភិក្ខុ១០អង្គ) គួរក្នុងសង្ឃកម្មទាំងអស់ វៀរតែអព្ភានកម្មចេញ ។

៤-សង្ឃវីសតិវគ្គ, (ភិក្ខុ២០អង្គ) គួរក្នុងសង្ឃកម្មគ្រប់យ៉ាង ។

៥-សង្ឃអតិរេកវីសតិវគ្គ, (ភិក្ខុលើសពី២០អង្គ) ដូចគ្នា ។

(មាតិកដ្ឋកថា ១/៥)

## សីមាមាន ២ យ៉ាង

១-ពទ្ធសីមា, សីមាដែលសង្ឃបានសូត្រចងដោយកម្មវាចា

២-អពទ្ធសីមា, សីមាដែលសង្ឃមិនបានសូត្រចងដោយកម្មវាចា

(មាតិកដ្ឋកថា ១/៩)

## ពទ្ធសីមាមាន ៣ យ៉ាង

១-ខណ្ឌសីមា, សីមាតូច

២-សមានសំវាសសីមា, សីមាដែលសង្ឃសន្មតិឲ្យមានសំវាសស្មើគ្នា

៣-អវិប្បវាសសីមា, សីមាដែលសង្ឃសន្មតិដើម្បីនៅប្រាសចាកត្រៃចីវរ ។

## អពទ្ធសីមាមាន ៣ យ៉ាង

១-គាមសីមា, សីមាស្រុក

២-សត្តព្ភន្តរសីមា, សីមា (ក្នុងព្រៃដែលអត់មានមនុស្សទៅដល់) កំណត់ដោយទីមានប្រមាណ ៧ អព្ភន្តរៈ (១ អព្ភន្តរៈ= ២៨ហត្ថ)

៣-ឧទកុក្ខេបសីមា, សីមាកំណត់ដោយការសាចទឹក ។

# សីមាវិបត្តិ ១១ យ៉ាង

១-អតិខុទ្ទកា, សីមាតូចពេក

២-អតិមហតី, សីមាធំពេក

៣-ខណ្ឌនិមិត្តា, សីមាមាននិមិត្តដាច់

៤-ឆាយានិមិត្តា, សីមាមានស្រមោលជានិមិត្ត

៥-អនិមិត្តា, សីមាមិនមាននិមិត្ត

៦-ពហិសីមេ ឋិតសម្មតា, សីមាដែលសង្ឃឋិតនៅខាងក្រៅសីមា ហើយសន្មតិ

៧-នទិយា សម្មតា, សីមាដែលសន្មតិក្នុងស្ទឹង

៨-សមុទ្ទេ សម្មតា, សីមាដែលសន្មតិក្នុងសមុទ្រ

៩-ជាតស្សរេ សម្មតា, សីមាដែលសន្មតិក្នុងជាតស្រះ

១០-សីមាយ សីមំ សម្ភិន្ទន្តេន សម្មតា, សីមាដែលសន្មតិទំលាយសីមា ដោយសីមា

១១-សីមាយ សីមំ អជ្ឈោត្ថរន្តេន សម្មតា, សីមាសន្មតិគ្របសីមា ដោយសីមា ។

(មាតិកដ្ឋកថា ១/១០)

# និមិត្តសីមា ៨ យ៉ាង

១–បព្វតនិមិត្ត, ភ្នំជានិមិត្ត

២–បាសាណនិមិត្ត, ថ្មជានិមិត្ត

៣–វននិមិត្ត, ព្រៃជានិមិត្ត

៤–រុក្ខនិមិត្ត, ដើមឈើជានិមិត្ត

៥–មគ្គនិមិត្ត, ផ្លូវជានិមិត្ត

៦–វម្មិកនិមិត្ត, ដំបូកជានិមិត្ត

៧–នទីនិមិត, ស្ទឹងជានិមិត្ត

៨–ឧទកនិមិត្ត, ទឹកជានិមិត្ត ។

(មាតិកដ្ឋកថា ១/១៣)

# ទិសទាំង ៨ សម្រាប់កំណត់និមិត្តសីមា

១–បូព៌, ទិសខាងកើត

២–អគ្នេយ៍, ទិសខាងកើតឈាងខាងត្បូង

៣–ទក្សិណា, ទិសខាងត្បូង

៤–និរតី, ទិសខាងត្បូងឈាងខាងលិច

៥–បស្ចិម, ទិសខាងលិច

៦–ពាយព្យ, ទិសខាងលិចឈាងខាងជើង

៧-ឧត្តរ, ទិសខាងជើង

៨-ឦសាន, ទិសខាងជើងឈាងខាងកើត

## ញត្តិមានទោស ៥ យ៉ាង

១-វត្ថុអបរាមសនំ, មិនប្រាប់វត្ថុ

២-សង្ឃាបរាមសនំ, មិនប្រាប់សង្ឃ

៣-បុគ្គលាបរាមសនំ , មិនប្រាប់បុគ្គល

៤-ញត្តិអបរាមសនំ, មិនប្រាប់ញត្តិ

៥-បច្ឆា ញត្តិដ្ឋបនំ, តាំងញត្តិក្រោយ ។

## អនុស្សាវនាមានទោស ៥ យ៉ាង

១-វត្ថុអបរាមសនំ, សូត្រមិនចេញឈ្មោះវត្ថុ

២-សង្ឃាបរាមសនំ, សូត្រមិនចេញឈ្មោះសង្ឃ

៣-បុគ្គលាបរាមសនំ, សូត្រមិនចេញឈ្មោះបុគ្គល

៤-សាវនាយ បហានំ, ធ្វើសវនវិធីឲ្យខូច

៥-អកាលេ សាវនំ, សូត្រក្នុងកាលមិនគួរ ។

(មាតិកដ្ឋកថា ១/៥៥_៥៦)

## ភិក្ខុអ្នកចោទមានបំណងនឹងចោទភិក្ខុដទៃ

### ក. ត្រូវពិចារណាធម៌ ៥ ប្រការចំពោះខ្លួនឯងសិន រួចសឹមចោទ

១-បរិសុទ្ធកាយសមាចារោ នុ ខោម្ហិ អាត្មាអញមានកាយសមាចារបរិសុទ្ធ ឬហ្ន៎

២-បរិសុទ្ធវចីសមាចារោ នុ ខោម្ហិ អាត្មាអញមានវចីសមាចារបរិសុទ្ធ ឬហ្ន៎

៣-មេត្តំ នុ ខោ មេ ចិត្តំ បច្ចុបដ្ឋិតំ សព្រហ្មចារីសុ អនាឃាតំ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោ ។ ចិត្តរបស់អាត្មាអញ មានមេត្តាតាំងមាំទាំងមិនចង្អៀតចង្អល់ ក្នុងសព្រហ្មចារីបុគ្គលទេឬហ្ន៎ ធម៌នោះមានគ្រប់គ្រាន់ដល់អាត្មាអញឬមិនមានទេ ។

៤-ពហុស្សុតោ នុ ខោម្ហិ សុតធរោ សុតសន្និចយោ អាត្មាអញជាពហុស្សុតទ្រទ្រង់ព្រះសូត្រសន្សំព្រះសូត្រ ឬហ្ន៎

៥-ឧភយានិ នុ ខោ មេ ចាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុតសោ អនុព្យញ្ជនសោ ។ បាតិមោក្ខទាំងពីរ អញក៏ចេះចាំដោយសេចក្ដីពិស្ដារ ចែកចេញបានដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់

សេចក្ដីបានដោយល្អ តាមសូត្រ គឺខន្ធកៈ និងបរិវារៈ តាមអនុព្យញ្ជនៈ ដែរឬទេ ។

## ខ. ត្រូវតាំងខ្លួនឲ្យមាំក្នុងធម៌ ៥ យ៉ាង

១-កាលេន វក្ខាមិ នោ អកាលេន អាត្មាអញនឹងនិយាយត្រូវតាមកាលគួរ មិននិយាយខុសកាល

២-ភូតេន វក្ខាមិ នោ អភូតេន អាត្មាអញនឹងនិយាយពាក្យពិត មិននិយាយពាក្យមិនពិត

៣-សណ្ហេន វក្ខាមិ នោ ផរុសេន អាត្មាអញនឹងនិយាយពាក្យផ្អែមល្ហែម មិននិយាយពាក្យអាក្រក់

៤-អត្ថសញ្ហិតេន វក្ខាមិ នោ អនត្ថសញ្ហិតេន អាត្មាអញនឹងនិយាយពាក្យប្រកបដោយប្រយោជន៍ មិននិយាយពាក្យឥតប្រយោជន៍

៥-មេត្តចិត្តោ វក្ខាមិ នោ ទោសន្តរោតិ អាត្មាអញនឹងតាំងមេត្តាចិត្ត ហើយសឹមនិយាយ មិននិយាយទាំងទោសៈចិត្ត ។

(វិនយបិដក ១១/២៤៥_២៤៩)

## គ. ត្រូវធ្វើទុកក្នុងចិត្តដោយធម៌ ៥ យ៉ាង ក្នុងខ្លួនឯងសិន

១-ការុញ្ញតា ជាអ្នកមានចិត្តករុណា

២-ហិតេសិតា អ្នកស្វែងរកប្រយោជន□

៣-អនុកម្បិតា　　អ្នកទំនុកបម្រុង(ដោយប្រយោជន៍នោះ)

៤-អាបត្តិវុដ្ឋានតា　　អ្នកប៉ងឲ្យភិក្ខុជទៃរួចចាកអាបត្តិ

៥-វិនយបុរេក្ខារតា　　យកវិន័យជាប្រធាន ។

(វិនយបិដក ១១ /២៥៣)

## ភិក្ខុដែលត្រូវគេចោទត្រូវតាំងនៅក្នុងធម៌ ២ យ៉ាង

១-សច្ចេ　សេចក្តីពិតត្រង់ (ឆ្លើយតាមពិតដែលខ្លួនធ្វើឬមិនធ្វើ)

២-អកុប្បេ　សេចក្តីមិនក្រោធ (មិនគប្បីឲ្យកើតសេចក្តីល្អក-កករខឹងក្នុងអ្នកចោទ ឬក្នុងភិក្ខុដែលពោលអត្ថក្តី ឬក្នុងសង្ឃ ) ។

(វិនយបិដក ១១/២៥៤)

## កុលទូសកៈ ៨ យ៉ាង

១-បុប្ផេន វា,　　ឲ្យផ្កាឈើខ្លះ

២-ផលេន វា,　　ឲ្យផ្លែឈើខ្លះ

៣-ចុណ្ណេន វា,　　ឲ្យគ្រឿងលំអិតសម្រាប់ងូតខ្លះ

៤-មត្តិកាយ វា,　　ឲ្យដីស្អិតខ្លះ

៥-ទន្តកដ្ឋេន វា,　　ឲ្យឈើស្ទន់ខ្លះ

៦-វេឡុយា វា,　　ឲ្យឫស្សីខ្លះ

៧-វេជ្ជិកាយ វា, ដោយកិរិយាធ្វើពេទ្យខ្លះ

៨-ជង្ឃបេសនិកោន វា, ដោយការបម្រើដោយស្មងខ្លះ ។

(វិន័យបិដក ២/៣៨១)

## អន្តគ្គាហិកទិដ្ឋិ ១០ ប្រការ

១_លោកទៀង

២_លោកមិនទៀង

៣_លោកមានទីបំផុត

៤_លោកមិនមានទីបំផុត

៥_ជីវិតក៏គឺសរីរៈ

៦_ជីវិតដទៃ សរីរៈដទៃ

៧_សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀត

៨_សត្វខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀត

៩_សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មាន មិនកើតទៀតក៏មាន

១០_សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។

(អភិធម្មបិដក៨២/២៦២)

# បរិយត្តិមាន ៣

តិស្សោ ហិ បរិយត្តិយោ អលគទ្ទូបមានិស្សរណា-ត្ថា ភណ្ឌាគារិយបរិយត្តីតិ ។

បរិយត្តិមាន៣ គឺ អលគទ្ទូបមាបរិយត្តិ ១ និស្សរណត្ថបរិយត្តិ ១ ភណ្ឌាគារិយបរិយត្តិ ១ ។

បណ្ដាបរិយត្តិទាំង៣នោះ បរិយត្តិណាដែលបុគ្គលរៀនមិនល្អ គឺរៀនព្រោះហេតុនៃការប្រណាំងប្រជែងជាដើម បរិយត្តិនេះ ឈ្មោះថា អលគទ្ទូបមាបរិយត្តិ (បរិយត្តិប្រៀបដោយពស់ពិស) ដែលព្រះមានព្រះ-ភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសដែលមានសេចក្ដីត្រូវការដោយពស់ពិស ត្រាច់ស្វែងរកពស់ពិស គេក៏បានជួបពស់ពិសធំក៏ចាប់ពស់ពិសនោះត្រង់ខ្លួន ឬត្រង់កន្ទុយនៃពស់ពិសនោះ ពស់នោះគប្បីត្រឡប់ចឹកត្រង់ដៃ ឬត្រង់ដើមដៃ ឬត្រង់អវយវៈតូចធំណាមួយ គេគប្បីដល់សេចក្ដីស្លាប់ ឬសេចក្ដីទុក្ខជិតស្លាប់ ដែលមានការខាំនោះជាហេតុ ដំណើរនោះព្រោះហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ព្រោះពស់ពិសគេចាប់មិនល្អ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មោឃបុរសពួកខ្លះក្នុងធម្មវិន័យនេះក៏យ៉ាងនោះដែរ រមែងរៀនធម៌គឺ **សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ** ពួកគេកាលរៀនធម៌នោះហើយ រមែងមិនពិចារណានូវអត្ថ នៃធម៌ទាំងនោះដោយបញ្ញា

ធម៌ទាំងនោះ រមែងមិនគួរដល់ការសម្លឹងពិនិត្យ នៃពួកគេអ្នកមិនពិចារណាអត្ថដោយបញ្ញា ពួកគេរៀនធម៌មានការប្រណាំងប្រជែងជាអានិសង្ស នឹងមានការដោះវាទយ៉ាងនេះជាអានិសង្ស រមែងមិនបានទទួលប្រយោជន៍នៃធម៌ដែលពួកកុលបុត្រត្រូវការទើបរៀន ធម៌ទាំងនេះដែលពួកគេរៀនមិនល្អ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលដ៏យូរដល់មោឃបុរសទាំងនោះ ដំណើរនោះព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ទាំងឡាយដែលមោឃបុរសទាំងនោះរៀនមិនល្អ ។

ម្យ៉ាងទៀតបរិយត្តិណាដែលបុគ្គលរៀនល្អហើយ គឺរៀនប្រាថ្នាការបរិបូរណ៍នៃគុណមានសីលខន្ធជាដើម មិនមែនរៀនព្រោះហេតុ មានការប្រណាំងប្រជែងជាដើម បរិយត្តិនេះឈ្មោះថា និស្សរណត្ថបរិយត្តិ(រលាស់ខ្លួនចេញចាកទុក្ខ) ។ដែលព្រះដ៏មានព្រះភាគទ្រង់សំដៅដល់ ត្រាស់ថា ធម៌ទាំងនេះ ដែលកុលបុត្ររៀនល្អហើយ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលដ៏យូរ ដល់កុលបុត្រទាំងនោះ ដំណើរនោះព្រោះហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ទាំងឡាយដែលកុលបុត្រទាំងនោះរៀនដោយល្អ ។

ចំណែកព្រះខីណាស្រពអ្នកមានខន្ធកំណត់ដឹងហើយ មានកិលេសដែលលះបង់ហើយ មានមគ្គដែលអប់រំហើយ មានធម៌ដែលមិនកំរើកចាក់

ធ្ងុះហើយ មាននិរោធធ្វើឲ្យជាក់ច្បាស់ហើយ រមែងរៀននូវបរិយត្តិណា ដើម្បីត្រូវការរក្សាប្រពៃណី ដើម្បីបំណងដល់វង្សប៉ុណ្ណោះ បរិយត្តិនេះ ឈ្មោះថា ភណ្ឌាគារិកបរិយត្តិ (បរិយត្តិដូចនាយរក្សាឃ្លាំង) ដូច្នេះឯង ។

(បឋមសាមន្ត . ពាហិរនិទាន)

## បុគ្គលឈ្មោះថាជាអលជ្ជី

សញ្ចិច្ច អាបត្តឹ អាបជ្ជតិ អាបត្តឹ បរិគូហតិ

អគតិគមនញ្ច គច្ឆតិ ឯទិសោ វុច្ចតិ អលជ្ជិបុគ្គលោ ។

បុគ្គលមានចិត្តក្លែងត្រូវអាបត្តិ ១ បិទបាំងអាបត្តិទុក ១ លុះក្នុងអំណាចអគតិ (មានឆន្ទាគតិជាដើម) ១ បុគ្គលយ៉ាងនេះ ព្រះមានព្រះ-ភាគត្រាស់ហៅថា អលជ្ជីបុគ្គល ។

(គម្ពីរបរិវារ: ១៣/១៧៣)

## ទោសនៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ៥ ប្រការ

១-យោ ទុស្សីលោ សីលវិបន្នោ បមាទាធិករណំ មហាតឹ ភោគជានឹ និគច្ឆតិ ។

បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ក្នុងលោកនេះ តែងបាននូវសេចក្តីវិនាសនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីប្រមាទ ។

២-យោ ទុស្សីលស្ស សីលវិបន្នស្ស បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ ។

បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ តែងមានកិត្តិស័ព្ទអាក្រក់ព្ទខ្ចរខ្ចាយទៅ ។

៣-ទុស្សីលោ សីលវិបន្នោ យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យោ យទិ សមណបរិសំ អវិសារទោ ឧបសង្កមតិ មង្កុភូតោ ។

បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ បើចូលទៅកាន់បរិស័ទណាទោះបីជាខត្តិយបរិស័ទក្តី ជាព្រាហ្មណ៍បរិស័ទក្តី ជាគហបតិបរិស័ទក្តី ជាសមណៈបរិស័ទក្តីក៏គ្មានក្លៀវក្លា មានតែមុខឱនចុះ ហើយដើរចូលទៅ ។

៤-យោ ទុស្សីលោ សីលវិបន្នោ សម្មូឡ្ហោ កាលំ ករោតិ ។

បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ វេលាទៀបស្លាប់ តែងវង្វេងស្មារតី ។

៥-យោ ទុស្សីលោ សីលវិបន្នោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។

បុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីលហើយ លុះរំលាងខន្ធបន្ទាប់អំពីមរណៈ រមែងទៅកាន់អបាយ[១] (តិរច្ឆាន) ទុគ្គតិ[២] (ប្រេត) វិនិបាត[៣] (អសុរកាយ) និរយ[៤] (នរក) ។

ឥមេ ខោ គហបតយោ បញ្ច អាទីនវា ទុស្សីលស្ស សីលវិបត្តិយា ។

ម្នាលគហបតិទាំងឡាយ ទោសទាំង៥ប្រការនេះឯង ជាទោសនៃបុគ្គលទ្រុស្តសីល ឬវិបត្តិចាកសីល ។

**អានិសង្ស ៥ ប្រការនៃបុគ្គលមានសីលឬបរិបូណ៌ដោយសីល**

១-សីលវា សីលសម្បន្នោ អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ ។

បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលក្នុងលោកនេះ តែងបានទូវគំនរនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្ដីមិនប្រមាទ ។

២-សីលវតោ សីលសម្បន្នស្ស កល្យាណោ កិត្តិ-សទ្ទោ អព្ភុគ្គច្ឆតិ ។

បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ តែងមានកិត្តិស័ព្ទដ៏ពីរោះ ព្ញខ្ចរខ្ចាយទៅ ។

---

១ កំណើតសត្វតិរច្ឆាន ។ ២ ប្រេតវិស័យ ។ ៣ អសុរកាយ ដែលមានមហិទ្ធិឬទ្ធិ ដូចរាហូអាសុរិន្ទជាដើម ។ ៤ លោកដែលគ្មានសេចក្ដីចម្រើន មានប្រការច្រើន មានអវចីនរកជាដើម ។

៣-សីលវា សីលសម្បន្នោ យញ្ញទេវ បរិសំ ឧប-

សង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ

គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្ក-

មតិ អមង្កុភូតោ ។

បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ (បើ) ចូលទៅកាន់

បរិស័ទណា ទោះបីជាខត្តិយបរិស័ទក្តី ជាព្រាហ្មណបរិស័ទក្តី ជាគហបតិ

បរិស័ទក្តី ជាសមណៈបរិស័ទក្តី ក៏ក្លៀវក្លាមិនឱនមុខចុះ គឺថាមិនក្រអឹម

ក្រអៀម ហើយដើរចូលទៅ ។

៤-សីលវា សីលសម្បន្នោ អសម្មូឡ្ហោ កាលំ ករោតិ

បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ លុះវេលាទៀបស្លាប់

ក៏មិនវង្វេងស្មារតីឡើយ ។

៥-សីលវា សីលសម្បន្នោ កាយស្ស ភេទា បរម្មរ-

ណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។

បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ លុះរំលាងខន្ធ

បន្ទាប់អំពីមរណៈ រមែងទៅកាន់មនុស្សលោក ឬទេវលោក ។

ឥមេ ខោ គហបតយោ បញ្ច អានិសំសា សីល

វតោ សីលសម្បទាយាតិ ។

ម្នាលគហបតិទាំងឡាយ អានិសង្ស ទាំង ៥ ប្រការនេះឯង ជាអានិសង្សនៃបុគ្គលមានសីល ឬបរិបូរណ៏ដោយសីល ។

*(វិនយបិដក ៧ / ៣០៣_៣០៥)*

## ថេរគាថា

អាទិ សីលំ បតិដ្ឋា ច កល្យាណានញ្ច មាតុកំ
បមុខំ សព្វធម្មានំ តស្មា សីលំ វិសោធយេ ។

សីលជាខាងដើម ជាទីតាំង ជាមេនៃកល្យាណធម៌ នឹងជាប្រធាននៃធម៌ទាំងពួង ព្រោះហេតុនោះបុគ្គលគប្បីជម្រះនូវសីល ។

*(សុត្តន្តបិដក ៥៧ / ២៨)*

## ថេរគាថា

បាតិមោក្ខំ វិសោធេន្តោ អប្បេវ ជីវិតំ ជហេ
បញ្ញត្តំ លោកនាថេន ន ភិន្ទេ សីលសំវរំ ។

កុលបុត្រកាលជំរះនូវបាតិមោក្ខសំវរសីល ស៊ូប្រថុយលះបង់ជីវិតរបស់ខ្លួន ពុំព្រមទម្លាយនូវសីលសំវរៈ ដែលព្រះបរមលោកនាថ ទ្រង់ត្រាស់បញ្ញត្តិទុកមកហើយនោះឡើយ ។

*(វិសុទ្ធមគ្គ សីលនិទ្ទេស)*

# សប្បុរិសានុស្សតិ

ធនំ ចជេ អង្គវរស្សេ ហេតុ អង្គំ ចជេ ជីវិតំ រក្ខមានោ

អង្គំ ធនំ ជីវិតញ្ចាបិ សព្វំ  ចជេនរោ ធម្មមនុស្សរន្តោ ។

នរជនគប្បីលះបង់ទ្រព្យ ព្រោះហេតុនៃអវយវៈដ៏ប្រសើរ កាលនឹងរក្សាជីវិត គប្បីលះបង់អវយវៈ កាលរលឹកដល់ធម៌ គប្បីលះបង់អវយវៈ ទ្រព្យ នឹងសូម្បីលះបង់ជីវិត ។

## គោលធម៌ផ្សេងៗដែលជាគន្លឹះនៃការសិក្សា

### អង្គ ៤ នៃការសិក្សាទៅជាបណ្ឌិត

សុ, សុតៈ ការស្តាប់,ការរៀន

ចិ, ចិន្តនៈ ការត្រិះរិះគិតពិចារណា

បុ, បុច្ឆនៈ ការសាកសួរ(១)

លិ, លិខនៈ ការកត់ត្រាទុក , ការចងចាំទុក ។

---

(១) ១–អទិដ្ឋជោតនាបុច្ឆា សួរដើម្បីដឹងក្នុងវត្ថុដែលខ្លួនមិនទាន់ដឹង មិនទាន់យល់

២–ទិដ្ឋសំសន្ទនាបុច្ឆា សួរដើម្បីប្រៀបធៀបនឹងវត្ថុដែលខ្លួនដឹង

៣–វិមតិច្ឆេទនាបុច្ឆា សួរដើម្បីកាត់នូវសេចក្តីសង្ស័យ

៤–អនុមតិបុច្ឆា សួរដើម្បីការយល់ឃើញប្រពៃ (អនុមតិយល់ស្រប)

៥–កថេតុកម្យតាបុច្ឆា សួរដើម្បីឆ្លើយខ្លួនឯង ។ (អភិធម្មត្ថសង្គហៈ)

សុ,ចិ,បុ,លិ=ហិ សម្បន្នោ ពហុំ សោ បណ្ឌិតោ ភវេ

បើបរិបូរណ៍ ឬដល់ព្រមដោយគុណធម៌ ៤ យ៉ាងនេះ អាចទៅជាបណ្ឌិតបាន ។

សុ,ចិ,បុ,លិ=វិនិមុត្តោ កកថំ សោ បណ្ឌិតោ ភវេ

បើរួចផុត ឬមិនមានគុណធម៌៤យ៉ាងនេះ មិនគប្បីទៅជាបណ្ឌិតបាន ។

សុ ប្រែថាប្រឹងចាំស្ដាប់គេ ចិ រិះរេគិតចំណាំ

បុ អោយសាកសួរសាំ លិ ចំណាំកត់ត្រាទុក ។

**ឥទ្ធិបាទ ៤**

**១–ឆន្ទៈ** ពេញចិត្ត

**២–វិរិយៈ** ព្យាយាម

**៣–ចិត្តៈ** យកចិត្តទុកដាក់

**៤–វិមំសា** មានបញ្ញា

គុណធម៌ ៤ ប្រការនេះ អ្នកណាមានបរិបូរណ៍ហើយ ជាគុណឲ្យសម្រេចតាមសេចក្ដីប្រាថ្នា អាចដឹកនាំឲ្យបុគ្គលនោះ បានដល់គោលបំណង គឺ សេចក្ដីសម្រេច ។ ធម៌ទាំង ៤ នេះ នឹងមានសេចក្ដី សម្ព័ន្ធជាប់ទាក់ទង ជាហេតុនឹងផលរបស់គ្នានឹងគ្នា ពោល គឺ ១ ១ (ឆន្ទៈ) ជាហេតុ ១ ២ (ចិត្តៈ) ជាផល កាលចាប់ផ្ដើម ១ ៣ ជាហេតុ ១ ៤ (វីមំសា)

ជាផល គ្រប់ ៦ នឹងជួយបំពេញចំពោះគ្នានឹងគ្នា ជួយឲ្យការកិច្ចដែលធ្វើបានប្រសប់សេចក្ដីសម្រេច ។

ទាំង ៤ ៦ នេះ **ឆន្ទៈ** សំខាន់បំផុត សម្រាប់ ៦ ក្រោយ រមែងកើតតាមមកឯង ។

(ឃ្លាំងបរិយត្តិ ១/១៣៩)

## បញ្ញា ៣ យ៉ាង

**១-សុតមយប្បញ្ញា** បញ្ញាថ្នាក់ស្ដាប់

**២-ចិន្តាមយប្បញ្ញា** បញ្ញាថ្នាក់គិត

**៣-ភាវនាមយប្បញ្ញា** បញ្ញាថ្នាក់អប់រំចម្រើន ។

## ហេតុនាំឱ្យចម្រើនមោហៈ(ល្ងង់)

១_ការច្រណែន

២_ការស្លឹកស្រពន់ទម្រន់ខ្លួន

៣_ការជ្រប់ងប់ទៅក្នុងសេចក្ដីសោក

៤_ការខ្ជិលច្រអូស

៥_ការត្រេកអរក្នុងការច្របូកច្របល់ដោយពួកគណៈ

៦_ការដេកលក់ច្រើន

៧_ការមិនតាំងចិត្តឲ្យពិតប្រាកដ

៨_ការមិនចាប់អារម្មណ៍ក្នុងញាណ

៩_ការប្រកាន់ខ្លួន

១០_ការមិនសាកសួរ

១១_ការមិនរក្សារាងកាយឲ្យល្អ

១២_ការមិនតម្កល់ចិត្តឲ្យតាំងមាំ

១៣_ការសេពគប់បុគ្គលអន់ថយដោយបញ្ញា

១៤_ការមិនចូលទៅជិតបុគ្គលដែលមានបញ្ញា

១៥_ការមើលងាយខ្លួនឯង

១៦_ការគិតត្រិះរិះខុស

១៧_ការប្រកាន់ វិបរិត គឺ ប្រកាន់អ្វីៗប្លែកៗដែលខុសពីធម្មតានៃការពិត បានដល់ទិដ្ឋិ ៦២

១៨_ការមិនមានសេចក្ដីសង្វេគ

១៩_ការមានទូវនីវរណៈធម៌ ៥ ( កាមច្ឆន្ទ, ព្យាបាទៈ, ថីនមិទ្ធ , ឧទ្ធច្ចកុក្កុច្ច, វិចិកិច្ឆា )

២០_ការដែលសេពគប់ក្នុងព្រះធម៌ ឬស្វែងយល់អំពីព្រះធម៌ដោយសង្ខេបតិចតួចពេក ដែលធ្វើឲ្យបញ្ញាដែលមិនទាន់កើតឡើង រមែងមិនកើតឡើង បញ្ញាដែលកើតឡើងហើយ រមែងសាបសូន្យ ។

(ចាកបារមីភាគ ទី ២ ( ប៊ុត សាវង្ស )

## សុភាសិត

➤ **ចង់ចេះឱ្យសម្លាប់អាចារ្យ   ចង់បានផ្លែផ្កាយកភ្លើងដុតគល់**

ពាក្យថា **សម្លាប់អាចារ្យ** គឺ សម្តៅយកការដេញដោលសាកសួរ រាល់ចម្ងល់ដែលចូល់ ពាក្យថា **យកភ្លើងដុតគល់** គឺ សំដៅយក ការថែរក្សាគល់ ដោយការជ្រុំគល់ ដាក់ជី ស្រោចទឹកជាដើម ទើបបានផ្លែផ្កា។

➤ **អ្នកចេះរិតតែចេះព្រោះធ្វើល្ងង់   អ្នកល្ងង់រិតតែល្ងង់ព្រោះធ្វើចេះ**

បានសេចក្តីថា ចូល់សួរ។ ដូចជាអ្នកអត់ចេះ តែធ្វើឲ្យរិតតែចេះ ចំណែកអ្នកល្ងង់វិញ ចូល់ដែរតែមិនចង់សួរ ធ្វើដូចជាខ្លួនចេះណាស់ តែរិតតែល្ងង់ ។

**ធម៌អាថ៌មិនស្តាប់ច្បាប់មិនអាន   ចេះចាំនឹងមានមកពីណា**
**ខ្លួនឯងមិនស្វែងរកជោគវាសនា   សង្ឃឹមទេវតាណាគេអាណិត ។**

# ច  ប់

តំណក់ទឹកភ្លៀងមិនអាចលិចស្រោចផ្ទះដែលគេប្រក់ដោយល្អយ៉ាងណា រាគៈក៏មិនអាចនឹងចាក់ទំលុះចិត្ត ដែលបុគ្គលបានចំរើនដោយល្អក៏យ៉ាងនោះដែរ ។ កាលបើភិក្ខុមិនបានសង្រួមឥន្ទ្រិយសំវរៈសីលដោយល្អទេ សូម្បីបាតិមោក្ខសំវរៈសីល ក៏មិនអាចនឹងតាំងនៅបានយូរឡើយ ប្រៀបដូចជាសន្ទូង ដែលគេមិនបានធ្វើរបងឡោមព័ទ្ធ គោទាំងឡាយរមែងធ្វើសេចក្តីអន្តរាយដល់សន្ទូង ក៏យ៉ាំងនោះដែរ ភិក្ខុកាលដែលមិនធ្វើឥន្ទ្រិយសំវរៈឲ្យដល់ព្រមហើយ រមែងត្រូវចោរ គឺកិលេសទាំងឡាយប្រទូស្តរ៉ាយបាន រាគៈរមែងហូរស្រោចភិក្ខុនោះឯង ដូចជាភ្លៀងហូរស្រោចផ្ទះដែលប្រក់មិនល្អដូច្នោះ ។ ភិក្ខុត្រូវរក្សាឥន្ទ្រិយ៍កុំឲ្យ អភិជ្ឈាយ៍ និងទោមនស្សកើត ឡើងបានព្រោះតែ ឃើញរូប ឮសម្លេង ធុំក្លិន ដឹងរស និងពាល់ត្រូវសម្ផស្ស ទាំងឡាយឡើយ ព្រោះថាទ្វារទាំងឡាយ មានចក្ខុទ្វារជាដើម តែភិក្ខុណាមិនសង្រួមហើយ មុខជានឹងបៀតបៀនភិក្ខុនោះពុំខាន ដូចជាស្រុកដែលគេបើកទ្វារចំហចោល ចោរទាំងឡាយ រមែងចូលមកបៀតបៀនអ្នកស្រុកបានដូច្នោះឯង ។

